# រឿង

# សារាណីយមាតា

និពន្ធ និងរចនាក្រប ដោយ

អ្នកស្រី កែវ ចន្ទ័បូរណ៍

P.O.Box 600279
Saint Paul, MN 55119
USA
chanbokeo@yahoo.com
www.angkorwat.com
www.camboda.com
www.chanbokeo.com

សូមទាក់ទង
016-318-023
012-774-751

ខែតុលា ២០០៦

រក្សាសិទ្ធិគ្រប់យ៉ាង

CHANBOKEO . COM

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៍


១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្ទឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង បើសិននៅមានថ្ងៃស្អែក
១២- រឿង តន្ត្រីបេះដូង
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណដួងចិត្ត
១៥- រឿង ស្អែកចាកផុតទៅ
១៦- រឿង លំអងផ្កាស្នេហ៍
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្នើយវាសនា
១៩- រឿង បើសិនអាចបង្វិលផែនដី
២០- រឿង សីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីស្នូនសុបិន
២៦- រឿង ពិដោន្តភាណុមា
២៧- រឿង មួយខែក្បែរមច្ចុរាជ
២៨- រឿង ផ្ការីកក្រៅស្នួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង សារិកា
៣៣- រឿង ផ្ការាជបឹងរាំង
៣៤- រឿង នភាមណី
៣៥- រឿង ស្រីនាថភ្ជួងមាលា
៣៦- រឿង វាយោដួងចិត្ត


CHANBOKEO.COM

ISBN: 99950-79-06-2

9 789995 079062

# សូមឧទ្ទិសស្នាដៃនេះប្រគេននិងជូនចំពោះ

- ព្រះគ្រូ សេងប៊ុនសង ព្រះគ្រូចៅអធិការ ម៉ឹងសាង ភិក្ខុ វុមភិរម្យ ភិក្ខុ គិមសុវត្ថិ  ភិក្ខុ ជុំ វិចិត្រ ភិក្ខុ គង់សុជា
- លោក មេងសួងសុវណ្ណធី ជាស្វាមី
- កុមារី សុវណ្ណធីធម្មិកាបារមីបុណ្យជាបុត្រី
- លោកឪពុក ប៊ុនថង អ្នកម្តាយ កែវយឿង  ប្អូនទាំងបួនព្រមទាំងក្រុមគ្រួសារ
- លោកឪពុកក្មេក មេងសួង និងអ្នកម្តាយក្មេក កូវសារ៉ាន់ ព្រមទាំងកូនចៅ
- បណ្ឌិតឃួគិមទូយ សាស្ត្រាចារ្យគិមមាសកូយ ចាន់សុខា និង អួននឿង។
- អ្នកស្រីនៅសារិម វិទ្យុសម្លេងសហរដ្ឋអាមេរិក VOA
- អ្នកស្រី ប៉ិច សង្វារ៉ាន វិទ្យុបារាំងអន្តរជាតិ RFI
- លោក លីតាយហុង អ្នកគ្រូ ទូច សារឿង និងអ្នកគ្រូមៀចសុខារី
- លោកអ៊ុមសុនាថ លោកជិនសៅរិន   លោកជាសយនា  សារពត៌មាន
  កោះសន្តិភាព។
- លោកខូតារាឫទ្ធិ នាយកកម្មវិធីអក្សរសិល្ប៍សមូហកម្មនូហាច ភ្នំពេញ
- សាស្ត្រាចារ្យយូ សុភា មជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម



អ្នកស្រី កែវ ចន្ទ័បូរណ៍

CHANBOKEO.COM

# វាចារអ្នកនិពន្ធ

ជាទូទៅ មិនថានៅក្នុងសាច់រឿងព្រេងនិទាន រឿងប្រឌិត ឬរឿងជីវិតពិតៗអ្វីនោះទេ សង្គមខ្មែរមិនដែលអោយតម្លៃទៅលើ អ្នកដែលជាម្តាយចុងឡើយ ។ ឯម្តាយចុងវិញ ភាគច្រើនក៏មិនបាន ប្រព្រឹត្តខ្លួនជាស្ត្រីល្អ ជាមាតាគំរូ ឬជាម្លប់ត្រជាក់ដល់កូនដើមកំព្រីកំព្រានោះដែរ ។ អាស្រ័យហេតុនេះ អ្នកនិពន្ធក៏បានប្រឌិតរឿង សារាណីយមាតានោះឡើង ដោយជ្រើសរើសតួអង្គម្តាយចុងក្នុង លក្ខណៈស្ត្រីដែលប្រកបដោយសន្តានចិត្តប្រពៃ មានសីលធម៌មាន សតិនិងប្រាជ្ញា និងជាម្លប់ដ៏ត្រជាក់សំរាប់កូនចៅគ្រប់គ្នា មិនថាក្មេងនោះជាកូនដើមឬកូនចុងនោះឡើយ ដើម្បីជាគំរូដល់បច្ចាជន ជំនាន់ក្រោយឲ្យរៀនទទួលស្គាល់ថា ម្តាយចុងទាំងអស់មិនមែន សុទ្ធតែជាមនុស្សទ្រឹស្នូរអាត្មានិយម និងមានចិត្តចង្អៀតចង្អល់រហូត ជានិច្ចនោះដែរ ។

អ្នកនិពន្ធខ្ញុំសូមទទួលនូវមតិយោបល់អំពីប្រិយមិត្តអ្នកអានទាំងឡាយតាមរយៈអាសយដ្ឋានដូចខាងក្រោមនេះ ៖

Pannalai KhmerVissal
P.O.Box 600279
Saint Paul, MN 55119
USA
chanbokeo@yahoo.com
www.chanbokeo.com

សូមប្រិយមិត្តបានប្រកបតែវឌ្ឍនសុខរៀងរាល់ទិវារាត្រី ។

អ្នកស្រី កែវ ចន្ទ័បូរណ៍
ខែវិច្ឆិកា២០០៦

CHANBOKEO.COM

# កំណាព្យ

===================================================================

## តួឯក និង តួរង

ឯកៗមានន័យថាម្នាក់ឯង ឯកនៅចំបែងយ៉ាងកណ្តោច
ឯកចេញសម្តែងរែងត្រមោច ទំរាំបានរួចជួបដៃគូ ។
តួរងសម្តែងកៀនខាងៗ បើមានសំណាងចាំត្រងយក៏
លាតដៃត្រកងមិនទុកយូរ ឯកណាខ្វះគូ រងទទួល ។
តួរងសំណាងច្រើនបំផុត មិនបាច់នឿយហត់រត់ច្រាលជ្រួល
ដូចជាតួឯកភ័យរមួល ឡើងភ្នំចុះទួលតាមសាច់រឿង ។
តួរងចាំត្រងយកអ្នកឯក ជួនកាលក៏ប្លែកថែមថយគ្រឿង
ផ្តល់នូវរសជាតិដល់សាច់រឿង ខ្វះរងលែងសឿងរឿងស្រកន័យ ។
ច្នេះមិនគួរខឹងប្រឹងចង់ឯក ធ្វើរងក៏ប្លែករសវិស័យ
សាច់រឿងខ្វះរងស្រកអត្ថន័យ មានឯកម្តេចក្តីមិនគ្រប់គ្រាន់ ។
តួរងតួឯកប្លែកតាមងារ នាទីស្មើគ្នាយ៉ាងសំខាន់
មានឯកខ្វះរងអ្នកមើលទ្រាន់ សាច់រឿងសិយភ័ន្តលែងពិរោះ ។
មិនខុសនាទីវិស័យជាតិ មិនបាច់ខំឆ្លៀតធ្វើឯកស្រស់
ការងារតូចធំគ្រប់កៀនកោះ រងប្រឹងជួយអស់ទើបជាតិថ្កើង ។
ជាតិមួយជឿនលឿនពឹងគ្រប់ជ្រោយ ពឹងតួឯកហើយពឹងរងផង
ធ្វើការព្រមគ្នាយ៉ាងត្រសង ទើបជាតិថ្កុំថ្កើងវឌ្ឍនភាព ។

CHANBOKEO.COM

# សមុទ្ទនិងត្រពាំង

សមុទ្ទធំធេងទឹកថ្លាក្រៃ　　ស្រណោះវិស័យពឹងមិនបាន
ពេលឃ្លានពេលស្រេកបែរអាក់ខាន　　សមុទ្ទប្រៃខានផឹកសម្រន់ ។
ត្រពាំងតូចក្តាត់ទឹកល្អក់ខ្វល់　　បែរជានិមលគួរអោយភ័ន្ត
អ្នកស្រុកដងប្រើពេញភូមិលាន់　　រស់រានឃ្លានស្រន់ត្បិតទឹកជា ។
សមុទ្ទដូចមនុស្សអស្សុរស　　មានបុណ្យសក្តិយសមានទ្រព្យា
ចិត្តវិញជាកំណាញ់មិនធូរធារ　　នឹងមនុស្សដូចគ្នាសូម្បីមិត្ត ។
វីទឹកត្រពាំងដូចអ្នកបុណ្យ　　តិចតួចចែកគ្រាន់លៀងជីវិត
មិនមើលបំណាំស្តាំវិបរិត　　ញាតិផៅឆ្ងាយជិតពឹងពាក់បាន ។
ច្នេះធ្វើសមុទ្ទប្រយោជន៍អ្វី　　ធំធេងពោកក្រៃតែសាមាន្យ
សូវធ្វើត្រពាំងទឹកកល្យាណ　　សន្តានរំភើបត្បិតសប្បុរស ។

# សមុទ្រនិងត្រពាំង (ត)

សមុទ្ទប្រៃពិតតែប្រយោជន៍　　បំរើរុងរោចន៍មិនធុញទ្រាន់
ផលិតអំបិលចែកចាយលាន់　　ញាតិឆីមិនភន្ត័គ្រាន់រស់រាន ។
ត្រពាំងទឹកសាបចាំអំបិល　　ដងទឹកស្លគិលទទួលទាន
ទាំងពីរជាគូពិតធរមាន　　ញាតិឆីរស់រានមានជីវិត ។
សមុទ្ទសំបុកផ្ទុកមច្ឆា　　អស់ក្តាមបង្គាជាម្ហូបពិត
មិនចាញ់ត្រពាំងតូចប្រណិត　　ចិញ្ចឹមជីវិតអស់ផងញាតិ ។
ច្នេះប្រមាថគ្នាប្រយោជន៍អ្វី　　គួរតែស្រោក់ដៃកុំឃ្លាឃ្លាត
សមុទ្ទត្រពាំងបំរើជាតិ　　ខ្មែររស់វរនាថសុខរៀងអើយ ។

CHANBOKEO.COM

# ពេលដាស់កូនឲ្យក្រោក

ចាស់ទុំខ្លះតឿនកូនៗអើយក្រោក　　មាត់ស្រែកកោកៗដៃខោកឲ្យភ្ញាក់
ថៃ្ងដន្យដាស់ហើយបានត្រឹមពញ្ញាក់　　លុះដល់កូនភ្ញាក់ភ្លេចប្រាប់ផ្លូវនាំ ។
ដាស់ភ្ញាក់ធ្វើអ្វីបើគ្មានឧបាយ　　ប្រាប់កូនឆោមឆាយផ្លូវណាចាកកម្ម
ចេះត្រឹមបន្ទោសជេរស្តីបង្ខំ　　កូនអើយចងចាំក្រោកឡើងធ្វើការ ។
ទៅធ្វើការអ្វីសូមម៉ែបង្រៀន　　ពុកអើយសូមប្រៀនកូនអាប់ប្រាជ្ញ
បំភ្លឺសតិកូនអោយភ្លឺថ្លា　　មធ្យោបាយណានាំកូនចំរើន ។
នរណាក៏ចេះដាស់កូនអោយភ្ញាក់　　ប៉ុន្តែរឿងលក្ខណ៍ឧស្សាហ៍ក្រវើន
ត្រូវធ្វើអ្វីខ្លះដើម្បីចំរើន　　ចាស់ទុំយើងច្រើនភ្លេចប្រាប់មាគ៌ា ។
នឹងឲ្យកូនដើរទិសបែរយ៉ាងម៉េច　　ជើងត្បូងកើតលិចសូមលោកមេត្តា
ត្រាយផ្លូវគំរូកូនធ្វើបែបណា　　កុំឲ្យកុនការធ្លាក់ជ្រោះជួបកម្ម ។
មុននឹងដាស់កូនសូមគិតមុនផង　　ត្រៀមនូវគំរោងឧបាយឧត្តម
ចាប់ត្រីយ៉ាងម៉េចទើបបានផលធំ　　ធ្វើច្បារដំណាំបែបណាល្អផល ។
កុំដាស់កូនហើយកន្តើយចាំគន់　　វាយដំជេរលាន់ពេលគ្នាមិនយល់
ដាស់ហើយគួរប្រៀនប្រាប់ផ្លូវនិមល　　នោះទើបកូនយល់ធ្វើអ្វីប្រសើរ ។
នឹងអោយលទ្ធផលមានប្រសិទ្ធិភាព　　ម៉ែពុកផងទៀតកុំស្ងៀមទំយើ
ស្ទុះដើបផងដែរបង្ហាញថ្នាក់ធ្វើ　　ផ្លូវជ័យប្រសើរឲ្យកូនត្រងត្រាប់ ។
មានតែទ្រឹស្តីខ្វះអនុវត្តន៍　　ចាស់ទុំភ្លាំងភ្លាត់កូនភ្លេចសណ្តាប់
ភ្ញាក់រួចអង្គុយគ្មានផ្លូវដើរគាប់　　មុខដើបគូថងាប់ខ្វះគោលដៅតដាំ ។
ធ្ងេះជាឪម៉ែគួរប្រែគិតថ្មី　　ដាស់កូនប្រុសស្រីកុំភ្លេចណែនាំ
នាំមុខកូនដើរទិសណាសមរម្យ　　កូនភ្ញាក់ខិតខំដើរតាមមិនខាន ។

CHANBOKEO.COM

# មេកោយគំរូ

មេកោយដែលល្អ ចរនាំមុខ　　　　មិននៅសំកុកចាំត្រងផល
ចេញមុខធ្វើការយ៉ាងរចល់　　　　មិនរួញកាយកលលាក់ក្នុងស្នូក ។
ពេលបំពេញកិច្ច លឿនមុនគេ　　　　ឥតឡើយនៅគ្នេរដេកសណ្ដូក
គេធ្វើការវីរ ឯងដេកពួក　　　　កើយដៃចាំលូកកើបត្រើយផល ។
មេកោយគំរូគ្រូផងញាតិ　　　　មិនឆ្លៀតប្រវញ្ច័លើអស់ពល
ខ្លាចចិត្តកូនចៅខឹងអំពល់　　　　បើមេកោយកលភ្លេចភារកិច្ច ។
នៅការិយាល័យ គ្រូ មន្ត្រី　　　　រោងចក្រ មន្ទីរ ផងពាណិជ្ជ
មេកោយធ្វើការមិនកែគេច　　　　ញើសដាបគគ្រិចមិនទំរន់ ។
មេកោយឧត្ដមនាំយើងខ្ពស់　　　　ថ្កុំថ្កើងលូតលាស់យសរង្វាន់
ដល់ក្រុមក្រសួងកូនចៅលាន់　　　　ចំរើនលូតលឿនជំរឿនជ័យ ។

CHANBOKEO . COM

# ផ្កាយ

ផ្កាយអើយផ្កាយរះភ្លឺព្រិចៗ　　ពណ្ណរាយដូចពេជ្រឯវេហាស៍
យប់គ្មានដួងខែល្ងិតម្ល៉េះណា　　បានផ្កាយរះថ្លាកំដរលោក ។
ពិតមែនតែផ្កាយតូចល្អិតក្រៃ　　តែផ្តល់រស្មីយ៉ាងជ័យជោគ
ឃើញពន្លឺផ្កាយស្បើយវិយោគ　　មនុស្សសត្វក្នុងលោកក្សេមក្សាន្តចិត្ត ។
មិនខុសពលរដ្ឋជនសាមញ្ញ　　ក្នុងសង្គមមិញមានទឹកចិត្ត
សីលធម៌ភ្លឺថ្លាសាស្ត្រាក្រិត្យ　　វិជ្ជាគំនិតភ្លឺដូចផ្កាយ ។
ពិតមែនប្រទេសយើងក្រីក្រ　　ទុរគតទន់ទោរខ្វះពណ្ណរាយ
បើសិនពលរដ្ឋភ្លឺដូចផ្កាយ　　ប្រទេសចាកឆ្ងាយល្ងិតល្ងង់ខ្លៅ ។

CHANBOKEO . COM

# គំនិត

គំនិតចង្អៀតសង្កេតមនុស្សសត្វ សំបុកសម្បត្តិទ្រព្យធនរូបា
ភូមិស្ថានព្រៃព្រឹក្សទិដ្ឋភាពយ៉ាងណា អាក្រក់ល្អម្តាមិនឲ្យមានសល់ ។
គំនិតកណ្តាលបែរពិគ្រោះយុគ ស្ថានការណ៍ក្រោយមុខសុខឬអំពល់
សម័យហាយនៈរឿងអកុសល វិភាគគ្មានសល់ទៅមុខទៅក្រោយ ។
គំនិតទូលាយវិភាគគតិ ដាស់តឿនសតិមិនមានបណ្តោយ
ពិគ្រោះគំនិតគិតគ្រប់ជ្រុងជ្រោយ ប្រាប់មធ្យោបាយនាំជាតិថ្កើងថ្កាន ។
គំនិតត្រកាលជាថ្នាលរមណី ទង្ឋិសុរភីនាំភាពក្សេមក្សាន្ត
គតិឧត្តមជាតិថ្កុំកល្យាណ ខេមរាសុខសាន្តល្បីល្បាញកត្តិនាម ។

- Small minds discuss people and things.
- Everage minds discuss events and eras.
- Great minds discuss ideas and strategies for advancement.

CHANBOKEO .COM

# ដាំស្វាយ

ដប់ឆ្នាំចាំបេះផ្លែស្វាយឆី　　គួរឆ្ងៀតដាំស្ពៃ ជាធនធាន
យកលៀងជីវិតជាងដេកឃ្លាន　　ទំរាំស្វាយមានផ្លែអោយបេះ ។
ដូចសិស្សត្រេកត្រងការសិក្សា　　តក់ៗពេញការស្តារតម្រិះ
ប្រឹងស្រង់ពីតិចសាងចំណេះ　　មិនខ្ជិលដេកផេះបេះចុងក្រោយ ។
កុំប្រព្រឹត្តខ្លួនក្បួនផ្លូវកាត់　　ប្រយត្ន័ដើរភ្លាត់មិនដល់ជ្រោយ
ដាំស្ពៃតាមផ្លូវកុំបណ្តោយ　　ទំរាំដើមស្វាយមានផ្កាផ្លែ ។
នោះទើបឆ្អែតផ្អែសុខកាយា　　ទំរាំស្វាយផ្កាច្រើនហូរហៃ
មិនដេកផ្សាពោះដល់ស្វាយផ្លែ　　បេះផលកញ្ឆែចេររៀងទៅ ។

CHANBOKEO . COM

# ការនិពន្ធអភិវឌ្ឍន៍

រឿងប្រលោមលោកមនុស្សយក្សនាគ   រឿងកុនតភាគជូនផងញាតិ
កំប្លែងលើឆាកស្តែងព្រោងព្រាត   តែងឆ្លៀតបញ្ជាំងនូវសង្គម ។
សង្គមបុរាណឬសម័យ   សង្គមប្រពៃខ្ពស់ឧត្តម
សង្គមអវិចីពលរន្ធយំ   បង្ហាញគ្រប់មុំរសប្លែកៗ ។
ថៃ្ងនេះសម័យស្រុកជឿនលឿន   គេនិពន្ធរឿងលែងរាវែក
ឈប់ធ្វើកញ្ជក់ឆ្លុះល្អឯក   ធ្វើពន្លាកដៃកន្លាក់វិញហោង ។
ខេមរានិពន្ធច្រើនក្បួនខ្នាត   អ្នកប្រាជ្ញសង្វាតក្បួនចំបង
សរសេរស្រាវជ្រាវស្រាយចំណង   ឆ្លាក់គំនិតផងឲ្យចរណៃ ។
អ្នកមើលអ្នកអានអ្នកទស្សនា   ជួបរឿងពិស្តារមានអត្ថន័យ
យល់គំនិតខ្ពស់ល្អប្រពៃ   លែងអីមិនត្រង់គតិស្ងួន ។
បំណាច់ចាយពេលមានតម្លៃ   ចងក្រងស្នាដៃអស់ផងក្បួន
គួរនាំគំនិតល្អនឹមនួន   ចែករំលែកជូនជាប្រយោជន៍ ។
សម័យនិពន្ធអភិវឌ្ឍន៍   លូតលាស់បំផុតយ៉ាងរុងរោចន៍
គួរស្មេរគតិនាំប្រយោជន៍   អ្នកអានបានបោចប្រយោជន៍ថ្កើង ។

CHANBOKEO.COM

# មេបា

| | |
|---|---|
| មុនប្រដៅកូនមើលខ្លួនឯង | ស្រវាស្វះស្វែងយ៉ាងឧស្សាហ៍ |
| ធ្វើល្អត្រឹមត្រូវបានត្រឹមណា | មុននឹងស្តីហារប្រដៅកូន ។ |
| សិនបើខ្លួនអើយដេកទំរន់ | ស្រពន់ដៃជើងអស់ផងខ្លួន |
| ខ្ជិលអូសគគូថមិនគិតស្ងួន | យ៉ាកនឹងស្តីកូនអោយវាស្តាប់ ។ |
| មុនប្រឹងដេញកូនអោយខំរៀន | គប្បីខ្មាស់អៀនខ្លួនអ្នកប្រាប់ |
| ធ្វើអ្វីរៀនអ្វីអោយកូនត្រាប់ | ទុកជាផលគាប់គំនិតជ័យ ។ |
| បើសេពថ្នាំញៀនល្បែងស្រីស្រា | ខ្ជិលទៅធ្វើការផងអ្វីៗ |
| ប្រៀនកូនម្តេចស្តាប់ពាក្យសំដី | ប្រដៅឥតន័យប្រសិទ្ធភាព ។ |
| បើប្រដៅខ្លួនមិនទាន់បាន | កុំគិតនឹកស្មានថាមានប្រៀប |
| ពេលប្រដៅកូនតាមខ្លួនកៀប | កូនរើគេចឃ្មៀបមិនស្តាប់ឡើយ ។ |
| ច្នេះមុនគិតកូនគិតខ្លួនឯង | ធ្វើអ្វីជាក់ស្តែងមិនកន្តើយ |
| ជាគំរូកូនកុំបណ្តោយ | ថ្ងៃក្រោយគង់កូនត្រងត្រាប់យល់ ។ |

CHANBOKEO.COM

# ពេលឃើញកូនខុស

ពេលកូនធ្វើខុសកុំស្តីថែម ម៉ែឪត្រូវត្រៀមហៅពិគ្រោះ
ណែនាំផ្លូវល្អចាកផុតគ្រោះ កុំជេរបន្ទោសស្តីច្រំដែល ។
កូនកាន់កាំបិតចិតមុតដៃ ម៉ែឪគប្បីប្រៀនឲ្យក្រែល
ប្រាប់របៀបថ្មីលែងដងដែល កុំឲ្យមុតដៃសាម្តងទៀត ។
កូនជិះកង់ដួលកុំឡើយសើច ពន្យល់ប្រយោជន៍ស្វែងរកស្នៀត
ឲ្យកូនដើបឡើងសាកម្តងទៀត សំភីគ្រប់ស្នៀតលុះត្រាជ័យ ។
កូនឡើងដើមឈើធ្លាក់ដួលដំ កុំជេរចំព្រាំឲ្យកូនភ័យ
ណែនាំកូនយើងរបៀបអ្វី ពេលឡើងជាថ្មីលែងមានគ្រោះ ។
កូនធ្វើលំហាត់មានខុសខើច កុំជេរបញ្ចើចថាកូនដោះ
ឲ្យគ្នាស្រពោនទឹកចិត្តអស់ ថ្ងៃក្រោយកូនច្បាស់គេចសាលា ។
កូនមានសង្សារហៅប្រៀនប្រាប់ ពិគ្រោះប្រញាប់ពន្យល់សា
តឹងពេកនាំដាច់ ធូរធ្លោយការ គប្បីពិចារណាផ្លូវកណ្តាល ។
ធ្វើជាម៉ែឪត្រូវសំភី វៃកឧបាយទីល្អត្រកាល
ប្រៀនការណែនាំល្អវិសាល ទើបកូនយល់ថ្លាលភព្វរុងរឿង ។

CHANBOKEO.COM

# ត្រចៀកនិងខួរក្បាល

ត្រចៀកទាំងពីរផ្ទៀងផ្ទាត់ស្តាប់ រឿងរ៉ាវគួរគាប់រឿងឥតន័យ
ត្រចៀកត្រងស្តាប់គ្រប់សំដី មិនរំលងអ្វីផុតត្រចៀក ។
ចំណែកខួរក្បាលដូចចង់យាម ត្រៀមខ្លួនទទួលអស់ពេចន៍ពាក្យ
សាច់រឿងប្លែកៗគ្រប់ភិនភាគ តែស្ទួប់នូវពាក្យនាំសំរាម ។
ពេលត្រចៀកស្តាប់រឿងអំពល់ យប់ឡើងខួរខ្វល់គិតក្រវាម
ទោម្នេញក្នុងចិត្តព្រួយសាំញ៉ាំ ស្មែកឡើងរកាំក្រហមភ្នែក ។
ច្នេះខួរបែរផ្តាំប្រាប់ត្រចៀក ន៎ុយ ! រៀនវិភាគពាក្យល្អឯក
កុំស្ទូវត្រងយករឿងចម្លែក នាំសំរាមចែកខួរយើងគិត ។
ចង់ខួរសុំស្រង់តែរឿងល្អ ដល់យប់ឡើងមក៍ឆ្មេចភ្នែកជិត
ដេកលក់យល់សប្តិរឿងប្រណិត ចាកភាពវិបរិតអ្វីទាំងឡាយ ។

CHANBOKEO . COM

# ឫស្សីសាយគុម្ព

| | |
|---|---|
| ឫស្សីមួយមែកដុះសាយគុម្ព | ព្រោះទំពាំងធំលូតលាស់មក៏ |
| ភ្លោះកូនថ្មីៗមិនឈប់ឈរ | ជាឫស្សីល្អខ្ពស់លើសមុន ។ |
| បើឫស្សីក្រោយក្លាយតូចស្តួច | គុម្ពច្បាស់ជាហោចប្រែស៊ិយស៊ុន |
| ស្រកម្តងបន្តិចតូចជាងមុន | គុម្ពទ្រោមតត្រុនលែងឲ្យផល ។ |
| ដូចប្រទេសជាតិក្លាយខ្សោយទន់ | បើបច្ឆាជនយន់កាយកល |
| ទំពាំងក្រោយទ្រោមស្រុតគុម្ពគល់ | ជាតិច្បាស់ជាយល់ហាយនៈ ។ |
| ឫស្សីសាយគុម្ពពឹងទំពាំង | ជាន់ក្រោយធំខ្លាំងខ្ពស់ប្រត្យក្ស័ |
| លើសឫស្សីមុនយ៉ាងអនគ្ឃ | សាយគុម្ពឥតអាក់ស្តុកស្តម្ភក្រៃ ។ |
| មិនខុសប្រទេសដែលជឿនលឿន | ពលរដ្ឋជំរឿនសព្វវិស័យ |
| ក្មេងមានវិជ្ជាខ្ពស់លលៃ | លើសចាស់សម័យពីបុរាណ ។ |
| ច្នេះយើងចាស់ៗគួរបណ្តុះ | ឲ្យក្មេងលូតលាស់ខ្ពស់ថ្កើងថ្កាន |
| គំនិតប្រាជ្ញវិជ្ជាបាន | ចំណេះសំខាន់ជួយជាតិយើង ។ |
| ហើយទទួលផងថាយើងចាញ់ | ក្មេងក្រោយត្របាញ់ខ្ពស់ថ្កុំថ្កើង |
| កាន់តែឆ្ងាយទៅលើសរូបយើង | សាយគុម្ពរីកឡើងយ៉ាងវិសាល ។ |

CHANBOKEO.COM

# វត្ថុអច្ឆរិយៈ

ក្នុងរឿងបុរាណមនុស្សចេះហោះ　　នាគហង្សគ្រុឌអស់យក្សអសុរី
ហោះហើរលើកភ្នំឆ្លងជលស័យ　　សិល្ប៍ច្បាំងខ្ស័រដឹកក្រើកមេឃ ។
នៅពេលបច្ចុប្បន្នមនុស្សអស់ឫទ្ធិ　　លែងចេះហោះពិតគួរសង្វេគ
ថៃ្ងនេះមនុស្សមានវត្ថុឯក　　អាចផលិតដែកឲ្យហោះបាន ។
ដែកហោះដឹកមនុស្សដឹកឥវ៉ាន់　　ឆ្លងទ្វីបមិនភន្ត័មិនដែលខាន
ផលិតដែកឲ្យអណ្តែតបាន　　លើសមុទ្ទត្រាណដឹកសព្វមុខ ។
មនុស្សចេះផលិតជាយន្តហោះ　　វិទ្យុទូរទស្សន៍យន្តយានផ្ទុក
ទូរសព្ទ័ឆ្លងទ្វីបមើលឃើញមុខ　　កុំព្យូទ័រស្តុកស្តម្ភសាស្រ្តា ។
នោះព្រោះមនុស្សមានទ្រព្យវរលក្ខណ៍　　មានអច្ឆរិយៈយ៉ាងអស្ចារ្យ
គឺជាគំនិតនិងប្រាជ្ញ　　ជាសិល្ប៍ស្រោយការយ៉ាងប្រសិទ្ធិ ។
ខួរក្បាលជាទ្រព្យអច្ឆរិយៈ　　កុំអោយស៊ីយធ្លាក់ភពវិបរិត
គួរណាស់ប្រើខួរអោយសុក្រិត　　បំរើជីវិតអោយថ្កុំថ្កើង ។

CHANBOKEO.COM

# ឆ្លាក់

នាមល្បីជាតិខ្មែរពូកែឆ្លាក់ រូបក្បាច់ចម្លាក់ឆ្លាក់ប្រាសាទ
ឆ្លាក់ថ្មឆ្លាក់ឈើធ្វើសង្ហាត ក្លាយក្បាច់ស្រស់ស្អាតល្អគ្មានពីរ ។
ជាតិផ្សេងរែងស្ងើចស្នាដៃខ្មែរ ឆ្លងយុគហូរហែយ៉ាងរមណី
ថ្វីដៃល្បីល្បាញគ្រប់ទិសទី គេឯងសំភីប្រាថ្នាយល់ ។
បច្ចុប្បន្នយើងប្រឹងឆ្លាក់របស់ ព្រងើយឆ្លាក់មនុស្សអោយនិមល
ពិភពលោកចរខ្ពស់មង្គល ជាតិយើងបែរវិលថយសីលធម៌ ។
ឆ្លាក់ថ្មវិចិត្រពិតមិនស្មើ ឆ្លាក់មនុស្សប្រសើរដើរផ្លូវល្អ
ឆ្លាក់ថ្មនៅស្ងៀមមិនអាចចរ ធ្វើអំពើល្អជូនដល់ជាតិ ។
បើសិនឆ្លាក់មនុស្សបានប្រពៃ នោះទើបស្នាដៃពិតវរនាថ
មនុស្សឆ្លាក់មនុស្សល្អថែមព្រោងព្រាត ចរនាំស្រុកជាតិរីកចំរើន ។

CHANBOKEO . COM

# ទទួលនិងអោយ

ពេលមានញាតិមិត្តអោយយោបល់ បន្ទន់កាយកលទទួលដៃ
ស្តាប់ពាក្យលោកប្រៀនក្រែងមានន័យ ប្រើការអ្វីៗប្រសិទ្ធិភាព ។
រៀនស្តាប់រៀនគិតរៀនពិចារណ៌ ញាតិស្តីប្រាប់អាចិការណ៌ខ្ពស់ទាប
ត្រងយកគំនិតកត់ប្រៀបធៀប ក្រែងលោត្រងលាភគំនិតជ័យ ។
បើយើងជាអ្នកអោយយោបល់ រើសវេលាផ្តល់នូវសំដី
ប្រើពាក្យពិរោះទោះវែងខ្លី វែកញែកអត្ថន័យអោយគេស្តាប់ ។
កុំបង្ខំគេអោយតាមខ្លួន ទុកពេលគេស្ងួនពួនគិតគាប់
វិភាគពិចារណ៌ពាក្យរ៉ាយរ៉ាប់ អោយគេឆ្លើយប្រាប់តាមវេលា ។
ធម្មតាមនុស្សយើងម្នាក់ៗ មានសម្បជញ្ញៈមនសិការ
ពេលគេបានយល់ន័យពិស្តារ ច្បាស់នឹកម្ចាស់សារមិនលែងឡើយ ។

CHANBOKEO . COM

# ក្ដាម

ក្ដាមថ្មក្ដាមគ្រោងក្ដាមស្រែងៃ ក្ដាមពីវាលស្រែក្ដាមសមុទ្ទ
ក្ដាមនៅជាក្ដាមថៀសមិនផុត ដើរប្លែកពេកក្ដាត់ចំហៀងខ្លួន ។
ដង្កៀបកៀបកាត់អស់គល់ស្រូវ កៀបសត្វទូទៅមិនលាក់ពួន
ភ្នែកលៀនរំពៃរំពឹងក្បួន ដើរចំហៀងខ្លួនកៀបគេឯង ។
ដូចចរិតមនុស្សគិតសាមាន្យ ផ្លូវល្អកល្យាណបែរព្រលែង
រីផ្លូវងងិតទើបរអែង ស្រវាប្រឡែងអស់កាយកល ។
ដូចកូនបែរឆ្គងដើរចំហៀង ព្រងើយមិនផ្ទៀងពាក្យពន្យល់
ពុកម៉ែទូន្មានប្រៀនសោតសល់ គេចផ្លាញខ្លាចយល់ផ្លូវសុក្រិត ។
ជាតិក្ដាមខ្វាមដីដើរចំហៀង ភ្នែកលៀនខ្លួនផ្ទៀងខាងវិបរិត
កែខ្លួនដើរត្រង់ពិបាកពិត លើផ្លូវសុក្រិតត្រង់មិនរួច ។

CHANBOKEO . COM

# ផ្លែងង្កោ

ផ្លែងង្កោជ័រយ៉ាកនឹងធី　　មិនថាទុំខ្ចីបេះលាងមាត់
រសជាតិផលាហៅសែនចត់　　ខាំជ័រតតាត់យ៉ាកនឹងលេប ។
ថៃងន្យពេលគេយកទៅផ្សះ　　ត្រាំទឹកស្រោបផេះមិនគួរនែប
ហាលថ្ងៃរួចចិតយកមកសេព　　ឆ្ងាញ់គួរចង់ក្រេបមិនលែងដៃ ។
ដូចក្មេងទុរគតរស់គ្រិច　　ចរិតពាក្យពេចន៍យ៉ាកស្តាប់ក្រៃ
បើសិនបានផ្សះដោយប្រពៃ　　ក្មេងក្លាយចរណៃខ្ពស់សង្គម ។
ច្នេះកុំរំលងពលរដ្ឋជា　　ទោះក្រវេទនាឥតទ្រនំ
បើសិនយើងផ្សះដោយសមរម្យ　　ក្មេងក្លាយគ្រឹះមាំនាំជាតិថ្កើង ។

CHANBOKEO . COM

# ស៊ូរស់ដើម្បីជាតិ !

តើស្លាប់ធ្វើអ្វីដើម្បីជាតិ ស្លាប់ហើយអស់ស្មៀតខានការពារ
ស៊ូប្រឹងរស់វិញពេញកម្ពុជា ការ(១)ដីធារាធ្លាប់អំណាច ។
ស៊ូរស់ការពារនូវភាសា សញ្ញាណខេមរាភ្លឺចិញ្ចាច
រក្សាវប្បធម៌ល្បីបាចសាច ការពារអង់អាចមិនរាថយ ។
ស៊ូដកងង្ហើមទោះតិចៗ មិនរាបែរគេចដើរថយក្រោយ
ច្រវាចូកចែវសំដៅជ្រោយ តិចតួចក៏ដោយប្រឹងតាមបុណ្យ ។
ភាសារលត់ជាតិរលាយ វប្បធម៌ពណ្ណរាយក្លាយសិយស៊ុន
បើមិនរក្សាជាតិយើងកុន យូរឆាប់អាប់ឱនបើយើងភ្លាត់ ។
ច្នេះសិនម្នាក់ៗរួមចំណែក ភារៈរំលែកយ៉ាងមធ្យ័ត
រក្សាថៃទាំអភិវឌ្ឍន៍ ជាតិភ្លឺមរកតពេជ្រពណ្ណរាយ ។ (១) ការពារ

# គ្រូ

គ្រូពីកំណើតមានពុកម៉ែ ចិញ្ចឹមធ្លួនថៃហៅប្រដៅ
លុះធំដឹងក្ដីចូលរៀនទៅ គ្រូប្រៀនរូបពៅនៅសាលា ។
នៅវត្តអារាមមានព្រះសង្ឃ ទូន្មានកាយអង្គឲ្យវន្ទា
គោរពព្រះគ្រូពុទ្ធធម្មា មានចាស់ព្រឹទ្ធាណែនាំជោគ ។
ក្នុងភូមិមានញាតិហៅស្ដីប្រាប់ ប្រៀននូវទម្លាប់គួរត្រាប់យក
នៅទីការងារមាននាយក ណែនាំស្ដាប់ដក់នូវវិន័យ ។
មិនថាទីណាក្នុងជីវិត យើងមានគ្រូពិតពាសពេញដី
បើសិនចេះស្ដាប់ត្រងអត្ថន័យ ជីវិតជួបជ័យថ្កើងមិនលែង ។

អ្នកស្រីកែវចន្ទ័បូរណ៍

CHANBOKEO . COM

# វគ្គទីមួយ
## ចិត្តវិបត្តិរបស់កូន

CHANBOKEO.COM

តុក! តុក! តុក!

- នរណាហ្នឹង ?
- ចាស លោកវណ្ណៈ! គឺខ្ញុំ យាយរៀម!

យាយរៀមបើកទ្វារចូលទៅក្នុងបន្ទប់ធ្វើការដ៏ទូលាយមួយ ក្នុង វិឡាស្តុកស្តម្ភហ៊ឺហារបស់លោកអភិជនវណ្ណៈ ឃើញបុរសម្នាក់ក្នុង វ័យប្រហែល៤០ឆ្នាំ កំពុងអង្គុយនៅមុខកុំព្យូទ័រ ធ្វើការងារ តាមឥន្តឺណិត ។ ឃើញយាយរៀមចូលមកដល់ លោកក៏បែរសួរ ៖

- រកមនុស្សមកជួយដៃជើងនៅផ្ទះយើងបានហើយឬនៅ យាយ ?
- ចាស បានហើយ លោកប្រុស!
- ជាអ្នកមកពីខាងណាដែរ ?
- ជាក្មេងស្រីមកពី ភូមិបឹងរាំង បាត់ដំបង លោកប្រុស!
- ក្មេងស្រី ? តើយកមកប្រើធ្វើការងារក្នុងផ្ទះស្អីកើតទៅយាយ ?
- គឺនាងនោះវាក្មេងសំរាប់យាយ តែមិនមែនកូនក្មេងទេ ។ នាង មានអាយុ២៨ឆ្នាំហើយ ។ ពេលយាយត្រឡប់ទៅស្រុកវិញភ្លាមនោះ ក៏ឮអ្នកជិតខាងប្រាប់ថានាងកំពុងរកការងារធ្វើដែរ ទើបខ្ញុំទៅហៅ នាងមកជួបលោកតែម្តងទៅ ។
- ហើយនាងមកទេហ៍ ?

- ចា៎ស មក៎! កំពុងអង្គុយនៅចាំខាងក្រៅ ។

- ប៉ុន្តែ...យាយនឹងប្រវត្តិច្បាស់ហើយឬនៅ ថាស្រីក្មេងដែលមកសុំ ការងារធ្វើនៅផ្ទះខ្ញុំនេះ ជាមនុស្សសុចរិត អាចទុកចិត្តបាន ?

- បើតាមសំដីដែលកូនចៅរបស់ខ្ញុំវាប្រាប់ គ្រប់គ្នាគេថានាងជា មនុស្សគ្រាន់បើម្នាក់ក្នុងគ្រួសាររបស់នាង ។

- អញ្ចឹង នាងមកធ្វើជាអ្នកដាំបាយ ហើយយាយជាអ្នកមើលកូនៗ របស់ខ្ញុំវិញ មែនទេ ?

- ចា៎ស អត់ទេ លោកប្រុស! យាយចាស់ហើយ រត់តាមក្មេងមិន ទាន់ទេ ដូច្នេះ យាយសូមធ្វើការជាអ្នកដាំបាយជូនគ្រួសារលោក ប្រុសដដែលចុះ ។ ចំណែកនាងថ្មីនោះវិញ គេនៅក្មេងមានកម្លាំង រឹងប៉ឹងរហ័សរហួន អាចទប់ទល់នឹងភាពពិសរបស់ក្មេងៗបាន ។ យាយគិតថា ទុកអោយនាងទទួលខុសត្រូវខាងនោះចុះ ។

- ចុះគំនិតមារយាទរបស់នាងវិញនោះ ?

- ថ្វីបើនាងជាក្មេងស្រីសាមញ្ញម្នាក់នៅក្នុងភូមិ ប៉ុន្តែមិនដែលលេច ឮល្បីថានាងមានប្រវត្តិអាស្រូវអ្វីទេ ឃើញតែស្រវាស្រទេញធ្វើការ មិនទំនេរឡើយ លោកប្រុស ។

លោកវណ្ណៈគិតមួយស្របក់ ក៏ងក់ក្បាល ៖

- សមហេតុសមផលណាស់យាយ! អញ្ចឹង សូមយាយទៅហៅ នាងអោយចូលមកជួបខ្ញុំមក៎!

- ចា៎ស! លោកប្រុស!

ការពិត យាយរៀមនិងប្តីរបស់គាត់បានមកនៅបំរើក្រុមគ្រួសារ លោកវណ្ណៈតាំងពី២០មុនម្ល៉េះ ។ ក្រោយពីប្តីរបស់គាត់អនិច្ចកម្មទៅ យាយក៏មិនដែលត្រឡប់ទៅរស់នៅស្រុកកំណើតវិញទេ ព្រោះកូន ចៅរបស់គាត់ក្រីក្រ មិនអាចជួយទំនុកបំរុងយាយបាន ។ ម្យ៉ាង ទៀត ពេលនៅបំរើលោកវណ្ណៈ យាយរៀមក៏អាចសន្សំកម្រៃធ្វើទៅ ផ្ទះដើម្បីជួយទំនុកចៅៗអោយរៀនសូត្រនឹងគេទៀតផង ។ ដូច្នេះ ហើយបានជាយាយនៅបំរើលោកវណ្ណៈមិនព្រមទៅណាមកណា ។

បន្តិចមក យាយរៀមក៏នាំមាណវីមួយរូបចូលមកដល់ ។ លោក វណ្ណៈសម្លឹងមុខនារីដោយក្រសែភ្នែកយ៉ាងមុត រួចហើយក៏មាន ប្រសាសន៍សួរថា ៖

- នាងឈ្មោះអ្វីដែរ ?

- ឈ្មោះ យ៉ា ចា៎ស!

- ធ្លាប់រៀនសូត្រអ្វីខ្លះនឹងគេដែរទេ នាង ?

CHANBOKEO COM

- ចា៎ស រៀនតិចតួចដែរ អាចអានបាន សរសេរបាន!

យាយរៀមនៅអង្គុយក្បែរនោះ ស្តាប់លោកវណ្ណៈសម្ភាសន៍ នាងយ៉ាយ៉ាងល្អិតល្អន់ ។ លោកវណ្ណៈក៏ងើបឈរឡើង ដើរទៅក្បែរ បង្អួច ក្រពាត់ដៃទៅក្រោយ ហើយស្រដីថា ៖

- ខ្ញុំមានកូនបួននាក់ ប្រុសពីរស្រីពីរ ។ ពេលនេះ កូនប្រុសច្បង អាយុ១៨ឆ្នាំ កំពុងរៀនមហាវិទ្យាល័យឆ្នាំដំបូងនៅប្រទេសជប៉ុន ។ ចំណែកកូនស្រីទីពីរអាយុ១៨ឆ្នាំ ត្រូវចូលប្រឡងឌីប្លូមឆ្នាំក្រោយ ។ កូនប្រុសទីបីមានអាយុ៩ឆ្នាំ ហើយកូនស្រីពៅអាយុ៦ឆ្នាំ ។ ម្តាយ របស់គេបានធ្វើមរណកាលទៅកាលពី៤ខែមុន ។ រីឯខ្ញុំឯណោះវិញ ក៏ធ្វើការមិនសូវមានពេលទំនេរ ត្រូវចេញទៅប្រទេសក្រៅញឹក ញាប់ណាស់ ទើបមិនសូវមានពេលជាមួយកូន មើលថែទាំពួកគេ អោយបានដិតដល់ទេ មានតែយាយរៀមប៉ុណ្ណោះដែលជួយអ្វីសព្វ បែបយ៉ាង នៅក្នុងផ្ទះនេះ ។ ប៉ុន្តែ យាយរៀមក៏មានវ័យកាន់តែ ចាស់ទៅហើយ មិនអាចជួយខ្ញុំបានច្រើនប៉ុន្មានឡើយ ម្ល៉ោះហើយ ខ្ញុំត្រូវការនាង អោយមកជួយមើលណែនាំនិងថែទាំកូនចៅរបស់ខ្ញុំ ទុកអោយយាយរៀមជាអ្នកថែផ្នួនខាងអាហារនិងជើងក្រាន ហើយ នាយតឿជាអ្នកថែទាំផ្ទះ ថែសួននិងបើកឡាន ។ តើនាងអាចធ្វើ បានទេ ? បើនាងសិនជាមិនចូលចិត្តធ្វើការជាមួយក្មេង នាងអាច សុំប្តូរការងារជាមួយយាយរៀមវិញក៏បាន ។

- អត់ទេ លោកប្រុស! ខ្ញុំសូមនៅធ្វើការឯចង្ក្រានបាយដូចមុនៗ ទៅចុះ (យាយរៀមប្រកែក) នាងថា គេអាចទទួលខុសត្រូវក្មេងៗ បាន មិនអីទេ ។

- ហេតុអ្វីក៏មានជំនឿដល់ម្លឹង យាយ ?

- គឺ មកពីនាងធ្លាប់ថែទាំងប្អូនរបស់នាងជាច្រើននាក់នោះអី ។

លោកវណ្ណៈបែរមើលនារី ហើយក៏ញញឹម ៖

- អញ្ចឹង ខ្ញុំសង្ឃឹមថានាងអាចទទួលកិច្ចការនេះបាន!

ធិតាញញឹមតបវិញ ហើយវាចាឆ្លើយ ៖

- ចា៎ស! នាងខ្ញុំអាចទទួលបាន លោកប្រុស!

- ហើយចុះនាងចង់ទទួលប្រាក់ខែប៉ុន្មានដែរ ?

នាងយ៉ាឈ្ងោកមុខមួយស្របក់ក៏ឆ្លើយថា ៖

- នាងខ្ញុំចង់ស្តាប់សំណើលោកប្រុសវិញ ថាតើលោកប្រុសអាចផ្តល់ ប្រាក់ខែប៉ុន្មានដល់នាងខ្ញុំទៅ ?

CHANBOKEO.COM

លោកវណ្ណៈ សម្លឹងមុខនារីដោយក្រសែភ្នែកយ៉ាងមុត បន្តិច មក ក៏មានប្រសាសន៍ថា ៖

- មួយខែ ៤០ដុល្លារ យ៉ាងម៉េចដែរ ?

ញូដូច្នោះ នាងយ៉ាបើកភ្នែកមូលក្លំ ទំនងភ្ញាក់ផ្អើល ៖

- មែនឬ លោកប្រុស ? បើដូច្នោះ នាងខ្ញុំមិនតថ្លៃទេ សូមយល់ ព្រមទាំងស្រុងចាំស!

- ឈប់! នៅស្ងៀមបន្តិចសិនណា៎! (លោកវណ្ណៈមានប្រសាសន៍ឃាត់) មិនមែនងាយដូចនាងគិតទេណា៎ ព្រោះយើងមិនទាន់និយាយគ្នាពីរឿងភារៈដែលនាងត្រូវទទួលខុសត្រូវនៅឡើយ ។

- ចាំស! លោកប្រុស! នាងខ្ញុំក៏កំពុងតែឆ្ងល់ដែរ ថាហេតុអ្វីលោកប្រុសហ៊ានអោយប្រាក់ខែនាងខ្ញុំច្រើនដល់ម្លឹង ?

- ត្រូវហើយ! គឺខ្ញុំចង់អោយនាងថែទាំមើលការខុសត្រូវកូនប្រុស កូនស្រីរបស់ខ្ញុំអោយគេទៅរៀនទៀងទាត់ ស្លៀកពាក់ត្រឹមត្រូវ និយាយត្រឹមត្រូវ មិនព្រហើនកោងកាចមានសណ្តាប់ធ្នាប់ គេង ទៀង បរិភោគទៀង ហើយជួយមើលទុកដាក់បន្ទប់ផ្ទាល់ខ្លួនរបស់គេអោយមានរបៀបផង ។ នាយតឿជាអ្នកថែទាំផ្ទះមែន តែនាយ តឿជាបុរសមិនអាចឡើងចុះបន្ទប់កូនស្រីរបស់ខ្ញុំនៅខាងលើបាន ទេ ដូច្នេះខ្ញុំអនុញ្ញាតអោយនាងនិងយាយរៀមជាអ្នកទទួលបន្ទុក ខាងនេះ ។ ពេលណាខ្ញុំចេញទៅបរទេសនាងត្រូវជួយយាយរៀម និងនាយតឿថែផ្ទះអោយបានល្អផង ។ ផ្ទះយើងមិនទទួលភ្ញៀវចម្លែកទេ បើសិនណាខ្ញុំមិនបានប្រាប់អ្នកទាំងអស់ជាមុន ។ ម្យ៉ាង ទៀតចៅហ្វាយក្នុងផ្ទះនេះមានតែម្នាក់គត់ គឺខ្ញុំ មិនមែនកូនប្រុស ឬកូនស្រីរបស់ខ្ញុំទេ ។ សូមកុំថែទាំគេ របៀបទំយើទំរើសអោយ សោះ ។ ប៉ុន្តែ នេះមិនមែនបានន័យថានាងមានសិទ្ធិវាយដំជេរស្តី កូនរបស់ខ្ញុំទេណា៎! បើនាងមិនយល់អ្វី នាងមានយាយរៀមសំរាប់ពិគ្រោះហើយ ។ គាត់ជាចាស់ទុំដែលរស់នៅទីនេះជាងម្ភៃឆ្នាំមកហើយ ដូច្នេះ យាយដឹងច្បាប់ទម្លាប់របស់ផ្ទះយើងមុតមាំណាស់ ។

- ចាំស លោកប្រុស!

- នាងត្រូវធ្វើការដោយប្រយ័ត្នមធ្យ័តបំផុត ។ នៅទីនេះ នាងមិនអាចនាំញាតិមិត្តមកលេងចេញចូលតាមចិត្តបានទេ ។ នៅក្នុងបីខែ ម្តងនាងអាចឈប់សំរាកទៅលេងផ្ទះបីថ្ងៃ ។ បើនាងសុខចិត្តនៅ ធ្វើការបន្ត

នាងនឹងទទួលប្រាក់បន្ថែម ។ ប៉ុន្តែ បើនាងសុំឈប់ទៅ លេងផ្ទះមួយឆ្នាំមួយដងវិញ នាងអាចឈប់បានពីរអាទិត្យដោយមិន បាត់បង់ប្រាក់ខែរបស់នាងអ្វីឡើយ ។

- ចាស! លោកប្រុស! នាងខ្ញុំយល់ព្រម ប៉ុន្តែ...
- ប៉ុន្តែ យ៉ាងម៉េច ?
- នាងខ្ញុំសុំបើកប្រាក់មុនមួយឆ្នាំបានទេ ?
- ខ្ញុំមិនទាន់ដឹងថា នាងធ្វើការល្អឬយ៉ាងណា បើកប្រាក់ខែអោយ មុនយ៉ាងម៉េចនឹងកើត ?
- បើដូច្នោះ នាងខ្ញុំសូមធ្វើការមួយខែសិន បើសិនលោកប្រុសទុក ចិត្តហើយ នាងខ្ញុំសុំបើកមួយឆ្នាំមុន ដើម្បីផ្ញើជូនម៉ែនៅស្រុក ។

លោកវណ្ណៈសម្លឹងមុខនារីម្តងទៀត ដោយក្រសៃភ្នែកយ៉ាងមុត ហាក់ដូចជាចង់ស្គាល់ទឹកចិត្តរបស់នាង ។ បន្តិចមក លោកក៏ងក់ ក្បាលយល់ព្រម ។ យាយរៀមក៏នាំមាណវីចេញទៅបន្ទប់ ដែលនៅ អាគារខាងក្រោយផ្ទះធំ ។ ឯលោកវណ្ណៈ ក៏ត្រឡប់ទៅធ្វើការរបស់ លោកវិញដូចធម្មតា ។

- ខ្ញុំស្នាក់នៅបន្ទប់ជាមួយយាយដែរ មែនទេយាយ ?
- មែនហើយ! ឯនាយតឿវិញ ដេកនៅបន្ទប់ចុងគេខាងនោះ ជាប់នឹងចង្ក្រានបាយ ។
- ហើយចុះពូតឿទៅណាហើយ បានជាមិនឃើញគាត់អញ្ចឹង ?
- នាយតឿអាល័យបើករថយន្ត ទៅទទួលកូនចៅលោកប្រុសមកពី សាលារៀន បន្តិចទៀត នាងបានជួបគ្រប់គ្នាហើយ ។

ល្ងាចនោះ នាងយ៉ា ជួយធ្វើការយាយរៀមនៅឯចង្ក្រានបាយ បណ្តើរ លួចសង្កេតអ្វីៗក្នុងផ្ទះបណ្តើរ ។ បន្តិចមក នាងសួរយាយ រៀមថា ៖

- យាយ! លោកប្រុសជាមនុស្សកាចទេយាយ ?
- មិនកាចទេ តែមធ្យ័តហ្មត់ចត់ និយាយម៉ាត់ណាម៉ាត់ហ្នឹង មិនចូល ចិត្តនិយាយច្រើនឥតប្រយោជន៍ទេ ។ កាលលោកស្រីនៅរស់គ្រាន់ នឹងរួសរាយខ្លះ ។ ប៉ុន្តែតាំងពីអត់ពីលោកស្រីប៉ុន្មានខែមក ផ្ទះនេះ ស្ងាត់ជ្រងំណាស់ ។ កូនៗមិនសូវហ៊ានក្អករំខានចិត្តឪពុកទេ ប៉ុន្តែ គ្នាក៏មានទុក្ខសោកខាងផ្លូវចិត្តមិនខុសពីឪពុកដែរ គ្រាន់តែគេមិន ហ៊ានទៅស្និទ្ធស្នាលនឹងឪពុកគេដូចជាម្តាយរបស់គេឡើយ ។
- គួរអោយអាណិតពួកគេណាស់ ។ ខ្ញុំក៏ធ្លាប់កំព្រាម្តាយដែរ តាំង ពីអាយុបីបួនឆ្នាំ ដឹងថាការនឹកម្តាយនោះវាធំធេងប៉ុនណាហើយ!

CHANBOKEO.COM

- បើនឹងដូច្នោះហើយ ចៅត្រូវជួយមើលគេអោយបានល្អផង ។
- ហើយចុះពួកក្មេងៗនោះ គេយ៉ាងម៉េចដែរ យាយ ?
- ជាក្មេងល្អទេ ប៉ុន្តែ តាំងពីលោកស្រីស្លាប់ទៅ អ្នកនាងតូចវណ្ណនី ចូលចិត្តលួចដើរលេងណាស់ ជាពិសេសពេលលោកប្រុសមិននៅ ។ ពេលនេះ អ្នកនាងតូចដូចជាម្ដាយម៉ៅក្រឡូវម៉ូវខុសធម្មតាតែម្ដង ។
- អញ្ចឹង យាយមិនជំរាបលោកប្រុសទេ ?
- ថានឹងជំរាបម្ដងៗហើយ តែលោកប្រុសចេះតែរវល់ជាប់ ដកឃ្លា មិនរួច រកតែនិយាយអ្វីមិនទាន់ទេ លោកប្រុសចេញទៅបាត់ទៀត ហើយ ។ យាយក៏ចេះតែខកខានទៅ ។

រំពេចនោះរថយន្តថ្មីស្រឡាងមួយបានផ្ទុកក្មេងប្រុសស្រីមុខមាត់ស្អាតបាតបីនាក់មកដល់ ។ នាងយ៉ា ក៏ដើរពីក្រោយយាយរៀមចេញ ទៅទទួល ។

- ចៅវណ្ណនី វណ្ណនេត្រ វណ្ណា! យើងមានគ្នីគ្នាថ្មីម្នាក់ រស់នៅជា មួយពួកយើងនែ៎ក!

យាយរៀមបង្ហាញខ្លួនមាណវីអោយក្មេងៗស្គាល់ ។ ពួកគេងើបមុខមើលនាងហើយញញឹមស្ងួត ។ វណ្ណនីក៏សួរថា ៖

- បងស្រីឈ្មោះអ្វីដែរ ?
- ឈ្មោះយ៉ា ចា៎ស!
- ហេតុអ្វីបានមកស្នាក់នៅទីនេះ ?
- គឺឪពុកអ្នកនាងទទួលខ្ញុំមកអោយជួយធ្វើកិច្ចការក្នុងផ្ទះ ។
- មានយាយរៀមនិងពូតឿមើលថៃហើយ យើងដូចជាមិនត្រូវការ បងស្រីមកធ្វើការស្អីទីនេះ នាំតែចង្អៀតផ្ទះឥតប្រយោជន៍ទេ ។

ថាហើយ នារីតូចក៏ដើរត្រុយចូលផ្ទះទៅ ។ កុមារវណ្ណនេត្របែរ សម្លឹងមុខនាងយ៉ា ហើយនៅស្ងៀមរួចហើយក៏ដើរតាមក្រោយបង ស្រីឡើងទៅខាងលើផ្ទះបាត់ ។ ចំណែកនាងតូចវណ្ណាក៏ដើរមកចូល ជិតនាងយ៉ា ហើយស្រវាចាប់តោងដៃមាណវីភ្លាម ៖

- បងស្រីចេះលេងបាយខុមទេ ? វណ្ណាចង់លេងបាយខុម តែបង វណ្ណនីនិងបងវណ្ណនេត្រ មិនដែលអោយខ្ញុំលេងជាមួយទេ ។

មាណវីដាក់ខ្លួនអង្គុយចុះទាប ហើយនិយាយជាមួយនាងតូច យើងថា ៖

- បើនាងតូចស្ដាប់បង នោះបងនឹងលេងបាយខុមជាមួយប្អូនរាល់ ថ្ងៃតែម្ដង ។
- មែនណា៎!

CHANBOKEO . COM

- ចាស! មែនហើយ!

- ជយោ! តែប៉ុណ្ណោះ វណ្ណាបានគ្នាលេងបាយខុមហើយ ។

នាងតូចសំដែងក្តីរីករាយភ្លាមមួយរំពេច ។ ពេលនោះ ពូតឿ ពោលពៅកាន់នាងយ៉ា ថា ៖

- រាប់តែនាងតូច មិនរាប់ពូផងទេហ្អីនាង ?

នាងយ៉ាងើបមុខឡើង ឃើញពូតឿសើចគ្របាញ ក៏ញញឹម តបវិញ ៖

- ហើយពូចង់លេងបាយខុមជាមួយពួកយើងដែរទេ ?

- ថីមិនចង់ ប៉ុន្តែ ពូសុំកាន់ខាងនាងតូចវណ្ណាចុះ កុំអោយមានគេ ដើរខ្សែលើ ។

- ម៉េចក៏ពូដឹងកើត ថាខ្ញុំដើរខ្សែលើ ?

- ប្រយត្ន័ទុកជាមុនទើបប្រសើរ ក្រែងចាស់ៗដើរខ្សែលើក្មេង ។

ពូតឿសើចខឹកៗហើយក៏បរឡានត្រឡប់យកទៅលាង ។ មើល ទៅពូតឿក៏រួសរាយណាស់ដែរ មិនចង្អៀតចង្អល់ពោកទេ ខុសអ្វីតែ អ្នកនាងតូចវណ្ណានីដែលដូចជាហ្មួហ្មងក្នុងចិត្តជាងគេក្នុងផ្ទះនោះ ។

ព្រលប់ពេលបាយ...

នាងយ៉ាធ្វើការផង លួចសង្កេតកិរិយានិងទម្លាប់គ្រប់ៗគ្នាដែល នៅក្នុងផ្ទះផង ។ នាងជួយយាយរៀមរៀបតុបាយទទួលលោកវណ្ណៈ និងកូនប្រុសស្រីទាំងបីនាក់ ព្រមទាំងនៅចាំបំរើរហូតដល់ម្ចាស់ផ្ទះ បរិភោគរួចរាល់ ។ មាណវីសង្កេតឃើញលោកវណ្ណៈរក្សាកិរិយា ស្ងៀមស្ងាត់មិនមាត់កអ្វីទេ រហូតដល់លោកបរិភោគអាហារហើយ ។ ចំណែកក្មេងៗ ឃើញតែលួចចោលកន្ទុយភ្នែកដាក់គ្នាទៅវិញទៅ មកមិនដាច់ ប៉ុន្តែក៏គ្មាននរណានិយាយអ្វីឡើយ កាលបើឃើញឪពុក នៅស្ងៀមស្ងាត់ដូច្នោះ ។

បន្តិចមក លោកវណ្ណៈក៏ស្លៀកពាក់រៀបរបចេញទៅក្រៅ ។ នាងយ៉ា នៅឈរមាត់ទ្វារ ចាំបំរើ ស្រាប់តែលោកវណ្ណៈពោលថា ៖

- នាងមិនបាច់នៅបំរើខ្ញុំទេ ទុកអោយនាយតឿធ្វើចុះ ។

- ចាស លោកប្រុស!

នាងយ៉ា ក៏ឈ្ងោកមុខដើរខិនៗចេញទៅ ។ លុះលោកវណ្ណៈ ចេញទៅបាត់ នាងក៏ឡើងទៅលើឡៅ ជួយមើលក្មេងៗ ។

- នរណាគេអនុញ្ញាត្តអោយបងស្រីឡើងមកខាងលើឡៅនេះ ?

CHANBOKEO.COM

នាងយ៉ាក្រឡេកទៅម្ចាស់សម្លេងឃើញនាងតូចវណ្ណនីកំពុងឈរ
ច្រត់ចង្កេះសម្លក់នាង ។

- គឺលោកប្រុសបានអនុញ្ញាតហើយ អ្នកនាង ?
- ពីអង្កាល់ ?
- ពីរសៀលពេលខ្ញុំមកដល់ ។
- តែខាងលើនេះ ប្រើបានតែម្ចាស់ផ្ទះទេ ។ អ្នកដែលមិនមែនជា ម្ចាស់ផ្ទះ
មិនអាចឡើងមកបានទេ ។
- ហើយចុះ អ្នកនាងតូចសំអាតផ្ទះខាងលើនេះ ដោយខ្លួនឯង មែនទេ ?
- មិនមែនទេ! គឺយាយរៀម!
- ថៃដន្យ យាយគាត់ចាស់អាយុជិតចិតសិបហើយ ឡើងចុះជណ្តើរ ពិបាកណាស់
ទើបលោកប្រុសអោយខ្ញុំមកធ្វើកិច្ចការជំនួស ។

ក្រមុំតូចឈរទ្រឹងមួយស្របក់ ក៏និយាយថា ៖

- បាន! បើចង់មកសំអាតមែន ចាំពេលព្រឹកទៅ ព្រោះពេលនេះ ជាវេលាផ្ទាល់ខ្លួនរបស់ខ្ញុំ ។
- បើដូច្នោះ ខ្ញុំមិនរំខានអ្នកនាងទេ ។

ថាហើយ នាងយ៉ា ក៏ដើរទៅរកវណ្ណនេត្រនិងវណ្ណាដែលកំពុង ឱនឈ្ងោកគូររូប ។

- កិច្ចការសាលាមែនទេ ប្រុសតូច ? នាងតូច ?

វណ្ណនេត្រឃើញវត្តមានរបស់នាងយ៉ាភ្លាម ក៏ឆក់ក្រដាសគំនូរ និងខ្មៅដៃពណ៌ដើបយ៉ាងរហ័ស
រត់ចូលបន្ទប់គេងផ្ទាល់ខ្លួនបាត់ទៅ ដោយមិនស្រដីអ្វីមួយម៉ាត់ជាមួយនាងទេ
សល់តែនាងតូចពៅដែល ញញឹមហើយស្រដីថា ៖

- បងចេះគូរទេ ? ជួយគូរអោយអូនបន្តិចមក៎!
- បងមិនចេះគូរទេ ប៉ុន្តែ បងចេះសរសេរ ។ នាងតូចចង់រៀន សរសេរទេ ?
- ចង់! តែខ្ញុំទើបចូលរៀន ចេះសរសេរតិចៗទេ បងអើយ!
- អញ្ចឹង យើងរៀនសរសេរទាំងអស់គ្នា យ៉ាងម៉េចដែរ ?
- ចា៎ស!

នាងយ៉ាចាប់ខ្មៅដៃ មកណែនាំនាងតូចយើងអោយរៀនគូស វាសអក្សរទៅតាមដំណើរ ។
មួយស្របក់ក្រោយមក នាងតូចក៏ ស្ទាបហាមៗ ។

- ចូលគេងទេ នាងតូច ?

CHANBOKEO COM

- អត់ទេ! ចាំប៉ាមកវិញសិន!
- ចាំធ្វើអ្វី ? ប៉ាមកវិញ នៅពេលយប់ជ្រៅឯណោះ ។
- គឺចាំអោយគាត់មកនិទានរឿងអោយអូនពៅស្តាប់ ។
- ប៉ុន្តែ បងថាក៏ចេះនិទានរឿងដែរ ។ អូនចង់ស្តាប់ទេ ?
- ចា៎ស ចង់!
- អញ្ចឹង អូនទៅគេងទៅ! ចាំបងនិយាយរឿងអោយស្តាប់ ។

នៅក្នុងបន្ទប់គេងរបស់នាងតូច មាណវីបបោសនាងតូចអោយ គេងបណ្តើរ និយាយរឿងព្រេងអោយស្តាប់បណ្តើរ ។

- បងយ៉ា!
- ចា៎ស!
- បងដឹងរឿងព្រេងដែរហ្ន៎ស ?
- ដឹងច្រើនណាស់ ។
- បងដឹងពីណាមក ?
- ដឹងពីឪពុកបង ពីម្តាយបង ពីអ្នកជិតខាង ពីសាលារៀន
- អូហ៍! ហេតុអ្វីខ្ញុំទៅរៀនដែរ មិនដែលឃើញលោកគ្រូនិទាន រឿងដូច្នេះ ?
- នៅពេលអូនចេះអានអក្សរ ចេះសរសេរជ្រៅជ្រះ នោះលោកគ្រូ នឹងអោយអូនអានសៀវភៅរឿងព្រេងច្រើនណាស់យកមិនអស់ទេ
- អញ្ចឹងអូនតូចនឹងខំរៀន ដើម្បីអោយឆាប់បានអានរឿងព្រេង
- ចា៎ស! ប៉ុន្តែពេលនេះ នាងតូចដល់ម៉ោងគេងហើយ ។ ថ្ងៃ ស្អែកចាំបងនិយាយអោយស្តាប់ទៀត ។

នាងតូចញញឹមពព្រាយ ។ នាងយ៉ាពន្លត់ភ្លើង ហើយបិទទ្វារ បន្ទប់ ដើរចេញទៅ ទុកអោយនាងតូចនៅឆ្មេចគេងម្នាក់ឯងយ៉ាង ស្ងៀមស្ងាត់ ។ មកដល់ជិតមាត់ជណ្តើរ នាងយ៉ាប្រទះឃើញកុមារ វណ្ណនេត្រច្រត់ចង្កា អង្គុយសំកុកធ្វើមុខហ្មួហ្មង ។ នាងក៏ដាក់ខ្លួន អង្គុយចុះក្បែរកុមារ ហើយស្រដីសួរដោយទន់ភ្លន់ ថា ៖

- ប្រុសតូចកំពុងចាំផ្លូវលោកប៉ា មែនទេ ?

កុមារវណ្ណនេត្រញោចខ្លួនបែរសម្លឹងមាណវី រួចក៏ឈ្ងោកមុខចុះ មិនស្រដី ។ ឃើញដូច្នោះ នាងយ៉ាក៏ស្រដីបន្ត ៖

CHANBOKEO.COM

- បងគិតថា អូនកំពុងនឹកម៉ាក់ហើយ!

ស្រាប់តែកុមារភ្ញាក់ក្រញាង លាន់មាត់ភ្លាម ៖

- ម៉េចក៏បងដឹងកើត ?

- គឺទឹកមុខដ៏ក្រៀមក្រំរបស់ប្អូននោះអី ដែលបញ្ជាក់ប្រាប់បង ។

កុមារឈ្ងោកមុខចុះធ្វើទឹកភ្នែករលីងរលោង ។ នាងយ៉ាយកដៃ បបោសខ្នងកុមារ ក្នុងកិរិយាហាក់ដូចជាកំពុងលួងលោមអោយគេ បានធូរស្រាលទុក្ខសោកក្នុងចិត្ត រួចហើយក៏វាចាបន្តថា ៖

- បងដឹងណា៎... ថាប្រុសតូចសោកសៅប៉ុនណា...

- មែន ? ហេតុអ្វីបានបងដឹង ? (កុមារសួរទាំងមុខស្រពោន)

- ព្រោះបងធ្លាប់កំព្រាម្ដាយតាំងពីក្មេង មិនខុសពីប្អូនទេ ។ កាល នោះ បងនៅជាក្មេងតូចម្នាក់ដូចនាងអូនវណ្ណាអញ្ចឹង ។

- ហើយចុះ បងធ្វើម៉េចខ្លះ ដើម្បីកុំអោយនឹកគាត់ ?

- គឺ... ដំបូងៗ បងអង្គុយសំកុកយំ... តែម្នាក់ឯង ។

- មែនហើយ! ដូចខ្ញុំពេលនេះអញ្ចឹង... ខ្ញុំយំឡើងរកទឹកភ្នែកយំ លែងឃើញហើយ ប៉ុន្តែ ខ្ញុំនៅតែនឹកម៉ាក់ដដែល...

វណ្ណនេត្រក៏ងើបមុខឡើងបែរមើលនាងយ៉ាហើយសួរបន្តថា ៖

- រួចហើយ បងធ្វើយ៉ាងណា កាលបើបងនឹកម្ដាយ ប៉ុន្តែគ្មានទឹក ភ្នែកសំរាប់យំ ?

នាងយ៉ាគិតមួយស្របក់ក៏ឆ្លើយថា ៖

- កាលនៅតូច បងមិនចេះអក្សរ បងយំ រួចហើយបងសំកុកដូច ជារូបប្អូនពេលនេះអញ្ចឹង ។ ក្រោយមក បងក៏អង្គុយស្ដាប់ចម្រៀង ហើយរៀនច្រៀង បន្លប់អារម្មណ៍ ។ កាលនោះ ពេលបងនឹកម្ដាយ បងកាលណា បងតឹងទ្រូងណាស់ ប៉ុន្តែ កាលបើបងបានច្រៀង ចេញមក បងហាក់ដូចជារសាយចិត្តតប់ប្រមល់ខ្លះ ។

- ហើយបងមានរសាយចិត្តខ្លះទេ ?

- រសាយខ្លះដែរ ប៉ុន្តែ...

- ប៉ុន្តែ យ៉ាងម៉េចទៅបង... ?

- ពេលបងរៀនអក្សរ ចេះអាន ចេះសរសេរ បងក៏ចាប់ផ្ដើមរៀន

សរសេរអ្វីៗដែលនៅក្នុងខួរក្បាលបងនោះដាក់ក្នុងសៀវភៅ រៀង រាល់ថ្ងៃ ។ ជួនកាលបងសរសេរទៅម៉ាក់បងទៀតផង ។ ក្រោយ មក ពេលឪពុករបស់បងចែកស្ថានទៅ បងក៏ធ្វើដូចគ្នាទៀត ។

- ធ្វើដូច្នោះរួចហើយ បងបានរសាយជាងមុនហ្មែស ?

- មែន! ដំបូង បងគិតថា ជាការឥតប្រយោជន៍ទេ ព្រោះបង សរសេររួចហើយ មិនឃើញធូរទ្រូងអ្វីសោះ ។ ប៉ុន្តែលុះបង សរសេរយូរៗទៅ ទើបបងដឹងថា បងបានធូរក្នុងចិត្ត មួយថ្ងៃ បន្តិចៗ ដោយមិនដឹងខ្លួនឡើយ ។ ពេលនោះ ទើបបងដឹងថា ការ សរសេរបញ្ចេញនូវអារម្មណ៍អាប់អួររបស់យើង ទៅលើក្រដាស អាចធ្វើអោយយើងរសាយទុក្ខសោក ដូចគ្នានឹងការដែលយើងយក រឿងទុក្ខសោករបស់យើង ទៅនិយាយចែករំលែកអោយញាតិស្តាប់ ដើម្បីបន្ធូរទ្រូងរបស់ខ្លួនយើងនោះឡើយ ខុសគ្នាត្រង់ថា សៀវភៅ មិនចេះមានមាត់វែង នាំរឿងរបស់យើងលេចឮទៅក្រៅឆ្ងាយ វែងឆ្ងាយដូចមាត់មនុស្សទេ ។ ដូច្នេះហើយ ទើបបងគិតថា ការ សរសេរបញ្ចេញនូវអារម្មណ៍របស់យើងទៅលើក្រដាសដើម្បីសំរាល ទុក្ខនៅក្នុងទ្រូង មានសុវត្ថិភាពសំរាប់អ្នកដែលមានការឈឺចាប់ដូច ជាពួកយើងនេះណាស់ ព្រោះគ្មាននរណាគេដឹងអំពីចំណុចខ្សោយ របស់យើង ដែលនាំអោយមនុស្សផងទាំងឡាយពេបជ្រាយនិយាយ ដើមបានឡើយ ។

- បងស្រីឆ្លាតណាស់ ចេះរកវិធីសម្រាលទុក្ខឃើញដោយខ្លួនឯង! ចំណែកនេត្រវិញ រកនឹកមិនឃើញទេ ថាតើត្រូវធ្វើម៉េចដើម្បីកុំឲ្យ ពិបាកចិត្តនឹកម៉ាក់ពេក ។ មើលទៅលោកប៉ាចុះ! រវល់អីរវល់ មិន ដែលនឹកនាពីកូនសោះ ។ ពេលលោកមកដល់ផ្ទះវិញ ក៏មិនឃើញ សំដីរួសរាយដាក់កូនអ្វី ដូចពីដើមឡើយ ។

- នេះក៏ព្រោះលោកប៉ាកំពុងនឹកម៉ាក់របស់ប្អូន ហើយក៏កំពុងឱប ទុក្ខសោកសៅនៅក្នុងចិត្ត មិនខុសគ្នាប៉ុន្មានពីរូបប្អូនទេ ដូច្នេះ ហើយ ទើបលោកមិនអាចនិយាយស្រដីអ្វីមកក្រៅ ជាមួយនរណា បាន ។ ជាពិសេស ពេលលោកបិទទ្វារលាក់ខ្លួននៅក្នុងការិយាល័យ របស់លោក ប្រហែលជាលោក កំពុងតែលួចសរសេរបញ្ចេញនូវ អារម្មណ៍របស់លោក ទុកជាសំណៅនៅក្នុងសៀវភៅផង ក៏មិន ដឹង ។

- មែនហើយ ខ្ញុំឧស្សាហ៍ឃើញលោកប៉ាសរសេរណាស់ ជាពិសេស ពេលលោកនៅម្នាក់ឯង ។ នេះ ប្រហែលជាដូចពាក្យបងនិយាយ មែនទេដឹង ?

ស្រាប់តែកុមារបែរមុខសម្លឹងមាណវី ហើយជ្រួញចិញ្ចើម រួច សួរថា ៖

- បងទើបតែមកផ្ទះយើងមួយថ្ងៃ ហេតុអ្វី បងហាក់ដូចជាយល់ស្ថានការណ៍ក្នុងផ្ទះរបស់យើងម្ល៉េះ ? បងធ្លាប់ស្គាល់ពួកយើងពីមុន មក មែនទេ ?

នាងយ៉ាគ្រវីក្បាល ៖

- អត់ទេ! បងទើបស្គាល់គ្រួសាររបស់ប្រុសតូច ថ្ងៃនេះឯង ។
- ខ្ញុំគិតថា បងជាមនុស្សឆ្លាតណាស់ ព្រោះជួបពួកយើងតែមួយថ្ងៃ ដឹងចិត្តដឹងថ្លើមរបស់ពួកយើង អស់រលីងតែម្តង ។
- មិនមែនទេ អូនតូច! បងគ្រាន់តែយល់ដឹងពីអារម្មណ៍អ្នកដែលមានទុក្ខដោយការព្រាត់ប្រាសនោះទេតើ ព្រោះបងធ្លាប់ហែលឆ្លងការពិសោធន៍នោះដោយខ្លួនឯងរួចមកហើយ ។ អូហ៎ នែ៎! នេះ យប់ហើយណ៎! ដល់ម៉ោងចូលគេងហើយ ។ ប្អូនទៅគេងសិនទៅ ចាំស្អែក យើងនិយាយគ្នាទៀតណ៎ ។
- បាទ បង!

កុមារវណ្ណនេត្រដើបឡើងដើរទៅរកបន្ទប់គេង ស្រាប់តែគេ ទុចជំហ៊ាន បែរក្រោយហើយស្រដីថា ៖

- យើងនិយាយគ្នាស្អែកទៀតទេ បងស្រី ?

នាងថាញញឹមហើយឆ្លើយថា ៖

- ចា៎ស! ស្អែក យើងនឹងនិយាយគ្នាបន្តទៀត!
- អញ្ចឹងនេត្រទៅគេងហើយ ។

វណ្ណនេត្រញញឹមតបវិញ រួចហើយក៏លើកដៃបក់បោយ លាទៅគេងបាត់ទៅ ។ នាងយ៉ាដើរចុះជណ្តើរមកដល់បន្ទប់ទទួលភ្ញៀវ ស្រាប់តែប្រទះឃើញនាងតូចវណ្ណនីកំពុងនិយាយទូរសព្ទ័ខ្លាំងៗ ៖

- មកយកខ្ញុំពេលនេះភ្លាមណ៎! ទាន់លោកប៉ាមិននៅ!... អូហ៍! លោកមិនចង់ដឹងទេថាខ្ញុំនៅឬមិននៅ... ព្រោះឥឡូវនេះ លោក មិនដែលរវីរវល់នឹងសុខទុក្ខរបស់ខ្ញុំដូចមុនៗឡើយ... កុំទៅភ័យ! ខ្ញុំមានលុយ... យើងដើរលេងទល់ព្រឹកក៏បានដែរ ។

នាងយ៉ាភ្ញាក់ព្រើត កាលបើឮប្រយោគនេះ ។

រំពេចនោះ នាងតូចវណ្ណនីបែរមកចំឃើញវត្តមាននាងភ្លាម ក៏បើកភ្នែកធំៗ ទម្លាក់ទូរសព្ទ័ហើយក៏ស្រដីខ្លាំងៗដាក់នាងយ៉ា ៖

CHANBOKEO.COM

- នែ៎! អត់សុជីវធម៌ម្ល៉េះ មកលួចស្តាប់គេនិយាយទូរសព្ទ័ ?

នាងយ៉ាភ្ញាក់ក្រញាង ដែលនាងតូចច្រឡឹងសោភានោះមានសំដី អសុរសមិនគួរបើគិត ។ មាណវីក៏ឆ្លើយរឹងឡើងថា ៖

- អ្នកនាងតូចមាត់ឮយ៉ាងនេះ មិនបាច់លួចស្តាប់ ក៏ឮដែរ ។
- កុំមកតមាត់! ត្រឹមជាអ្នកបំរើ គឺចាំតែស្តាប់បញ្ជាតែម្យ៉ាងទេ មិន មែនជួលអោយតមាត់ម៉ុងម៉ាំងវាយឫកស្មើចៅហ្វាយទេ ។

រំពេចនោះ ស្រាប់តែនាងយ៉ាញញឹម ហើយឆ្លើយថា ៖

- ពិតមែនហើយអ្នកនាង! ខ្ញុំជាអ្នកបំរើ ត្រូវស្តាប់បញ្ជាចៅហ្វាយ ជានិច្ច ខានមិនបានទេ ព្រោះខ្លាចដាច់ប្រាក់ខែណាស់ ។ បើដូច្នោះ សូមអ្នកនាងជួយខ្ញុំអោយបំពេញនាទីជាបំរើដ៏ល្អ ចំពោះចៅហ្វាយ នាយផង ។
- ចង់មានន័យថាម៉េចហ្នឹង ?
- គឺខ្ញុំចង់ជំរាបអ្នកនាងតូចថា លោកប្រុសបានអោយសិទ្ធិខ្ញុំមើល ការខុសត្រូវលើអ្នកនាង ទាំងចរិយាមារយាទ ការប្រព្រឹត្ត និងការ សិក្សា ។ ពេលនេះ អ្នកនាងមានសំដីឫកពាឆ្គាំឆ្គងណាស់ ។ ខ្ញុំ សូមដាក់ទោសមិនអោយអ្នកនាងចេញទៅក្រៅជាមួយមិត្តណាទេ!
- ព្រហើន! ហ៊ានមកប្រដៅយើងផងហ្ទែ៎ស ? មុខស្ទី អំណាចស្ទី មកដល់មិនទាន់បានម៉ាដៃផង វាយឫកដូចស្តេចក្នុងផ្ទះយើងនេះ ?
- ហើយចុះអ្នកនាងវិញនោះ រស់នៅផ្ទះនេះយូរមកហើយ មិនដឹង ទេហ៍ ថារបៀបរស់នៅជាកូនស្រីអ្នកថ្លៃថ្នូរនោះ គេត្រូវនិយាយ បែបណា មានកិរិយា មានសណ្តាប់ធ្នាប់បែបណា ? ហេតុអ្វី បានជា ថ្ងៃនេះ អ្នកនាងនិយាយស្តី ធ្វើឫកច្រងេងច្រងាងម្ល៉េះ ?

ឮដូច្នោះ នាងតូចវណ្ណនីជ្រួញចិញ្ចើមភ្លិប បិទមាត់ដូចគេចុក កាលបើត្រូវនាងយ៉ាចំអកអោយដូច្នោះ ។ រំពេចនោះ ស្រាប់តែឆវី នាង ដើរប៉េវចេញទៅក្រៅយ៉ាងរហ័ស ។

- អ្នកនាងចង់ទៅណាមិនបានទេ យប់ហើយ! (នាងយ៉ាឃាត់)
- កុំមកចេះហៃហែ! ចង់ទៅណាមកណាស្រេចតែយើង!
- ប៉ុន្តែ អ្នកនាងត្រូវសុំច្បាប់ពីលោកប្រុសសិន ។

CHANBOKEO.COM

នាងតូចវណ្ណនីធ្វើមិនឮ គិតតែពីសំរុកទៅរកបើកទ្វាររបង
ចេញទៅចាំពួកម៉ាកមិត្តភក្តិបើកឡានមកទទួល ប៉ុន្តែ នាងយ៉ាស្ទុះ
យ៉ាងលឿនទៅពាំងទ្វារមិនអោយនាងចេញទៅបាន ៖

- នេះ ម៉ោង១០យប់ហើយអ្នកនាងតូច! អ្នកនាងមិនអាចចេញ ទៅក្រៅបានទេ ។
- ថ្លើមធំ ចង់ធ្វើជាអ្នកត្រួតត្រាជីវិតយើងផងហ្ន៎ស ? នេះសូម្បី
តែឪពុកយើងយ៉ាងម៉េចមិនដែលនឹងមករវល់នឹងយើងផង ហើយ ចុះអ្នកជាស្ទីដែរ
ហ៊ានមកធ្វើអុងអាត់របៀបនេះ ?

នាងយ៉ាសំដែងកិរិយាហួសចិត្ត កាលបើឮនាងតូចវណ្ណនីស្រស់
សោភាមានសំដីទ្រគោះអសុរសយ៉ាងនេះ ។ នារីក៏ឈប់មាត់ឈប់ក
មិននិយាយអ្វីអោយនាងតូចមួម៉ៅតទៅទៀតទេ ប៉ុន្តែ ក៏នៅឈរ
រាំងទ្វារមិនអោយនាងចេញដែរ ។ កាលបើឃើញនាងយ៉ានៅឈរ ពាំងផ្លូវ
នាងតូចវណ្ណនីក៏រត់រឹងទៅម្ខាង ហក់ផ្លេកផ្លោះតោងរបង រត់ចេញទៅក្រៅប្រុយ ។
នាងយ៉ាឃើញដូច្នេះ ក៏បើកទ្វាររបងរត់ ដេញស្រវាអោបចង្កេះចាប់ជាប់ពីក្រោយ ។

- លែង! ថាអោយលែងមើស៍! យី!
- មិនលែងទេ ។ បើលែងអោយអ្នកនាងទៅ នោះលោកប្រុសនឹង ស្តីបន្ទោសខ្ញុំមិនខាន ។

រំពេចនោះ ស្រាប់តែមានភ្លើងរថយន្តចាំងឆ្វាចមកលើអ្នកទាំង ពីរ ។
នាងតូចវណ្ណនីក៏រលាស់ខ្លួនភិលយ៉ាងរហ័ស គេចទៅម្ខាង ក្នុងចិត្តនឹកសង្ឃឹមថា
រថយន្តនោះជារថយន្តដែលមិត្តរបស់នាងមក ទទួល ។ នាងក៏ហក់ទៅជិតរថយន្តហើយស្រែកថា
៖

- តោះយើងប្រញាប់ចេញទៅ!... ខ្មោចវាតាមលងខ្ញុំគួរអោយធុញ ដល់សូរហើយ ។
- ចង់ទៅណា វណ្ណនី ?

ឮវាចានោះ នាងតូចភ្ញាក់ព្រើត បើកភ្នែកមូលក្រឡង់ សម្លឹង
ម្ចាស់សម្លេងដែលកំពុងបើកទ្វាររថយន្តចុះចេញមក ។

- លោកប៉ា ?
- មែនហើយ! ហើយពេលនេះ កូនកំពុងចេញទៅណាហ្នឹង ?
- គឺ... គឺ...

CHANBOKEO.COM

វណ្ណនីឆ្លើយតតាក់តតុបព្រោះភ័យខ្លួន ដែលឪពុកនាងមកទាន់ នាងលួចចេញពីផ្ទះពេលយប់ ដើម្បីទៅដើរលេងសប្បាយជាមួយ មិត្តភក្តិ ។ នាងយ៉ាឃើញដូច្នេះ ក៏ឆ្លើយជំនួសវិញ ៖

- គឺអ្នកនាងឃើញស្រមោលមនុស្សភ្លិបភ្លែតៗនៅមុខផ្ទះនេះទើប អ្នកនាងតូចរត់ចេញមកមើល ទទួលខ្ញុំនឹកដល់សុវត្ថិភាពរបស់អ្នក នាងទើបចេញមកជួយមើលគ្នាទៅ ។

លោកវណ្ណៈធ្វើទឹកមុខស្មើ មិននឹងថាលោកជឿសំដីរបស់នាង យ៉ាងែរឬយ៉ាងណាទេ ។ បន្ទាប់មក លោកក៏ងាកមករកនាងតូច វណ្ណនីហើយមានប្រសាសន៍ថា ៖

- ហើយម៉េចបានតែងខ្លួនចម្លែកៗម្ល៉េះ ថ្ងៃនេះ ? បំរុងនឹងទៅដើរ លេងជាមួយមិត្តពេលយប់មែនទេ កូន ?

វណ្ណនីភ្ញាក់ព្រើត បែរមុខទៅរកនាងយ៉ា រួចឈ្ងោកមុខចុះជ្រប់ នៅស្ងៀម បន្ទាប់មក ក៏ស្ទុះរត់ត្រឡប់ក្រោយចូលផ្ទះវិញបាត់ទៅ ។ ភ្លាមនោះ លោកវណ្ណៈបែរមកសម្លឹងនាងយ៉ា ដោយក្រសែភ្នែក យ៉ាងមុត រួចហើយក៏ដើរចូលទៅក្នុងផ្ទះដោយស្ងៀមស្ងាត់ មិនមានស្រដីអ្វីឡើយ ទុកអោយនារីឈរឈ្ងោកមុខ នឹកភ័យខ្លួនរអួចៗ នៅក្នុងពោះ តែម្នាក់ឯង ។

នាងយ៉ាក៏ត្រឡប់ទៅបន្ទប់នាងវិញ ។

- យាយ ? សំរាន្តហើយនៅ ? (នាងយ៉ាសួរ)

- នៅទេ ចៅយ៉ា! ចូលមក!

នាងយ៉ាបើកទ្វារដើរចូលទៅ ឃើញយាយកំពុងកោសខ្យល់ខ្លួនឯង ក៏ស្ទុះទៅជួយ ។

- យាយមិនស្រួលខ្លួនដូច្នេះ ម៉េចមិនហៅខ្ញុំអោយមកជួយកោស ខ្យល់អោយអញ្ចឹង ? ម៉ោះ! ខ្ញុំកោសជូន ។

យាយរៀមហុចសេនទៅនារី ហើយក៏មានប្រសាសន៍តបថា ៖

- មកពីឃើញចៅរវល់ទៅមើលក្មេងនៅខាងលើផ្ទះធំ ទើបយាយ ខ្ជិលរំខាន ។ ម្យ៉ាងទៀត យាយកោសខ្យល់ខ្លួនឯងដូច្នេះ រាល់ថ្ងៃ ឡើងធ្លាប់ទៅហើយ ។

នាងយ៉ាកោសខ្យល់អោយយាយរៀមបណ្តើរ ជជែកគ្នាបណ្តើរ...

- យាយ! លោកប្រុសធ្វើការអ្វីទៅយាយ ?

- គឺ លោកមានជំនួញពីរបីកន្លែង ជាម្ចាស់ហាងលក់កុំព្យូទ័រផង ជាម្ចាស់ហាងលក់ទូរស័ព្ទផង និងបើកហាងលក់ម៉ូតូផង ។

- លោកមានសាច់ញាតិច្រើនមែនទេ ទើបអាចកាន់ការងារច្រើន កន្លែងបានដូច្នេះ ?

CHANBOKEO.COM

- អត់ទេ លោកមានតែម្នាក់ឯងទេ ។ ក្រុមគ្រួសាររបស់លោកបាន
ស្លាប់អស់តាំងពីសម័យខ្មែរក្រហមកាន់កាប់ស្រុកម្ល៉េះ ។ អ្នកដែល ជួយលោកទាំងបីនាក់នោះ
ពីរនាក់ជាប្អូនបង្កើតរបស់លោកស្រី ហើយម្នាក់ទៀត ជាប្អូនធម៌របស់លោកប្រុស ។
- ពួកគេឧស្សាហ៍មកផ្ទះនេះទេ យាយ ?
- មិនសូវទេ ។ គេមកតែពិគ្រោះការងារម្ដងមួយយាម ឬក៏មក ជូនពរក្មួយៗ
ពេលបុណ្យកំណើតតែប៉ុណ្ណោះ ។
ភ្លាមនោះ ពូតឿដើរមកដល់ ៖
- ក្មួយយ៉ា! លោកប្រុសមានប្រសាសន៍អោយទៅជួបលោកមួយ ភ្លែត
ហើយអោយយកទឹកត្រជាក់ទៅជូនលោកមួយកែវផង ។
- ចា៎សពូ!... អញ្ចឹងពូជួយមើលយាយផង!
នាងយ៉ាដាក់សេនចុះ រួចហើយក៏ស្ទុះធ្វើតាមភ្លាម ។
នៅក្នុងបន្ទប់ការងាររបស់លោកវណ្ណៈនៅលើឡើជាន់ទីពីរ...
- នេះ ទឹកត្រជាក់ លោកប្រុស!
- អរគុណ! នាងទុកលើតុនេះចុះ!
- ចា៎ស!
នាងយ៉ាដើរឱនៗ បង្ហាញនូវការគោរពកោតខ្លាចចំពោះលោក វណ្ណៈដែលជាម្ចាស់ផ្ទះ
បំរុងចេញពីបន្ទប់ទៅវិញ ស្រាប់តែលោក វណ្ណៈមានប្រសាសន៍ឡើងថា ៖
- កុំទាន់ទៅណា៎! ខ្ញុំមានការចង់និយាយជាមួយនាង!
នាងយ៉ាភ្ញាក់ព្រើត ដើរថយក្រោយទៅឈរកៀនម្ខាង ៖
- ចា៎ស លោកប្រុស!
លោកវណ្ណៈបែរសម្លឹងមុខនារីបន្តិច រួចហើយបែរចេញវិញ បន្ទាប់មក
លោកក៏មានប្រសាសន៍ថា ៖
- ថ្ងៃក្រោយ នាងកុំរៀនកាន់ជើងក្មេងខូច លាក់ជាមួយចាស់ទុំ ដូច្នេះទៀត ឮហើយនៅ ?
ឮប្រយោគនោះ នាងយ៉ាយល់ភ្លាមថាលោកមិនសប្បាយចិត្ត
ដែលនាងនិយាយការពារនាងតូចវណ្ណនី កាលពីមួយស្របក់មុននេះ ប៉ុន្តែ
នោះក៏ព្រោះនាងមិនចង់អោយនាងតូចវណ្ណនីត្រូវមាត់ឪពុក របស់នាងតែប៉ុណ្ណោះ ។
- ដឹងទេ ថានាងធ្វើដូច្នេះវាខុស ? (លោកវណ្ណឧទាន)

CHANBOKEO . COM

- គឺ... នឹងចាស! ប៉ុន្តែ...
- ប៉ុន្តែ... អ្វីទៅ ?
- កាលបើចាស់ទុំដេញទាន់ជាន់កែងទៅហើយ នឹងបន្ទោសជាន់ កែងថែមទៀត ក្រែងលោគ្នាមានការអាមាសក្នុងចិត្តរិតតែខ្លាំង ឈឺចិត្តរិតតែខ្លាំង ឬភិតភ័យរិតតែខ្លាំង ម្ល៉េះហើយ នាងអាចរក មធ្យោបាយថ្មីធ្វើអ្វី ធ្វើនចិត្តចាស់ទុំទៅថ្ងៃក្រោយឲ្យចាស់ទុំអំពល់លើសមុនទៅទៀតផង ក៏មិនដឹង ។

លោកវណ្ណៈនៅស្ងៀម ពេលដែលបានឮការពន្យល់របស់នាង យ៉ា ។ លោកក៏សួរបន្ថែមថា ៖
- ហើយចុះនាងដឹងទេ ថានាងតូចវណ្ណនីបំរុងចេញទៅណា ?
- ចាស នាងខ្ញុំបានឮអ្នកនាងទូរសព្ទ័ថា ចង់ទៅលេងក្លិបយុវជន នៅត្រង់ណាមិនដឹង ឮទូរសព្ទ័គ្នារួចហើយ ក៏រត់ចេញទៅក្រៅ ។ នាងខ្ញុំខំឃាត់ដែរ ប៉ុន្តែជួនអីលោកក៏មកដល់ចំពេលល្មមតែម្តង ។

លោកវណ្ណៈដកដង្ហើមធំលាន់យូ បន្ទាប់មកក៏ស្រដីថា ៖
- អរគុណដែលបានប្រាប់ខ្ញុំអោយដឹង ។ នាងអាចត្រឡប់ទៅវិញ បានហើយ ។
- ចាស!

នាងយ៉ាលួចសង្កេតឃើញលោកវណ្ណៈជ្រួញចិញ្ចើម រួចហើយ ប្រញាប់រៀបចំទុកដាក់ការងារនៅលើតុបង្ហើយ ។ នាងក៏ដើរត្រឡប់ ចេញទៅវិញ ក្នុងចិត្តនឹកពិភាល់ថា តើលោកនឹងប្រដៅនាងតូច វណ្ណនីរបៀបណា ។

តុក! តុក! តុក!
- គឺប៉ាណា៎ កូននី! បើកទ្វារអោយបន្តិចមក ។

នាងតូចវណ្ណនីបើកទ្វារឡើង ឃើញឪពុកឈរនៅមាត់ទ្វារ ក៏ ធ្វើមុខស្លូត ទំនងភ័យខ្លួន ។
- អោយប៉ានិយាយជាមួយកូនបន្តិចបានទេ ?

នាងតូចក៏បើកទ្វារអោយធំដើម្បីឲ្យលោកវណ្ណៈដើរចូលទៅ ។
- កូនមិនទាន់ងងុយគេងទេ ?
- ចា៎ស...! គឺនៅទេលោកប៉ា!
- មកអង្គុយជិតប៉ាបន្តិចមក៍ កូន!

នាងតូចដាក់ខ្លួនអង្គុយជិតឪពុកតាមសំណើ ។ លោកវណ្ណៈក៏ មានប្រសាសន៍បន្តថា ៖

CHIANBOKEO.COM

- មួយរយៈពេលកន្លងមក តាំងពីម៉ាក់របស់កូនចែកឋានទៅ ប៉ាពុំសូវមានពេលជិតដល់ជាមួយកូនសោះ ។ ប្រហែលជាកូនអផ្សុក កណ្តោចកណ្តែងក្នុងចិត្តណាស់មែនទេ កូន ?

វណ្ណនីឈ្ងោកមុខនៅស្ងៀម ។

- មែនហើយ! ប៉ារវល់នឹងធ្វើការពេក រហូតភ្លេចកូនចៅរបស់ប៉ា អស់រលីង! ប៉ុន្តែ ប៉ាសន្យាថានឹងរៀបចំកាលវិភាគ ដើម្បីអោយ ក្រុមគ្រួសារយើងមានបរិយាកាសប្រសើរដូចដើមវិញ ។ កូនយល់ យ៉ាងម៉េចដែរ វណ្ណនី ?

យុវតីញញឹមឡើង ហើយឆ្លើយថា ៖

- អញ្ចឹង! អោយកូនសុំពេលវេលាជាមួយលោកប៉ានិងក្រុមគ្រួសារ របស់យើងមួយអាទិត្យម្តងបានទេ លោកប៉ា ដើម្បីអោយយើងមានឱកាសធ្វើអ្វីសប្បាយៗជាក្រុមគ្រួសារសាជាថ្មី ។

- បាន! ចាំប៉ារៀបចំពេលវេលារបស់ប៉ា ដើម្បីកូន ។

- ចុះថ្ងៃអាទិត្យខាងមុខនេះ លោកប៉ាទំនេរទេ ?

- ថ្ងៃអាទិត្យ ? មិនអីទេកូន! ដើម្បីកូនស្រីរបស់ប៉ា ប៉ានឹងឈប់ពី ការងារមួយថ្ងៃ ។

- អរគុណណាស់លោកប៉ា!

នាងតូចវណ្ណនីស្រវាអោបចង្កេះឪពុក ដោយក្តីសោមនស្ស ។ អំបាញមិញនេះ នាងភ័យផ្អូចៗក្នុងពោះ ស្មានថាត្រូវលោកប៉ាស្តី បន្ទោសទៅហើយ ប៉ុន្តែ លោកបែរជាមកនិយាយយ៉ាងស្រទន់ ដាក់នាងទៅវិញ ធ្វើអោយនារីមានការខ្មាសអៀនក្នុងចិត្តណាស់ ដែលនាងបានប្រព្រឹត្តកិរិយាមិនគប្បីជាលើកដំបូង អោយឪពុកនាង ព្រួយបារម្ភ ។

លោកវណ្ណៈក៏ដើរចេញពីបន្ទប់កូនស្រី ហើយក៏លួចទៅបង្អើប ទ្វារបន្ទប់ម្ខាងទៀត ឃើញវណ្ណនេត្រនិងវណ្ណាគេងលង់លក់ស្ងប់ ស្ងៀម ក៏វិលមកកាន់បន្ទប់របស់ខ្លួនវិញធ្វើការតទៅទៀត ។

មួយស្របក់ក្រោយមក លោកក៏ចេញទៅខាងក្រៅយកខ្យល់ អាកាសរាត្រីទំនងប្រាថ្នាទម្លាយនូវក្តីតប់ប្រមល់ក្នុងចិត្ត ស្រាប់តែ ប្រទះនឹងនាងយ៉ាកំពុងអង្គុយសរសេរ ក្រោមពន្លឺភ្លើងអំពូលម៉ែត្រ តូចមួយ ដែលដាក់បំភ្លឺចោលនៅមុខផ្ទះ ។

CHANBOKEO.COM

គ្រាន់តែឃើញវត្តមានរបស់លោកវណ្ណៈភ្លាម នាងយ៉ាក៏បិទ សៀវភៅ ហើយដើរឱនៗសម្ដែងក្ដីគោរពចំពោះលោក គេចចេញ ទៅបន្ទប់វិញយ៉ាងលឿន ។ លោកវណ្ណៈបែរក្រោយសម្លឹងមើលតាម ឆឹតារហូតបាត់ស្រមោល រួចហើយក៏ជ្រួញចិញ្ចើម ទំនងគិតអ្វីម្យ៉ាង នៅក្នុងចិត្ត តែម្នាក់ឯង ។

*OOOOOOOOOOOOOO*

*OOOOOOO*

*O*

CHANBOKEO . COM

# វគ្គទីពីរ
## បរិយាកាសគ្រួសារ

ថ្ងៃអាទិត្យចូលមកដល់...

នៅក្នុងគេហដ្ឋានរបស់លោកវណ្ណ: ....

នាងយ៉ាកំពុងរៀនបោសសំអាតរៀបចំទុកដាក់ផ្ទះ តាមការណែ នាំរបស់យាយរៀម ។ នៅបន្ទប់គ្រួសារខាងលើឡើដែលមានតាំង ទូរទស្សន៍ធំមួយ និងគ្រឿងសង្ហារឹមជាឈើខ្លឹមបុរាណយ៉ាងល្អវិចិត្រ មាណវីបានប្រទះឃើញរូបថតស្ត្រីម្នាក់ ដែលតាំងនៅលើជញ្ជាំង ប្រកបដោយទឹកមុខញញឹមឥតហ្មង ។

- នេះជារូបលោកស្រីម្ចាស់ផ្ទះ មែនទេយាយ ?

នាងយ៉ាសួរទៅយាយរៀម ។

- មែនហើយ លោកស្រីមានឈ្មោះថា កន្និដ្ឋា មានរូបសោភ័ណល្អ ស្រស់ស្អាត ហើយមានចរិតទន់ភ្លន់ណាស់ ខុសតែអ្នកស្រីមានរោគ ប្រចាំកាយ ហើយក៏ត្រូវលាលោកទៅទាំងក្មេងមិនទាន់គ្រប់៤០ឆ្នាំ ស្រួលបួលផង ។
- គួរសោកស្តាយណាស់ យាយ! ជាពិសេសក្មេងៗជាកូនរបស់ លោកស្រីតែម្តង... ប៉ុន្តែ ទោះជាយ៉ាងណាក៏ពួកគេនៅមានសំណាង ជាងក្មេងទូទៅដទៃទៀតច្រើនណាស់ ថ្វីបើគេកំព្រាម្តាយក៏ដោយ ។
- ម៉េចក៏ថាសំណាងទៅកើត នាងយ៉ា ? នេះពួកគេកំព្រាម្តាយមួយ ទាំងមូលទៅហើយ ឯងថាសំណាងយ៉ាងណាទៅ ?

- គឺមកពីពួកគេមានឪពុកដ៏រឹងមាំមួយ មានទ្រព្យអាចរស់នៅបាន សុខស្រួល មិនដូចក្មេងខ្លះដែលក្រីក្រទុរគត បើសិនជាអត់ពីឪពុក ឬពីម្តាយ ពួកគេច្បាស់ជាជួបសំណោកជីវិតខ្លាំងជាងនេះទៅទៀត..
- អីក៏គិតវែងឆ្ងាយម្ល៉េះឯងនេះ នាងយ៉ា ?
- គឺ... ចេះតែពិចារណាលេងៗទៅណា៎យាយ !
 នាងយ៉ាញញឹម រួចហើយក៏បែរមកមើលរូបថតស្ត្រីម្ចាស់ផ្ទះ ហើយក៏នឹកនៅក្នុងចិត្តតែម្នាក់ឯង ៖
- លោកស្រីមិនបាច់ព្រួយបារម្ភទេ ថាក្រុមគ្រួសារលោកស្រីខ្វះការ កក់ក្តៅ ។ ខ្ញុំនឹងព្យាយាមជួយលើកកម្លាំងចិត្តកូនចៅលោកស្រី មិន អោយគេបាក់ទឹកចិត្តឬស្រកស្រុតបញ្ញាស្មារតីឡើយ ។ សូមលោក ស្រីទុកចិត្តចុះ ។
 កំពុងតែឈរគិតភ្លេចខ្លួន ស្រាប់តែនាងយ៉ាឮស្នូរសម្លេងស៊ីផ្លេ ឡានទៅមុខផ្ទះ ។
 ទីន! ទីន! ពីរបីដង... រួចហើយ ទីន! ទីន! ម្តងទៀត ។
- ពូតឿមិនទៅទេហ៏ យាយ បានជាគាត់មិនបើកទ្វាររបង ?
- ប្រហែលជានាយតឿជូនលោកប្រុសទៅធ្វើការហើយ មិនទាន់ មកវិញទេមើលទៅ ។ អញ្ចឹងចៅឯងទៅបើកទ្វារឲ្យបន្តិចទៅ ។
- ចា៎ស យាយ !
 នាងយ៉ាស្ទុះចុះជណ្តើរយ៉ាងលឿនទៅ បើកទ្វាររបង ស្រាប់តែ ប្រទះនឹងសុភាពស្ត្រីមួយរូប ក្នុងវ័យប្រហែលសាមសិបប្រាំឆ្នាំ កំពុងបើករថយន្តឡិចសឺសព៌សថ្មីស្រឡាងមួយ ។
- លោកវណ្ណៈអោយខ្ញុំមករង់ចាំលោកនៅទីនេះ ។ សូមនាងជួយ បើកទ្វារឲ្យខ្ញុំចូលឡានបន្តិច ។
 នាងយ៉ាឮហើយ ក៏បើកទ្វារអោយភ្លាម ។ រំពេចនោះស្រាប់តែ ពូតឿបើករថយន្តមកដល់ដែរ ។ សុភាពស្ត្រីក្រឡេកឃើញភ្លាម ក៏ បើកកញ្ចក់បង្អួចរថយន្ត សួរពូតឿថា ៖
- ម៉េចបានពូតឿមកតែម្នាក់ឯងដូច្នេះ ? ឯណាលោកវណ្ណៈ ?
- គឺថ្ងៃនេះមានទំនិញថ្មីទើបមកដល់ ទើបលោកត្រូវទៅរាប់ទំនិញ សិន ។ លុះចប់កិច្ចការហើយ លោកនឹងអោយគេជូនលោកមកវិញ ហើយ (ពូតឿឆ្លើយ)
- ហើយលោកត្រូវធ្វើការយូរម៉ោងប៉ុនណាទៀតទៅ ពូតឿ ?
- បាទ! មិនដឹងទេ អ្នកនាង ។

CHANBOKEO.COM

សុភាពស្ត្រីនោះទម្លាក់ទឹកមុខស្ងួត ទំនងហាក់ដូចជាខកចិត្ត ដែលលោកវណ្ណៈមិនបានគោរពវេលាទៀងទាត់ តាមការណាត់ ។ បន្តិចមក សុភាពស្ត្រីក៏ចុះពីរថយន្ត ដើរសំដៅទៅបន្ទប់ទទួល ភ្ញៀវ ហើយស្រដីទៅនាងយ៉ាងថា ៖

- សុំទឹកត្រជាក់មួយកែវមក នាង!
- ចា៎ស!

នាងយ៉ាលើកទឹកមកជូនហើយ ក៏ឡើងជណ្តើរទៅលើឡៅ ទុកឲ្យសុភាពស្ត្រីនោះអង្គុយចាំក្នុងបន្ទប់ទទួលភ្ញៀវតែម្នាក់ឯង ស្រាប់តែប្រទះឃើញកូនប្រុសស្រីទាំងបីនាក់របស់លោកវណ្ណៈ កំពុងឈរជុំគ្នាមុខបន្ទប់គេ ធ្វើកិរិយាជ្រួលច្រាលៗ ។

- អ្នកនាងតូច ប្រុសតូច អូនតូច មិនទាន់ស្លៀកពាក់ហើយទេ ? បន្តិចទៀត លោកប៉ាមកដល់ នឹងនាំអ្នកទាំងបីទៅដើរលេងហើយ!

នាងយ៉ានិយាយតិចៗទៅកាន់អ្នកទាំងបី ។

- ប៉ុន្តែ ពេលនេះ ពួកយើងលែងចង់ទៅហើយ (កុមារវណ្ណនេត្រ ឆ្លើយទាំងជ្រួញចិញ្ចើម)
- ព្រោះហេតុអ្វីទៅ ប្រុសតូច ?
- គឺយើងចង់ដើរលេងជាគ្រួសារ មិនចង់បានមនុស្សចម្លែកមក ចូលរួមជាមួយទេ ។

ឮដូច្នោះ នាងយ៉ាលួចចោលកន្ទុយភ្នែកសម្លឹងទៅសុភាពស្ត្រី មួយរូបនោះ ហើយក៏សួរបន្តថា ៖

- អ្នកនាងម្នាក់នោះ មិនមែនជាញាតិមិត្តរបស់ប្អូនៗទេ ហ្ន៎ស ?
- មិនមែនទេ បង! ពួកខ្ញុំមិនដែលស្គាល់គាត់ពីមុនមកទេ ទើបតែឃើញមកលេងលោកប៉ាប្អូនដប់ថ្ងៃកន្លងមកនេះឯង (កុមារនេត្រ ឆ្លើយតបវិញ)
- ប្រហែលសុភាពស្ត្រីនោះជាអ្នកធ្វើការជាមួយលោកប៉ាហើយ ។
- មិនមែនទេ បងយ៉ា ។ ខ្ញុំថា គាត់កំពុងតែរកចូលខ្លួនមករកចាប់ ទីត្រៀមខ្លួនធ្វើជាម៉ាក់ថ្មីរបស់ពួកយើងហើយ ។
- ស៊ូច! ប្រុសតូច! យើងនៅក្មេង កុំរៀននិយាយអ្វី ដែលមិន ពិរោះស្តាប់អញ្ចឹង ។ ទាំងអស់នេះ ជារឿងមនុស្សចាស់ ទុកឲ្យ លោកប៉ា សំរេចចិត្តសំរាប់ខ្លួនលោកទៅ ។
- តែលោកត្រូវតែស្តាប់ចិត្តកូនផងដែរថា ពួកយើងមិនអាចទទួល នរណាមកធ្វើជាម្តាយបានទេ ក្រៅពីម៉ាក់កន្និដ្ឋារបស់យើង ។

CHANBOKEO.COM

នាងយ៉ាមិនបានប្រកែកប្រណាំងអ្វីនឹងក្មេងទេ ដើម្បីកុំអោយគេ
មានអារម្មណ៍រិតតែល្អក់កករឡើង ។ នាងក៏សម្រួលស្ថានការណ៍ ដោយពន្យល់ថា ៖
- ថ្ងៃនេះ អ្នកនាងវណ្ណនី ប្រុសតូច និងស្រីតូច តុបតែងខ្លួនស្រស់ ស្អាតណាស់
បើសិនជាផ្ទៃមុខមានភាពញញឹមខ្លះៗ ប្រហែលជានាំ រាសីល្អដល់ជីវិតជាមិនខាន ។ ពេលនោះ
អ្នកដែលមានបំណងមិន ល្អមកលើយើងនឹងត្រូវចុះចាញ់ ហើយក៏មិនអាចធ្វើអ្វីអោយយើង
ខូចរាសីខូចលាភបានដែរ ។ ប៉ុន្តែ បើសិនយើងមានទឹកមុខអាប់អួរ មានចិត្តមានអារម្មណ៍អាប់អួរ
នោះវានឹងធ្វើអោយរាសីយើងធ្លាក់ ទាប ។ ពេលនោះ អ្នកដទៃដែលមានរាសីខ្ពស់ជាងយើង
នឹងចូល មកដណ្តប់ជីវិតយើងហើយ ។ ដូច្នេះ បើសិនជាយើងមិនចង់ឲ្យ
នរណាមកចូលរំខានដើម្បីកាច់ចង្កូតជីវិតរបស់យើងនោះ យើងត្រូវ តែដើបមុខឡើងយ៉ាងក្លាហាន
ញញឹមបង្ហាញនូវភាពរឹងប៉ឹងរបស់ យើង រក្សារាសីរបស់យើងឲ្យនៅខ្ពស់ជានិច្ច ។
ឯអ្នកដែលមាន បំណងមិនល្អ ចង់បំបាក់ទឹកចិត្តយើង ច្បាស់ជាធ្វើអ្វីយើងមិនបែក ទេ
ប្អូនៗដឹងទេ ?

ឮប្រយោគនោះភ្លាម នាងតូចវណ្ណនីដែលឈរស្ងៀមយូរមក ហើយ ក៏សួរឡើងថា ៖
- ហើយចុះរវាងសុភាពស្ត្រីរូបសោភាវ័យក្មេង និងកូនប្រុសស្រីជា ទីស្រឡាញ់ តើបងស្រីគិតថា
លោកប៉ានឹងជ្រើសរើសមួយណា ?
- បងគិតថា លោកពិតជាត្រូវពិចារណាយូរណាស់ ទើបអាចសំរេច ចិត្តជ្រើសរើសបាន ព្រោះថា
លោកពិតជាមិនចង់ឃើញកូនបាក់ទឹក ចិត្ត ស្រកស្រុតក្តីសប្បាយរីករាយក្នុងជីវិតឡើយ
ជាពិសេសកាល បើលោកឃើញកូនរបស់លោកកំពុងអោបទុក្ខកង្វល់ ដោយការបាត់ បង់ម្តាយ ។
លោកពិតជាជ្រើសរើសផ្លូវណាដែលនាំអោយកូនចៅ មានការរីករាយ
មានសុខុមាលភាពផ្លូវចិត្តមកវិញមិនខាន ។ លោក មិនជ្រើសរើសផ្លូវជីវិត
ដែលធ្វើអោយកូនចៅរបស់លោក ធ្លាក់ក្នុង ទុក្ខសោកធ្ងន់ធ្ងរជាងមុនទេ ។
- បើដូច្នោះមែន ហេតុអ្វីបានជាលោកប៉ានាំសុភាពស្ត្រីចម្លែកចូល ផ្ទះ
បញ្ឈឺចិត្តពួកយើងដែលកំពុងនឹកម្តាយនោះទៅវិញ ?
- មិនមែនទេ អ្នកនាងតូច! បើតាមបងគិត ប្រហែលជាលោក
កំពុងនាំសុភាពស្ត្រីល្អម្នាក់មកអោយកូនៗស្គាល់ ដើម្បីអោយជួយ គិតលោក
ថាតើអ្នកនាងសោភាមួយរូបនោះ សក្តិសមនឹងទទួល
នាទីបន្តពីម្តាយរបស់អ្នកនាងតូចដែរឬយ៉ាងណា ។

CHANBOKEO.COM

- តើមូលហេតុអ្វីទៅដែលនាំអោយបងស្រីគិតដូច្នោះទៅវិញ ?

- អ្នកនាងតូចមិនឃើញទេ ? លោកប្រុសបានអនុញ្ញាតិឲ្យសុភាព ស្ត្រីនោះមកជួបលោកដល់ផ្ទះ ប៉ុន្តែលោកបែរជាមិននៅផ្ទះទៅវិញ ហើយបែរជាទុកអោយកូនៗជាអ្នកទទួលភ្ញៀវជំនួសលោក នោះ មិនគួរអោយឆ្ងល់ទេហ្អី អ្នកនាង ?

នាងតូចវណ្ណានីនិងប្អូនៗមើលមុខគ្នាឡឹងឡង់ យកដៃឈ្លីថ្ងាស ទំនងគិត ។ បន្តិចមក វណ្ណានីក៏ស្រដីឡើងថា ៖

- មែនហើយ! បើពិតដូច្នោះមែន ខ្ញុំពិតជាចង់ដឹងណាស់ ថាតើ សុភាពស្ត្រីមួយរូបនោះ មានលក្ខណៈគុណសម្បត្តិអ្វីល្អខ្លះ ដើម្បី អាចទាក់ទាញចិត្តលោកប៉ានិងពួកយើងទាំងអស់គ្នាបាន ?

- ខ្ញុំក៏ចង់ពិសោធន៍ដែរ (កុមារនេត្រស្រដីបន្ទរ)

ប៉ុន្តែនាងតូចវណ្ណាដែលនៅខ្ចីសេចក្តីស្តាប់មិនបានទេ ។ នាង យ៉ាក៏ពន្យល់ថា ៖

- អូនតូចជាម្ចាស់ផ្ទះ ។ ពេលណាលោកប៉ាមិននៅ អូនតូចព្រម ទាំងបងៗត្រូវតែរៀនទទួលភ្ញៀវអោយបានសមរម្យបំផុត ដើម្បីកុំ អោយភ្ញៀវសើចយំយើងបាន ថាលោកប៉ាមិនបានប្រដៅកូន ។ អូន តូចយល់ទេ ?

- ចាស យល់!

- អញ្ចឹង អូនតូចជួយបងៗទទួលភ្ញៀវអោយល្អផងណា! និយាយ អោយពិរោះ ហើយសម្តែងការគោរពចាស់ទុំអោយសមជាក្មេងល្អ ណា អូនតូច ។

- ចាស បងស្រី!

ទាំងអស់គ្នាញញឹមឡើង កាលបើបានទទួលការលើកទឹកចិត្តពី នាងយ៉ាយ៉ាងជ្រាលជ្រៅ ។ បន្តិចមក នាងតូចវណ្ណានីស្រដីថា ៖

- អោយខ្ញុំសូមទោសបងស្រីផង ដែលខ្ញុំបានទម្លោះសំដីបោះបោក ដាក់បងស្រី កាលពីម្សិលមិញ ។

- មិនអីទេ! អ្នកនាង! ខ្ញុំមិនបានប្រកាន់ខឹងអ្វីនៅក្នុងចិត្តទេ ។ ពេលនេះ អ្នកនាងត្រូវនាំប្អូនទទួលភ្ញៀវអោយបានល្អបំផុត នោះ យើងនឹងដឹងថា នៅពេលដែលយើងគោរពគេយ៉ាងល្អទៅហើយ ប៉ុន្តែ បើគេបង្ហាញនូវភាពគ្រោតគ្រាតរបស់គេ ត្រឡប់មកយើង វិញនោះអ្នកនាងនឹងដឹងហើយ ថាគួរដាក់ពិន្ទុយ៉ាងម៉េចទើបសម ?

វណ្ណានីក៏ញញឹមគ្រហាញ ហើយស្រដីតបវិញថា ៖

CHANBOKEO .COM

- បងស្រីឆ្លាតមែន... ហាក់ដូចជាគ្រូបង្រៀនម្នាក់អញ្ចឹង មិនសម ជាអ្នកស្រុកសាមញ្ញសោះ ។
- បញ្ឆោរបងម្ល៉េះ អ្នកនាងតូច ? បងយ៉ាឡើងឈាមស្លាប់ហើយ ។
នាងយ៉ាតបវិញ ។ ទាំងអស់គ្នាក៏សើចកខឹកឡើង ។ បន្តិចមក
នាងតូចវណ្ណនីនាំប្អូនចុះទៅជួបភ្ញៀវ ៖
- ជំរាបសួរអ្នកមីង !
- ចា៎សជំរាបសួរក្មួយៗ !
- អ្នកមីងមានការជាមួយលោកប៉ាមែនទេ ?
- ចា៎ស ! លោកប៉ារបស់ក្មួយបបួលមីងទៅដើរលេងជាមួយលោក និងក្មួយៗថ្ងៃនេះ
ទើបមីងមកនេះអី ។
រំពេចនោះ លោកវណ្ណៈក៏មកដល់ ។ គ្រាន់តែក្រឡេកឃើញ សុភាពស្ត្រីនោះភ្លាម
លោកវណ្ណៈក៏លាន់មាត់ឡើង ៖
- សួស្តី ! ម៉ាលីណា ! មកដល់យូរហើយហ្អេស៎ ?
លោកមានប្រសាសន៍ផង ញញឹមផង ។
- ចា៎ស ! មួយស្របក់ធំហើយ លោកវណ្ណៈ ។
ភ្លាមនោះ កូនទាំងបីនាក់ក៏ស្ទុះព្រួទៅរកលោក ៖
- លោកប៉ា ! មិនថាតែអ្នកមីងទេ ដែលចាំលោកប៉ា ! កូនៗក៏ចាំ លោកប៉ាផ្សាភ្ញែកដូចគ្នាដែរ
(កុមារវណ្ណនេត្រស្រដីឡើង)
លោកវណ្ណៈយកដៃអង្អែលក្បាលកូន រួចហើយតបថា ៖
- ប៉ាខំធ្វើការយ៉ាងប្រញាប់បំផុត ដើម្បីត្រឡប់មកផ្ទះតាមសន្យា របស់ប៉ាជាមួយកូននោះអី ។
- ហើយចុះពេលនេះ យើងទៅលេងឯណាដែរ លោកប៉ា ? (នាង តូចវណ្ណាអង្រួនដៃឪពុកសួរ)
- ប៉ាគិតថា ចង់អោយកូននិងអ្នកមីងម៉ាលីណាជ្រើសរើសចុះ ។
ភ្លាមនោះ ក្មេងទាំងបីនាក់ក៏សម្លឹងមុខគ្នាឡឹងឡង់ ដែលឪពុក របស់គេបានបង្ហាញថា
លោកកំពុងតែអោយពួកគេរៀនពិគ្រោះកិច្ច
ការហើយរៀនសំរបសំរួលខ្លួនជាមួយនឹងអ្នកនាងម៉ាលីណា មិនខុស
ពីអ្វីដែលនាងយ៉ាប្រាប់ពួកគេអំបាញ់មិញនោះឡើយ ។ នាងតូច វណ្ណនីលាន់មាត់ខ្សិបប្រាប់ប្អូនៗថា ៖
- ហេតុអ្វីក៏បងយ៉ាទាយត្រូវម្ល៉េះហ្ន៎ ?

CHANBOKEO.COM

ពេលនោះ ពួកគេលួចបែរញញឹមដាក់នាងយ៉ា ដែលនៅឈរ
មើលអ្នកទាំងបីពីចម្ងាយ ឯចំហៀងផ្ទះ ។ ភ្លាមនោះ អ្នកនាងរូប ស្រស់ម៉ាលីណាស្រដីថា ៖

- ក្មួយៗចង់ទៅលេងកៀនស្វាយទេ ? យើងទៅជិះទូកលេងម្តង យ៉ាងម៉េចដែរ ?
- អូហ៍! សប្បាយណាស់! វណ្ណាចង់ទៅលេងណាស់ចាស!

ប៉ុន្តែ ពីរនាក់ទៀតហាក់ដូចជានៅអេះអុញ លួចបែរទៅមើល នាងយ៉ា បំរុងស៊ីញ៉ូសួរយោបល់ ស្រាប់តែបាត់ស្រមោលនារីយើងពី ទីនោះទៅ ។ គេក៏មើលមុខគ្នាហើយញោចស្មា រួចក៏នៅស្ងៀម ព្រោះពួកគេមិនដឹងថាត្រូវយល់ព្រមឬត្រូវជំទាស់ ។ ម្យ៉ាងទៀត បើជំទាស់វិញ តើពួកគេត្រូវជ្រើសរើសកន្លែងណាសំរាប់ទៅ ដើម្បី អោយអ្នកនាងម៉ាលីណាយល់ព្រម ។ ទីបំផុត គេសំរេចចិត្តធ្វើតាម មសំណូមពររបស់សុភាពស្ត្រីមួយរូបនោះ ។

បន្តិចមក លោកវណ្ណៈក៏នាំកូនទាំងបីនិងអ្នកនាងម៉ាលីណាឡើង រថយន្ត បំរុងនឹងចេញដំណើរទៅ ស្រាប់តែនាងតូចវណ្ណាពោលកាត់ ឡើងថា ៖

- លោកប៉ា ! អោយកូនសុំយកបងយ៉ាទៅតាមផងបានទេ ?

លោកវណ្ណៈបែរមើលមុខកូន ធ្វើភ្នែកមូលក្រឡង់ ទំនងឆ្ងល់ ហើយក៏មានប្រសាសន៍ថា ៖

- នេះជាពេលវេលារបស់គ្រួសារយើង ប៉ាមិនចង់យកនរណាទៅ តាមទេ ណា៎កូន!
- ប៉ុន្តែ បងយ៉ាក៏ជាអ្នកផ្ទះយើងដែរ ។
- តែគេជាអ្នកបំរើយើងតើហ៍ កូន!
- អត់ទេ! បងយ៉ាជាបងស្រីរបស់វណ្ណា កូនចង់បានបងទៅដើរ
លេងជាមួយជាគ្នា ព្រោះបងយ៉ាជាមនុស្សល្អ ។

ឮប្រយោគនេះ លោកវណ្ណៈជ្រួញចិញ្ចើម សួរកូនថា ៖

- នាងទើបតែមករស់នៅជាមួយយើងបានពីរថ្ងៃ ម៉េចក៏កូនដឹង កើតថា
បងយ៉ានោះជាបងល្អរបស់កូន ?

នាងតូចវណ្ណាយកដៃអេះក្បាលព្រោះមិនដឹងឆ្លើយយ៉ាងម៉េច ។ ភ្លាមនោះ វណ្ណនេត្រក៏ស្រដីឆ្លើយជួសថា ៖

- គឺបងយ៉ាអាចជួយមើលការខុសត្រូវពួកយើងបាន បើសិនជា
លោកប៉ាចង់ទៅជិះទូកលេងតែពីរនាក់ជាមួយអ្នកមីងម៉ាលីណា ។

លោកវណ្ណៈបែរសម្លឹងមុខអ្នកនាងម៉ាលីណា ឃើញនាងញញឹម តបមកវិញ ក៏ងក់ក្បាលយល់ព្រម ៖

- អញ្ចឹង! កូនទៅហៅនាងយ៉ាមក!

វណ្ណនេត្ររត់ត្រុយចុះទៅភ្លាម យ៉ាងលឿន មួយស្របក់មកក៏ អូសដៃនាងយ៉ាមកដល់វិញ ។ លោកវណ្ណៈក៏ស្រដីប្រាប់នារីថា ៖

- ឡើងឡានមក!
- ចាសលោកប្រុស!

ធិតាក៏លូនចូលទៅអង្គុយនៅបាំងក្រោយបង្អស់ តែម្នាក់ឯង ។ ពូតឿក៏រៀបចំបញ្ឆេះឡានចេញទៅ ។ ស្រាប់តែនាងតូចវណ្ណាស្ទុះ ដើប ឡើងពីកៅអី ៖

- ដើបទៅណាកូន ? (លោកវណ្ណៈសួរ)
- ទៅអង្គុយជាមួយបងយ៉ាចាស!
- អញ្ចឹង នេត្រទៅអង្គុយនៅខាងក្រោយជាមួយដែរ ។

ឃើញប្អូនៗដើបអស់ វណ្ណនីក៏ដើបឡើងដែរ ព្រោះមិនចង់នៅអង្គុយក្បែរអ្នកនាងម៉ាលីណាតែម្នាក់ឯង ។ នារីក៏ស្ទុះទៅអង្គុយជិតប្អូនៗទាំងពីរនាក់ដែលអង្គុយអមសងខាងនាងយ៉ា ។ លោក វណ្ណៈជ្រួញចិញ្ចើមនឹកឆ្ងល់ចម្លែកក្នុងចិត្ត ត្បិតនាងយ៉ាទើបតែមក ដល់បានពីរថ្ងៃសោះស្រាប់តែអាចទាក់ទាញចំណាប់អារម្មណ៍របស់ កូនប្រុសកូនស្រីរបស់លោកអស់រលីងយ៉ាងដូច្នោះ ។ តាមផ្លូវលោក វណ្ណៈលួចសសង្កេតកិរិយានាងយ៉ាតាមកញ្ចក់បើកបរ ឃើញកូនៗ របស់លោកនិយាយលេងជាមួយមាណវីសើចលេងកក្អឹកតាមផ្លូវ ។ ពេលនោះលោកហាក់ដូចជាមានសេចក្ដីរីករាយក្នុងបេះដូងណាស់កាលបើឃើញកូនៗសប្បាយរីករាយគ្រប់គ្នាដូចពីដើមវិញ ។

នៅកៀនស្វាយ...

ពូតឿអង្គុយយាមរថយន្តនៅក្រោមដើមឈើធំមួយ សម្លឹងតាមមើលលោកវណ្ណៈនាំមុខអ្នកទាំងអស់គ្នា ដើរស្ទួលើស្ពានឬស្សី ដែលនាំពួកគេទៅដល់រោងស្បូវមួយសង់នៅលើទឹក មានក្រាលកន្ទេលទទួលភ្ញៀវរង់ចាំយ៉ាងស្អាតជាស្រេច ។ លោកវណ្ណៈក៏ដាក់ខ្លួន សណ្ដូកជើងទៅក្នុងអង្រឹងមួយដែលចងបែរទៅរកទឹក យោលទៅ មកយឺតៗបណ្ដែតអារម្មណ៍ស្ងៀមស្ងាត់ ។ រីឯអ្នកនាងម៉ាលីណាវិញ ក៏ដាក់ខ្លួនអង្គុយក្បែរលោក នាំគ្នានិយាយពីនេះពីនោះ ទំនងហាក់ដូចជាកំពុងរិតចំណងមេត្រីជាមួយលោកវណ្ណៈ អោយកាន់តែជិត ជិតជាងមុន ។

CHANBOKEO.COM

នៅជាយម្ខាងទៀតនៃរោងស្បូវដ៏ទូលាយនោះ កូនចៅរបស់លោកវណ្ណៈទះដៃច្រៀងលេងយ៉ាងសប្បាយជាមួយនាងយ៉ាដែលជា អ្នកណែនាំបរិយាកាសអោយក្មេងមានសកម្មភាព មិននៅសំកុក ស្ងៀមធុញថប់នោះឡើយ ។ មួយស្របក់ក្រោយមកនាងយ៉ាក៏ដើប ដើរចេញទៅជាមួយក្មេងៗ ធ្វើអោយលោកវណ្ណៈចាប់ភ្លឹកនឹកឆ្ងល់ ចង់តាមដានថាតើពួកគេទៅណា ។ លោកក៏លួចបែរមើលតាមពី ក្រោយពួកគេយ៉ាងភ្លន់ភ្លឹក ស្រាប់តែអ្នកនាងម៉ារីណា ស្រដីសួរទៅ

លោកថា ៖

- ចង់ទៅជិះទូកលេងទេ លោក ?

លោកវណ្ណៈភ្ញាក់ព្រើត បែរមកឆ្លើយតបយ៉ាងរហ័ស ៖

- ចាំក្មេងៗគេមកវិញសិន ចាំយើងទៅទាំងអស់គ្នាណា៎អ្នកនាង!

ស្ត្រីសោភារបស់យើងធ្លាក់ទឹកមុខ ឈប់ញញឹមភ្លាម ព្រោះ មានអារម្មណ៍ថាលោកវណ្ណៈផ្តោតអារម្មណ៍លើក្មេងៗជ្រុលពេក រហូតដល់លែងរវីរវល់អំពីអារម្មណ៍ផ្ទាល់ខ្លួនរបស់នាងតែម្តង ។

មួយស្របក់ក្រោយមក នាងយ៉ានិងកូនទាំងបីរបស់លោកវណ្ណៈ ក៏ត្រឡប់មកវិញដោយមាននាំក្មេងអ្នកលក់អាហារពីរបីនាក់ លើក ថាសចំណីអាហារមកដល់ដែរ ។ នាងយ៉ាក៏ស្ទុះដើបរៀបអាហារ ជូនក្រុមគ្រួសាររបស់លោកវណ្ណៈ យ៉ាងរវាសរវៃ ។

- សូមលោកប្រុស និងអ្នកនាងអញ្ជើញពិសារអាហារ!

លោកវណ្ណៈក្រឡេកមើលអាហារ ឃើញមានមាន់ដុតព្រមទាំង អាហារពីរបីមុខទៀតសុទ្ធតែជារបស់ដែលលោកនិងកូនៗចូលចិត្ត បរិភោគទាំងអស់ ។

- នាងរើសមុខម្ហូបទាំងនេះ ដោយខ្លួនឯងមែនទេ យ៉ា ?

លោកវណ្ណៈសួរ ។

- ចា៎ស អត់ទេ លោកប្រុស! គឺអ្នកនាងតូចនិងប្រុសតូចជាអ្នក ជ្រើសរើសតើហ៎!

(នាងយ៉ាឆ្លើយវិញ)

លោកវណ្ណៈនឹកចម្លែកចិត្ត ព្រោះនៅរៀងរាល់ឆ្នាំដែលលោកនាំ កូនមកលេងទីនេះលោកមិនដែលឃើញពួកគេនឹកចង់ដើរទៅរក ទិញអាហារដោយខ្លួនឯងទេ ហើយរឿងដែលថាក្មេងៗហៅអាហារ សំរាប់ផ្គាប់ចិត្តលោកក៏គ្មានដែរ ។ ពួកគេច្រើនតែនាំគ្នារត់ទៅជិះទូកលេងកំសាន្ត ច្រៀងលើទូកយ៉ាងទ្រហឹងអឹងកង ។ លុះត្រឡប់ មកវិញ

CHANBOKEO.COM

គេតែងមករកបរិភោគតែម្តង ។ មានតែអ្នកស្រីកន្និដ្ឋា ភរិយារបស់លោកទេ ដែលជាអ្នកជ្រើសរើសហៅម្ហូបអាហារទាំង នោះសំរាប់លោកនិងក្រុមគ្រួសារ ។

លោកវណ្ណៈបរិភោគបណ្តើរ លួចសង្កេតឥរិយាបថរបស់នាង យ៉ាបណ្តើរ ថ្វីបើលោកប្រព្រឹត្តកិរិយាហាក់ដូចជាព្រងើយៗ មិន ខ្វល់មិនរវល់នឹងអ្វីជុំវិញខ្លួនយ៉ាងណាក៏ដោយ ។ ប៉ុន្តែ នាងយ៉ាមិន បានចាប់ភ្លឹកអ្វីទេ ឃើញតែធ្វើការតាមធម្មតាតាមតួនាទីជាអ្នកបំរើ ដូចគេឯងទូទៅប៉ុណ្ណោះ ។ មួយស្របក់ក្រោយមក វណ្ណាក៏បបួល លោកវណ្ណៈ ឡើងថា ៖

- តោះ! ទៅជិះទូកលេង លោកប៉ា ?
- មែនហើយ មីងបានបបួលលោកប៉ារបស់ក្មួយទៅជិះទូកលេង ដែរ ប៉ុន្តែ លោកមានប្រសាសន៍ថា រង់ចាំក្មួយៗជុំគ្នាសិន ។

អ្នកនាងម៉ាលីណាស្រដីកាត់នាងតូចវណ្ណា រួចហើយក៏បែរទៅ លោកវណ្ណៈ ស្រដីបន្តទៀតថា ៖

- ទៅជិះទូកកំសាន្តលេងទេ លោកវណ្ណៈ ?

លោកវណ្ណៈញញឹមនៅស្ងៀម ព្រោះថា ទោះបីជាចង់ឬមិនចង់ ក៏ទូកមួយបានមកអែបដល់រោងស្បូវនោះទៅហើយ ។ ក្មេងៗក៏នាំ គ្នាហក់ចូលរឹងទៅអង្គុយក្នុងឃ្លប់ទូក ដែលមានតែដំបូលឥតជញ្ជាំង អាចអោយអ្នកដំណើរមើលទេសភាពយ៉ាងសប្បាយ ។ បន្ទាប់មក លោកវណ្ណៈក៏ដើរចុះពីក្រោយអ្នកនាងម៉ាលីណា ។  លុះដាក់ខ្លួនចុះ អង្គុយ ស្រាប់តែលោកឃើញនាងយ៉ានៅអង្គុយក្នុងរោងស្បូវតែ ម្នាក់ឯង ។

- មិនទៅជាមួយពួកយើងទេ បងយ៉ា ? (កុមារវណ្ណនេត្រសួរ)
- ចាស! បងគិតថា បងនៅចាំឥវ៉ាន់នៅក្នុងរោងនេះចុះ ។ សូម ប្អូនជិះទូកលេងអោយបានសប្បាយ!

នាងយ៉ាឆ្លើយទាំងទឹកមុខញញឹម ។ ការពិត នាងយ៉ាកំពុង គិតថា នោះជាពេលវេលាផ្ទាល់ខ្លួន របស់ក្រុមគ្រួសារលោកវណ្ណៈ ម្ល៉ោះហើយមិនហ៊ានរំខាន ទើបសំរេចចិត្តនៅចាំក្នុងរោងស្បូវតែ ម្នាក់ឯងទៅវិញ ។ អ្នកនាងម៉ាលីណាសំដែងកិរិយាហាក់ដូចជារីក ថ្លើមប្រមាត់ណាស់ ដែលអ្នកនាងមានឱកាសមានពេលវេលាផ្ទាល់ ខ្លួនជាមួយលោកវណ្ណៈនិងគ្រួសារ ដោយគ្មានមនុស្សចម្លែកមកនៅ ទើសមុខទើសមាត់ ។

CHANBOKEO.COM

អ្នកទូកក៏ចែវនាំអ្នកទាំងអស់ចេញឆ្ងាយពីរោងស្បូវទៅហើយ... នាងយ៉ាញញឹម រួចលើកដៃបក់បោយជាសញ្ញាជូនពរអោយក្មេងៗ ដើរកំសាន្តបានសុខសប្បាយ ។ បន្ទាប់មក នារីក៏ផ្អែកខ្នងនឹងសសរ រោង ទាញសៀវភៅទស្សនាវដ្ដីមួយមកអានលេង ស្រាប់តែ...

- អាយ៉ា ?

នាងយ៉ាភ្ញាក់ព្រើត កាលបើឮសម្លេងមនុស្សនិយាយហៅឈ្មោះ នាង ។ ធិតាងើបមុខឡើងឃើញបុរសម្នាក់ឈរញញឹមពីរោងស្បូវ មួយក្បែរនោះ ។ នាងក៏លាន់មាត់ឡើង ៖

- បងមេសា ?
- មែនហើយ! នៅចំណាំបងបានដែរ ?

ធិតាក៏ស្ទុះងើបទៅដើរទៅជាយរោង ដើម្បីអោយបានជិត នឹងអាលបាននិយាយសួរគ្នាដោយមិនបាច់ស្រែករំពង ។

- សុខសប្បាយទេ បង ?
- បាទ សុខសប្បាយទេ ។
- បាត់បង ម៉ាឆ្នាំហើយ មិនដែលឃើញត្រឡប់ទៅស្រុកសោះ ។
- បងធ្វើការមមាញឹកពេក ទើបរកពេលទៅស្រុកមិនបាន... ហើយចុះអាយ៉ាវិញ ? ហេតុអ្វីមកដល់ម្ដុំនេះដែរ ?
- គឺខ្ញុំមកធ្វើការបំរើគ្រួសារមួយនៅភ្នំពេញ ហើយម្ចាស់ផ្ទះគេនាំ កូនចៅមកលេងទីនេះ ទើបគេហៅអោយមកជួយបំរើគេនៅទីនេះ តែម្ដងទៅ ។
- ស្លាប់ហើយ ហេតុអ្វីក៏... ?
- មានស្លាប់អីឯណា បងមេសា! ការងារជាអ្នកបំរើមិនមែនជាការ ងារថោកទាបទេ ។ ថោកឬថ្លៃ វាស្ថិតនៅលើគំនិតមារយាទរបស់ យើងជាជាង ។
- ហើយម្ចាស់ផ្ទះរបស់យ៉ា គេនៅម្ដុំណាដែរ ?

យ៉ាក៏ទាញក្រដាសមួយសរសេរហុចអោយ ៖

- ខ្ញុំនៅធ្វើការទីនេះ ។ គេអោយឈប់ទៅលេងផ្ទះ បីខែម្ដង!
- អូហ៍ គេចិត្តបានដែរតើហ៍ ។
- ចាស! មើលទៅ មិនអីទេ បង! ហើយចុះបងវិញធ្វើការនៅ ឯណាដែរ ?

CHANBOKEO.COM

- បងធ្វើការនៅរោងចក្រ ជានាយកោយខាងបញ្ជូនឥវ៉ាន់ទៅក្រៅ ប្រទេស ។ ប៉ុន្តែ ការងារនឿយហត់អត់ងងុយណាស់ ។ ពេលនេះ បងគិតថានឹងដើររកការងារថ្មីធ្វើហើយ ។ ហើយអាយ៉ាឯងមាន ទូរសព្ទ័ទេ ?

- ចាស អត់មានទេ ។

- អញ្ចឹង យកទូរសព្ទ័បងទៅ! បើទំនេរហៅទៅលេងបងផង!

- ចាសបង!

រំពេចនោះ ស្រាប់តែ...

- បងយ៉ា!

នាងយ៉ាក្រឡេកទៅម្ចាស់សម្លេង ក៏ប្រទះឃើញទូករបស់លោក វណ្ណៈបានវិលមកដល់រោងស្បូវវិញ ។

- ខ្ញុំត្រូវទៅធ្វើការវិញហើយ បងមេសា ។

- អឺ ទៅចុះ ។

នាងយ៉ាក៏ស្ទុះយ៉ាងរហ័សទៅទទួលគ្រួសាររបស់លោកវណ្ណៈ ៖

- ឆាប់អញ្ជើញមកវិញម្ល៉េះ លោកប្រុស ? (មាណវីសួរ)

- គឺយើងមកទទួលបងស្រីទៅជិះទូកលេងជាមួយពួកយើងដែរ ។

កុមារវណ្ណនេត្រស្រែកពីក្នុងទូកមក ។ នាងយ៉ាបែរសម្លឹងទៅ លោកវណ្ណៈ ស្រាប់តែឃើញលោកងក់ក្បាលដាក់នាង ។ ឃើញ បញ្ជាដូច្នេះ នាងក៏ទម្លាក់ខ្លួនចុះទៅក្នុងទូកភ្លាម ទាំងនឹកឆ្ងល់ក្នុង ចិត្តថា ហេតុអ្វីពួកគេបំបែរក្បាលទូកមកទទួលនាងវិញ ។

នៅលើទូក...

លោកវណ្ណៈអង្គុយខាងមុខ ក្បែរអ្នកនាងម៉ាលីណាដ៏សោភានោះ ទុកអោយក្មេងៗអង្គុយខាងក្រោយជាមួយនាងយ៉ា និយាយគ្នាពីនេះ ពីនោះ សើចកខឹក ។

- លោកវណ្ណៈឧស្សាហ៍មកលេងទីនេះញឹកញាប់ណាស់ មែនទេ ?

អ្នកនាងម៉ាលីណាសួរ ។

- មិនសូវទេ! មកលេងម្តងម្កាលប៉ុណ្ណោះ ។

លោកវណ្ណៈឆ្លើយទៅកាន់សុភាពស្ត្រីនោះវិញ ប៉ុន្តែភ្នែកសម្លឹង ទៅភូមិអ្នកស្រុកនៅត្រើយម្ខាង ឯត្រចៀកលួចស្ដាប់សំណើចរបស់ កូនៗដែលនៅអង្គុយខាងក្រោយ ។ ភ្លាមនោះ នាងតូចវណ្ណាស្រដី ឡើងថា ៖

- បងយ៉ាចេះច្រៀងទេ ?
- បងមិនចេះទេ អូនតូច ។
- អូហ៍ស្ដាយណាស់ ព្រោះអូនតូចចង់ស្ដាប់ចម្រៀង ។
- ខ្ញុំក៏ចង់ស្ដាប់ដែរ (កុមារវណ្ណនេត្រវាចាបន្ទរ)
- មែនហើយ! បើសិនមានចម្រៀងមកលោសញ្ចេតនាកំដរខ្លះៗ ប្រហែលជាបរិយាកាសនៅពេលនេះ មានភាពរមនាណាស់ ។

យុវតីវណ្ណនីស្រដីឡើងពីក្រោយថែមទៀត ។

- ជាពិសេស គឺលោកប៉ាតែម្ដង... លោកប៉ាច្រៀងពិរោះណាស់ (នាងតូចវណ្ណាទះដៃដោយក្ដីរីករាយ) លោកប៉ាច្រៀងអោយពួក យើងស្ដាប់បន្តិចមក!

លោកវណ្ណៈភ្ញាក់ព្រើតដែលកូនរបស់លោកទាមទារអោយលោក ច្រៀង ។

- មែនហើយបាទ! លោកប៉ាច្រៀងម៉ាបទមក៍! កូនចង់ស្ដាប់ ។

វណ្ណនេត្រនិយាយ ។ ប៉ុន្តែ តើអោយលោកវណ្ណៈច្រៀងម្ដេច ចេញទៅកាលបើបេះដូងរបស់លោកកំពុងតែទទួលភាពក្រៀមស្វិត ស្រពោន តាំងពីមរណភាពរបស់ភរិយាជាទីស្រឡាញ់ ទៅហើយ នោះ ? លោកវណ្ណៈនៅស្ងៀម មិនហ៊ានស្ដីថាម៉េចទេ គ្រាន់តែធ្វើ មុខញញឹមៗមិនអោយកូនៗអាក់អន់ស្រពាន់ចិត្ត ។ ស្រាប់តែអ្នកនាង ម៉ាលីណាឆ្លើយជំនួសថា ៖

- ចុះបើសិនណាមីងច្រៀងជំនួសលោកប៉ា ក្មួយទាំងអស់គ្នាជួយ ច្រៀងបន្ទរអោយមីងទេ ?
- ចាំសៗ! បាទ! ចាំពួកយើងជួយ ។ សូមអ្នកមីងច្រៀងមក៍!

ក្មេងទាំងអស់ឆ្លើយស្រុះគ្នាឡើង ។ អ្នកនាងម៉ាលីណាញញឹម យ៉ាងស្រស់ កាលបើក្មេងសម្ដែងភាពរួសរាយត្រឡប់មករកនាង វិញដោយមិនមានអារិចិត្ត ។ ការពិត អ្នកនាងកំពុងរកផ្លូវទាក់ទាញ ចំណាប់អារម្មណ៍ពីលោកវណ្ណៈដែលនៅតែស្ងៀមៗ មិនសូវស្រដី ។ អ្នកនាងសោភាស្គាល់លោកវណ្ណៈពីរបីឆ្នាំហើយ តាំងពីអ្នកស្រីកន្និដ្ឋា នៅរស់ម្ល៉េះ គ្រាន់តែមិនសូវរាក់ទាក់នឹងគ្នា ព្រោះលោកវណ្ណៈមាន ភរិយា ។

CHANBOKEO . COM

អ្នកនាងម៉ាលីណានៅលីវយូរហើយ ធ្លាប់មានគូដណ្ដឹង ម្នាក់ ប៉ុន្តែ គេបានបែកចិត្តទៅមានអ្នកថ្មី ដែលជាអនិកជនមកពី បរទេស ធ្វើអោយសុភាពស្រ្តីយើងខូចចិត្ត លែងចង់ស្គាល់បុរស ណា រហូតមកទល់នឹងពេលបីបួនអាទិត្យមុននេះ អ្នកនាងក៏បានជួប លោកវណ្ណៈដោយចៃដន្យនៅក្នុងពិធីជប់លៀងមួយហើយបានឡើង រាំវង់ជាមួយគ្នាមួយបទ ។ បន្ទាប់មក អ្នកទាំងពីរក៏ចាប់រាប់អានគ្នា វិញ ទំនងចង់អោយជិតដិតជាងមុន ។ ប៉ុន្តែភាពស្ងៀមស្ងាត់របស់ លោកវណ្ណៈ បានធ្វើអោយអ្នកនាងម៉ាលីណាពិបាករកនឹកពាក្យមក ចាប់ផ្តើមការសន្ទនាគ្នាណាស់ ហើយនៅរៀងរាល់ដងដែលមានការ សន្ទនា គឺសុភាពស្រ្តីយើងជាអ្នកចាប់ផ្តើមប្រយោគអោយរាល់តែ ដង ។ ជួនកាល អ្នកនាងមានអារម្មណ៍ហាក់ដូចជាគ្មានកម្លាំងចិត្ត នឹងភ្ជាប់ទំនាក់ទំនងជាមួយលោកវណ្ណៈតទៅទៀត ប៉ុន្តែ រូបសង្ហា ឋានៈគ្រួសារ និងទ្រព្យធនរបស់លោកវណ្ណៈ ហាក់ដូចជាមាន ទំនាក់ទំនាញយ៉ាងខ្លាំងក្លាមកលើម៉ាលីណា ធ្វើអោយនាងដកខ្លួនទៅ ណាមិនរួចសោះ ថ្វីបើលោកជាពោះម៉ាយមានកូនដល់ទៅបួនរួច ហើយ នោះក៏ដោយ ។

ភ្លាមនោះ ស្រ្តីរូបស្រស់របស់យើងក៏បន្លឺសំនៀងឡើង យ៉ាង គ្រលួច កាត់ផ្ទៃទឹក ៖

រាំងវារី

គង្គាថ្លាល្វេងឃើញបាតដី ត្រីហែលឆ្វែលឆ្វាត់កាត់ទងឈូក
ក្រអៅលូតឡើងឆ្តោះពពក នាំក្រពុំឈូកចោះវេហាស៍ ។
ខ្យងទំសំងំទងត្រកួន អណ្តើកលាក់ខ្លួនពួនកាយា
ជ្រកម្លប់ស្លឹកឈូកយោលផ្កាប់ផ្ងារ ក្រោមមេឃាថ្លាច្បាស់សុរិយង្គ ។

មកដល់ត្រង់នេះ ស្រាប់តែអ្នកនាងទុចដ៏ក់ ឈប់ឈឹង មួយ រំពេច ត្បិតភ្លេចទំនុកច្រៀងវគ្គចុងក្រោយ រកនឹកមិនឃើញ ។ អ្នកនាងក៏ញញឹមឡើង ៖

- មីងភ្លេចវគ្គចុងក្រោយហើយ ក្មួយៗ ! មាននរណាចាំទេ ?
- ពុទ្ធោអើយ ! បទនេះពិរោះណាស់ ហើយសម្លេងអ្នកមីងក៏ពិរោះ ទៀតផង ប៉ុន្តែ គួរឲ្យស្តាយ ពួកយើងអត់ចេះបទនេះសោះ ។

វណ្ណនីស្រដីឡើង ។

- លោកប៉ាចេះវគ្គបន្តទៀតទេ ? (វណ្ណនេត្រសួរ)

CHANBOKEO.COM

លោកវណ្ណៈគ្រវីក្បាល ។ ស្រាប់តែនាងយ៉ាវាចាឡើងជាកាព្យ ទំនុកបទ វគ្គចុងក្រោយនោះថា ៖

- ការពិត វគ្គបន្តនោះគឺ...

ដើមត្រែងយោលយោគតាមជំនោរ ទាហៃលក្រៀងគូអួតត្រយង

ព្រលិតពណ៌ស្វាយណាយរំចង់ សក្បុសផ្ទូផង់ពាសផ្ទៃទឹក ។

អុំទូកបណ្តើរច្រៀងបណ្តើរ ល្អអ្វីមិនស្មើល្អពន្លឹក

ទេសភាពស្រុកស្រែព្រហាមព្រឹក ចុះទឹកហែលលេងជ្រះសៅហ្មង ។

អ្នកនាងម៉ាលីណាឮដូច្នោះក៏ចាប់ច្រៀងបន្តទៅទៀត រហូតដល់ ចប់ ។ ទាំងអស់គ្នាក៏ទះដៃហ៊ោរយ៉ាងសប្បាយ ។ ម៉ាលីណារីកមុខ ដូចគ្រាប់ដីរ កាលបើបានទទួលនូវភាពកក់ក្តៅពីក្រុមគ្រួសារលោក វណ្ណៈ ។ បន្តិចមក អ្នកនាងក៏សួរនាងយ៉ា ៖

- នាងស្គាល់ទំនុកចម្រៀងច្រើនទេ ?

- ចា៎ស ! ចេះតិចតួចបទទេ អ្នកនាង ! (នាងយ៉ាឆ្លើយ)

- ហេតុអ្វីក៏មិនរៀនច្រៀងផង ហ៎ក ? (ម៉ាលីណាសួរបន្ត)

ប៉ុន្តែ នាងយ៉ាបែរជាញញឹម មិនតបទៅវិញថាម៉េចឡើយ ។ ម៉ាលីណាក៏ស្រដីបន្តទៀតថា ៖

- នោះក៏ល្អដែរ បើសិនណានាងអាចសរសេរទំនុកចម្រៀងដែល នាងស្គាល់ទុកក្នុងសៀវភៅ ថ្ងៃក្រោយ ខ្ញុំអាចយកមកច្រៀងកំដរ បរិយាកាសរបៀបនេះ ដើម្បីអោយសប្បាយរីករាយទាំងអស់គ្នា ។

- ចា៎ស អ្នកនាង !

មើលទៅបរិយាកាសពេលនេះ ហាក់ដូចជាមានភាពស្និទ្ធស្នាល ជាងមុន ជាពិសេសរវាងម៉ាលីណានិងនាងយ៉ា ព្រោះពេលនេះនាង យ៉ាបានរាយទំនុកលើកមុខមាត់របស់ម៉ាលីណា អោយច្រៀងយ៉ាង ពិរោះដល់ចប់ នៅចំពោះមុខលោកវណ្ណៈ ។

រសៀលបន្តិច ពួកគេក៏នាំគ្នាឡើងពីទូក ចូលរោងស្បូវ បំរុង ត្រឡប់ទៅផ្ទះវិញ ។ លោកវណ្ណៈក៏ដើរស្ទួតាមស្ពានឫស្សីនាំមុខអ្នក នាងម៉ាលីណានិងកូនៗចេញពីរោងស្បូវសំដៅច្រាំង ដោយមាន នាងយ៉ាជាអ្នកដើរក្រោយគេបង្អស់ ។ វណ្ណនេត្រនិងនាងតូចវណ្ណា ដើរស្ទួស្ពានបណ្តើរ ប្រឡែងញ៉េះគ្នាបណ្តើរ លាន់សំណើចឲ្យកក្អឹក ស្រាប់តែកុមារវណ្ណនេត្ររអិលធ្លាក់ជើងលើស្ពាន ។

កុមារ ភ្ញាក់ព្រើត លាតដៃស្រវាតោងបង្កោលស្ពាន ជាប់តែលតោលៗ ព្រយុងជើងទាំងពីរទម្លាក់ទៅក្នុងទឹក ។ នាងតូចវណ្ណាក៏ស្រែកវ៉ាស ឡើង ។ នាងយ៉ាដែលដើរពីក្រោយវណ្ណនេត្រ ក៏ស្ទុះស្រវាចាប់ កុមារបានដៃម្ខាង ជួយអូសទាញកុមារអោយឡើងត្រឡប់មកលើ ស្ពានវិញ ។ ថៃដន្យ កុមារមានមាឌរាងធំបន្តិច ម្លោះហើយចំពោះនារីរាងតូចស្ដើងដូចនាងយ៉ា ការជួយទាញដៃលើកកុមារឲ្យ ឡើងមកខាងលើស្ពានវិញហាក់ដូចជាតតេះតតះដល់សូរហើយ ។ លោកវណ្ណៈក្រឡេកក្រោយឃើញដូច្នោះក៏បក់ដៃអោយកូនៗរត់សួ ស្ពានឡើងគោកផុតអស់ ទើបលោករត់ត្រឡប់ទៅរកជួយវណ្ណនេត្រវិញ ព្រោះក្ដារបន្ទះស្ពានវាតូចពេក អាចដើរឆ្លងម្ដង បានតែ ម្នាក់ ។ លុះលោកទៅដល់ជួយស្រវាទាញដៃកូនប្រុសម្ខាងទៀត ដើម្បីជួយលើកនាយអោយឡើងមកលើស្ពាន ស្រាប់តែនាងយ៉ា ឈានថយជាន់ខុសក្ដារស្ពាន ក៏ផ្ងាកក្រោយវឹង ។ ធិតាភ្ញាក់ព្រើតលូកដៃម្ខាងស្រវាចាប់បង្កាន់ដៃស្ពានភ្លិប ។ លោកវណ្ណៈឃើញ ដូច្នោះក៏លូកស្រវាចាប់ដៃនាងយ៉ាម្ខាងទៀត ហើយព្រលែងកុមារវណ្ណនេត្រអោយឈរនៅលើស្ពានតាមសម្រួល ។ នាងយ៉ាក៏ប្រឹង តោងដៃលោកវណ្ណៈនៅដៃម្ខាងតោងបង្កាន់ស្ពាន នៅដៃម្ខាងទៀត ស្រាប់តែបង្កាន់ដៃបាក់ប្រេសទម្លាក់ខ្លួននារីទាំងជំហរទៅក្នុងទឹកវឹង តែម្ដង ។ លោកវណ្ណៈក៏អស់លំនឹងទប់ខ្លួនរលីងព្រោះក្ដារស្ពាន តូចពេក ក៏ដួលត្មោល ធ្លាក់ទៅក្នុងទឹកតាមពីក្រោយនារីយើងទៅ ។

ភ្ញៀវដែលមកដើរលេងកំសាន្តទីនេះក៏រត់មកឈរមើលរហង់ ។ ចំណែកម្ចាស់រោងស្បូវក៏ស្ទុះស្ទ្រូស្រមកជួយអ្នកទាំងពីរ ។ បន្តិច មកលោកវណ្ណៈនិងនាងយ៉ាក៏ឡើងមកដល់ខាងលើគោកវិញ ទាំង ភក់ស្រមក ។ នាងយ៉ាក្រឡេកឃើញលោកវណ្ណៈប្រឡាក់ ពេញខ្លួន ក៏លើកដៃប្រណម្យសំពះ ៖

- នាងខ្ញុំសូមទោសចំពោះការធ្វេសប្រហែស ធ្វើអោយលោកប្រុស ត្រូវធ្លាក់ទឹក ប្រឡាក់ខ្លួនអស់!
- មិនមានជាកំហុសរបស់នាងទេ កុំភ័យអី ។ ការពិត មកពីកូននេត្រឯនោះតើហ៍!

នាងយ៉ាធូរទ្រូងខ្យាក កាលបើដឹងថាលោកមិនប្រកាន់ខឹងនឹង រូបនាងបន្តិចមកក៏ស្ទុះដើរទៅរកផ្ទះអ្នកស្រុកម្ដុំៗនោះ ដើម្បីសុំ ទឹកជម្រះខ្លួន ។ អ្នកស្រុកក៏មិនកំណាញ់ដែរ កាលបើគេឃើញអ្នក ទាំងពីរមានគ្រោះថ្នាក់យ៉ាងនោះទៅហើយ ។

CHANBOKEO.COM

នាងយ៉ាក៏ដើរទៅ យកឥវ៉ាន់មួយកញ្ចប់ពីខាងក្រោយរថយន្ត រួចហើយ ក៏ទៅអញ្ជើញលោកវណ្ណៈមកលាងជំរះភក់ ។

មុននឹងចូលបន្ទប់ទឹក នាងក៏ហុចកញ្ចប់ឥវ៉ាន់ជូនលោកវណ្ណៈ ៖

- នេះ ខោអាវរបស់លោកប្រុស ចាស!
- អូហ៍ ? នាងយកមកជាមួយដែរហ៍ ?
- ចាស! ព្រោះខ្ញុំឮប្រុសតូចប្រាប់ថាទៅលេងទឹក ទើបរៀបខោ អាវសំរាប់ផ្លាស់យកមកបន្ថែមក្រែងត្រូវការ ។

លោកវណ្ណៈសម្លឹងមុខនាងយ៉ាយ៉ាងចម្លែកចិត្ត ប៉ុន្តែមិនមាន ប្រសាសន៍អ្វីទេ គ្រាន់តែទទួលខោអាវហើយ ក៏ដើរចូលបន្ទប់ទឹក បាត់ទៅ ។ លុះត្រឡប់មកវិញស្រាប់តែឃើញនាងយ៉ាស្ថិតនៅក្នុង សម្លៀកសើមដដែល គ្រាន់តែលាងជំរះភក់ប៉ុណ្ណោះ លោកវណ្ណៈក៏ សួរថា ៖

- នាងមិនមានខោអាវផ្លាស់ទេ ?
- ចាស! លោកប្រុស! នាងខ្ញុំមិនបានរៀបចំរុងសំរាប់ខ្លួនឯងទេ ព្រោះគិតថាគ្រាន់តែមកបំរើលោកនិងក្រុមគ្រួសារតែប៉ុណ្ណោះ ។

ភ្លាមនោះ នាយតឿក៏បើកឡានមកដល់ ដោយមានផ្ទុកអ្នកនាង ម៉ាលីណានិងក្មេងទាំងបីនាក់ ។ លោកវណ្ណៈក៏ហាក់ឡើងរថយន្ត លុះងាកក្រោយ ឃើញនាងយ៉ាឈរកាន់ថង់ខោអាវរបស់លោកនៅខាងក្រៅធ្វើរេរា ។

- ម៉េចមិនឡើងមក នាងយ៉ា ? (ពូតឿស្រដី)
- ចាស មិនអីទេពូ! (នាងយ៉ាគ្រវីក្បាល) ពូនាំលោកប្រុសទៅ មុនចុះចាំខ្ញុំជិះម៉ូតូឌុបចេញទៅតាមក្រោយ ព្រោះខោអាវខ្ញុំ ជាប់ក្លិនមិនល្អ ។
- នោះល្អហើយ! (អ្នកនាងម៉ាលីណាស្រដី សម្តែងកិរិយាហាក់ ខ្ពើមក្លិនភក់) ព្រោះកុំអោយមានក្លិនមិនល្អជាប់ឡានថ្មីរបស់យើង ផង ។

ថាហើយ អ្នកនាងម៉ាលីណា ក៏ស្រវាប្រាក់ប្រាំពាន់រៀលហុចឲ្យ នាងយ៉ា ៖

- នេះ ថ្លៃម៉ូតូឌុបជិះត្រឡប់ទៅផ្ទះវិញ ។ ថ្ងៃមុខថ្ងៃក្រោយ ធ្វើអ្វីរៀនប្រយត្ន័ប្រយែងបន្តិចណា៎! កុំអោយបាក់មុខដូចថ្ងៃនេះទៀត ឃើញទេ ការមិនប្រយត្ន័ធ្វើអោយគេឯងអំពល់ទុកជាមួយដោយ សារដូច្នេះឯង ?
- ចាស អ្នកនាង (នាងយ៉ាឆ្លើយ)

ភ្លាមនោះ លោកវណ្ណៈជ្រួញចិញ្ចើម រួចហើយស្រដីថា ៖
- កុំបន្ទោសគ្នាអី! គ្មាននរណាម្នាក់ចង់ធ្លាក់ទឹកប្រឡាក់ភក់ទេ ។
ម៉ាលីណាញញួច្រោះក៏បិទមាត់នៅស្ងៀមវិញ ។ ការពិត លោកវណ្ណៈគិតបារម្ភក្រែងកូនប្រុសរបស់លោក នឹកភិតភ័យក្នុងចិត្ត ខ្លាច ឪពុកស្ដីបន្ទោស ព្រោះគេជាដើមហេតុ ទើបមិនចង់អោយអ្នកនាង ម៉ាលីណានិយាយច្រើន ខ្លាចប៉ះពាល់ដល់អារម្មណ៍កូន ។ ចំណែក វណ្ណនេត្រវិញនោះ ភ័យរួញខ្លួនណាស់ទៅហើយ ថ្វីបើឪពុកមិនបាន ស្ដីបន្ទោសអ្វីមួយម៉ាត់ ព្រោះឃើញឪពុកធ្លាក់ទឹកភក់ប្រឡាក់ពេញខ្លួនកណ្ដាលចំណោមយ៉ាងនោះ ។
បន្តិចមក ពូគឿក៏បរឡានចេញទៅ ។ នាងយ៉ាក៏ដើរត្រឡប់ទៅរកម៉ូតូចំណតម៉ូតូឌុប បំរុងហៅរកអ្នកជួយដឹកត្រឡប់ទៅផ្ទះ ស្រាប់តែប្រទះនឹងបុរសសង្ហាម្នាក់ ។
- អាយ៉ា ត្រូវការអ្នកជូនទៅផ្ទះ មែនទេ ?
- ចា៎ស មែនហើយបងមេសា ។ អំបាញមិញ បងឃើញខ្ញុំធ្លាក់ ទឹកដែរ ?
- ចីមិនឃើញ! ថាចង់ទៅរកជួយដែរ តែខ្លាចចិត្តចៅហ្វាយនាយ របស់អាយ៉ាឯងទើបបងរារែក ។
- មិនអីទេបង! ព្រោះខ្ញុំធ្លាក់ប៉ះចំទឹករាក់ត្រឹមចង្កេះ បើសិនជ្រៅ ជាងនោះ ច្បាស់ជាវីវរហើយ ព្រោះខ្ញុំមានចេះហែលទឹកឯណា ?
មេសាទាញម៉ូតូមកបញ្ឆេះ ។
- តោះឡើងម៉ក! បងជូនទៅ ។
- ចា៎ស អរគុណបង! ហើយចុះបងមកតែម្នាក់ឯងទេ ?
- នរណាថា ? បងមកគ្នាម៉ាហ្វូងធំឯណោះ ។
- ហើយចុះម៉េចទៅវិញតែម្នាក់ឯងអញ្ចឹង ?
- ព្រោះពួកគេខ្លះទៅច្រៀងការាអូខេអស់ហើយ ខ្លះទៀតនាំគ្នាទៅ ហែលទឹក ហើយខ្លះក៏ត្រឡប់ទៅសំរាក ដើម្បីធ្វើការស្អែក ។
អ្នកទាំងពីរជិះម៉ូតូបណ្ដើរ ជជែកគ្នាបណ្ដើរ ។
- ហើយចុះបងមេសាឯងរៀបការជាមួយបងកញ្ញានាហើយឬនៅ ?
- នៅទេ អាយ៉ា ។

CHANBOKEO.COM

- អូហ៎ ? ហេតុអ្វីក៏ដូច្នោះ ?
- ព្រោះអី...កញ្ញានាគេជួបបុរសថ្មី ដែលមានគុណសម្បត្តិល្អជាងបង ទើបគេដូរចិត្ត...
- ពុទ្ធោ! ដល់ថ្នាក់ហ្នឹងផង ?
- មែនហើយ! ភ្នំពេញជាកន្លែងសំបូរការងារ សំបូរមនុស្សប្លែកៗ ហើយក៏មានឥទ្ធិពលផ្លាស់ប្តូរចិត្តមនុស្សអោយគិតប្លែកៗ ប្រព្រឹត្ត ប្លែកៗណាស់ទៀតផង ។

ពេលនោះ នាងយ៉ាំលែងហ៊ានសួរតទៅទៀត កាលបើឮសំដី របស់មេសា ទំនងសោកសៅក្នុងចិត្ត ។ មិនយូរប៉ុន្មាន មេសាក៏នាំ នាងយ៉ាំមកដល់គេហដ្ឋានរបស់លោកវណ្ណៈវិញ ។

- អរគុណណាស់ បងមេសា!
- មិនអីទេ យ៉ាំ! ថែរក្សាខ្លួនណា៎! ថ្ងៃណាទំនេរ ទូរសព្ទ័ទៅលេង បងផង ។
- ចា៎ស បង! ហើយសូមអោយបងមានភព្វ័សំណាងល្អជានិច្ច ជា ពិសេសរឿងគូស្រករ ។

មេសាញញឹមដាក់នាង ហើយកាច់ចង្កូតម៉ូតូថយត្រឡប់ទៅវិញ បាត់ទៅ ។ នាងយ៉ាំក៏ដើរចូលទៅក្នុងផ្ទះ ឃើញកុមារវណ្ណនេត្ររត់ មករកនាងភ្លាម ៖

- បងយ៉ាំ! អរគុណបងដែលជួយនេត្រមិនអោយធ្លាក់ទឹក ហើយ នេត្រសុំទោសបងដែរ ដែលធ្វើអោយបងធ្លាក់ទឹកវិញ ។
- មិនអីទេ! ការពិត អូននេត្រមិនបានធ្វើអោយបងធ្លាក់ទឹកទេ គឺ បងទេតើដែលដើរជាន់ខុសក្តារស្ពាន ។ អូហ៎! កុំទាន់មកជិតបងអី ព្រោះបងនៅមានក្លិនភក់ជាប់ខ្លួននៅឡើយ ។ បងសុំទៅលាងខ្លួន សិនណា៎!
- បាទ!

នាងយ៉ាំក៏ដើរតាមចំហៀងទៅរកបន្ទប់ទឹក ។ ភ្លាមនោះ នាង បានចោលកន្ទុយភ្នែកទៅខាងលើឡៅ ឃើញលោកវណ្ណៈកំពុងឈរ ក្រពាត់ដៃសម្លឹងមករកនាង ដោយខ្សែនេត្រាយ៉ាងប្លែកយ៉ាងណា មិនដឹង ។ កាលបើប្រទះក្រសែភ្នែករបស់មាណវីយើងដែលបែរ ងើយសម្លឹងមករក លោកវណ្ណៈក៏បែរមុខចេញយ៉ាងលឿន ហើយ ដើរគេចចូលផ្ទះបាត់ទៅ ។ នាងយ៉ាំភ្ញាក់ព្រើត នឹកភ័យខ្លួន ត្បិត លោកវណ្ណៈបាន ប្រទះនាងជាមួយកម្លោះមេសាពីរដងហើយថ្ងៃនេះ ខ្លាចលោកគិតសង្ស័យមែច្រឡំផ្តេសផ្តាស អំពីចំណាងរបស់នាង និងបុរសមួយរូបនោះ ប៉ុន្តែ

CHANBOKEO.COM

បន្តិចមក នាងក៏តាំងស្មារតីបានមក វិញ ព្រោះគិតថានាងមិនបានធ្វើអ្វីខុសទេ គ្រាន់តែជាការជួបញាតិពីស្រុក ដោយថៃដន្យតែប៉ុណ្ណោះ...

រាត្រីដដែល...

នៅក្នុងបន្ទប់...

លោកវណ្ណៈមានអារម្មណ៍ហាក់ដូចជាធុញថប់ក្តៅស្អុះខុសធម្មតា ក៏ចេញដើរមកលើរានហាល ។ ឯក្រសែនេត្រាវិញក៏រេរាចុះឡើង មើលទៅទីធ្លាមុខផ្ទះខាងក្រោម ទំនងហាក់ដូចជាកំពុងសម្លឹងរកស្រមោលនរណាម្នាក់ ។ លោកនៅឈរសំកុកចាំទីនោះយ៉ាងយូរ ឃើញទីធ្លាមុខផ្ទះនៅតែស្ងាត់ឈឹងដដែល ក៏បែរក្រោយត្រឡប់ទៅ រកបន្ទប់របស់លោកវិញ ដោយដួងចិត្តតប់ប្រមល់ សាជាថ្មី....

*oooooooooooooooooo*

*ooooo*

*o*

CHANBOKEO . COM

# វគ្គទី៣
# ទំនាញអារម្មណ៍

*ម៉ោង៨ រសៀល ថ្ងៃមួយ...*

*រ៉ឺង! រ៉ឺង! រ៉ឺង! ទូរសព្ទ័ក្នុងផ្ទះរោទិ៍ឡើង ។ វណ្ណនីកំពុងតែ ឈ្ងោកអានសៀវភៅ ក៏ស្ទុះដើបទៅទទួល ៖*

*- ជំរាបសួរ ចាស!*

*- កូននី! នេះប៉ាណា៎!*

*- ចាសលោកប៉ា!*

*- ល្ងាចនេះ អោយប៉ាសូមទោសផង ដែលមិនបាននៅបរិភោគ បាយ ជាមួយកូនទាំងបី ព្រោះប៉ាជាប់រវល់បន្តិច មិនដឹងថ្មើរម៉ាន បានទៅដល់ផ្ទះវិញទេ ។*

*វណ្ណនីញញូញ្ញោះ ខកចិត្តស្រឡេត ទម្លាក់ទូរសព្ទ័យ៉ាងលឿន ដោយមិនបានលាឪពុកមួយម៉ាត់ រួចហើយរត់ទៅសំកុកក្នុងសាឡុង ធ្វើមុខក្រញូវ ។*

*- ម៉េចហ្នឹង បងនី? (វណ្ណនេត្រសួរ)*

*- គឺលោកប៉ានោះអី! លោកប៉ាទៅបរិភោគបាយនៅក្រៅភ្លេចពួក យើងហើយ ។*

*- ក្រែងលោកប៉ាជាប់រវល់ការងារទេនឹង?*

*- មិនមែនទេ! បងថា លោកប៉ាច្បាស់ជាទៅបាយក្រៅជាមួយអ្នក មីងម៉ាលីណាហើយ ។*

CHANBOKEO.COM

ឃើញបងស្រីធ្វើមុខស្មើក វណ្ណនេត្រក៏ធ្វើទឹកមុខស្មើកតាម ដែរ ។ នាងតូចវណ្ណាដែលកំពុងអង្គុយគូររូបលេង ក៏ធ្វើភ្នែកឡឹង ឡង់ៗ ។ រំពេចនោះ នាងយ៉ានិងយាយរៀមដើរចូលមកដល់ ។

- យ៉ាងម៉េចហ្នឹង អ្នកនាងតូច បានជាធ្វើមុខស្រពោនគ្រប់គ្នា ?

នាងយ៉ាសួរ ។

- គឺថ្ងៃនេះ ពួកយើងត្រូវបរិភោគបាយដោយគ្មានលោកប៉ាហើយ...

កុមារវណ្ណនេត្រនិយាយ ។

- មែនហើយ! (វណ្ណនីបន្ទរ) កាលមុន បើលោកប៉ាធ្វើការហួស ម៉ោងមិនបានមកបរិភោគបាយជុំគ្នា ក៏ពួកយើងនៅមានម៉ាក់ដែរ តែពេលនេះ យើងលែងមាននរណាទាំងអស់... វាហាក់ដូចជា កណ្ដោចកណ្ដែងណាស់ បងយ៉ា ។ ដូច្នេះហើយណា៎ ដែលខ្ញុំចេះតែ ចាក់ស្មុគ្រអផ្សុកក្នុងចិត្ត ចង់ទៅច្រៀងរាំលោតកញ្ឆែងនៅក្រៅ ដើម្បីរំសាយភាពតប់ប្រមល់ក្នុងអារម្មណ៍នោះអី ។ គិតកាលណា កាន់តែធុញថប់ឡើងកាលនោះ រួចចង់រត់ទៅក្រៅលោតកញ្ឆែង កាលហ្នឹងដែរ ។

យាយរៀមឮដូច្នោះក៏មានប្រសាសន៍ថា ៖

- កុំធ្វើដូច្នេះអីចៅអើយ! ជីវិតក្ដុងក្ដាំងនៅក្រៅ មិនដែលឃើញ ហុចផលល្អដល់យុវជនយុវតីណាទេ ឃើញតែលោតហក់កញ្ឆែងក្ដុង ក្ដាំងហើយក៏វាយគ្នា ចាក់គ្នាស្លាប់តែប៉ុនហ្នឹងឯង ។ ចំពោះនារី ភេទទន់ខ្សោយដូចចៅនេះ ពិតជាគ្មានសុវត្ថិភាពឡើយ ។

- ប៉ុន្ដែ ខ្ញុំតប់ប្រមល់ណាស់យាយ! ម្សិលមិញ ខ្ញុំគិតថា ជីវិតរីក រាយជាគ្រួសារកំពុងវិលត្រឡប់មកវិញហើយ ស្រាប់តែថ្ងៃនេះបែរ ក្លាយមកជាអាប់អួរដដែលទៅវិញ ។

នាងយ៉ាឈរស្ងៀមយូរហើយ ក៏ស្រដីតបទៅនាងថា ៖

- អ្នកនាងតូចចង់អោយបរិយាកាសគ្រួសារវិលត្រឡប់មករកភាព រមនាឡើងវិញមែនទេ ?

- ចា៎ស មែនហើយបង! (វណ្ណនីតប)

- អញ្ចឹង បងមានមធ្យោបាយមួយ ។ ប្អូនចង់សាកទេ ក្រែងលោ មានប្រសិទ្ធិភាព ។

- មែនឬបង ? តើបងមានមធ្យោបាយអីទៅ ?

CHANBOKEO.COM

ភ្លាមនោះ ទាំងអស់គ្នា ព្រមទាំងយាយរៀមផង ដកក នឹកឆ្ងល់ ភ្លាមតែម្ដងថា តើនាងយ៉ាមានគំរោងអ្វីដែរទៅ ។ ទាំងអស់គ្នាក៏ ឈ្ងោកមុខស្ដាប់នាងយ៉ារៀបរាប់...

ម៉ោង១០យប់ថ្ងៃដដែល...

ពូតឿបរឡាននាំលោកវណ្ណមកដល់ផ្ទះវិញ ។ នាងយ៉ាស្ទុះទៅ ទទួលលោកវណ្ណៈដែលបើកទ្វាររថយន្តចុះចេញមក ។

- ក្មេងៗចូលគេងអស់ហើយហ្ន៎ស នាងយ៉ា ?
- ចា៎ស ចូលតាំងពីម៉ោងណម្លេះ លោកប្រុស ។

លោកវណ្ណៈដើរឡើងលើឡៅសំដៅបន្ទប់របស់លោក សម្ដែងកិរិយាទំនងហាក់ដូចជាអស់កម្លាំង ។ នាងយ៉ាលួចខ្សិបពូតឿ ៖

- ប្រហែលជាលោកធ្វើការច្រើនទេដឹង បានជាទឹកមុខដូចជា... ?
- គឺមកពីមានចោរចូលប្លន់ហាងទូរស័ព្ទរបស់លោកទើបលោកមានអារម្មណ៍ចង្អៀតចង្អល់បន្តិច..!
- អូហ៍ ស្លាប់ហើយ! ខាតបង់ច្រើនទេ ពូតឿ ?
- អស់ប្រហែលបួនប្រាំពាន់ដុល្លារ ប៉ុន្តែ ប៉ូលីសចាប់បានក្រុមស្ទាវ នោះបានបីនាក់មកវិញ រត់រួចបីនាក់ ហើយសើរើយកលុយមកវិញ បានជាង៨០០ដុល្លារដែរ ។
- សំណាងហើយ ដែលលោកមិនគ្រោះថ្នាក់ ។
- អូហ៍ លោកមិនគ្រោះថ្នាក់ទេ ព្រោះលោកនៅធ្វើការឯហាងលក់ កុំព្យូទ័រឯណោះ ។ ប៉ុន្តែ សាច់ញាតិរបស់លោកដែលធ្វើការប្រចាំ ហាងទូរសព្ទ័នោះ ត្រូវក្មេងស្ទាវវាយពកមុខឡើងខៀវទាំងអស់គ្នា
- អញ្ចឹង យើងត្រូវធ្វើយ៉ាងម៉េចទៅ ដើម្បីជួយសម្រាលអារម្មណ៍ របស់លោកដែលកំពុងហ្មួហ្មងនេះ ?
- លោកជាមនុស្សស្ងៀមស្ងាត់បែបនេះ ពិបាកនឹងដឹងចិត្តណាស់ ។ កាលពីដើម យើងធ្វើអ្វីតាមតែលោកស្រីកន្និដ្ឋាបង្គាប់បញ្ជា ។ ដល់ អស់ពីលោកស្រីទៅ យើងក៏ធ្វើតាមតែបាន... ខុសខ្លះត្រូវខ្លះតែ អញ្ចឹងទៅ ។

នាងយ៉ាសម្លឹងទៅខាងលើផ្ទះ នឹកពិភាល់ថាតើ ទាំងអស់គ្នានៅ ក្នុងផ្ទះ គួរធ្វើយ៉ាងណាដើម្បីជួយម្ចាស់ផ្ទះអោយធូរស្រាលសម្ពាធ ធុញថប់ក្នុងដើមទ្រូង ។ បន្តិចមក នាងក៏គេចខ្លួនទៅរកយាយ រៀមឯបន្ទប់គាត់ ។

CHANBOKEO.COM

ចំណែកឯលោកវណ្ណៈវិញ...

ពេលដែលលោកឡើងមកដល់លើឡើង ស្រាប់តែមានអារម្មណ៍ ថា អ្វីៗទីនោះដូចជាមានការរៀបចំផ្លាស់ប្តូរ ប្លែកខុសធម្មតា ។ លោកបែរមើលជុំវិញខ្លួនមួយស្របក់ ក៏បើកទ្វារដើរចូលបន្ទប់ផ្ទាល់ ខ្លួនរបស់លោក ស្រាប់តែភ្ញាក់ក្រញាងម្តងទៀត ព្រោះអ្វីៗទីនោះ មានការតុបតែងខុសធម្មតា យ៉ាងប្លែក បែបណាមិនដឹង ។ លោក ជ្រួញចិញ្ចើម មិនដឹងថា ត្រូវសប្បាយរីករាយនឹងការផ្លាស់ប្តូរនោះ ឬក៏មួម៉ៅនោះទេ ព្រោះអ្វីៗទុកដាក់ខុសកន្លែង ខុសទម្លាប់ និង ការចំណាំរបស់លោក ។ ពេលនោះ ពូតឿលើកថាសទឹកត្រជាក់មក ដល់ ។

- ពូតឿ! សូមពូទៅហៅនាងយ៉ាអោយខ្ញុំម៉ាភ្លែត ។
- បាទ លោកប្រុស!

លោកវណ្ណៈទាញកៅអីមកក្រេប ស្រាប់តែដាក់ភ្នែកទៅមុខ កញ្ចក់ទូដែលលោកស្រីកន្និដ្ឋាភរិយារបស់លោកធ្លាប់អង្គុយតុបតែង ខ្លួន ក៏ប្រទះឃើញផ្កាអ័រគីដេពណ៌សចំនួន១ទងដាក់ក្នុងថូយ៉ាងស្អាត មួយ ព្រមទាំងមានភ្ជាប់កាតជូនពរមួយមកផង ។ លោកក៏ទាញ យកមកលាតអានយ៉ាងរហ័ស ៖

- ផ្កាអ័រគីដេរបស់យើងកំពុងលាស់ទងផ្កាថ្មីយ៉ាងស្រស់ស្អាត ទើប កូនៗនាំគ្នាកាត់យកមកជូនលោកប៉ា ជាការថ្លែងអំណរគុណដែល លោកប៉ាបានបង្កើតបរិយាកាស អោយកូនបានសប្បាយរីករាយជា ក្រុមគ្រួសារ យ៉ាងរមនាសាជាថ្មី និងជាការសូមទោសដែលកូនៗ បានធ្វើអោយលោកប៉ាធ្លាក់ទឹកប្រឡាក់ភក់កណ្តាលចំណោម កាលពី ម្សិលមិញនេះ ។ សង្ឃឹមថា ផ្កានេះនឹងនាំភាពញញឹមដល់ដួងចិត្ត របស់លោកប៉ាដែលកំពុងកណ្តោចកណ្តែង ដោយការបាត់បង់រូប ម៉ាក់ទៅ... ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ កូនៗសង្ឃឹមថា បេះដូង លោកប៉ានឹងបានជួបភាពរីករាយ ដោយសារសោភ័ណផ្កា១ដើមនេះ មិនខាន ព្រោះកូនៗស្រឡាញ់លោកប៉ាណាស់ ចង់ឃើញលោកប៉ា ញញឹមរាល់ថ្ងៃ ហើយកូនក៏សូមរង់ចាំទទួលភាពញញឹមលើផ្ទៃមុខ របស់លោកប៉ាចំពោះកូនជានិច្ចរៀងរាល់ថ្ងៃវិញដែរ ។ ពីកូននី កូន នេត្រ និងកូនវណ្ណា !

ភ្លាមនោះ លោកវណ្ណៈក៏ឧទានខ្សិបៗឡើង លាយនឹងភាព ញញឹមលើផ្ទៃមុខរបស់លោកផង ៖

- អរគុណណាស់កូន ដែលគិតមកដល់ប៉ាយ៉ាងធំធេង!

តុក! តុក! តុក! ស្នូរគោះទ្វារលាន់ឡើង ។

CHANBOKEO.COM

- នាងយ៉ាមែនទេ ?

- ចាស លោកប្រុស !

- ចូលមក៏ !

នាងយ៉ាបើកទ្វារចូលមក ។

- នាងជាអ្នករៀបចំផ្លាស់ប្តូរបន្ទប់របស់ខ្ញុំនេះ មែនទេ ?

- គឺ... មិនមែនទេ លោកប្រុស... គឺ... កូនប្រុសស្រីរបស់លោក ប្រុសទេតើហ៏ ។

- មិនយល់សោះ ថាហេតុអ្វីគេចង់មកផ្លាស់ប្តូរដូច្នេះ ព្រោះកាល ដើមឡើយ គេមិនដែលរវីរវល់នឹងបន្ទប់ផ្ទាល់ខ្លួនរបស់ខ្ញុំផង ។

- ប្រហែលជាពួកគេចង់អោយលោកឪពុកផ្លាស់ប្តូរអារម្មណ៍ កុំឲ្យ សោកសៅពេកទេដឹង ចាស ?

- កិរិយារបស់ខ្ញុំបានបង្ហាញកូនរបស់ខ្ញុំបែបហ្នឹង មែនទេ ?

- អ្នកក្រៅប្រហែលមើលមិនដឹងទេ ប៉ុន្តែ ជាកូនដែលរស់នៅ ជា មួយលោករាល់ថ្ងៃ ប្រហែលស្តាប់ភាសាកិរិយារបស់លោកបានគ្រប់ ពេលវេលា ។

លោកវណ្ណៈនៅស្ងៀមទំនងគិត បន្តិចមក ក៏សម្លឹងទៅថូផ្កា អ័រគីដេ រួចសួរបន្តទៀតថា ៖

- ម៉េចបាននាងដឹងថា ខ្ញុំចូលចិត្តផ្កាអ័រគីដេ ?

- នាងខ្ញុំមិនដឹងទេ លោកប្រុស ! គឺកូនប្រុសស្រីរបស់លោកទាំង បីនាក់ជាអ្នកកាត់ផ្កានេះដាក់ចូជូនលោកប្រុសទាំងអស់ ។

លើកនេះ លោកវណ្ណៈជ្រួញចិញ្ចើមជាងមុន នឹកពិភាល់ថាហេតុ អ្វីក៏កូនចៅរបស់លោក មានគំនិតចាស់ទុំខុសទម្លាប់ធម្មតារបស់គេ សូម្បីតែភាសានៅក្នុងកាតជូនពរមួយសន្លឹកនោះ ក៏តចឹងដែរ គឺ ដូចជាមិនសមជាភាសាដែលកូនរបស់លោកសរសេរ ដោយខ្លួនឯង ទេ ។ ពេលនេះ លោកហាក់ដូចជាចាប់ភ្លឹកថា នាងយ៉ាហាក់ដូចជា មានការចេះដឹងទាន់សម័យណាស់ ។

ភ្លាមនោះ លោកវណ្ណៈមានប្រសាសន៍ថា ៖

- នាងទៅវិញចុះ ។ ស្អែកមិនបាច់មករៀបចំបន្ទប់អោយខ្ញុំទេណា៎ ទុកអោយកូនចៅរបស់ខ្ញុំរៀបចុះ ។ ពេលនេះ ខ្ញុំសប្បាយចិត្ត ហើយ ព្រោះកូនចៅរបស់ខ្ញុំចេះធ្វើការផ្ទះខ្លះៗដោយខ្លួនឯងដោយ គ្មានគេណែនាំ ។

នាងយ៉ាក៏ថយខ្លួនចេញទៅវិញ ។ លោកវណ្ណៈសម្លឹងតាមនាង ដោយមិនព្រិចភ្នែក ហាក់ដូចជាកំពុងពិចារណារឿងអ្វីក្នុងចិត្ត ។ បន្តិចមក លោកក៏ដើរចេញមកក្រៅបន្ទប់ ឃើញភ្លើងភ្លឺៗចាំង ចេញតាមក្រោមទ្វារបន្ទប់របស់វណ្ណនី ។

CHANBOKEO.COM

- នីកូន!
- ចាស!
- គេងហើយឬនៅ ហ្នឹង?
- ចាសនៅទេ លោកប៉ា!

វណ្ណនីក៏ស្ទុះមកបើកទ្វារអោយឪពុករបស់នាង ។ លោកវណ្ណៈ ក៏ដើរចូលទៅ ។ លុះដាក់ខ្លួនអង្គុយចុះស្រួលបួលហើយ លោកក៏ មានប្រសាសន៍ទៅកូនស្រីថា ៖

- អរគុណណាស់ កូននី ដែលសរសេរសំបុត្រយ៉ាងពិរោះមកប៉ា ព្រមទាំងផ្កាយ៉ាងស្រស់ស្អាត ជាពិសេស គឺការតុបតែងបន្ទប់យ៉ាង ប្លែកៗនោះផង ។

វណ្ណនីញញឹម កាលបើបានឮឪពុកសរសើរ ៖

- លោកប៉ាពេញចិត្តទេ?
- ពេញចិត្តណាស់កូន! ហើយកូនប៉ាទៅរៀនពីណាមក ទើបចេះ ឆ្លៀវឆ្លាតយ៉ាងនេះ?
- មានទៅរៀនពីណា? គឺ បងយ៉ាហ្នឹងណា៎ ជាអ្នកណែនាំ!
- ហើយគេមានធ្វើជាមួយកូនទេ?
- ចាស! គាត់ធ្វើជាមួយពួកយើង ទាំងអស់គ្នា ប៉ុន្តែភាគច្រើន គាត់បណ្ដោយអោយពួកយើងសាករៀនធ្វើដោយខ្លួនឯងសិន បើ ទៅមិនរួចទើបគាត់ជួយថែមទៀត ។
- ស្រាប់តែកូនប៉ាក៏ធ្វើបានយ៉ាងល្អតែម្ដង ។
- មានគ្រូល្អ កូនសិស្សល្អដូច្នេះឯង ចាស!
- អញ្ចឹង សូមអោយកូនរៀនពីបងយ៉ាអោយច្រើនៗ ហើយបង្ហាញ ស្នាដៃអោយប៉ាឃើញបន្ថែមទៀតណា៎ ។
- ចាស លោកប៉ា!
- អញ្ចឹង ប៉ាទៅវិញហើយ ។ កូនគេងវិញចុះ ។

លោកវណ្ណៈបោះជំហានចេញពីបន្ទប់របស់កូនស្រី ។

- លោកប៉ា! (វណ្ណនីហៅឪពុក)
- យ៉ាងម៉េចកូន?
- ស្អែក! លោកប៉ាមកពិសារបាយល្ងាចជាមួយកូនៗណា៎... កូនសុំ អោយលោកប៉ាភ្លក្សស្នាដៃដំបូងរបស់កូននី ។

- មែនហ្អ៎ស កូន ?
- ចា៎ស !
- អញ្ចឹង ប៉ានឹងត្រឡប់មកផ្ទះអោយទាន់ពេល ។
- អរគុណលោកប៉ា ។

រាត្រីនោះ វណ្ណនីរីករាយក្នុងចិត្តណាស់ ដែលលោកប៉ារបស់ នាងញញឹម ហើយសរសើរលើកទឹកចិត្តនាង ។ ធិតាតូចបានធ្មេចភ្នែកនិន្ទ្រាទៅទាំងដួងចិត្តរំភើបរីករាយជាលើកដំបូង តាំងពីច្រើន ខែមកហើយ ។

នៅក្នុងបន្ទប់ដំណេក...

លោកវណ្ណៈដាក់ខ្លួនលើខ្នើយដែលផ្ទែកនឹងក្បាលគ្រែ អោបដៃ សម្លឹងទៅផ្កាអ័រគីដេទាំង៦ទង គិតក្នុងចិត្តតែម្នាក់ឯង ថា ៖

- ហេតុអ្វីបានជានាងយ៉ាដ៏សាមញ្ញម្នាក់ បែរជាមានគុណសម្បត្តិ ប្រសើរ មិនខុសពីអ្នកមានត្រកូលល្អខ្ពង់ខ្ពស់ ?

បន្តិចមក លោកក៏ដើបទៅអង្គុយពីមុខកញ្ចក់ សម្លឹងផ្កាអ័រគីដេ សាជាថ្មី ៖

- អ័រគីដេ៦ទង ជាចំនួនផ្កាដែលអ្នកនិន្ទ្រាតែងតែកាត់យកមកតុប តែងបន្ទប់ផ្ទាល់ខ្លួនរបស់យើងពីរនាក់ ហើយកូនៗក៏មិនដែលឃើញ ចូលមកទីនេះចំណាំទម្លាប់អ្វីផ្ទាល់ខ្លួនរបស់យើងនិងភរិយាយើង ដែរ ហេតុអ្វីក៏ចៃដន្យម្ល៉េះ ? ឬក៏ជារឿងចៃដន្យពិតមែន ?

បន្តិចមក លោកវណ្ណៈក៏វិលចូលទៅក្នុងដំណេកវិញ រួចហើយ ក៏ទាញកាតដែលកូនប្រុសស្រីសរសេរជូនពរ អានហើយអានទៀត រហូតលង់លក់ក្នុងដំណេកទៅ ។

ព្រឹកស្អែកឡើង...

លោកវណ្ណៈស្លៀកពាក់ចុះមកដល់ក្រោម ឃើញនាងយ៉ាកំពុង រៀបចានអាហារលើតុ ។

- នាងធ្វើអាហារដោយខ្លួនឯងហ្អ៎ស ព្រឹកនេះ ?

នាងយ៉ាភ្ញាក់ព្រើត បែរឃើញលោកវណ្ណៈ ក៏ឆ្លើយថា ៖

- ចា៎ស អត់ទេ លោកប្រុស ! គីយាយរៀមជាអ្នកធ្វើ ។ នាងខ្ញុំគ្រាន់តែជួយជាដៃជើងបន្តិចបន្តួចប៉ុណ្ណោះ ។

លោកវណ្ណៈដាក់ខ្លួនអង្គុយចុះ ក្នុងទឹកមុខញញឹមខុសធម្មតា រួច ហើយស្រដីថា ៖

CHANBOKEO.COM

- អរគុណណាស់ នាងយ៉ា ដែលជួយណែនាំកូនប្រុសស្រីរបស់ខ្ញុំឲ្យ
គេចេះយកចិត្តយកថ្លើមឪពុករបស់គេ ។
នាងយ៉ាញញឹម ហើយតបថា ៖
- ការពិត នាងខ្ញុំមិនបានជួយណែនាំអ្វីទេ ពួកគេឈ្លាសវៃស្រាប់ ទៅហើយ ។
- ប៉ុន្តែ បើសិនណាគេគ្មានមនុស្សចាស់ជួយណែនាំខ្លះទេ ប្រហែល
ជាគេមិនអាចគិតឃើញវែងឆ្ងាយអ្វីដល់ម្លឹងទេ ។
នាងយ៉ាឈ្ងោកមុខនៅស្ងៀម ។ លោកវណ្ណៈងើបសម្លឹងមុខ មាណវី ហើយស្រដីទៀតថា ៖
- ហើយល្ងាចនេះ នៅមានអ្វីធ្វើអោយខ្ញុំភ្ញាក់ផ្អើលទៀតទេ នាង ?
នាងយ៉ាភ្ញាក់ព្រើតឆ្លើយថា ៖
- ចា៎ស! គ្មានទេ លោកប្រុស! បើសិនជាមានវិញ ប្រាកដជាអ្វី
ដែលកូនប្រុសកូនស្រីរបស់លោកប្រុស ធ្វើអ្វីដើម្បីអោយលោក ប្រុសសប្បាយចិត្តហើយ ។
- រួចហើយ... តើមេគំនិតវិញនោះ នៅតែជានាងទៀតដែរទេ ?
នាងយ៉ាធ្វើមុខញឹមៗ មិនឆ្លើយទេ បែរជាសួរបន្លប់ទៅលោក វិញថា ៖
- លោកប្រុសពិសារបបរ ឬក៏កាហ្វេទឹកដោះគោ នំបុ័ង ?
- ថ្ងៃនេះ ខ្ញុំមានអារម្មណ៍ល្អណាស់ សុំបរិភោគបបរចុះ ។
- ចា៎ស លោកប្រុស ។
លោកវណ្ណៈញញឹមយ៉ាងបំព្រងដាក់នាងយ៉ា ។
បន្តិចមក លោកវណ្ណៈក៏អោយពូតឿបររថយន្តនាំលោកចេញ ទៅធ្វើការ ។
ចំណែកនាងយ៉ាក៏ស្ទុះឡើងទៅលើឡៅជួយរៀបចំ ក្មេងៗទៅសាលារៀន ទើបដើរមកក្រៅផ្ទះ
បំរុងថានឹងទៅរកម៉ូតូ ឌុបជិះ ស្រាប់តែ ជួបនឹងមេសាដែលទើបជិះម៉ូតូមកដល់ ៖
- បងមេសា ? មិនធ្វើការទេហ៎ បានជាមកដល់ទីនេះ ?
- បងសុំច្បាប់គេឈប់មួយថ្ងៃ ដើរដាក់ការងារថ្មីធ្វើវិញ ។ ហើយ
ចុះអាយ៉ាឯងបំរុងទៅណាដែរ ?
- គឺទៅផ្សារទិញម្ហូបតើហ៎បង!
- អញ្ចឹង ឡើងម៉ូតូមក បងជូនទៅ ។
នាងយ៉ាស្ទុះឡើងទៅពីក្រោយភ្លាម ។
តាមផ្លូវ...

CHANBOKEO.COM

- បងទៅលេងស្រុក នៅថ្ងៃស្អែក អាយ៉ាងឯងចង់ផ្ញើអីទៅផ្ទះទេ ?
- មែនឬបង ? អញ្ចឹងបងចូលទៅហាងលក់ថ្នាំពេទ្យបន្តិចទៅ ខ្ញុំ ចង់ទិញថ្នាំផ្ញើម៉ែខ្លះ ។

មេសាក៏បត់ចង្កូតម៉ូតូទៅរកទិញថ្នាំពេទ្យ ថៃដន្យស្រាប់តែមាន ម៉ូតូមួយហោះរឹងមកពីខាងណាមិនដឹង មកបុកម៉ូតូមេសា ធ្វើអោយ អ្នកទាំងពីរដួលគ្រាំងទៅលើថិញ្ជើមថ្នល់ទាំងពីរនាក់ ។ ឯម៉ូតូវិញក៏ ដួលបោកទៅលើគួរថយន្តមួយ ។ ចំណែកបុរសម្ចាស់ម៉ូតូមួយទៀត ក៏ជ្រុលច្រឡោតគោត ទៅបុកគល់ឈើមួយមិនឆ្ងាយពីនោះប៉ុន្មាន រួចហើយក៏ដួលធ្លាក់ដេកដី បាត់មាត់ឈឹងតែម្តង ។

មេសាស្ទុះដើបឡើងទៅរកជួយនាងយ៉ា ៖
- ប្អូនមិនអីទេ ហ្ស៊ៃសុ យ៉ា ?
- ចា៎ស គ្រាន់តែរលាត់កែងដៃទេបង ។

មេសាក៏ ទាញទូរសព្ទ័ហៅប៉ូលីស ។ រំពេចនោះ បុរសម្ចាស់ រថយន្តក៏ស្ទុះចេញមកមើល ។
- សូមទោសលោក ដែលម៉ូតូខ្ញុំខ្ទាតចំឡានរបស់លោក ប៉ុន្តែមិន មែនជាកំហុសរបស់ខ្ញុំទេ ។ ការពិត គឺអ្នកដែលដេកដួលខាងនោះ ជិះមកបុក ទំនងប្រហែលជាស្រវឹងហើយ ។
- មិនអីទេ! ទុកអោយប៉ូលីសគេវាស់វែងចុះ ។

បុរសនោះនិយាយផង ដាក់ភ្នែកមើលទៅនាងយ៉ាផង ស្រាប់ តែបើកភ្នែកធំៗ ឧទានថា ៖
- អូនយ៉ា ?

នាងយ៉ាក្រឡេកឃើញបុរសនោះភ្លាម ក៏ធ្វើភ្នែកមូលក្រឡង់ដូច គ្នា ទំនងដូចជាភ្ញាក់ផ្អើលចំពោះវត្តមានបុរសម្ចាស់ឡាន ។ ប៉ុន្តែ នាងបែរជារៀបឬកពាធ្វើនឹងធឹងធម្មតាវិញ ហាក់ដូចជាមិនដែល ស្គាល់គ្នា ។ បុរសនោះក៏ដើរទៅជិតនាង ហើយវាចាថា ៖
- សុខសប្បាយជាទេ យ៉ា ?

នាងយ៉ានៅស្ងៀមមិនឆ្លើយ ។ បុរសនោះក៏ស្រដីបន្តទៀត ៖
- បងបានជួបម្តាយអូន ។ គាត់ប្រាប់ថា អូនបានមកធ្វើការនៅ ភ្នំពេញនេះហើយ ។

មេសាឃើញបុរសនោះស្រដីជាមួយនាងយ៉ា ក៏សួរ ៖
- អ្នកទាំងពីរធ្លាប់ស្គាល់គ្នាដែរ ?
- បាទ! គឺ... ស្គាល់យូរហើយ ។

CHANBOKEO.COM

ថៃដន្យ នាងយ៉ាបែរជាជ្រួញចិញ្ចើម ធ្វើមុខស្រងាកចិត្ត ហើយ បែរទៅមេសា ស្រដីប្រាប់ថា ៖

- បងមេសា! អោយយ៉ាសុំទៅមុន បានទេបង?
- អូនអាចទៅម្នាក់ឯងបានដែរឬ អាយ៉ា?
- ចាស! បងនៅកត់ហេតុជាមួយប៉ូលីសសិនចុះ ។ ខ្ញុំមិនចង់នៅ ទីនេះទេ ដូចជាធុញថប់ណាស់ ។ ខ្ញុំជំរាបលាសិនហើយបង!

ថាហើយ មាណវីដើរចេញទៅរកម៉ូតូឌុបយ៉ាងលឿន ស្រាប់តែបុរសម្នាក់នោះហក់រឹងរត់តាមពីក្រោយ ។

- យ៉ា! ឈប់សិន! អោយបងសុំនិយាយជាមួយយ៉ាពីរបីម៉ាត់បាន ទេ អូន?

ប៉ុន្តែ នាងយ៉ាដើរធ្វើមិនឮ ស្រាប់តែ...

ទីន! ទីន! ទីន! នាងយ៉ាបែរមើល ឃើញរថយន្តមួយបរមកឈប់ដ៏ក្បែរដងវិថីដែលនាងកំពុងដើរ ។

- លោកប្រុស?
- មែនហើយ! ហេតុអ្វីនាងមកដល់ទីនេះទៅវិញ នាងយ៉ា?

នោះគឺរថយន្តលោកវណ្ណៈ ដែលមានពូតឿជាអ្នកបរ ។

- គឺខ្ញុំមករកទិញថ្នាំផ្ញើម៉ែ ទទួលមានគ្រោះថ្នាក់ម៉ូតូ ។
- អូហ៍! ហើយចុះ នាងមិនអីទេ?
- ចាស ត្រូវរបួសតិចតួចទេ លោកប្រុស ។

រំពេចនោះ លោកវណ្ណៈក៏បែរស្រដីទៅបុរសម្នាក់នោះថា ៖

- សុខសប្បាយទេហ៍ ឆាយា? ក្មួយស្គាល់នាងយ៉ាដែរ?

ឆាយាលើកដៃផ្គុំសំពះ ៖

- ជំរាបសួរលោកពូ!

ពេលនោះ ប៉ូលីសផ្ទុកញ្ជែច្រចៗ បក់ដៃជាសញ្ញាហៅឆាយាអោយត្រឡប់ទៅកន្លែងកើតហេតុវិញ ។ គេក៏សំពះលាលោកវណ្ណៈ ហើយក៏អាក់ខានមិនបានសន្ទនាជាមួយនាងយ៉ាដែរ ។

- ឡើងឡានមកនាង!

នាងយ៉ាភ្ញាក់ព្រើត ដែលលោកវណ្ណៈហៅជិះឡានជាមួយ ។

CHANBOKEO.COM

- ចា៎ស មិនអីទេ លោកប្រុស! ខ្ញុំអាចជិះម៉ូតូឌុបទៅផ្ទះវិញបាន

- ប៉ុន្តែ នាងមានរបួសឈាមរហាម ពេញដៃពេញជើង យ៉ាងនេះ នាងមិនចង់ទៅពេទ្យទេហ៎ ?

- គឺ... គ្រាន់តែទិញថ្នាំក្រហមលាបទៅជាហើយ កុំអោយពិបាក អំពល់លោកអី! នាងខ្ញុំមិនអីទេ (នាងយ៉ាប្រកែក)

- ថាអោយ ឡើងឡានសិនមក៉ ឮហើយនៅ ?

មាណវីលែងហ៊ានប្រកែក ក៏ដើរឡើងរថយន្តទៅអង្គុយទន្ទឹម និងពូតឿ ។ មកដល់គ្លីនិកមួយ លោកវណ្ណៈក៏នាំនារីចូលពិនិត្យ របួស រួចហើយក៏នាំត្រឡប់ទៅផ្ទះ ។

- ថ្ងៃនេះ នាងជំរាបយាយរៀមទៅ ថាមិនបាច់ដាំស្លទេ ចាំខ្ញុំអោយ ពូតឿទិញអាហារយកមកបរិភោគវិញ ។

ថាហើយ លោកក៏អោយពូតឿបរនាំលោកចេញទៅ ។ នាងយ៉ា សម្លឹងមើលតាមលោកវណ្ណៈទាំងចម្លែកចិត្ត ដែលលោកប្រព្រឹត្ត កិរិយាមកលើនាង ហាក់ដូចជាញាតិម្នាក់ដែលបារម្ភចំពោះគ្នា មិន សមជាចៅហ្វាយនិងអ្នកបំរើនោះឡើយ ។

រសៀលបន្តិច លោកវណ្ណៈក៏ត្រឡប់មកវិញ ។

- ថ្ងៃនេះ លោកប្រុសឆាប់ចេញពីធ្វើការម្ល៉េះ ពូតឿ ?

មាណវីខ្សិបសួរពូតឿ ។

- មិនដឹងទេ តែពូឃើញលោកហាក់ដូចជាសប្បាយចិត្ត ហើយ ពោលថាចង់មកផ្ទះជួបកូន (ពូតឿឆ្លើយ)

នាងយ៉ាញញឹម កាលបើឮដូច្នោះ ។ មិនបានប៉ុន្មាននាទីផង កូនទាំងបីរបស់លោកវណ្ណៈមកដល់ ។ កាលបើគេឃើញវត្តមាន របស់ឪពុកនៅផ្ទះ គេភ្ញាក់ក្រញាងដោយក្តីសោមនស្ស ។ ម្នាក់ៗនាំ គ្នារត់ទៅអោបឪពុក ដែលកំពុងញញឹមដាក់គេយ៉ាងបំព្រង ។

- លោកប៉ា! ថ្ងៃនេះ ប៉ាអត់រវល់ទេហ៎ បានជាញញឹមស្រស់ ?

វណ្ណនីសួរឪពុក ។

- ក្រែងកូនៗបានសុំអោយប៉ាញញឹម ហើយអោយឆាប់មកផ្ទះ បរិភោគបាយជុំគ្នា មិនមែនទេ ?

- ចា៎សមែនហើយ!

- អញ្ចឹង ប៉ាមកហើយនេះអី ? ចុះឯណាអាហាររបស់យើង ?

វណ្ណនីញញឹមគ្រហាញដាក់ឪពុក រួចហើយស្រដីថា ៖

CHANBOKEO.COM

- ថ្ងៃនេះ កូនសប្បាយចិត្តណាស់ដែលលោកប៉ាត្រឡប់មកផ្ទះវិញ របស់ជាងរាល់ដង ហើយបានបរិភោគជុំគ្នា ។

ថាហើយ នាងតូចវណ្ណនី ក៏ស្ទុះរឹងរត់ចូលចង្ក្រានបាយ ។

- យាយ! ខ្ញុំមកជួយធ្វើម្ហូបដើម្បីរៀបជូនលោកប៉ាពិសា!

- អូហ៍ ថ្ងៃនេះមិនបានដាំស្លទេ ព្រោះនាយតឿទិញអាហារមក ។

- ម៉េចអញ្ចឹង ?

- ព្រោះនាងយ៉ាគ្រោះថ្នាក់ម៉ូតូ មិនបានទៅផ្សារទេ ។

ឮដូច្នោះ នាងវណ្ណនីក៏បែរទៅមើលនាងយ៉ា ៖

- ស្លាប់ហើយ របួសយ៉ាងម៉េចទៅហើយបង ?

- បងមិនអីទេ អ្នកនាងតូច!

- ថៃខ្លួនផងណ៎ាបង អាណិតកុំឈឺបានហើយ គ្រាន់នឹងជួយជាមេ គំនិតដល់ពួកខ្ញុំទៀត! ឃើញទេ កម្មវិធីរបស់បងមានប្រសិទ្ធិភាព ណាស់! ថ្ងៃនេះ លោកប៉ាមកផ្ទះពីថ្ងៃបរិភោគបាយជាមួយកូនៗដូច គម្រោងការដែលបងគិតទុកអញ្ចឹង ។ ខ្ញុំសប្បាយចិត្តណាស់បង! តើស្អែកយើងត្រូវធ្វើអ្វីតទៅទៀត ?

- គឺ... អ្នកនាងធ្វើអ្វីក៏បានដែរ អោយតែអាចបង្ហាញចំពោះលោក ប៉ាថា អ្នកនាងតូចស្រឡាញ់លោក ហើយនឹករលឹកលោក ត្រូវការ ចង់បានពេលវេលាជាមួយលោកជាឪពុក ឲ្យបានរមនាដូចពីដើម មកវិញ ។

- ចា៎ស! អរគុណបងយ៉ា! ចាំប្អូននឹងធ្វើតាម!

នាងយ៉ាក៏ស្រវាម្ហូបកញ្ចប់រៀបដាក់ចាន អោយវណ្ណនីជាអ្នក លើករៀបចំជូនលោកប៉ា ។

នៅក្នុងបន្ទប់ទទួលអាហារ លោកវណ្ណៈលួចដៀងកន្ទុយភ្នែក លួចសង្កេតកិរិយារបស់កូនស្រីផង កិរិយារបស់នាងយ៉ាផង ទំនង ដូចជាចង់ដឹងថា តើអ្នកទាំងពីរកំពុងគិតអ្វីនឹងគ្នា ហើយក៏លួចធ្វើ មុខញញឹមស្ញើៗតែម្នាក់ឯង ។ ពេលនេះ បរិយាកាសគ្រួសារ ដែល ធ្លាប់តែស្ងាត់ស្ងៀមយូរខែមកហើយ ក៏ប្រែជាស្រស់បំព្រងឡើង វិញយ៉ាងត្រកាល ដោយម្នាក់ៗបានបញ្ចេញភាពញញឹមមកលើផ្ទៃ មុខរៀងៗខ្លួន ចំពោះគ្នាទៅវិញទៅមក ។ រីឯអ្នកដែលទទួលនូវក្ដី រីករាយរំភើបក្នុងចិត្តច្រើនជាងគេយ៉ាងចម្លែកនោះ គឺលោកវណ្ណៈ ខ្លួនឯងនោះតែម្ដង ។

CHANBOKEO.COM

# វគ្គទី៨
# កំស្ដួលក្នុងបេះដូង

នៅខាងលើឡៀ...

លោកវណ្ណៈក៏បានជួយពិនិត្យកិច្ចការសាលារបស់កូន ព្រមទាំងបានអង្គុយជជែកសាសាងរបៀបឪពុកនឹងកូនយ៉ាងស្និទ្ធស្នាលនឹងគ្នា សាជាថ្មី ។ បន្ទាប់ពីដាក់នាងតូចវណ្ណាអោយគេងហើយ លោកក៏ដើរ ត្រឡប់មករកបន្ទប់របស់ខ្លួនវិញ ស្រាប់តែប្រទះឃើញស្រោម សំបុត្រមួយនៅលើតុធ្វើការរបស់លោក ក៏ទាញមកហែកអាន ៖

ពេលឃើញលោកប៉ាញញឹម

ឃើញភាពញញឹមលើផ្ទៃភក្ត្រា    របស់លោកប៉ាជាទីគោរព
បេះដូងកូនៗហាក់បានប្រសព្វ    មង្គលល្អគាប់ពេញដួងទ័យា ។
ពេលឃើញលោកប៉ាញញឹមរីករាយ    ចិត្តកូនសប្បាយគ្រប់ៗអង្គា
លោកប៉ាប្រៀបបានម្លប់ពុទ្ធធម្មា  ប្រោសប្រស់ជន្មាកូនឱ្យស្រស់ថ្លា ។
សូមលោកញញឹមជានិច្ចជាកាល    ផ្ដល់ភាពត្រកាលដល់ក្រុមគ្រួសារ
កូនសូមជូនពរសូមលោកសុខា    ជាម្លប់ឆាយាសុខសាន្តរៀងទៅ ។

ពីកូនដែលស្រឡាញ់លោកប៉ាបំផុតនៅលើលោកនេះ!

កូននី កូននេត្រ និងកូនពៅវណ្ណា

លោកវណ្ណៈភ្ញាក់ព្រើត នឹកក្នុងចិត្ត ៖

CHANBOKEO .COM

- កូនរបស់ប៉ា ចេះធ្វើអ្វីចម្លែកៗម្ល៉េះឥឡូវនេះ ? មានរហូតដល់ចេះសរសេរកំណាព្យពិរោះមានន័យដល់ម្លឹងផង ?

ពេលនេះ លោកវណ្ណៈកាន់តែពិភាល់មែនទែនហើយ ប៉ុន្តែលោកក៏សប្បាយចិត្តដែលបានទទួលលិខិតនោះ ព្រោះអក្សរទាំង ឡាយនៅលើកាតមួយសន្លឹកនោះ ជាអក្សររបស់កូនប្រុសស្រីទាំងបី របស់លោក ។ ភ្លាមនោះ លោកក៏លើកកាតឡើងយកមកមើប ៖

- ប៉ាក៏ស្រឡាញ់កូនទាំងអស់គ្រប់គ្នា ដឹងទេកូន ? សូមសរសេរមកប៉ាអោយបានរាល់ថ្ងៃកុំខានណា៎ ។

យប់នោះ លោកនៅមិនសុខទេ ចេះតែយកកំណាព្យមកអាន ហើយ អានទៀត ជាច្រើនសា ហើយលួចញញឹមតែម្នាក់ឯង ដោយ សេចក្តីពេញចិត្តចំពោះអត្ថរសនិងអត្ថន័យរបស់ពាក្យកាព្យ ។ ភ្លាម នោះ លោកក៏កើតមានការពិភាល់នៅក្នុងចិត្ត ។ ទ្រាំមិនបាន លោកវណ្ណៈក៏ស្ទុះដើបទៅបើកឥន្ទ្រីណិតចូលអាន ព្រោះនឹកឃើញថា ធ្លាប់ ឃើញកំណាព្យស្រដៀងៗនេះនៅត្រង់ណា ។ ការពិត លោក ធ្លាប់សរសេរកំណាព្យ ឆ្លើយឆ្លងជាមួយខេមរមិត្តទូទាំងពិភពលោក នៅក្នុងទំព័រកំណាព្យខ្មែរជាច្រើនកន្លែង នៅក្នុងវិបសៃថ៍ខ្មែរ ។ លោកក៏នឹកឃើញកំណាព្យមួយ ដែលសរសេរដាក់ផ្សាយ កាលពី ប៉ុន្មានខែមុន របស់អ្នកនិពន្ធអនាមិកម្នាក់ដែលមាននាមប៉ាកកាថា សោភ័ណដួងចិត្ត ។

ពេលឃើញអ្នកម៉ែញញឹម

ឃើញភាពញញឹមលើភក្ត្រអ្នកម៉ែ  កូនអរម្ល៉េះទេ ម៉ែទីគោរព
បេះដូងកូនៗហាក់បានប្រសព្វ  មង្គលល្អគាប់ពេញដួងទ័យា ។
ពេលឃើញអ្នកម៉ែញញឹមរីករាយ  ចិត្តកូនសប្បាយគ្រប់ៗអង្គា
អ្នកម៉ែប្រៀបបានម្លប់ពុទ្ធធម្មា  ប្រោសប្រស់ជន្មាកូនឱ្យស្រស់ថ្លា ។
សូមលោកញញឹមជានិច្ចជាកាល  ផ្តល់ភាពត្រកាលដល់ក្រុមគ្រួសារ
កូនសូមជូនពរសូមលោកសុខា  ជាម្លប់ឆាយាសុខសាន្តរៀងទៅ ។

- មែនហើយ ស្រដៀងគ្នាណាស់ ? តើកូនរបស់ខ្ញុំចម្លងកំណាព្យ នេះចេញពីឥន្ទ្រីណិត ឬក៏គេពឹងគេឲ្យសរសេរជួស ? ឬនាងយ៉ាជា អ្នកសរសេរកំណាព្យនេះ ?

CHANBOKEO.COM

តើនាងយ៉ាមានកំរិតវិជ្ជានិងការចេះដឹង ខ្ពស់ដល់ថ្នាក់នេះផងហ្ន៎ស ? បើចេះដល់ថ្នាក់នេះមែន ហេតុអ្វីក៏ សុខចិត្តមកលាក់ខ្លួនធ្វើអ្នកបំរើក្មេងនៅផ្ទះរបស់យើង ? ឬក៏មកពី ប្រាក់ខែដែលយើងអោយនោះ ខ្ពស់ជាងកំរិតប្រាក់ខែដែលនាងអាច បានទទួលតាមរយៈកំរិតវិជ្ជា ? គួរអោយឆ្ងល់ណាស់ ។

លោកវណ្ណៈអានកំណាព្យនោះពីរបីសា ទើបបិទឥន្លីណិត វិល ចូលដំណេកវិញ ប៉ុន្តែនៅសំរាន្តមិនលក់ដដែល ។ លោកក៏ងើប ឡើង ដើរចុះទៅជាន់ក្រោម ស្រាប់តែប្រទះឃើញនាងយ៉ាកំពុង អង្គុយសរសេរនៅតុក្នុងបន្ទប់បរិភោគបាយ ។

- សរសេរសំបុត្រទៅនរណា នាងយ៉ា ?

មាណវីភ្ញាក់ព្រើត ស្ទុះបិទសៀវភៅយ៉ាងប្រញាប់ ៖

- គឺសរសេរទៅផ្ទះ លោកប្រុស ! លោកប្រុសមានការអ្វីចង់ប្រើ នាងខ្ញុំដែរទេ ?
- មិនមានទេ... គ្រាន់តែអផ្សុក ចង់រកគ្នានិយាយលេង...
- ចង់អោយខ្ញុំទៅដាស់ពូតឿទេ លោកប្រុស ?
- មិនបាច់ទេ ខ្ញុំនិយាយជាមួយនាងក៏បាន បើនាងមិនទើសទាល់

នាងយ៉ា ស្ទុះឡើងក្រោកឈរសម្តែងសេចក្តីគោរព ពេល ឃើញលោកដើរចូលមក ។

- នាងចាក់ទឹកត្រជាក់អោយខ្ញុំមួយកែវ យកទៅអោយខ្ញុំនៅបន្ទប់ ទទួលភ្ញៀវផងណ៎ា ។
- ចា៎ស !

មាណវីប្រញិបប្រញាប់ ចាក់ទឹកត្រជាក់ពីទូទឹកកកជូនលោក យ៉ាងលឿន ។

- នាងនិយាយប្រាប់ខ្ញុំបន្តិចមើល អំពីក្រុមគ្រួសាររបស់នាង ?

លោកវណ្ណៈអង្គុយក្នុងសាឡុង និយាយទៅកាន់នាងយ៉ាដែល អង្គុយបត់ជើងនៅលើកំរាលឥដ្ឋក្នុងផ្ទះ សម្តែងការគោរពចំពោះ ម្ចាស់ផ្ទះ ។

- គឺនាងខ្ញុំកំព្រាម្តាយតាំងពីតូចរស់នៅជាមួយឪពុក ។ ក្រោយមក គាត់រៀបការប្រពន្ធថ្មី មានកូនពីរនាក់ទៀត រួចហើយឪពុកខ្ញុំក៏ចែក ស្ថានទៅ ទុកអោយខ្ញុំរស់នៅជាមួយម្តាយចុងរហូតមក ។
- ពិតជាកំសត់ណាស់ ! ហើយចុះម្តាយចុងរបស់នាង មានសន្តាន ចិត្តយ៉ាងណាដែរ ?
- សំណាងរបស់ខ្ញុំណាស់ ព្រោះគាត់ជាមនុស្សល្អ បានផ្តល់សេចក្តី សុខអោយខ្ញុំយ៉ាងកក់ក្តៅ មិនខុសពីកូនបង្កើតទេ ។ ថែដន្យ គាត់ មានជំងឺ ឯកូនម្នាក់ពិការ ម្នាក់ទៀតធ្វើការប្រាក់ខែតិចតួច ទប់ទល់ ការចំណាយក្នុងគ្រួសារមិនគ្រប់គ្រាន់

CHANBOKEO . COM

ទើបខ្ញុំស្ម័គ្រចិត្តចូលមកបំរើ លោកប្រុស ដើម្បីយកសោហ៊ុយផ្ញើទៅផ្ទះជួយទប់ទល់កង្វះខាតក្នុងគ្រួសារ ។

លោកវណ្ណៈសម្លឹងមុខឆវី យ៉ាងពិនិត្យពិច័យ រួចមកក៏មាន ប្រសាសន៍បន្តថា ៖

- ហើយនាងធ្វើការអ្វីដែរ មុននឹងមករស់នៅទីនេះ ?
- គឺ...ធ្វើការកំប៉ិកកំប៉ុកទេ លោកនាយ មិនសូវជាបានកម្រៃមកផ្ទះ ជួយម៉ែជួយប្អូនប៉ុន្មានទេ ។
- ហើយចុះនាងដែលប្រើឥន្លឺណិតទេ ?

ធិតាភ្ញាក់ក្រញាងកាលបើលោកវណ្ណៈសួរ ៖

- ចា៎ស! ចេះតិចតួច ពេលប្អូនប្រុសបង្គាប់ខ្ញុំ ព្រោះគេធ្វើការនៅហាងសេវាទូរសព្ទ័និងឥន្លឺណិតនោះស្រាប់ ។

ពេលនោះ លោកវណ្ណៈកំពុងតែស្រវាផ្គុំប្រស្នាដែលមាននៅក្នុងចិត្តរបស់លោកអំពីជីវប្រវត្តិពិតរបស់នាងយ៉ា ។

- ហើយចុះនាងមិនគិតថា ការងារជាអ្នកបំរើគេ វាអាប់អោនទេ ?
- ចា៎ស អត់ទេ លោកប្រុស! ថ្វីបើឈ្មោះជាអ្នកបំរើពិតមែន តែ នាងខ្ញុំគិតថាវាជាការងារសុចរិត ធ្វើដោយកម្លាំងរបស់ខ្លួនឯង មិនមានកេងប្រវ័ញ្ចនរណា ម្ល៉ោះហើយគ្មានអ្វីគួរឲ្យអាប់ឱនទេ ។ អ្នកដែលអាប់អោននោះគឺជាអ្នកដែលមាក់ងាយអ្នកបំរើនោះទៅ វិញទេតើ ព្រោះគេភ្លេចគិតថាខ្លួនគេបានរស់ស្រណុកស្រួលខ្លួនក្នុង ផ្ទះក៏ដោយសារសេវាអ្នកបំរើនោះឯង ។ បើសិនវាស់តម្លៃមនុស្ស ត្រឹមតែកំរិតទឹកលុយថ្លៃឈ្នួល នោះអ្នកបំរើពិតជាអាប់អោនមែនហើយ ។ ប៉ុន្តែបើនិយាយពីការងារសុចរិត ប្រើដោយកម្លាំងរបស់ ខ្លួនមិនបំពានមិនកេងប្រវ័ញ្ចនរណា ហើយថែមទាំងជួយសម្រាល អោយម្ចាស់ផ្ទះគ្រប់គ្នាស្រួលខ្លួនស្រួលចិត្តស្រួលអារម្មណ៍ វិញនោះ ការងារជាអ្នកបំរើ គឺពិតជាមានតម្លៃវាស់មិនបានទេ ។

លោកវណ្ណៈបើកភ្នែកធំៗ ព្រោះលោកមិនដែលឮនរណាវែកញែកពីតម្លៃរបស់អ្នកបំរើអោយបានល្អដល់កម្រិតនេះឡើយ ។

- នាងជាមនុស្សមានឧត្តមគតិណាស់តើ យ៉ា!

នាងយ៉ាធ្វើមុខញឹមៗ មិនមានឆ្លើយថាម៉េចទេ ។ បន្តិចមក លោកវណ្ណៈក៏សួរទៀតថា ៖

- នាងចូលចិត្តសរសេរទេ ?
- ចា៎ស ចូលចិត្ត!

CHANBOKEO.COM

- ហើយសរសេរពីអ្វីខ្លះដែរ ?
- គឺសរសេរបទចម្រៀង និងកំណាព្យ ។
- ក្រៅពីនោះទៀត មានទេ ?
- ចាស មិនមានទេ... មានតែសរសេរសំបុត្រជូនម៉ែប៉ុណ្ណោះ ។
- ហើយនាងមានដែលសរសេរអ្វីដាក់ក្នុងឥន្ទ្រីណិតដែរទេ ?

លុះមកដល់សំនួរនេះ និតានៅស្ងៀម មិនឆ្លើយ ។ បន្តិចមក នាងក៏បែរសួរបញ្ច្រាសទៅវិញថា ៖

- លោកប្រុសមិនទាន់ងងុយសម្រាន្តទេ ? នេះយប់ជ្រៅហើយ !
- មិនទេ ព្រោះខ្ញុំសប្បាយចិត្តដែលបានជជែកជាមួយនាង ។
- នាងខ្ញុំពុំមានចំណេះវិជ្ជាអ្វីអាចនឹងជជែកជាមួយលោកប្រុស ឲ្យ បានជ្រៅជ្រះទេ បើមានខុសឆ្គង សូមលោកប្រុសខន្តីអធ្យាស្រ័យ ផង ។

ពេលនេះ លោកវណ្ណៈហាក់ដូចជាមានការចាប់អារម្មណ៍លើនារី កាន់តែខ្លាំងឡើងហើយ ។ មើលទៅសំដី ឫកពា និងអាកប្បកិរិយា របស់នាងឃើញថា មាណវីបានទទួលការអប់រំល្អប្រពៃណាស់ ថ្វីបើ នាងជាពលរដ្ឋសាមញ្ញក៏ដោយ ។ លក្ខណៈឫកពា និងសំដីសំដៅ របស់នាង មិនសមជាអ្នកបំរើរបស់គេសោះ ។

- នៅថ្ងៃសុក្រនេះ ជាថ្ងៃខួបកំណើតរបស់កូនវណ្ណនីគម្រប់១៥ឆ្នាំ នាងជួយគិតខ្ញុំផងមើល៍ ថាតើខ្ញុំគួរធ្វើអ្វីអោយកូន ដើម្បីលើកទឹក ចិត្តនាង អោយនាងសប្បាយចិត្តហើយខំរៀន ?

នាងយ៉ាភ្ញាក់ព្រើត ដែលលោកវណ្ណៈមកពិគ្រោះនាងដូច្នោះ ។

- នាងខ្ញុំជាក្មេងភូមិ មិនដែលប្រារព្ធពិធីបុណ្យខួបកំណើតម្តងណា ឡើយ... មិនអាចជូនយោបល់លោកប្រុសបានសមរម្យទេ ចាស !
- ចុះបើខ្ញុំហៅភ្ញៀវមកទីនេះ ដើម្បីអោយគេច្រៀងជូនពរ តើជា គំនិតល្អទេ ?
- ប្រហែលជាល្អទេដឹងលោកប្រុស ព្រោះជាទម្លាប់របស់អ្នកទីក្រុង ប្រហែលជាអ្នកនាងទន្ទឹងរង់ចាំបែបនេះក៏មិនដឹង ។
- អញ្ចឹង នាងជួយរៀបចំជំនួសខ្ញុំផង ខ្ញុំនឹងហៅមិត្តភក្តិនិងសាច់ ញាតិពីរបីនាក់មកលេង ។

រាត្រីនោះ លោកវណ្ណៈហាក់ដូចជាមានអារម្មណ៍រំភើបក្នុងចិត្ត ខុសធម្មតា មិនដឹងថាមកពីហេតុអ្វីទេ ។ លោកសំរាន្តរសាប់រសល់ មួយយប់ទល់ភ្លឺ ។

ច្រើនថ្ងៃកន្លងទៅ...

CHANBOKEO.COM

ភាពរីករាយនិងភាពមនោរម្យក្នុងគ្រួសារ ហាក់ដូចជាប៉ិចពន្លក មានជីវិតឡើងវិញយ៉ាងត្រកាល ។ ប៉ុន្មានថ្ងៃនេះ លោកវណ្ណៈនិងកូនបានញញឹមដាក់គ្នាជាញឹកញាប់ បាននិយាយគ្នាក៏ច្រើន មិនសូវ ស្ងៀមស្ងាត់ដូចមុនទេ ជាពិសេស ភាពស្និទ្ធស្នាលរវាងឪពុកនិង កូនក៏បានវិលមកវិញដែរ ព្រោះនៅរៀងរាល់ថ្ងៃ ពេលលោកវណ្ណៈ ត្រឡប់មកពីធ្វើការ លោកតែងតែបានទទួលកាតជូនពរមួយសន្លឹក ពីកូនទាំងបីរបស់លោក ជាកាតដែលកូនកាត់ក្រដាសសរសេរជា ពាក្យកាព្យយ៉ាងពិរោះផ្អែមល្ហែម ធ្វើឲ្យលោកវណ្ណៈរីកថ្លើមប្រមាត់ ណាស់ ។

រៀងរាល់រាត្រីមុននឹងចូលដំណេក លោកវណ្ណៈតែងតែទាញយក បណ្ណ័ជូនពររបស់កូនទាំងអស់មកអានសាជាថ្មី ដដែលជាដដែល.... មិនអស់មិនហើយ... ហើយអង្គុយអង្អែលកំណាព្យនោះបន្ទើរ ទំនង ហាក់ដូចជាពេញចិត្តនឹងអត្ថរសរបស់ពាក្យពេចន៍ នៅក្នុងកំណាព្យ ទាំងឡាយនោះក្រៃលែង ។

ជាពិសេសបំផុតនោះ គឺកិរិយារបស់លោកវណ្ណៈចំពោះនាងយ៉ា ហាក់ដូចជាផ្លាស់ប្តូរបន្តិចដែរ ។ យាយរៀមនិងពូតឿលួចសង្កេត ឃើញថាលោកវណ្ណៈ ហាក់ដូចជាបញ្ចេញការចាប់អារម្មណ៍របស់ លោកមកលើនាងយ៉ា យ៉ាងពិសេស រៀងរាល់ថ្ងៃ ថ្វីបើមាណវី ហាក់ដូចជាមិនបានចាប់ភ្លឹកអ្វីក៏ដោយ ។

រសៀលថ្ងៃសុក្រ...

នាងយ៉ា យាយរៀម និងពូតឿជួយគ្នាតុបតែងផ្ទះយ៉ាងស្អាត បាត ដើម្បីទទួលភ្ញៀវដែលនឹងមកជូនពរដល់នារីតូចវណ្ណនី ។

នៅក្នុងបន្ទប់...

យាយរៀមទើបតែងូតទឹកហើយទទះម្សៅ បំរុងស្លៀកពាក់ រៀបចំខ្លួន ស្រាប់តែឮសូរគោះទ្វារ ។ យាយក៏ស្ទុះទៅបើកទ្វារ ស្រាប់តែប្រទះលោកវណ្ណៈ ធ្វើអោយយាយភ្ញាក់ព្រើតតែម្តង ៖

- មានការអ្វីដែរ លោកប្រុស ?
- នេះ៎ គឺខ្ញុំទិញខោអាវមកផ្ញើយាយនិងនាងយ៉ា សំរាប់ស្លៀកទទួលភ្ញៀវថ្ងៃនេះ ។

យាយរៀមលូកដៃទទួលយកមកបើកមើល ក៏លាន់មាត់ ៖

CHANBOKEO.COM

- យី! ចាំបាច់ស្លៀកស្អាតអ្វីដល់ម្លឹង ? ថ្ងៃនេះជាថ្ងៃពិសេសរបស់ អ្នកនាងតូចទេតើហ៎ ? មិនមែនរបស់យាយឯណា ?
- គឺស្លៀកអោយស្អាតលើករាសីចៅស្រីណ៎យាយ!
- អឺ... អញ្ចឹងក៏បាន ។
- សូមកុំភ្លេចយកមួយសំរាប់ទៀត អោយទៅនាងយ៉ាផង យាយ!
- ចា៎ស!

លោកវណ្ណៈក៏ដើរចេញទៅវិញ ។ យាយលើកសម្លៀកបំពាក់ មកសម្លឹងមើល ធ្វើមុខទំនងភ្ញាក់ផ្អើលហើយនឹកឆ្ងល់ក្រៃលែង ។

នៅខាងមុខផ្ទះ ភ្ញៀវបានមកដល់ម្តងមួយៗ ។ នាងវណ្ណនីក៏ រត់សំពះសួរទទួលគ្រប់ៗគ្នា ។ ពួកគេសុទ្ធតែជាសាច់ញាតិខាង ម្តាយរបស់នាង ឬក៏ជាអ្នកធ្វើការ នៅហាងរបស់លោកវណ្ណៈ ។ យាយរៀមសង្កេតឃើញមានភ្ញៀវប្រហែល២០នាក់ ភាគច្រើនជា ក្រុមគ្រួសារ ដែលមានកូនចៅស្រករៗគ្នានឹងកូនលោកវណ្ណៈដែរ ។ ក្រៅពីនោះមានបុរសនារីម្នាក់ឯងៗបានមកដល់រពុយៗ មានទាំង អ្នកនាងម៉ាលីណានិងភ្ញៀវបុរសសង្ហាពីរបីនាក់ទៀតផង ។

ម៉ោង៦កន្លះហើយ...

នាងយ៉ាស្លៀកសំពត់ខៀវអាវសយ៉ាងស្រគត់ស្រគំ រត់បំរើ អាហារនិងទឹកភេសជ្ជៈ ។ បន្តិចមក លោកវណ្ណៈក៏ដើរទៅជិតនាង ហើយខ្សិបសួរថា ៖
- យ៉ា! ហេតុម្តេចមិនស្លៀកសំលៀកដែលខ្ញុំទិញធ្វើអោយនាង ?

នាងយ៉ាងើបមុខញញឹមដាក់លោកវណ្ណៈហើយឆ្លើយថា ៖
- នាងខ្ញុំជាអ្នកបំរើ មិនហ៊ានស្លៀកស្រស់ឆើតឆាយ ខុសវណ្ណៈខ្លួន ទេ លោកប្រុស!
- តែនេះជាថ្ងៃបុណ្យពិសេសរបស់កូនវណ្ណនី នាងមិនចង់ស្លៀក ពាក់លើករាសីរបស់កូនវណ្ណនីទេហ្ន៎ស ?

នាងយ៉ាភ្ញាក់ព្រើត ៖
- គឺ... បើសិនសំរាប់លើកទឹកចិត្ត លើករាសីអ្នកនាងតូចមែន ចាំខ្ញុំ ទៅផ្លាស់ឥឡូវនេះ ចា៎ស!

CHANBOKEO.COM

ថាហើយ នាងក៏ប្រញាប់ប្រញាប់រត់ទៅបន្ទប់របស់នាងបាត់ទៅ ទុកអោយលោកវណ្ណៈលួចមើលពីក្រោយញញឹមតែម្នាក់ឯង ។ ឯពូតឿនិងយាយរៀមក៏លួចមើលមុខគ្នា ធ្វើកិរិយាទំនងចាប់ភ្លឹកចំពោះ កិរិយាលោកវណ្ណៈ ។

បន្តិចមក ភ្ញៀវទាំងអស់គ្នា ក៏នាំគ្នាច្រៀងបទជូនពរថ្ងៃកំណើត ជូនដល់នាងតូចវណ្ណនី ព្រមជាមួយនឹងស្នូរទះដៃលាន់ប្រាវៗយ៉ាង រីករាយ ។ បន្ទាប់មក អ្នកនាងតូចយើងក៏ឡើងប្រកាសថា ៖

- ជំរាបសួរលោកពូអ្នកមីង បងៗនិងប្អូនទាំងអស់! សូមអរគុណណាស់ដែលអញ្ជើញមកចូលរួមពិធីបុណ្យកំណើតរបស់នាងខ្ញុំនារាត្រី នេះ ។ ដើម្បីតបស្នងទៅវិញ នាងខ្ញុំសូមធ្វើស្នាដៃធ្វើនំជាលើក ដំបូងជូនលោកពូអ្នកមីង បងៗនិងប្អូនៗពិសារ ចាស!

ទាំងអស់គ្នាក៏ទះដៃប្រាវឡើង ។ លោកវណ្ណៈភ្ញាក់ព្រើតលាន់ មាត់ថា ៖

- យី! កូននីចេះធ្វើនំខ្លួនឯងផង ?

អ្នកនាងម៉ាលីណាដែលអង្គុយក្បែរលោកវណ្ណៈ ឮដូច្នោះក៏ស្រដី តបទាំងមុខញញឹមថា ៖

- ក្មេងសម័យឥឡូវគេឆ្លាតអញ្ចឹងឯង លោកដឹងទេ ?
- អ្នកនាងជាអ្នកបង្រៀនកូនវណ្ណនីអោយធ្វើនំមែនទេ ?
- ចាស អត់ទេ! ខ្ញុំគ្រាន់តែជាអ្នកដែលលើកទឹកចិត្តនាងទេតើ!

ភ្លាមនោះ លោកវណ្ណៈឃើញនាងយ៉ាដើរចេញមកស្ងាត់ៗទៅឈរនៅក្រោយតុដែលមានរៀបអាហារនិងភេសជ្ជៈ រួចហើយក៏ ចាប់លើកភេសជ្ជៈទទួលភ្ញៀវ ។ លោកចោលកន្ទុយភ្នែកលួចគយ គន់នាងឡើងភ្លន់ភ្លឹកតែម្នាក់ឯង ព្រោះរាត្រីនេះនាងយ៉ាហាក់ដូច ជាមានសោភ័ណស្រស់ស្អាតខុសធម្មតា ធ្វើអោយបេះដូងរបស់បុរសពោះម៉ាយលួចរំជើបរំជួលយ៉ាងចម្លែក ។

រំពេចនោះ ស្រាប់តែមានបុរសម្នាក់បានមកដល់មាត់ទ្វាររបង ផ្ទះរបស់លោកវណ្ណៈ ធ្វើកិរិយារេរាៗមិនហ៊ានចូល ។ លោកវណ្ណៈ ឃើញដូច្នោះក៏លើកដៃធ្វើសញ្ញាអោយពូតឿចេញទៅទទួល ។

- មានការអ្វីដែរក្មួយប្រុស (ពូតឿសួរបុរសនោះ)
- បាទពូ! ខ្ញុំឈ្មោះមេសា មកទទួលឥវ៉ាន់ពីប្អូនយ៉ា ដើម្បីផ្ញើទៅ ផ្ទះ ព្រោះខ្ញុំចេញដំណើរទៅបាត់ដំបង យប់នេះឯង ។
- អញ្ចឹងក្មួយចាំម៉ាភ្លែតណា៎!

CHANBOKEO.COM

- បាទ!

ពេលនោះ លោកវណ្ណៈចំណាំបានថា លោកធ្លាប់ឃើញមុខបុរស ក្មេងនោះនៅកៀនស្វាយកាលពីថ្ងៃមុន ឈរជជែកគ្នាជាមួយនាង យ៉ា ឆ្លងឆ្លើយពីខ្ទមស្បូវនៅមាត់ទឹក ពេលលោកកំពុងជិះទូកលេង ជាមួយកូនៗ ។ ភ្លាមនោះ លោកឃើញពូតឿដើរទៅខ្សិបនាងយ៉ា រួចហើយ ឃើញនាងយ៉ាស្ទុះយ៉ាងលឿនទៅបន្ទប់របស់នាង ។ បន្តិចក្រោយមក មាណវីកាន់កញ្ចប់មួយរត់យកមក ហុចឲ្យបុរស នោះ រួចហើយនិយាយគ្នាពីរបីម៉ាត់ ។ បន្ទាប់មកបុរសនោះក៏ឡើង ម៉ូតូចេញទៅ ។ រីនាងយ៉ាវិញ ក៏វិលត្រឡប់មកបំរើភ្ញៀវដូច ធម្មតាវិញ ។ លោកវណ្ណៈជ្រួញចិញ្ចើម ចង់ដឹងថា តើនៅក្នុងកញ្ចប់ នោះមានរបស់អ្វីខ្លះ ហើយនាងយ៉ានិងបុរសនោះ មានចំណង សម្ពន្ធ័នឹងគ្នា យ៉ាងណាដែរ ។ ភ្លាមនោះ ស្រាប់តែមានបុរសថ្មីម្នាក់ ទៀត មកដល់មាត់របងទៀតហើយ ។

- បងឆាយា!

កុមារវណ្ណនេត្រលាន់មាត់ស្រែកហៅរួចហើយក៏រត់ទៅទទួល ។

- អូននេត្រ សុខសប្បាយទេ ?

ឆាយាចូលមកធ្វើគារវកិច្ចចំពោះលោកវណ្ណៈ និងញាតិចាស់ទុំ បីបួននាក់ទៀតដែលនៅទីនោះ ។

- ជំរាបសួរលោកពូ!

- អឺ! សុខសប្បាយទេ ឆាយា ? អរគុណណាស់ដែលបានមកជូន ពរប្អូនរបស់ឯង ។

ការពិត ឆាយាជាក្មួយរបស់អ្នកស្រីកន្និដ្ឋា ត្រូវជាបងជីដូនមួយ របស់កូនចៅលោកវណ្ណៈទាំងបីនាក់ ។ ភ្លាមនោះ ឆាយាចោលភ្នែក ទៅឃើញនាងយ៉ាកំពុងឈររៀបចំថាសអាហារ ។ គេក៏ស្ទុះរឹងទៅ ជិតនាង ។

- អូនយ៉ា!

នាងយ៉ាភ្ញាក់ស្រឡាំងកាំងតែម្តងពេលឃើញវត្តមានរបស់បុរស យើង ។ ឆាយាសម្លឹងទឹកមុខរីករាយយ៉ាងចម្លែកដែលគេបានមក ប្រទះឃើញនាងនៅពេលនេះ ។

- សុខសប្បាយទេ យ៉ា ? ដឹងទេ ថាបងតាមរកអូនចង់ស្លាប់ទៅ ហើយ ?

នាងយ៉ាងើបមុខឡើង ហើយស្រដីថា ៖

- សូមទោស! នាងខ្ញុំកំពុងធ្វើការ អាចទទួលលោកត្រឹមតែជា ភ្ញៀវដូចគេដូចឯងប៉ុណ្ណោះ ។

CHANBOKEO . COM

- អញ្ចឹងពេលចប់ពិធីបុណ្យ អោយបងសុំនិយាយជាមួយអូនបន្តិច បានទេ?

- លោកទៅសុំអនុញ្ញាតលោកវណ្ណៈ ចៅហ្វាយនាយរបស់ខ្ញុំសិន ទៅ
មុននឹងមកនិយាយជាមួយខ្ញុំ ។

- ហេតុអ្វីក៏រឹងត្អឹងម្ល៉េះ យ៉ា? អនុញ្ញាតិអោយបងមានឱកាស ពន្យល់អ្វីខ្លះដល់អូនបានទេ?

- ចៃដន្យ នាងខ្ញុំមិនមានឱកាសនឹងនិយាយជាមួយជាមួយលោក ទៀតទេ
ព្រោះលោកបានបំផ្លាញវាច្រើនដងរួចហើយ សូមទោស!

នាងយ៉ាក៏លើកថាសអាហារចេញបំរើភ្ញៀវ ដើរគេចពីឆាយា រឹង
ក្នុងកិរិយាហាក់ដូចជាខឹងស្អប់នរៈយើងណាស់ ។ នៅតុមួយ ឆ្ងាយពីនោះបន្តិច
លោកវណ្ណៈអង្គុយជជែកគ្នាជាមួយញាតិសាច់ថ្លៃ របស់លោកដែលរកស៊ីជាមួយគ្នា
ប៉ុន្តែភ្នែកវិញលួចចោលទៅលើ នាងយ៉ានិងឆាយាមិនព្រិចទេ ។ ទាំងអស់គ្នាបរិភោគអាហារផង
ជជែកគ្នាផង យ៉ាងសប្បាយ ខុសអ្វីតែនាងយ៉ាទេ ដែលស្លៀកពាក់ តុបតែងខ្លួនយ៉ាងសោភា
ប៉ុន្តែទឹកមុខរបស់មាណវីបែរជាបង្កប់នូវ ភាពធុញថប់តប់ប្រមល់ពន់ពេកក្រៃ ។ យូរៗម្តង
លោកវណ្ណៈ ឃើញនាងយ៉ាបែរគេចឈ្ងោកលួចផ្តិតទឹកភ្នែកចេញពីមុខ ។ ពេល នោះ
លោកវណ្ណៈចាប់ផ្តើមមានអារម្មណ៍ ហាក់ដូចជាជ្រួលច្រាល ក្នុងចិត្តយ៉ាងចម្លែក រកថាមិនត្រូវ ។

នៅក្នុងចង្ក្រានបាយ...

នាងយ៉ាឈរទ្រោបមុខនឹងទូទឹកកក ដកដង្ហើមធំៗ ស្រាប់តែ ឆាយាដើរចូលមកដល់ ៖

- យ៉ា? អូនមិនស្រួលខ្លួនមែនទេ?

នាងយ៉ាឮសម្លេងរបស់ឆាយាភ្លាម ក៏ងើបដើរគេចទៅទ្វារម្ខាង
ស្រាប់តែឆាយាស្ទុះទៅពាំងផ្លូវភ្លាម ៖

- ហេតុអ្វីចាំគេចមុខបងផង អូនយ៉ា?

នាងយ៉ាងើបមុខឡើង សម្លឹងឆាយាមិនដាក់ភ្នែក ៖

- លោកដឹងហើយតើហ៎ ថាហេតុអ្វី?

- ប៉ុន្តែ បងបានសារភាពហើយតើហ៎!

- បើសារភាពហើយ តើលោកមានទទួលខុសត្រូវទេ?

- ឲ្យបងទទួលខុសត្រូវយ៉ាងណា បើនាងជានារីពិការបែបនោះ?
បងមិនអាចទទួលនាងធ្វើជាភរិយាបានទេ ។

- ចុះបើដឹងថា នាងជានារីពិការទៅហើយ ហេតុអ្វីក៏លោកនៅតែ ធ្វើបាបនាង?

CHANBOKEO.COM

- គឺមកពីបងស្រវឹង.. មិនដឹងខ្លួន... បងសូមទោស!!
- គួរអោយអាមាសណាស់...!! នៅហ៊ានដើរមកអោយខ្ញុំឃើញ មុខទៀត?
- យ៉ា! បងដឹងថា បងបានធ្វើខុសហើយ... អូនមិនអោយឱកាស បងកែខ្លួនទេ?
- លោកឆាយា! អ្នកដែលទទួលរងគ្រោះដោយសារលោក គឺអូន ចិន្តា មិនមែនខ្ញុំទេ។ បើចង់បានឱកាសកែខ្លួន សូមលោកទៅសុំ ទោស សុំឱកាសពីអូនចិន្តាទៅ។
- ប៉ុន្តែ នារីដែលបងស្រឡាញ់គឺអូន!
- ឈប់ទន្ទេញពាក្យនេះទៀតទៅ លោកឆាយា។ ខ្ញុំលែងចង់ស្តាប់ ពាក្យលោកយូរហើយ។

ថាហើយ នាងក៏ស្រវាទាញដៃឆាយាចេញពីមាត់ទ្វារ បំរុងដើរ ចេញទៅ ស្រាប់តែឆាយាស្រវាអោបចង្កេះនាងយ៉ាពីក្រោយជាប់។
- លែងខ្ញុំ លោកឆាយា! លែង!
- មិនលែងទេ លុះណាតែអូនឆ្លើយយល់ព្រមនឹងបងសិន!
- មិនទេ! លែងខ្ញុំ! លែង។

ថៃដន្យ ឆាយាមិនស្តាប់នាងទេ បែរជាអោបនាងរិតតែណែន ឡើង ស្រាប់តែ...
- លែងនាងយ៉ាភ្លាម ឆាយា!

ឆាយាភ្ញាក់ព្រើត កាលបើឮប្រយោគនោះ រួចហើយក៏ព្រលែង នាងយ៉ាយ៉ាងរហ័ស។ ទាំងពីរនាក់បែរក្រោយឃើញលោកវណ្ណៈ ឈរក្រពាត់ដៃ ធ្វើទឹកមុខយ៉ាងមាំ នៅមាត់ទ្វារម្ខាងទៀត។
- មានរឿងអ្វី ម៉េចមិននិយាយគ្នា? ម៉េចចាំប្រទាញប្រទង់គ្នា ដូច ជាក្មេងយ៉ាងនេះ? (លោកវណ្ណៈមានប្រសាសន៍)

នាងយ៉ាធ្វើមុខស្លេកដោយក្តីភិតភ័យ រួចក៏ស្ទុះរត់ចេញទៅ ទុក ឲ្យឆាយាឈរទីនោះម្នាក់ឯង ដើម្បីតបសំនួររបស់លោកវណ្ណៈ។
- គឺយើងមានរឿងផ្ទាល់ខ្លួនដែលត្រូវដោះស្រាយគ្នា លោកពូ!
- រឿងផ្ទាល់ខ្លួន? រឿងអ្វី?
- គឺ...គឺ... ចាំលោកពូសួរអូនយ៉ាចុះ! ខ្ញុំជំរាបលាសិនហើយបាទ!

ឆាយាលើកដៃប្រណម្យសំពះលាលោកវណ្ណៈ ហើយក៏ស្ទុះទឹង ចេញទៅយ៉ាងលឿន ធ្វើអោយលោកជឿងឆ្ងល់ធ្វើស្រឡាំងកាំង តែម្នាក់ឯង។

ម៉ោងនយប់...

CHANBOKEO.COM

នៅខាងក្រៅ ភ្ញៀវទាំងឡាយក៏នាំគ្នាត្រឡប់ចេញទៅផ្ទះវិញ ម្តងមួយៗ ។ ចំណែកក្មេងទាំងបីក៏នាំគ្នាអង្គុយប្រមុំជើង ហែក ប្រអប់ចំណងដៃអនុស្សាវរីយ៍ សើចលាន់អឺងកង ។ លោកវណ្ណៈ ដើរឡើងទៅបន្ទប់លោកទាំងចិត្តតប់ប្រមល់ចម្លែកណាស់ ។ កាល ពីព្រឹកមិញរហូតទល់ព្រលប់ រហូតដល់ពេលចាប់ផ្តើមពិធីជប់លៀង លោកហាក់ដូចជាមានអារម្មណ៍ល្អក្រៃលែង ប៉ុន្តែពេលនេះ អ្វីៗបែរ ជាអួរអាប់អស់រលីងគ្មានសល់ ។

នៅក្នុងបន្ទប់...

លោកវណ្ណៈយកដៃជូតញើសចេញពីថ្ងាស ហើយស្រដីសួរខ្លួន ឯងថា ៖

- តើយើងតប់ប្រមល់ធុញថប់រឿងអី ? ហេតុអ្វីចាំមួម៉ៅផង កាល បើកូនទាំងបីនាក់របស់យើងរីករាយសប្បាយក្អាកក្អាយ យ៉ាងអស់ពី ចិត្តទៅហើយនោះ ?

លោកសម្លឹងមុខរបស់លោកក្នុងកញ្ចក់ទូសំអាង ៖

- តើបងកំពុងនឹកអូនមែនទេ... កន្និដ្ឋា ?

រំពេចនោះ លោកក៏ទាញថតទូយកសៀវភៅរូបថតមកបើក មើល បន្តិចមក ក៏លូកស្រវាយកប្រអប់អលង្ការដែលភរិយាចំណាំ ដាក់របស់ផ្ទាល់ខ្លួន ស្រាប់តែបាត់រកមិនឃើញ ។ លោកក៏ទាញថត ទូដទៃទៀត ដើម្បីរកមើល តែក៏នៅមិនឃើញទៀត ។ ទ្រាំមិនបាន លោកក៏ដើរចេញទៅក្រៅ បំរុងទៅសួរយាយរៀមនិងនាងយ៉ា ស្រាប់តែប្រទះពូតឿនៅមាត់ជណ្តើរខាងក្រោមកំពុងជូតផ្ទះ ។

- ពូតឿ ! ទៅហៅនាងយ៉ាអោយខ្ញុំម៉ាភ្លែត !

- បាទ !

វណ្ណនី វណ្ណនេត្រ និងនាងតូចពៅកំពុងអង្គុយឆែកចំណងដៃ ក្បែរនោះ កាលបើឃើញឪពុកជ្រួញចិញ្ចើមធ្វើទឹកមុខមាំ មិន ញញឹមដូចកាលពីព្រលប់ ក៏នឹកពិភាល់ចម្លែកចិត្ត ឈប់ប្រឡែង គ្នាអស់រលីងតទៅទៀតដែរ ។

ភ្លាមនោះ នាងយ៉ាក៏ឡើងជណ្តើរមកយ៉ាងរហ័ស ក៏ប្រទះលោក វណ្ណៈឈរក្រពាត់ដៃបែរខ្នង នៅក្នុងបន្ទប់គ្រួសារខាងលើឡៅ ។

- នាងខ្ញុំមកដល់ហើយ លោកប្រុស ?

CHANBOKEO.COM

លោកវណ្ណៈបែរមុខមក ឃើញនាងយ៉ាស្ថិតនៅក្នុងសម្លៀក ដដែលមិនទាន់ផ្លាស់ប្តូរ ហើយឃើញស្នាមទឹកភ្នែកដក់នៅក្នុងរង្វង់ ភ្នែកនៅឡើយ ថ្វីបើនាងខំលើកដៃផ្ចិតយ៉ាងញាប់ ដើម្បីជូតជរះ អោយស្ងួតបែបណាក៏ដោយ ។ ភ្លាមនោះ ស្រាប់តែលោកវណ្ណៈ ក្រឡេកឃើញខ្សែដៃភ្លឺផ្លេកៗ មានបន្តោងរូបបេះដូងធ្លាក់តិងតុងៗ នៅលើដៃនាងយ៉ា ។ លោកក៏ស្ទុះទៅចាប់ដៃមាណវីកន្ត្រាក់យ៉ាង រហ័ស ហើយស្រដីសួររន្ថើន ថា ៖

- បានខ្សែដៃនេះពីណាមក នាងយ៉ា ?
- ចា៎ស! គឺ... ជាកេរ្តិ៍របស់ម៉ែខ្ញុំ ។
- កុហក!... នេះគឺជារបស់ប្រពន្ធខ្ញុំ! ទើបតែមកនៅទីនេះប៉ុន្មាន ថ្ងៃ នាងចេះមានដៃមានជើងផងហ្ន៎ស នាងយ៉ា ?

លោកវណ្ណៈខឹងច្រឡោតរលាស់នារីដួលប្រូសទៅលើកំរាល ។

- អត់ទេ! លោកប្រុស! នាងខ្ញុំមិនបានលួចទេ ។ នេះគឺជារបស់ នាងខ្ញុំពិតមែន ។
- តែផ្តាស! មាត់រឹងណាស់! យើងបានឃើញនាងខ្ចប់ប្រអប់មួយ យកទៅអោយអាក្មេងម្នាក់នោះ តើវាជាកញ្ចប់អី ? ហើយអាប្រុស នោះជានរណា ? ត្រូវជាអ្វីនឹងនាង ទើបវាហ៊ានមកទទួលរបស់ពី នាងដល់ទីនេះ ដោយមិនខ្លាចចិត្តយើងជាម្ចាស់ផ្ទះ ?
- គឺជាកញ្ចប់ថ្នាំលោកប្រុស ។ ខ្ញុំផ្ញើតាមបងមេសាទៅអោយម៉ែ!
- កុហកទាំងរស់! គឺនាងបានលួចប្រអប់អលង្ការរបស់ប្រពន្ធយើង ហើយលួចបណ្តោះចេញទៅអោយប្រុសសង្សាររបស់នាង នៅហ៊ាន ផ្គើនតបមាត់មកយើង ទាំងមុខខ្លាញ់បែបនេះដាក់យើងផងហ្ន៎ស ? នាងឡូយ គ្រាន់បើណាស់តើហ៎! ខំធ្វើកិរិយាប្រពៃអោយគេអាណិត ការពិត នាងគឺជាខ្លាលាក់ក្រចកទាំងសាច់ទាំងឈាម!
- លោកប្រុស មានប្រសាសន៍អ្វីហ្នឹង ? នាងខ្ញុំមិនយល់ទេ!
- មិនបាច់ធ្វើមុខអោយគេអាណិតទេ! ចោរមុខស្រស់ដូចជានាង មិនអាចរស់នៅផ្ទះនេះជាដាច់ខាត ចេញទៅ..! ចេញទៅ!
- លោកប្រុស! នាងខ្ញុំមិនមែនជាចោរទេ! លោកប្រុសបន្ទោស ខុសហើយ!
- កុំប្រកែក! យើងចាប់បានភស្តុតាងនៅនឹងមុខហើយ នៅហ៊ាន ប្រកែកស្អីទៀត ?

នាងយ៉ាជ្រួញចិញ្ចើមទំនងខកចិត្ត ប៉ុន្តែ ក៏មិនប្រកែកអ្វីតទៅ ទៀតដែរ ។ ឆវីក៏ដើបឡើងដើរចេញទៅ ។ ស្រាប់តែ ៖

CHANBOKEO.COM

- នាងទៅមិនទាន់បានទេ នាងយ៉ា!

នាងយ៉ាភ្ញាក់ព្រើតបែរមើលលោកវណ្ណៈ ទ្រង់ឆ្ងល់ ព្រោះលោកបណ្តេញនាងរួចហើយបែរជាឃាត់នាងទៅវិញ ។ ស្រាប់តែលោក វណ្ណៈមានប្រសាសន៍ថា ៖

- គឺ... នាងត្រូវដោះខ្សែដៃនោះអោយខ្ញុំវិញ មិននឹងចេញទៅ ព្រោះវាជាទ្រព្យរបស់ប្រពន្ធខ្ញុំ ។

នាងយ៉ាភ្ញាក់ព្រើត យកដៃលាក់ក្រោយខ្នង តបថា ៖

- អត់ទេ! នេះជាកេរ្តិ៍របស់ម៉ែ... ខ្ញុំជូនលោកមិនបានទេ ។

លោកវណ្ណៈខឹងណាស់ ដែលនាងមិនស្តាប់បង្គាប់ ក៏ស្ទុះទៅជិត ធិតាចាប់ដៃនាងកាច់ទៅក្រោយ ដោះយកខ្សែដៃនោះចេញពីកដៃ នារីទាំងកម្រោល ។ ចំណែកធិតាយើងវិញ ក៏ខំប្រវាយការពារ មិនអោយលោកវណ្ណៈដោះចេញពីដៃ ប៉ុន្តែក៏ទប់មិនឈ្នះកម្លាំង បុរសមាឌធំដូចលោកវណ្ណៈឡើយ ។ ទីបំផុត ខ្សែដៃក៏របូតចេញពីកដៃនារី ។ លោកវណ្ណៈក្តាប់ខ្សែដៃជាប់ រួចហើយក៏ច្រាននាងយ៉ាយ៉ាងអស់ទំហឹងឲ្យនាងដួលច្រឡោតតោតទៅមុខ ទប់ខ្លួនមិនជាប់ ក៏ជ្រុលរហូតដល់មាត់ជណ្តើរ ។ មាណវីក៏លូកដៃស្រវាចាប់ក្បាល ជណ្តើរដើម្បីទប់ខ្លួន តែទប់មិនទាន់ ក៏ធ្លាក់ក្រោយវឹង ។ លោកវណ្ណៈឃើញដូច្នោះក៏ភ្ញាក់ព្រើត កាលបើឃើញនាងធ្លាក់ដួល ក៏ស្ទុះទៅចាប់ដៃនាងវិញការពារមិនអោយដួលធ្លាក់តាមកាំជណ្តើរ ប៉ុន្តែ ចាប់មិនទាន់ ។ នាងយ៉ាក៏រមៀលរូច្រឡោតតោតតាមជណ្តើររហូត មកដល់មាត់ជណ្តើរខាងក្រោម ។ ពេលនោះលោកវណ្ណៈមាន អារម្មណ៍ស្តាយក្រោយណាស់ ដែលខ្លួនប្រើកម្លាំងដៃទៅលើនាងយ៉ាជ្រុលជ្រួសខ្លាំងហួសហេតុ ។ ចៃដន្យ លោកក៏កំពុងមានកំហឹងចំពោះនាងយ៉ាដែលលួចទ្រព្យផ្ទាល់ខ្លួនរបស់ភរិយាសំណព្វ ថែម ទាំងនឹកតប់ប្រមល់ នឹកខឹងនឹកសង្ស័យចំពោះចំណងសម្ពន្ធរវាង នាងយ៉ានិងឆាយារវាងនាងយ៉ានិងបុរសម្នាក់ទៀតឈ្មោះមេសា លោកវណ្ណៈបែរជាទុចដំណើរដ៏ក់មិនព្រមដើរចុះទៅមើលនាងឯ ខាងក្រោមទេ ថាមាណវីយ៉ាងម៉េចទៅហើយ ។ លោកបែរជាជ្រួញចិញ្ចើមឈរក្រពាត់ដៃបែរខ្នងធ្វើតោះតើយទៅវិញ ។

នៅឯមាត់ជណ្តើរខាងក្រោម ពូតឿភ្ញាក់ស្រឡាំងកាំងដែលគាត់ឃើញលោកវណ្ណៈធ្វើមាត់ខ្លាំងៗលាន់ឮខ្ទ័រផ្ទះ ព្រោះគាត់មិនដែលឃើញលោកវណ្ណៈខឹងអ្វីដល់ថ្នាក់ហ្នឹងទេ ។ ចំណែកកូនទាំងបីរបស់លោកដែលនៅអង្គុយក្នុងសាឡុងខាងក្រោម ក៏ភ្ញាក់ផ្អើលមិនខុស គ្នាពីពូតឿដែរ ។

គេទាំងអស់ឈរភាំងស្រឡាំងកាំងមួយស្របក់ ទើបនាំគ្នាស្ទុះឆោឡោ ទៅចាប់លើកបីនារីឡើង ដោយក្ដីភិតភ័យ តក្កមា ។ រំពេចនោះ យាយរៀមក៏លេចឆ្លោពីបន្ទប់របស់គាត់ដែរ ដោយព្រោះឮសម្លេងក្ដុងក្ដាំង ។

- បងយ៉ា! (នាងតូចវណ្ណាហៅ) បងយ៉ាងម៉េចហើយ ?

ពូតឿនិងវណ្ណានីក៏ជួយបំបែរនាងយ៉ា ដែលដួលផ្កាប់មុខទៅលើ ឥដ្ឋអោយប្រែខ្លួនឡើង ស្រាប់តែឃើញឈាមហូរពីមាត់និងច្រមុះ របស់នាង ។ រីឯខ្លួននាងវិញឡើងទន់ល្វក់ ។ ពូតឿភ័យណាស់ ក៏សួរយាយរៀម ៖

- យើងធ្វើយ៉ាងណាទៅយាយ ?

យាយរៀមងើយមើលទៅលើឡៅ ឃើញលោកវណ្ណៈក្រពាត់ដៃ ឈរបែរខ្នង មិនព្រមយកភ្នែកមើលនាងយ៉ាទេ ប៉ុន្តែក៏មិនឃើញ គេចចេញទៅណាដែរ ទំនងប្រហែលជានៅចង់ដឹងថា នាងយ៉ាសុខ ទុក្ខយ៉ាងម៉េច គ្រាន់តែមិនចង់ឲ្យគេឯងដឹងចិត្តលោកតែប៉ុណ្ណោះ ។

- លើកនាងទៅបន្ទប់សិនទៅ នាយតឿ!
- បាទ!

រំពេចនោះស្រាប់តែនាងយ៉ាកំរើកខ្លួន ហើយស្រដីខ្សាវៗថា ៖

- ខ្ញុំមិនអីទេយាយ! ពូតឿ!

មាណវីក៏ខំប្រឹងក្រោកងើបដោយខ្លួនឯងទាំងតតេះតតះ ។

- ចៅចង់ងើបទៅណា យ៉ា? (យាយរៀមសួរ) ចៅរបួសធ្ងន់ ណាស់ ចូលបន្ទប់លាបថ្នាំសិនទៅ ។

នាងយ៉ានៅស្ងៀមមិនឆ្លើយទេ ។ នាងប្រឹងលើកដៃស្ដាំរបស់ នាងទៅចាប់ដៃនាងតូចវណ្ណា ហើយសម្លឹងមុខក្មេងទាំងបីនាក់ មួយ ស្របក់ក៏ស្រដីឡើងថា ៖

- អូនទាំងអស់រក្សាខ្លួនណា៎... យើងលែងមានឱកាសជាមួយគ្នា ទៀតហើយ ។
- បងយ៉ាចង់ទៅណាហ្នឹង ? (វណ្ណនេត្រសួរ)
- បងត្រឡប់ទៅផ្ទះបងវិញហើយ ប្រុសតូច!

រួចហើយ នាងក៏លើកដៃផ្គុំសំពះលាយាយរៀមនិងពូតឿ ៖

- យាយ! ពូតឿ! ខ្ញុំជំរាបលា!

ស្រាប់តែវណ្ណនីស្ទុះឃាត់ ៖

CHANBOKEO.COM

- បងយ៉ាទៅណាមិនបានទេ! បងត្រូវទៅពេទ្យជាមួយខ្ញុំ!
- បងមិនអីទេ អ្នកនាងតូច! បងអរគុណដែលប្អូនមានទឹកចិត្ត ចំពោះបង... ថ្ងៃក្រោយមានសំណាង យើងជួបគ្នាទៀត ។

នាងយ៉ាប្រឹងឆ្មេចលេបទឹកភ្នែកនិងការឈឺចាប់ចូលទៅក្នុងពោះ រួចហើយក៏ដើបដើរទាំងតតេះតតះសំដៅបន្ទប់ ។ បន្ទាប់ពីផ្លាស់សម្លៀកដែលលោកវណ្ណ:ទិញអោយនោះហើយ ក៏ស្រវាសំពៀត ខោអាវរបស់នាងដើរចេញទៅទាំងទុរន់ទុរា ។

- នេះម៉ោងជិត១០យប់ហើយចៅ យើងជាស្រី ចេញទៅក្រៅ ពេលយប់មិនមានសុវត្ថិភាពទេណា៎ ចៅយ៉ា! (យាយរៀមឃាត់)

នាងយ៉ាបែរក្រោយ ឃើញពូតឿ យាយរៀម និងកូនទាំងបី នាក់របស់លោកវណ្ណ: បបោយដៃឃាត់គ្រប់គ្នា ប៉ុន្តែ ពាក្យជេរស្តី ប្រមាថរបស់លោកវណ្ណ: នៅលាន់ទ្រហឹងខ្លាំងៗក្នុងត្រចៀករបស់ មាណវីនៅឡើយ ។ នាងទ្រាំទៀតមិនបានទេ... ធិតាក៏បែរមុខ ចេញមកវិញហើយ ដើរទៅមុខទៀតដោយលែងរវល់ពីអារម្មណ៍ នរណាទាំងអស់...

ភ្លាមនោះ កូនទាំងបីរបស់លោកវណ្ណ: ស្រវាអោបគ្នា ធ្វើមុខស្រងូតដោយការសោកស្តាយក្នុងចិត្ត ។ យាយរៀមក៏ដើរឡើងទៅ រកលោកវណ្ណ: ដែលនៅឈរសំកុកក្នុងបន្ទប់របស់លោក ៖

- មានរឿងអ្វីទៅ លោកប្រុស បានដល់ថ្នាក់ប្រើហឹង្សាដល់ក៏រិត នេះ ? យាយស្គាល់លោកប្រុសយូរហើយ មិនដែលឃើញលោក មួម៉ៅអីដល់ថ្នាក់ហ្នឹងទេ ។

លោកវណ្ណ:បែរមករកយាយ ហើយមានប្រសាសន៍តបថា ៖

- មកពីគេមានដៃជើង លួចឥវាន់របស់អ្នកន្និដ្ឋា ទើបខ្ញុំមិន សប្បាយចិត្ត!!
- ថាម៉េច ? នាងយ៉ាមានដៃមានជើងផង ?
- បាទ! គឺលួចយកឥវាន់មាសពេជ្ររបស់ប្រពន្ធខ្ញុំ ទាំងប្រអប់បណ្តោះអោយទៅសង្សាររបស់នាង ។
- ពុទ្ធោ! ហើយនាងយ៉ាលួចប្រអប់ណាមួយទៅ លោកប្រុស ?
- គឺប្រអប់ដាក់អលង្ការពណ៌ស ដែលអ្នកន្និដ្ឋាស្រឡាញ់ជាងគេ នោះអី! មិនតែប៉ុនហ្នឹងទេ នាងយ៉ាថែមទាំងយកខ្សែដៃរបស់ ប្រពន្ធមកពាក់សំញែងអោយខ្ញុំឃើញទៀតផង ។ នេ៎ះនែ៎! យាយ ឃើញទេ នេះខ្សែដៃរបស់ប្រពន្ធខ្ញុំ ដែលនៅលើដៃនាងយ៉ា ។

CHANBOKEO.COM

- ស្លាប់ហើយ លោកប្រុស! លោកខឹងខុសមនុស្សហើយ!

យាយរៀមយកដៃរឹតដើមទ្រូង ។

- យ៉ាងម៉េចហ្នឹងយាយ ?

- គឺខ្ញុំជាអ្នកយកប្រអប់នោះចេញមក ដើម្បីយកអលង្ការបំពាក់ឲ្យ អ្នកនាងតូចពីព្រលប់ ព្រោះអីនាងជាតួឯកក្នុងពិធីបុណ្យខួបកំណើត ឥលូវនេះ នៅក្នុងបន្ទប់អ្នកនាងតូចវណ្ណនីឯណោះ ។

ថាហើយ យាយរៀមក៏ស្ទុះទៅបន្ទប់នាងតូច យកប្រអប់មួយ មកហុចអោយលោកវណ្ណៈ ។

- ប្រអប់នៅទីនេះទេ មិនមានបាត់ទៅណាទេ លោកប្រុស!

លោកវណ្ណៈភ្ញាក់ព្រើត បើកភ្នែកម្លូលក្រឡង់ដោយការភ្ញាក់ ឆ្លើលក្រៃលែង ៖

- ពិតមែនឬយាយ ?

- ចាស! ពិតមែនហើយ!

យាយរៀមក៏បើកប្រអប់ឡើង ស្រវាយកខ្សែដៃមួយចេញមក ថែមទាំងស្រដីថា ៖

- ឯខ្សែដៃដែលអ្នកស្រីចូលចិត្តពាក់ជាងគេនោះ នៅទីនេះ ដដែលតើហ៍ មិនមានបាត់ទេ ។ ចំណែកខ្សែដៃដែលនៅក្នុងដៃ របស់លោក ជារបស់នាងយ៉ាពិតប្រាកដណាស់ ។

ពេលនេះ លោកវណ្ណៈមានអារម្មណ៍ហាក់ដូចជាកំពុងធ្លាក់ពីចុង ឈើអុកគូចទល់ផ្អកយ៉ាងណែនន្ទល់ក្នុងខ្លួនតែម្តង ។

- គឺខ្ញុំ... យល់ច្រឡំលើនាងយ៉ា ? (លោកវណ្ណៈសួរទាំងភ្ញាក់)

លោកវណ្ណៈមិនអស់ចិត្ត ក៏ស្រវាចាប់ខ្សែដៃពីយាយរៀមយក មកផ្ទៀងផ្ទាត់មើល ឃើញថា ក្បាច់រចនាដូចគ្នាណាស់ ខុសតែត្រង់ថា ខ្សែដៃរបស់អ្នកស្រីកន្និដ្ឋាមានដាំកូនពេជ្រល្អិតៗ បំភ្លឺជាច្រើនគ្រាប់ ហើយមានបន្តោងណិកណក់ជាផ្លែប៉ោមមួយគូមិនមែនជារូបបេះដូង តែមួយគ្រាប់នោះទេ ។ ម្យ៉ាងទៀត ទម្ងន់មាសក៏ធំតូច ខុសប្លែកគ្នា ដែរ ព្រោះរបស់នាងយ៉ាស្តើងហើយស្រាលជាង ។

លោកវណ្ណៈស្រវាក្តាប់ខ្សែដៃទាំងពីរយ៉ាងណែនពេញដៃ ហើយ ធ្វើមុខស្លេក បបូរមាត់ញ័រទទ្រើកដោយការខ្មាស់អៀនក្នុងចិត្តដែល លោកត្រូវកំរោលចូលថ្ងៃនេះ រហូតយារដៃធ្វើបាបនារីស្លូតត្រង់ម្នាក់ អោយនាងមានរបួសទ្រោមខ្លួន ។

- យ៉ា!... (លោកវណ្ណៈលាន់មាត់ហៅមាណវីខ្សឹបៗតែក្នុងមាត់)

CHANBOKEO.COM

រំពេចនោះ លោកមានអារម្មណ៍បេះដូងរបស់លោកហួលខ្លោកៗ ឡើងយ៉ាងខ្លាំងតែម្តង ស្ទើរតែទ្រាំលែងបាន ។ លោកក៏ទម្លាក់ខ្សែ ដៃទាំងពីរទៅក្នុងហោប៉ៅអាវរបស់លោក រួចក៏រត់រឹងចុះជណ្តើរ យ៉ាងលឿនចេញទៅក្រៅ ។ យាយរៀមបែរសម្លឹងមើលតាមពី ក្រោយ ដោយការភ្ញាក់ផ្អើលក្នុងចិត្ត ។ ចំណែកពូតឿនិងក្មេងៗ ដែលនៅអង្គុយស្ងៀមស្ងាត់ក្នុងផ្ទះយូរមកហើយ កាលបើឃើញ លោកវណ្ណៈរត់ចេញទៅក្រៅយ៉ាងលឿនដូចព្យុះ ក៏នាំគ្នាស្ទុះ ស្រូស្រ ទៅតាមមើលស្ថានការណ៍ ។

ថៃដន្យសំណាងមិនល្អ លោកវណ្ណៈរត់ទៅរត់មកតាមបណ្តោយ ប្លុកផ្ទះរបស់លោក ដែលមានភ្លើងគោមពណ៌សបើកបំភ្លឺតាមមុខផ្ទះ និមួយៗ ពីរបីសាហើយ នៅតែមិនឃើញស្រមោលនាងយ៉ាបន្តិច ណាឡើយ ។ លុះអស់ចិត្តហើយ លោកក៏វិលចូលផ្ទះវិញ ទាំងទឹក មុខស្រងូតស្រងាត់ក្រៃលែង ។

នៅក្នុងបន្ទប់...

លោកវណ្ណៈក្តាប់ខ្សែដៃទាំងពីរខ្សែយ៉ាងណែន ហើយបន់ស្រន់ ខ្សិបៗតែម្នាក់ឯងថា ៖

- យ៉ា! សូមអោយនាងមានសុវត្ថិភាព កុំអោយប្រទះគ្រោះ ថ្នាក់អ្វីទាំងអស់ ។ ពេលនេះ ខ្ញុំចង់អោយនាងត្រឡប់មកវិញណាស់ ដើម្បីអោយខ្ញុំបានសូមទោសនាងផង ណា៎ យ៉ា!!

*ooooooooooooooooooooo*

*ooooo*

*o*

CHANBOKEO.COM

# វគ្គទី៥
# វិប្បដិសារី

*ម៉ោង១១យប់ហើយ...*

*លោកវណ្ណៈដើរទៅដើរមកក្នុងបន្ទប់ យ៉ាងអន្ទះសា ព្រោះមិន ដឹងគិតយ៉ាងណា ធ្វើយ៉ាងណា ដើម្បីតាមទៅរកនាងយ៉ាឲ្យឃើញ ទាន់ចិត្តដែលបារម្ភពីនាង ។ នៅក្នុងដៃលោកវណ្ណៈក្តាប់ខ្សែដៃពីរ ខ្សែនោះជាប់មិនព្រមលែង ។ បន្តិចមក លោកក៏ស្លៀកពាក់ រួច បើកទ្វារបន្ទប់ចេញមក ស្រាប់តែប្រទះឃើញកូនទាំងបីឈររបាំង នៅមាត់ទ្វារ ៖*

*- កូន ?*

*- លោកប៉ា !*

*ទាំងអស់គ្នាស្រវាអោបឪពុកព្រមគ្នា ។ លោកវណ្ណៈស្រវាអោបកូនវិញទាំងបេះដូងញាប់ញ័រយ៉ាងចម្លែក ។*

*- អោយប៉ាសូមទោស ដែលប៉ាបានធ្វើអោយកូនភិតភ័យដោយសារ ភាពមួម៉ៅរបស់ប៉ា ។ ចាប់ពីថ្ងៃនេះតទៅ ប៉ាសន្យាថានឹងផ្តាច់ចរិត ហឹង្សារបស់ប៉ាចោលហើយ ។ ពាក្យចាស់លោកតែងប្រដៅថា ខឹង ខក ខឹងខុសខឹងខូចខាត ពិតជាត្រឹមត្រូវណាស់ ។ ហឹង្សានៅក្នុង ចិត្តប៉ា មិនបានធ្វើអោយស្ថានការណ៍ បានធូរស្រាលមកវិញឡើយ មានតែធ្វើអោយយើងក្រៀមក្រំថែមទៀតប៉ុណ្ណោះ ។*

*- កូនទាំងអស់ស្រឡាញ់លោកប៉ាណាស់ ! សូមលោកប៉ាឈប់ខឹង បងយ៉ាទៅ ។ កូនចង់អោយបងយ៉ាត្រឡប់មកវិញ ។ កូនៗអាណិត គាត់ណាស់ ។ ថ្ងៃនេះ មិនដឹងបងយ៉ាសុខទុក្ខយ៉ាងណាទៅហើយ ទេ (នាងតូចវណ្ណនីស្រដី)*

CHANBOKEO.COM

លោកវណ្ណៈឃើញកូនមានទឹកមុខហាក់ដូចជាព្រួយចំពោះលោក ផង ចំពោះនាងយ៉ាផង លោកក៏មានប្រសាសន៍បន្លប់ថា ៖

- កូនទៅគេងសិនទៅ ។ ចាំស្អែកយើងនិយាយគ្នា ថាយើងនឹង ទៅតាមរកបងយ៉ានៅឯណា ។

ទាំងបីនាក់សម្លឹងមុខឪពុក បន្តិចមក ក៏បំបែកជួរចូលដំណេក បាត់អស់ទៅ ទំនងមិនចង់អោយឪពុកគេពិបាកចិត្តថែមទៀតដោយ សារភាពសោកសៅក្នុងចិត្តរបស់ពួកគេ ។ រីឯលោកវណ្ណៈក៏ស្ទុះចុះ ទៅក្រោម ឃើញយាយរៀមនិងពូតឿអង្គុយសំកុកក្នុងចង្ក្រានបាយ ធ្វើមុខស្មឿកទាំងពីរនាក់ មិនពូនិយាយអ្វីទេ ។

- យាយ! អោយខ្ញុំសូមចូលបន្ទប់យាយបានទេ ?
- មានការអ្វីទៅលោកប្រុស ?
- គឺខ្ញុំចង់ទៅមើលអីវ៉ែអីវ៉ាន់របស់នាងយ៉ាបន្តិច ។
- ចា៎ស! អញ្ជើញ លោកប្រុស!

យាយរៀមឆ្លើយផង លួចដៀងភ្នែកសម្លឹងពូតឿផង ទំនង កំពុងប្រាប់ពូតឿថា លោកវណ្ណៈកំពុងមានចំណងជីវិតជំពាក់ជំពាន់ ជាមួយនាងយ៉ាកាន់តែធ្ងន់ធ្ងរឡើងហើយ ។

លោកវណ្ណៈបើកទ្វារចូលបន្ទប់ដែលយាយរៀមនិងនាងយ៉ាស្នាក់ នៅ ឃើញខោអាវមួយកំផ្លេដែលលោកទិញអោយមាណវី បត់ដាក់ នៅលើគ្រែរបស់នាងយ៉ាងស្អាត ។ លោកដាក់ខ្លួនអង្គុយលើគ្រែ រួចយកដៃអង្អែលខ្នើយនាងយ៉ា ហើយស្រដីខ្សិបៗថា ៖

- ឲ្យខ្ញុំសុំទោសនាងផង ព្រោះខ្ញុំមិនដឹងថាត្រូវតាមទៅរកនាងនៅ ឯណាទេ...! ពេលនេះ ខ្ញុំមានវិប្បដិសារីណាស់ យ៉ា ដែលខ្ញុំបាន យល់ច្រឡំទៅលើនាង ។ សូមអភ័យទោសអោយខ្ញុំផង! សូមឲ្យ នាងឆ្លងភាពងងឹតក្នុងរាត្រីនេះ ដោយសុខសប្បាយ!

បន្ទាប់មក លោកក៏ស្រវាអាវមួយកំផ្លេនោះអោបផ្ទាប់នឹងដើម ទ្រូងយ៉ាងណែន ៖

- បើសិនអាចធ្វើបាន ខ្ញុំនឹងអោបថែរក្សានាងអោយទទួលនូវភាព កក់ក្ដៅ មិនឲ្យនាងរបួសឈឺខ្លួនដួលដំនូច្នេះ តទៅទៀតឡើយ..! ដឹងទេយ៉ា... ថាខ្ញុំកំពុងមានវិប្បដិសារីធំធេងណាស់ ដែលខ្ញុំបានធ្វើ ជ្រុលជ្រួសទៅលើនាង ?

ពេលនោះ លោកវណ្ណៈមានអារម្មណ៍ថា បេះដូងរបស់លោក កំពុងតែកញ្ជ្រោលញាប់ញ័រយ៉ាងខ្លាំង... ស្ទើរតែធ្លាយទ្រូងមកក្រៅ ម្ដងៗទៅហើយ ។ រំពេចនោះ លោកដាក់ភ្នែកទៅលើតុ ក្បែរគ្រែ គេង ប្រទះឃើញកូនសៀវភៅក្របខ្មៅតូចមួយក្បាល ក៏លូកដៃ ស្រវាចាប់លើកយកមកមើល ។ នៅក្នុងនោះ មានកត់ឈ្មោះ កត់

CHANBOKEO.COM

លេខទូរសព្ទ័និងអាសយដ្ឋានជាច្រើន ថៃមទាំងមានរូបថតក្រុម គ្រួសារពីរបីសន្លឹកទៀត ។ នៅសន្លឹកទីមួយ មានរូបនាងយ៉ាអង្គុយ អោបកុមារីពិការម្នាក់ ។ លោកក៏ក្រឡាប់រូបថត អានអក្សរ ដែល ចារពីខាងខ្នង មានសេចក្ដីថា ៖

- នេះគឺរូបបងយ៉ានិងអូនដាជាទីស្រឡាញ់ ។ សូមអោយប្អូនឆាប់ ជាសះស្បើយ អាចដើរបានដូចគេដូចឯង ហើយអាចទៅរៀនបាន ទៀតផង ។ បងសង្ឃឹមថា អូនដានិងចេះអក្សរនៅថ្ងៃណាមួយ ដើម្បីអោយយើងបាននិពន្ធសៀវភៅជាមួយគ្នា ហើយអូនដានិង ក្លាយជាអ្នកនិពន្ធដ៏ល្បីមួយរូបមិនខាន ។

នៅសន្លឹកមួយទៀត មានរូបស្ត្រីចាស់មួយរូប អាយុប្រហែល ហុកសិប រាងស្គាំងស្គម ហើយសក់ស្កូវ មាននាងយ៉ា នាងដា និងយុវជនមួយរូប ហើយមានចារអក្សរថា ៖

- ចំពោះម៉ែជាទីស្រឡាញ់! រូបខ្ញុំជាកូនកំព្រាពិតមែន ប៉ុន្តែម៉ែបាន ថៃទាំខ្ញុំយ៉ាងល្អបំផុត រហូតពេញវ័យ ។ គុណបំណាច់នេះមានទំហំ ធំធេងដូចសមុទ្ទ ។ កាលបើម៉ែបូជាអ្វីៗសព្វយ៉ាងដើម្បីកូន កូនក៏ មិនរាថយនឹងបូជាអ្វីៗដើម្បីម៉ែវិញដែរ ។ ថ្វីបើកូនមានការងារត្រឹម តែជាអ្នកបំរើគេ តែកូនមានសេចក្ដីរំភើបក្នុងចិត្តឡិតមានឱកាសរក ប្រាក់ទៅជួយម៉ែថៃរក្សាជំងឺ និងថៃអូនដាដែលពិការ ។ សូមអោយ ម៉ែនិងប្អូនសុខសប្បាយ ។ បើសិនកូនមានឱកាស កូននឹងទៅបំរើ ម៉ែសងគុណលោកវិញជាមិនខាន ។

នៅរូបចុងក្រោយ គឺជារូបដែលនាងយ៉ាថតជាមួយនាងដានិង យុវជនមួយរូបទៀត ហើយដែលមានចំណារសរសេរល្អិតៗថា ៖

- នេះគឺបងយ៉ា និងអូនចាន់ ។ យើងជាបងប្អូនដែលស្រឡាញ់ គ្នាបំផុតលើលោក ។ តែគួរអោយស្ដាយ បងរៀនមិនឆ្លាត ដូច អូនចាន់សោះ ហើយគ្រួសារយើងក៏ក្រីក្រ មិនអាចជួយកូនចៅ អោយរៀនបានឆ្ងាយ ទើបយើងសំរេចអោយកូនប្រុសបានរៀន សូត្របានខ្ពស់តែម្នាក់ឯង ដើម្បីជាបង្គោលគ្រួសារ ។ ពេលអូនរៀន ចប់ បងសុំអូនចាន់ធ្វើជាគ្រូរបស់បងហើយ ។ បង្រៀនបងផង ណា៎! បងមិនចូលចិត្តធ្វើជាមនុស្សខ្វាក់ល្ងិតល្ងង់ទេ ។ បើអូនបាន ចូលធ្វើគ្រូបង្រៀនខាងកុំព្យូទ័រ សូមកុំភ្លេចចុះឈ្មោះបងជាសិស្ស ម្នាក់ផង ព្រោះបងចង់ចេះ ចង់ធ្វើជាគ្រូបង្រៀនដូចអូនដែរ ។

លោកវណ្ណៈលាន់មាត់ខ្សឹបៗ ៖

- នាងជាមនុស្សមានទឹកចិត្តល្អប្រពៃណាស់ យ៉ា! មិនគួរណាខ្ញុំ មើលរំលងគុណសម្បត្តិដ៏ល្អរបស់នាងសោះ ។

CHANBOKEO.COM

បន្តិចមក លោកក៏ដើរចេញទៅ ។

- លោកចង់ចេញទៅណាទាំងយប់ ដូច្នេះ ? (យាយរៀមសួរ)
- គឺខ្ញុំទៅតាមរកនាងយ៉ា
- នេះយប់ជ្រៅហើយណា៎ លោកប្រុស! នាងចាកចេញទៅពីរ ម៉ោងហើយ ហើយភ្នំពេញនេះវាធំសែនធំ មនុស្សអាក្រក់មនុស្ស ល្អ ក៏មានសព្វបែប មិនដឹងថាគិតទៅរកនាងនៅឯណាឃើញទៅ ?
- កុំទាន់អាលអស់សង្ឃឹមអី យាយ! ខ្ញុំគិតថា ខ្ញុំប្រហែលអាចរក នាងឃើញឆាប់ៗនេះ ។

មានប្រសាសន៍ហើយ លោកវណ្ណៈក៏សុំសោរឡានពីពូតឿ បើក ចេញទៅដោយខ្លួនឯង ។ ពូតឿហុចសោទាំងទឹកមុខមិនស្រួល ៖

- លោកប្រុសពិតជាមិនចង់អោយខ្ញុំជូនមែនឬបាទ ?
- មិនអីទេ ពូតឿនៅផ្ទះមើលខុសត្រូវក្មេងៗនិងយាយផង ។ ខ្ញុំ នឹងត្រឡប់មកផ្ទះវិញឆាប់ៗ ។

ថាហើយ លោកក៏ថយរថយន្តចេញទៅ ។

នៅលើវិថីម្តុំៗដែលលោករស់នៅ លោកវណ្ណៈបើកឡានទៅមក ទៅមកជាច្រើនសា រួចក៏បង្ហួសទៅកន្លែងឡានក្រុងទៀត រកមើល ក្រែងប្រទះស្រមោលនាងយ៉ា ប៉ុន្តែ ស្ងាត់សូន្យ ។ លោកមិនបាន ប្រទះនរណាម្នាក់ដែលមានភិនភាគដូចនាងយ៉ាទេ ។ ក្រោយមក លោកវណ្ណៈក៏ដាច់ចិត្តធ្វើដំណើរទៅបាត់ដំបងតែម្នាក់ឯង ។ តាម ផ្លូវ លោកលែងគិត លែងបារម្ភពីនរណាទាំងអស់ ក្រៅពីនាងយ៉ា សូម្បីតែស្រមោលអ្នកស្រីកន្និដ្ឋា ដែលលោកសំរាន្តនឹកអាល័យរាល់ យប់នោះ ក៏រលប់រូបពីបេះដូងរបស់លោកទៅហើយនៅពេលនេះ ព្រោះលោកកំពុងអន្ទះសា គិតព្រួយបារម្ភពីសុខទុក្ខរបស់នាងយ៉ា ពន់ពេកក្រៃ ។ លោកពិតជាមានវិប្បដិសារីណាស់ ព្រោះនេះជា លើកដំបូងហើយ ដែលលោកផ្ទុះចរិតហឹង្សាដាក់យ៉ាងធ្ងន់ធ្ងរទៅលើ នារីភេទដែលគ្មានសមត្ថភាពអាចការពារខ្លួនបាន ។

តាមផ្លូវ លោកវណ្ណៈយកដៃជូតញើសចេញពីផ្ទៃមុខជាច្រើនដង ព្រោះចំហាយពុះកញ្ជ្រោលក្នុងបេះដូង បានដុតរោលខ្លួនលោកឲ្យ រលាកយ៉ាងក្តៅងំ ថ្វីបើក្នុងឡានមានម៉ាស៊ីនត្រជាក់យ៉ាងរំភើយ មនោរម្យក៏ដោយ ។

ភ្លឺស្រាងៗ បួនម៉ោងក្រោយមក...

CHANBOKEO.COM

លោកវណ្ណៈក៏បានមកដល់ក្រុងបាត់ដំបង ។ បន្ទាប់មក លោកក៏បររថយន្តបោះពួយសំដៅទៅទិសភ្នំសំពៅ ។ លុះមកដល់ភូមិមួយ ដែលមានឈ្មោះថា បឹងរាំង លោកក៏ឈប់រថយន្តចុះសួរដំណឹងអ្នក ស្រុក ។ គេក៏ចង្អុលប្រាប់ទិសដែលលោកចង់ទៅ ។ បន្តិចមក លោកវណ្ណៈក៏បានមកដល់ផ្ទះឈើប្រក់ក្បឿងសង់ខ្ពស់ពីដីដ៏ចំណាស់ មួយ ។ លោកក៏ចុះពីរថយន្ត ដើរចុះទៅរកម្ចាស់ផ្ទះ ដែលជាដូន ចាស់មួយរូបកំពុងបាចចំណីអោយមាន់ នៅចំហៀងផ្ទះជាមួយនារី ពិការម្នាក់វ័យប្រហែល១៧ឆ្នាំ ទំនងទើបតែភ្ញាក់ពីដំណេក ។

- ជំរាបសួរលោកអ៊ំ!

ដូនចាស់លើកដៃទទួលការសំពះរបស់លោកវណ្ណៈដោយទឹកមុខភ្ញាក់ផ្អើល កាលបើឃើញបុរសទីក្រុងយ៉ាងសង្ហា ក្នុងសម្លៀកថ្លៃថ្នូរស្កាត់មករកគាត់ទាំងព្រឹកព្រហាម ។

- មានការអ្វីដែរ លោក ?
- លោកអ៊ំឈ្មោះ ខន ម្ដាយនាងយ៉ាមែនទេ ?
- ចា៎ស ពិតមែនហើយ! លោកមានការអ្វីរកនាងហ្នែស ? នាង មិននៅទេ ទៅធ្វើការនៅភ្នំពេញបាត់ទៅហើយ ។
- គឺនាងធ្វើការអោយគ្រួសារខ្ញុំ ប៉ុន្តែ នាងបានចេញពីផ្ទះកាលពី យប់មិញ ទើបខ្ញុំតាមមករកនាង ?
- ថាម៉េច ? នាងគេចខ្លួនបាត់យប់មិញ ? កូនយ៉ា ?

ដូនចាស់ថ្លោះទឹកមុខ ស្រកស្រុតភាពញញឹមមួយរំពេច កាល បើឮថានាងយ៉ាបាត់ខ្លួនពីផ្ទះ ។

- គឺជាកំហុសរបស់ខ្ញុំទេ លោកអ៊ំ ដែលស្ដីបន្ទោសដល់នាងដោយ ភន្ត័ច្រឡំ ។
- ពុទ្ធោអើយកូនយ៉ា! តើពេលនេះ កូនទៅឯណាទៅ ?

យាយខន យកដៃរឹតដើមទ្រូងដោយការសោកសៅនិងព្រួយ បារម្ភចំពោះនាងយ៉ា ។ រំពេចនោះ ស្រាប់តែមានបុរសម្នាក់ជិះម៉ូតូ មកដល់ ។

- ជំរាបសួរអ៊ំខន!
- អ៊ូហ៍ ក្មួយមេសា! មកលេងផ្ទះឬ ក្មួយ ?
- បាទ! មកលេង ពីរបីថ្ងៃ ។ នេ៎ះ កញ្ចប់ថ្នាំ ដែលអាយ៉ា ផ្ញើមកជូន ។
- អឺ អរគុណណាស់ មេសា!

CHANBOKEO.COM

- ខ្ញុំទៅវិញនៅថ្ងៃចន្ទ័ បើអ៊ីចង់ផ្ញើអ្វីទៅអាយ៉ា ចាំទូរសព្ទ័ទៅខ្ញុំ
ខ្ញុំនឹងជិះម៉ូតូមកយកដោយខ្លួនឯង ។

- អឺ! ចាំអ៊ីទូរសព្ទ័ទៅ ។

រំពេចនោះ មេសាដាក់ភ្នែកទៅចំលោកវណ្ណៈក៏ភ្ញាក់ព្រើត លើកដៃសំពះសួរថា ៖

- ជំរាបសួរបាទ! លោកជាម្ចាស់ផ្ទះដែលអាយ៉ាទៅធ្វើការជូននោះ មែនទេ ?
- មែនហើយ ប្អូន!
- ហើយអាយ៉ាមិនបានតាមលោកមកទេហ៍ ?
- អត់ទេ ។ ខ្ញុំកំពុងតាមរកនាង!
- តាមរកនាង ? ហេតុអ្វីទៅ ?

យាយខនក៏កេះមេសាមិនអោយនិយាយច្រើន ។

- បើឯងរវល់ ទៅផ្ទះសិនចុះ មេសា! បន្តិចទៀត ចាំអ៊ីទូរសព្ទ័ ទៅឯង ឮហើយនៅ ?

មេសាក៏សំពះលាយាយខននិងលោកវណ្ណៈចេញទៅ ។

- គេជាសាច់ញាតិរបស់អ៊ីមែនទេ ? (លោកវណ្ណៈសួរ)
- អត់ទេ គ្រាន់តែជាញាតិរាប់អានគ្នាក្នុងភូមិប៉ុណ្ណោះ ប៉ុន្តែមេសា ជាមនុស្សល្អមួយរូប អាចពឹងពាក់ជាញាតិទុកចិត្តបាន ។
- គេមិនមែនជាសង្សាររបស់នាងយ៉ាទេ ?
- អត់ទេ! នាងយ៉ាមិនដែលរវីរវល់នឹងបុរសណាទេ ឃើញតែ រអ៊ូចង់រៀន ចង់ធ្វើគ្រូ ចង់ធ្វើការក្នុងការិយាល័យ ។ ថែដន្យ យើង ជាគ្រួសារអ្នកក្រីក្រ មិនអាចមានលុយជួយកូនអោយរៀនបានខ្ពង់ ខ្ពស់ទេ ។

ពេលនេះ លោកវណ្ណៈស្គាល់នាងយ៉ាកាន់តែច្បាស់ហើយ ហើយបេះដូងរបស់លោកក៏ចាប់ស្រឡះ ពីភាពអាប់អួរកាលពីយប់មិញ មកវិញដែរ ថ្វីបើនៅសល់ភាពកន្ទះរាបន្តិចខ្លះៗនៅឡើយក៏ដោយ..

- ហើយចុះ បុរសឈ្មោះឆាយានោះ លោកអ៊ីស្គាល់គេទេ ?

រំពេចនោះ ស្រាប់តែនាងចិន្តាជាប្អូនស្រីពិការនិងយាយខនធ្លាក់ទឹកមុខ បែរសម្លឹងមុខគ្នា ។ បន្តិចមក យាយខនក៏ឆ្លើយថា ៖

CHANBOKEO.COM

- ឆាយាជាមនុស្សឧត្បាត ដែលគួរតែជាប់ទោសទណ្ឌកម្មទើបសម
ព្រោះគេបានប្រព្រឹត្តអំពើយង់ឃ្នងអនាចារ្យ ទៅលើក្មេងស្រីក្រោម អាយុ
មិនគួរអោយអភ័យទោសទេ ។ ថែងន្យ គេជាកូនអ្នកមាន មានលុយ មានអំណាច
គេអាចទិញខ្លួនគេអោយនៅក្រៅគុក រស់ នៅយ៉ាងរំភើយ
ហើយមានសេរីភាពអាចដើររំខាននារីណាក៏ស្រេច តែចិត្ត ដោយគ្មានទោសពៃរ៍ ។
នេះជាការឈឺចាប់បំផុត ចំពោះ អ្នករងគ្រោះនិងក្រុមគ្រួសារ ព្រោះគេមិនអាចស្វែងរកយុត្តិធម៌ឲ្យ
ខ្លួនគេបាន ព្រោះគ្មានលុយ គ្មានបុណ្យសក្តិ គ្មានអំណាច ។ សម័យ
ឥឡូវនេះប្រេតដើរពេញក្រុងហើយ មិនឃើញមានគ្រូណាសក្តិសិទ្ធិ
អាចធ្វើសីមាចាប់បិសាចរឧត្បាតទាំងនោះ កុំឲ្យមកយាយីមនុស្ស ស្លូតត្រង់បានសោះ ។
    យាយខនស្រដីទាំងមុខស្រងូត ។ ពេលនោះ លោកវណ្ណៈអាច កាត់យល់បានហើយថា
ឆាយាប្រាកដជាប្រព្រឹត្តអ្វីទៅលើនាងចិន្តា ពិការនោះប្រាកដណាស់ ។
មើលទៅនាងចិន្តាក៏មានមុខមាត់គួរឲ្យ ស្រឡាញ់ណាស់ ទាស់តែនាងពិការប៉ុណ្ណោះ ។
កាន់តែស្គាល់ គ្រួសារនាងយ៉ាច្បាស់ពេលណា លោកវណ្ណៈកាន់តែមានចិត្តនឹក
អាណិតនាងយ៉ាគ្រលួចក្នុងជំរៅបេះដូង ថែមទាំងអាណិតទាំងអស់ គ្នាក្នុងគ្រួសាររបស់មាណវី ។
ពេលនេះ លោកយល់ច្បាស់ហើយ ថានាងយ៉ាសុំបើកប្រាក់ខែពីលោក១២ខែមុន
ក៏ព្រោះនៅផ្ទះរបស់ នាង មានតែម្តាយដែលមានជំងឺរ៉ាំរ៉ៃនិងប្អូនស្រីពិការ ។
- ហើយចុះលោកអ៊ីមានកូនចៅប៉ុន្មាននាក់ដែរ ?
    លោកវណ្ណៈសួរ ។
- បីនាក់ នាងយ៉ា ចារ៉ាន់ ហើយនិងនាងជាកូនពៅរបស់ខ្ញុំម្នាក់នេះ
ប៉ុន្តែ នាងយ៉ាទៅធ្វើការនៅភ្នំពេញ ចំណែកកូនចារ៉ាន់នៅធ្វើការ
នៅហាងសេវាទូរសព្ទ័និងឥន្ធនិតឯផ្សារបាត់ដំបង យូរៗ បានមក លេងផ្ទះម្តង ។
ចំណែកយើងពីរនាក់នេះ ជាមនុស្សអាសារបង់ មិនអាចធ្វើអ្វីកើតទេ គ្រាន់តែដាំបាយបរិភោគ
ក៏ធ្វើទាំងយ៉ាប់យ៉ឺន បំផុតដែរ ។
    មែនហើយ មើលទៅយាយខនស្គាំងស្គមទុរន់ទុរាណាស់ ព្រោះ គាត់មានជំងឺរ៉ាំរ៉ៃយូរហើយ
ព្រោះគ្មានសោហ៊ុយទិញថ្នាំព្យាបាល ។ ចំណែកនាងដាវិញ ក៏ពិការ
បានត្រឹមធ្វើការស្រាលៗកៀនៗផ្ទះ ។ លោកវណ្ណៈសម្លឹងមើលក្រុមគ្រួសាររបស់នាងយ៉ាយូរៗទៅ
ក៏មាន វិប្បដិសារីកាន់តែខ្លាំងឡើង ដែលលោកមែច្រឡំមិនល្អទៅលើរូប នាងយ៉ា ។

CHANBOKEO.COM

គិតឡើងគិតចុះ លោកវណ្ណៈចង់នៅចាំមើលផ្លូវនាងយ៉ា មួយថ្ងៃសិន ក្រែងលោនាវីត្រឡប់មកផ្ទះវិញ ។ ប៉ុន្តែ លោកមិន ដែលស្គាល់យាយខនពីមុនមកទេ អោយសំកុកនៅលេងជាមួយ យាយនិងកូនស្រី លោកហាក់ដូចជាមើសទាល់នឹកខ្មាសដូនចាស់ យ៉ាងណាមិននឹងសោះ ។ ប៉ុន្តែ ទោះបីយ៉ាងណា លោកបានកាត់ សេចក្ដីខ្មាសអៀនចេញពីក្នុងចិត្ត ហើយនៅអង្គុយជជែកលេងជា មួយយាយខននិងកូនតទៅទៀត ដើម្បីលោះពេលកុំអោយកន្លងទៅ ឥតប្រយោជន៍ ។

- ចុះកូនប្រុសរបស់លោកអ៊ីនោះ ធ្វើការនៅហាងណាដែរ ?

លោកវណ្ណៈសួរ ។

- គឺនៅផ្លូវលេខមួយមាត់ស្ទឹងសង្កែជិតផ្សារណាត់ ។ គេធ្វើការ អោយមិត្តភក្ដិម្នាក់ ដែលបើកហាងនៅទីនោះ (យាយខនឆ្លើយ)
- បានប្រាក់ខែគួរសមទេ លោកអ៊ី ?
- ចាស! បានមួយខែ២៥ដុល្លារដែរ ។
- អូហ៍ ? ហេតុអ្វីក៏តិចម្ល៉េះ ?
- ព្រោះម្ចាស់ផ្ទះគេប៉ាវបាយប៉ាវផ្ទះនៅអស់ហើយ ។ ហើយចារ៉ាន់ ក៏ផ្ញើលុយមកផ្ទះរាល់ខែ មិនឃើញវាទុកចាយអីទេ ព្រោះគេប្រាប់ ខ្ញុំថា គេអាចរកក្រៅបានខ្លះសំរាប់ចាយវាយខ្លួនគេហើយ ។
- លោកអ៊ីសំណាងណាស់ដែលមានកូនល្អៗ ដូចនាងយ៉ានិងចារ៉ាន់
- ចាសមែនហើយ! ការពិត ទាំងពីរនាក់ហ្នឹង មិនមែនជាកូន បង្កើតរបស់ខ្ញុំទេ ។ នាងយ៉ាជាកូនដើមរបស់ប្ដីខ្ញុំ ចំណែកចារ៉ាន់ជា ក្មេងកំព្រា ដែលខ្ញុំរើសយកមកចិញ្ចឹមតាំងពីកូនង៉ាម្ល៉េះ ។ ឯកូន បង្កើតរបស់ខ្ញុំ គឺនាងចិន្តា ប៉ុន្តែ សំណាងមិនល្អ ពេលខ្ញុំកំពុងព ផ្ទៃនាងដា ខ្ញុំធ្លាក់ខ្លួនឈឺធ្ងន់វិះស្លាប់ លុះជាមកវិញ ក៏សំរាលបាន នាងដាមក ។ ប្រហែលជាមកពីខ្ញុំមានវ័យចំណាស់ ប្រហែល ដោយសារជម្ងឺ ឬក៏ដោយសារឥទ្ធិពលថ្នាំព្យាបាលជំងឺ ទៅលើកូន ក្នុងផ្ទៃក៏មិននឹង បានជានាងដាកើតមកមិនមានលក្ខណៈប្រក្រតីដូច គេឯងទូទៅសោះ ។ នាងដើរមិនបានឆ្ងាយ និយាយមិនច្បាស់ មើលក៏មិនសូវឃើញ ចេះតែញញឹមហើយទារញ៉ាំ ប៉ុន្តែ នាងមាន ប្រាជ្ញអាចស្ដាប់យើងនិយាយជាមួយយល់សេចក្ដី គ្រាន់តែនាង ពិបាកនិយាយតបមកវិញ ។

CHANBOKEO.COM

សំណាងល្អណាស់ ដែលខ្ញុំមានកូនយ៉ា និងកូនចារ៉ាន់ជាក្មេងល្អ ជួយខ្ញុំពីមុខពីក្រោយ កុំអីខ្ញុំនិងកូនដា ប្រហែលជាត្រូវវេទនាធំហើយ ។

- គេបានក្លាយជាក្មេងល្អនេះ ក៏មកពីការអប់រំឃុំគ្រងថែទាំរបស់ លោកអ៊ីយ៉ាងល្អបំផុតដែរ ទើបគេមានសេចក្តីកក់ក្តៅនៅក្នុងចិត្ត ចង់តែត្រឡប់វិលមករកលោកអ៊ី ដើម្បីទទួលភាពកក់ក្តៅពីគ្រួសារ បន្តទៅទៀត ។ បើសិនលោកអ៊ីមិនបានផ្តល់ការកក់ក្តៅដល់គេកាល ពីនៅក្មេងៗ ម្ល៉េះសមពេលនេះបេះដូងគេរងា រួចហើយរត់ស្វែង រកការកក់ក្តៅក្នុងចិត្តនៅទីដទៃហើយ ។ គេច្បាស់ជាមិនត្រឡប់មក រកក្រុមគ្រួសារវិញទេ បើសិនជាផ្ទះមិនអាចផ្តល់ភាពកក់ក្តៅនោះ ក្នុងចិត្ត ក្នុងបេះដូងរបស់គេបាន ។

- មែនហើយ! លោកមានប្រសាសន៍សមរម្យណាស់ ។ ការពិត ទៅ ខ្ញុំក៏បានថែទាំពួកគេដោយសេចក្តីស្រឡាញ់ ដោយមិនគិតថា គេជាកូនដើម កូនចុង កូនចិញ្ចឹមអីទេ ព្រោះគេជាក្មេងតូចៗ មិន អាចជួយខ្លួនឯងបាន ។ កាលបើគេគ្មានម្តាយនៅក្បែរថែទាំ ចិត្តគេ កំព្រារងាកណ្តោចកណ្តែងណាស់ ។ យើងជាមនុស្សចាស់ គួរតែ ចេះយល់ចិត្ត យល់អារម្មណ៍របស់ក្មេងអោយបានច្រើន ជាពិសេស បើយើងថែរក្សារូបគេដោយសេចក្តីស្រឡាញ់យ៉ាងកក់ក្តៅ ពេលគេ ធំឡើង គេនឹងតបស្នងយើងវិញ ដោយសេចក្តីស្រឡាញ់យ៉ាង កក់ក្តៅដូចគ្នា ។ ពេលនេះ ខ្ញុំចាស់ទុរន់ទុរា មានជំងឺ ។ ឯកូនស្រី វិញក៏ពិការ នេះបើកុំតែបានគេទាំងពីរជួយខ្ញុំវិញនោះ មិនដឹងថា ជីវិតរបស់ខ្ញុំពេលនេះ ធ្លាក់ទឹកសមុទ្ទដល់ក្រហែងបាតាលឯណាទៅ ហើយក៏មិនដឹង ។ អូហ៍! និយាយអញ្ចឹង នាងយ៉ាទៅបំរើលោក បានល្អទេ? ហើយគេធ្វើអ្វីឲ្យលោកទាស់ចិត្តឬអី ទើបនាងត្រូវ ចាកចេញពីផ្ទះយ៉ាងទាន់ហន់បែបនេះ?

លោកវណ្ណៈភ្ញាក់ព្រើត កាលបើឮប្រយោគនេះ ។ លោកប្រឹង លេបទឹកមាត់ផ្សើមបំពង់កបន្តិច ក៏មានប្រសាសន៍តបវិញថា ៖

- នាងយ៉ាគេប្រព្រឹត្តខ្លួនបានល្អប្រពៃណាស់លោកអ៊ី ។ ការពិត គឺ ខុសមកពីខ្ញុំទេ ដែលម្តយ៉ៅខុសរឿង ជ្រុលទៅលើនាងខ្លាំងបន្តិច ទើបនាងភិតភ័យហើយរត់ចេញមក ។ ពេលនេះ ខ្ញុំមករកនាង ដើម្បីហៅនាងអោយត្រឡប់ទៅវិញ ហើយមកសុំទោសលោកអ៊ីផង ដែលខ្ញុំបានបង្កក្តីបារម្ភរហូតមកដល់ផ្ទះឯបាត់ដំបងនេះ ។

យាយខនស្តាប់ប្រសាសន៍លោកវណ្ណៈហើយ ល្ហួចសម្លឹងមុខ លោកភ្លៀកៗ នឹកចម្លែកចិត្តដែលគាត់ប្រទះឃើញ ចៅកែមកតាម សុំទោសកូនឈ្លួលជាលើកដំបូងក្នុងជីវិតរបស់យាយ ។ ពេលនោះ យាយហាក់ដូចជាចាប់ភ្លឹកអំពីអកប្បកិរិយារបស់លោកវណ្ណៈតិចៗ ហើយ ។

បន្តិចមក លោកវណ្ណៈក៏សុំអនុញ្ញាតយាយខនដើរមើលដីចំការ ក្រោយផ្ទះ ស្រាប់តែប្រទះនឹងក្តារខៀនមួយដាក់ទុកនៅក្នុងរោង ស្បូវក្រោមដើមស្វាយខិករ៉ងដ៏ត្រឈៃមួយ ។ នៅលើក្តារខៀនមាន
ចំណារសរសេរថា ៖

- ដើម្បីជោគជ័យ យើងត្រូវតែមានសេចក្តីសង្ឃឹម! ដើម្បីអោយ ក្តីសង្ឃឹមមានរូបរាង យើងត្រូវតែខំពុះពារ ។ បើសិនជារាថយ មិនពុះពារ យើងនឹងក្លាយជាអ្នកចាញ់រហូត មិនអាចរកជោគជ័យ ឃើញឡើយ ។

ទម្រង់តួអក្សរទាំងឡាយនោះបានបញ្ជាក់ថា អ្នកសរសេរបាន ឆ្លាក់ក្បាច់យ៉ាងផ្ចិតផ្ចង់ ទំនងរបៀបសរសេរជាន់លើគ្នាងដែលៗ ដើម្បីរំលឹកអត្ថន័យដ៏ពិស្តាររបស់ប្រយោគ ។ លុះលោកសម្លឹងទៅ ជាយចំហៀងខាងក្រោម ឃើញស្នាមចុះហត្ថលេខាដែលទំនងជាត្រូវទឹកភ្លៀងសាច រាងរលប់ៗបន្តិចទៅហើយ ប៉ុន្តែ លោកក៏អាច នៅអានបាននឹងសេចក្តីថា នរណាជាម្ចាស់ប្រយោគមួយនោះដែរ ។ លោកក៏យកដៃទៅអង្អែលឈ្មោះនោះបន្តើរៗ មិនដឹងថាលោក ពេញចិត្តនូវអត្ថន័យដែលគេបានសរសេរលើក្តារខៀន ឬពេញចិត្ត នឹងឈ្មោះក៏មិនដឹង ។ រំពេចនោះ លោកបែរមើលតាមចន្លោះស្លឹក ឈើឃើញស្រមោលរ៉ឺម៉កកង់មួយបានបោះពួយ មកដល់ទីធ្លាមុខផ្ទះ របស់យាយខន ដោយផ្ទុកមាណវីមួយរូបមកផង ។

- យ៉ា! (លោកវណ្ណៈឧទានក្នុងមាត់ខ្សិបៗ ពេលលោកក្រឡេក ឃើញនាងភ្លាម)

ភ្លាមនោះ បេះដូងរបស់លោកក៏លោតកញ្ច្រោលខុសចង្វាក់តែ ម្តង ។ យាយខនក៏ស្ទុះទៅទទួលកូនស្រីដែលឈ្ងោកឈានចុះពី រ៉ឺម៉កទាំងកិរិយាទុរន់ទុរា ។

- កូនយ៉ា! កើតអីហ្នឹងកូន ?

- ជំរាបសួរម៉ែ..! ... អូនដា!

ធិតាស្រដីបានតែប៉ុននេះ ក៏អួលដើមក ញ័រដៃញ័រជើង ស្រក់ ទឹកភ្នែកច្រោកៗតែម្តង ។ យាយខនឃើញដូច្នោះ ភិតភ័យណាស់ ចំពោះសុខទុក្ខរបស់កូន

CHANBOKEO.COM

ក៏គ្រាហ៍កូនចុះពីរ៉ឺម៉កនាំឡើងទៅលើផ្ទះ ភ្លាម ។ ចំណែកនាងដាក៏ធ្វើមុខងីងើៗទំនងឆ្ងើលៗ ។ លោកវណ្ណៈ ឃើញស្រីបីនាក់សុទ្ធតែប្រកបដោយភាពយ៉ាប់យ៉ឺនទាំងអស់គ្នា ក៏ស្ទុះរឹងទៅរកជួយទប់នាងយ៉ា ។ គ្រាន់តែក្រឡេកឃើញមុខលោក វណ្ណៈភ្លាម មាណវីយើងបើកភ្នែកធំៗដោយការភ្ញាក់ផ្អើលផង ខឹង ផង ថែមទាំងលួចខាំធ្មេញលេបទឹកភ្នែកទៅវិញផង ។ នាងក៏គេច រឹង មិនឲ្យលោកវណ្ណៈប៉ះខ្លួននាងទេ រួចត្រដរវារឡើងទៅលើ ផ្ទះដោយខ្លួនឯង ថ្វីបើទឹកមុខរបស់នាងបានបញ្ជាក់ប្រាប់ថា នាង កំពុងឈឺចាប់ក្នុងខ្លួនយ៉ាងណាក៏ដោយ ។ ពេលនោះ លោកវណ្ណៈ ដឹងខ្លួនភ្លាមថា ធិតាកំពុងខឹងស្អប់លោកខ្លាំងណាស់ ប៉ុន្តែលោកក៏មិនអាក់អន់ចិត្តអ្វីដែរ ព្រោះលោកជាអ្នកប្រព្រឹត្តហឹង្សាទៅលើ នាងរហូតឈឺខ្លួនដូច្នោះ ។ លោកក៏ហៅពូរ៉ឺម៉ក អោយជួយគ្រាហ៍ ធិតាដាក់រថយន្ត ។

- លោកចង់នាំនាងយ៉ាទៅណា ? (យាយខនសួរ)
- យកទៅពេទ្យណា៎ លោកអ៊ី! (លោកវណ្ណៈឆ្លើយ)

ថៃដន្យ នាងយ៉ាបានវារឡើងដល់លើផ្ទះទៅហើយ រួចហើយ មិនព្រមស្តាប់នរណា មើលមុខនរណាឡើយ ។ ឃើញដូច្នោះ លោក វណ្ណៈសួរយាយខនថា ៖

- នៅម្តុំនេះមានគ្រូពេទ្យទេ ?
- ចា៎ស មាន!

លោកគ្រូពេទ្យក៏ហៅអ្នករ៉ឺម៉កអោយនាំមុខលោក ទៅហៅលោក គ្រូពេទ្យ ។ មួយស្របក់ក្រោយមក លោកក៏មកដល់វិញដោយមាន នាំលោកគ្រូពេទ្យវ័យចំណាស់ម្នាក់មកជាមួយផង ។ ថ្វីបើនាងយ៉ា ខឹងស្អប់មិនចង់ឃើញមុខលោកវណ្ណៈមែន ប៉ុន្តែ នាងមិនប្រកែក ចំពោះការពិនិត្យរបស់លោកគ្រូពេទ្យដែរ មើលទៅប្រហែលនាង ពិបាកទ្រាំនឹងការឈឺចាប់ក្នុងកាយណាស់ បានជាបណ្តោយលោកគ្រូ ព្យាបាលតាមសម្រួល ។ យាយខនអង្គុយក្បែរកូនស្រី លូកយកដៃ បបោសក្បាលនាងបន្តើរៗ ហាក់លួងលោមអោយមាណវីសម្រក សម្រន់អារម្មណ៍ពីការឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្ត ។ លោក វណ្ណៈដាក់ខ្លួននៅអង្គុយក្បែរមាត់ទ្វារ រង់ចាំលោកគ្រូពេទ្យពិនិត្យ ។ បន្តិចមក លោកគ្រូពេទ្យមានប្រសាសន៍ថា ៖

CHANBOKEO.COM

- គ្មានអីគួរបារម្ភទេ ព្រោះលើរូបកាយរបស់នាង គ្មានសញ្ញាថា
មានបាក់ឆ្អឹងដាច់សរសៃអ្វីឡើយ ។ នាងគ្រាន់តែលេបថ្នាំបំបាត់ការ ឈឺចាប់ទៅគ្រប់គ្រាន់ហើយ ។

លោកវណ្ណៈដកដង្ហើមយូបន្ធូរទ្រូង កាលបើឮដូច្នោះ ។ លោកគ្រូពេទ្យអោយថ្នាំទៅនាងយ៉ាហើយក៏ត្រឡប់ទៅវិញ ។

- អោយខ្ញុំសុំនិយាយជាមួយនាងយ៉ាបន្តិចបានទេ លោកអ៊ំ ?

យាយខនបែរមើលនាងយ៉ា ដែលគេងនៅលើគ្រែក្រាលកន្ទេលនីឡុងពណ៌ខៀវក្នុងផ្ទះដ៏ទូលាយល្ហល្ហេវ ។ ពេលនោះ លោកវណ្ណៈបានឃើញអ្វីសព្វយ៉ាងនៅក្នុងផ្ទះរបស់នាង ។ ការពិត ផ្ទះនោះ ធំទូលាយមែន ប៉ុន្តែក្នុងផ្ទះគ្មានសម្បត្តិទ្រព្យអ្វីល្អៗគួរសំគាល់ទេ គ្រាន់តែសមរម្យល្មមរស់នៅកក់ក្ដៅ ។ យាយខនក៏ថយខ្លួនចេញ ទៅខាងក្រោមផ្ទះបាត់ ទុកអោយលោកវណ្ណៈនិយាយគ្នា ជាមួយនាងយ៉ាតែពីរនាក់ ។

- យ៉ា!... អោយខ្ញុំសូមទោសណា៎ ដែលយប់មិញខ្ញុំជ្រុលដៃជ្រុល ជើងទៅលើនាងយ៉ាងកំរោល ។

នាងយ៉ាធ្មេចភ្នែកនៅស្ងៀមឈឹង ធ្វើមិនឮ ។

- យ៉ា! ខ្ញុំដឹងថានាងកំពុងមានការឈឺចាប់ ទាំងផ្លូវកាយផ្លូវចិត្តពិបាកនឹងអោយនាងអភ័យទោសអោយខ្ញុំងាយៗណាស់... ប៉ុន្តែ ខ្ញុំ ចង់អោយនាងដឹងថាខ្ញុំពិតជាមកបំណងមកសុំទោសនាងប្រាកដ មែន! នេះ ខ្ញុំមិនបានគេងមួយយប់ហើយ ព្រោះខ្ញុំបារម្ភពីនាង មិនដឹងថានាងមានសុវត្ថិភាព ឬក៏យ៉ាងណា ទើបខ្ញុំបើកឡានតាមមករកនាងរហូតដល់បាត់ដំបងនេះ ។ កាលបើឃើញនាងបានមក ដល់ផ្ទះវិញខ្ញុំក៏ធូរទ្រូង..ស្ងប់ចិត្តហើយ ដោយខ្ញុំដឹងថា នាង មានសុវត្ថិភាព ។

លោកវណ្ណៈនិយាយទាំងសម្លេងអួលៗ ដោយការសោកស្ដាយ ក្នុងចិត្ត ។ រំពេចនោះ សម្លេងទូរស័ព្ទរោទិ៍ឡើង ។

- សូមទោស យ៉ា! ខ្ញុំទៅទទួលទូរស័ព្ទម៉ាភ្លែត ។

លោកវណ្ណៈក៏ចុះជណ្ដើរចេញទៅ ។ ស្រាប់តែនាងយ៉ាបើកភ្នែក មកវិញសម្លឹងតាមលោកវណ្ណៈដោយទឹកមុខចម្លែក ព្រោះនាងមិន នឹកស្មានថាលោកវណ្ណៈតាមមករកនាងអញ្ចឹងទេ ។ ថ្វីបើនាងខឹង និងលោកវណ្ណៈពិតមែន ប៉ុន្តែកាលបើឃើញលោកបើកឡានមក ទាំងយប់រហូតដល់បាត់ដំបង

CHANBOKEO.COM

ហើយមកសុំទោសនាងដល់ផ្ទះដូច្នេះ នាងពិតជាមានការភ្ញាក់ផ្អើលក្នុងចិត្តណាស់ ថែមទាំងនឹកពិភាល់ថា អ្វីទៅដែលជាមូលហេតុធ្វើអោយលោកវណ្ណៈផ្លាស់ប្ដូរឥរិយាបថរបស់លោកដល់ម្លឹង ព្រោះអីកាលពីយប់មិញ លោកធ្វើខ្លួនដូចមារសត្រូវ ប្រចាំជាតិរបស់នាងអញ្ចឹង តែថ្ងៃនេះ លោកវណ្ណៈបែរក្លាយជាសត្វ ឈ្លូសដ៏ស្លូតចម្លែកមួយ...

បន្តិចមក លោកវណ្ណៈក៏ត្រឡប់មកវិញ ប្រាប់នាងថា ៖

- យ៉ា! ខ្ញុំត្រឡប់ទៅភ្នំពេញសិនហើយព្រោះមានភ្លើងទូស្ដេផ្ទុះក្នុង ហាងរបស់ខ្ញុំ ឆេះខ្ទេចម៉ូតូល្អៗអស់ជាច្រើនគ្រឿង ត្រូវទៅមើល ខុសត្រូវកិច្ចការបន្តិច ។ ដល់ទំនេរដៃ ខ្ញុំនឹងត្រឡប់មកមើលនាង ម្ដងទៀត ។

លោកវណ្ណៈសម្លឹងមុខនាងយ៉ាមួយស្របក់ ឃើញនាងនៅតែ ធ្មេចភ្នែកដដែល ក៏ចុះជណ្ដើរត្រឡប់ទៅវិញទាំងមុខស្រងូត ។

នៅមាត់ជណ្ដើរខាងក្រោម លោកវណ្ណៈលើកដៃសំពះលាយាយ ខន ព្រមទាំងដកប្រាក់មួយចំនួនហុចអោយគាត់ទៀតផង ៖

- នេះជាសោហ៊ុយតិចតួចសំរាប់ទុកបង់ថ្លៃព្យាបាលឲ្យនាងយ៉ា ។
- ចាស អរគុណលោក! (យាយខនលូកដៃទទួល)
- ម៉ែ កុំទទួលរបស់គេ! យើងគ្មានសមត្ថភាពរកសងគេវិញទេ ។

យាយខនបែរវឹងយ៉ាងរហ័សទៅរកម្ចាស់សម្លេង ឃើញនាង យ៉ាទ្រោបខ្លួននៅមាត់ទ្វារ រាំងដៃមិនអោយគាត់ទទួលប្រាក់ពីលោក វណ្ណៈ ។ យាយខនទុចដៃដ៏ក់ សម្ដែងទឹកមុខហាក់ដូចជាសោក ស្ដាយប្រាក់ដ៏សន្ធឹកសន្ធាប់នោះ ប៉ុន្តែ គាត់ក៏មិនប្រកែកអ្វីដែរ បែរជាហុចប្រាក់នៅត្រឡប់ទៅវិញយ៉ាងរហ័ស ។

- គឺ... ខ្ញុំមិនចង់អោយកូនគិតថា ម្ដាយរបស់គេស្រេកឃ្លានទឹក ប្រាក់ទេ... សូមលោកមេត្តាទទួលយកវិញផងចុះ ។

ថាហើយ យាយខនក៏យកប្រាក់ដាក់ទៅក្នុងដៃលោកវណ្ណៈវិញ ធ្វើអោយលោកវណ្ណៈភ្ញាក់ភាំង ត្បិតមិននឹកស្មានថាម្ដាយកូនទាំងពីរ ស៊ីចង្វាក់គ្នាដល់ម្លឹង ។ ចៃដន្យ លោកវណ្ណៈមិនស្រដីអ្វី បង្ខំអ្វីដល់ អ្នកទាំងពីរដែរ ព្រោះមិនចង់អោយគេល្អក់កករអារម្មណ៍ដោយសារ រូបលោកតទៅទៀត ។ លោកក៏ទទួលប្រាក់យកវិញ ហើយក៏ឱន សំពះយាយខន រួចឡើងរថយន្តចេញទៅ ទាំងប្រញាប់ប្រញាល់ ។

នៅលើផ្ទះ...

CHANBOKEO.COM

- មានរឿងអ្វី យ៉ា ? ប្រាប់ម៉ែបានទេកូន ?

យាយខនសួរនាងយ៉ា ។ ពូដូច្នោ ធិតាក៏ស្រវាអោបម្តាយយំ សសឹកខ្សឹកខ្សួលយ៉ាងយូរ...

យាយខនស្រដីជាមួយកូនស្រីបណ្តើរ លាបថ្នាំលើរបួសនាង បណ្តើរ ។

- កុំយំអីកូន! ទោះបីជាយ៉ាងណា ផ្ទះយើងនេះជាកន្លែងសុខបំផុត សំរាប់កូនហើយ... គ្មាននរណាមានចិត្តបាប ផ្តន្ទារូបកូនទៀតទេ!

ពាក្យលួងលោមរបស់យាយខន ប្រៀបបាននឹងថ្នាំទិព្វមកផ្សះ ភាពឈឺផ្សាក្នុងខ្លួនរបស់នាងយ៉ារលីង ។ មាណវីក៏លើកដៃជូតទឹក ភ្នែកហើយញញឹមដាក់ម្តាយវិញ ៖

- ម៉ែ! កូនស្រឡាញ់ម៉ែជាទីបំផុត នៅលើលោកនេះ!

oooooooooooooooo

ooooo

o

CHANBOKEO . COM

# វគ្គទី៦

## ដើម្បីនរណា ?

លោកវណ្ណៈបានមកដល់ភ្នំពេញនៅរសៀលថ្ងៃដដែល ។ ហាងម៉ូតូដ៏ធំមួយរបស់លោកបានត្រូវភ្លើងឆេះ អស់ម៉ូតូល្អៗថ្មីៗជាង១០ គ្រឿង ធ្វើអោយលោកវណ្ណៈស្លុតបំពាង់ក នឹកគិតថា ហេតុអ្វីក៏រាសី របស់លោកដាក់ម្ល៉េះ ? ប៉ុន្មានខែមុន ភរិយារបស់លោកស្លាប់ ។ អាទិត្យមុន ចោរប្លន់ហាងទូរសព្ទ័ រួចហើយ លោកមានរឿងជាមួយនាងយ៉ា ធ្លាក់ទឹកធ្លាក់ភក់នៅកៀនស្វាយម្តង រួចមកមានរឿងកាល ពីម្សិលម្តងទៀត ។ ពេលនេះ ហាងលក់ម៉ូតូទូស្តេខ្សែភ្លើង ឆេះម៉ូតូ ខូចខាតយ៉ាងដំណំ ។ លោកវណ្ណៈមួម៉ៅឈ្លីក្បាល ស្ទើររបោចសក់ អស់ពីក្បាលទៅហើយ...

ម៉ោងប្រហែល៨យប់ លោកក៏ត្រឡប់មកដល់ផ្ទះវិញ ឃើញកូនប្រុសស្រីចាំមើលផ្លូវលោកអោយរហង់ ។

- លោកប៉ា! (ពួកគេហៅឪពុកព្រមគ្នា)
- ប៉ាបានជួបបងយ៉ាហើយកូន!

លោកវណ្ណៈមានប្រសាសន៍ប្រាប់កូនកុំអោយគេភ័យបារម្ភ ប៉ុន្តែលោកមិនបានពន្យល់គេអោយក្បោះក្បាយទេ ព្រោះអស់កម្លាំងពេក ក៏ដើរហួសកូនទៅក្នុងបន្ទប់ ប្រាសលើខ្នើយទំរេតយកកម្លាំង ។ ភ្លាមនោះ លោកប្រទះកាតមួយដែលកូនរបស់លោកសរសេរទុក នៅលើពូក ក៏ទាញយកមកអាន ៖

- លោកប៉ា! កូនបារម្ភពីលោកប៉ាណាស់ ហើយក៏បារម្ភពីបងយ៉ាដូច គ្នា ។ ការដែលបងយ៉ាចាកចេញទៅ ហើយលោកប៉ាក៏ចាកចេញ តាមពីក្រោយទៅទៀត

CHANBOKEO.COM

ធ្វើឲ្យកូនៗមានអារម្មណ៍ថាកូនរងាណាស់ រងាដូចកាលដែលម៉ាក់ចាកចោលកូនទៅដូចគ្នាអញ្ចឹង ។ កូនចង់ឲ្យ លោកប៉ាត្រឡប់មកវិញ... ចង់អោយភាពញញឹមនៅលើផ្ទៃមុខរបស់លោកប៉ាវិលមកវិញ... ចង់អោយផ្ទះយើងមានសភាពរមនាដូចពី ដើមមកវិញ... ប៉ុន្តែ មិនដឹងថា កូនមានសំណាងអាចឃើញភាព ញញឹមនៅក្នុងផ្ទះរបស់យើងសាជាថ្មីឆាប់ៗនេះដែរឬទេ ? កាលពី មុន ផ្ទះយើងក្រៀមក្រំស្ងាត់ស្ងៀមមួយកំឡុងពេល បន្ទាប់ពីម៉ាក់ ចែកស្ថានទៅ ។ លុះបងយ៉ាមករស់នៅទីនេះ ផ្ទះយើងក៏ទទួល នូវភាពញញឹមឡើងសាជាថ្មីម្តងទៀតយ៉ាងបំព្រង ។ ចៃដន្យ ភាព ញញឹមនោះមិនទាន់មានជីវិតបានប៉ុន្មានថ្ងៃផង ស្រាប់តែត្រូវបាត់ បង់រលត់រលាយទៅវិញយ៉ាងតក្កហល ធ្វើអោយកូនៗត្រៀមចិត្ត ពត់ខ្លួនតាមរលកនៃការផ្លាស់ប្តូរក្នុងផ្ទះរបស់យើងមិនទាន់ ។ ពេល នេះ តើកូនត្រូវត្រៀមខ្លួនត្រៀមចិត្តបែបណាតទៅទៀតលោកប៉ា ? ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏កូននៅតែស្រឡាញ់លោកប៉ា ហើយរង់ចាំភាពញញឹមលើផ្ទៃមុខរបស់លោកប៉ាជានិច្ច...! ! ពីកូន នី និងប្អូនៗ ។

- កូននី... ការពិត ប៉ាក៏ចង់បានភាពញញឹមនោះត្រឡប់វិលមករក គ្រួសារយើងវិញដូចគ្នាដែរ (លោកវណ្ណៈពោលខ្សិបៗតែម្នាក់ឯង) ពេលនេះ ប៉ាកំពុងព្យាយាមហើយណាកូន! អ្វីៗទាំងអស់ជាកំហុស របស់ប៉ាទាំងអស់ដែលធ្វើឲ្យកូនស្រកស្រុតក្តីរមនានៅក្នុងចិត្ត...

លោកបែរមើលទៅមុខកញ្ចក់ ឃើញផ្កាអ័រគីដេ០ទងនោះ នៅតែរីកស្រស់ញញឹមយ៉ាងត្រកាលដដែល ។ លោកក៏ងើបឡើង យក ដៃទៅអង្អែលទងផ្កា ហើយស្រដីម្នាក់ឯងថា ៖

- ឱផ្កាដ៏ស្រស់អើយ! សូមអោយសោភ័ណរបស់អ្នកផ្តល់នូវភាព កក់ក្តៅដល់បេះដូងរបស់ខ្ញុំផងណា៎... ព្រោះបេះដូងរបស់ខ្ញុំពេល នេះ ក៏កំពុងរងា មិនខុសពីកូនប្រុសស្រីរបស់ខ្ញុំទេ... តើពេលណា ទើបខ្ញុំយល់ភាពកក់ក្តៅក្នុងចិត្ត សាជាថ្មីម្តងទៀត ?

រាត្រីនោះ...

លោកវណ្ណៈប្រឹងបិទភ្នែកនិន្ទ្រាទាំងដួងចិត្តតប់ប្រមល់ ម្តងនឹក ទៅដល់ភរិយាជាទីស្រឡាញ់ ដែលបានលាលោកទៅ ម្តងនឹកទៅ ដល់កូនគ្រប់ៗគ្នា ម្តងនឹកទៅដល់នាងយ៉ា... មែនហើយ! លោក ទើបតែស្គាល់មាណវីម្នាក់នេះមិនទាន់បានប៉ុន្មានផង ហេតុអ្វីក៏នារី មួយរូបនេះ

CHANBOKEO.COM

មានអនុភាពដណ្តប់លើក្រុមគ្រួសាររបស់លោកម្ល៉េះ ? ពេលនេះ លោកខំកាត់ចិត្តណាស់ ថាមិននឹកមាណវីក្មេងម្នួយរូប នោះទេ តែក៏ធ្វើមិនបាន! ពេលលោកធ្មេចភ្នែកម្តងណា ក៏ស្រម័យឃើញនារីម្នាក់ដែលធ្វើការរហ័សរហួន... ដែលចេះធ្វើឲ្យបរិយាកាសគ្រួសាររបស់លោកមានសភាពស្រស់បំព្រង... ដែលមានលក្ខណ: ជានារីខ្មែរសាមញ្ញ មិនឆើតឆាយ មិនស៊ីវិល័យ តែមានសតិប្រាជ្ញ មានគំនិតប្រពៃ ចេះនាំកូនរបស់លោកធ្វើអ្វីប្លែកៗក្នុងផ្ទះ ដែលនាំអោយសមាជិកគ្រួសាររបស់លោកមានអារម្មណ៍ល្អជានិច្ច...

រំពេចនោះ រូបភាពនារីម្នាក់ដួលស្តុកស្តឹង មានឈាមហូរចេញ ពីមាត់ពីច្រមុះ បានហោះអណ្តែតឆ្លៀឡើងកាត់អារម្មណ៍របស់លោក វណ្ណ: ធ្វើអោយលោកភ្ញាក់ក្រញាងស្វាងងងុយតែម្តង ។ ទ្រាំមិន បាន លោកក៏ងើបឡើងទាញកូនសៀវភៅក្របខ្មៅរបស់នាងយ៉ា មកបើកអាន ម្តងមួយសន្លឹកៗ យ៉ាងពិនិត្យពិច័យ ។ ស្រាប់តែ លោកវណ្ណ:បានប្រទះកំណាព្យមួយ ដែលមាណវីសរសេរកាលពីប៉ុន្មានថ្ងៃមុននេះ មានសេចក្តីថា ៖

ពេលឃើញបងញញឹម

ពេលអូនបានឃើញភក្រ្តបងញញឹម ចិត្តលួចសង្ឃឹមញញឹមម្នាក់ឯង
ទឹកមុខមន្តស្នេហ៍ឱ្យស្រីចំបែង អារម្មណ៏វង្វេងក្នុងភពកាមា ។
ពេលបងញញឹមអូនលួចចាំចង ផ្ចិតក្នុងបេះដូងមែកទងស្នេហា
ប្រៀបនឹងសន្សើមដក់ត្របកផ្កា ជាតិនេះសច្ចាសូមជួបជាគូ ។
សូមបងញញឹមញញឹមរៀងទៅ បំភ្លឺចិត្តពៅអើយល្អស្រស់ផូរ
ស្នាមញញឹមអើយកុំឡើយផ្លាស់ប្តូរ អូនត្រងដៃគូទទួលស្នេហ៏បង...!

ភ្លាមនោះ លោកវណ្ណនឹកពិភាល់ក្នុងចិត្តណាស់ ក៏ឧទានថា ៖

- យ៉ា! នាងជាម្ចាស់ប៉ាកកា សោភ័ណដួងចិត្តនោះមែនទេ ? ការ ពិត ខ្ញុំធ្លាប់អានកំណាព្យរបស់នាងជាច្រើនមកហើយ ។ ខ្ញុំចូលចិត្ត ចិត្តពាក្យពេចន៍ទាំងឡាយដែលនាងសរសេរនោះណាស់ ព្រោះមាន

CHANBOKEO.COM

ទឹកដមទន់ភ្លន់ហើយមានមន្តស្នេហ៍ក្រៃលែង ។ នាងពិតជាមាន
ទេព្យកោសល្យគួរអោយចាប់អារម្មណ៍បំផុត...!

ពេលនោះ លោកវណ្ណៈក៏បើកទំព័រទំនេរមួយ សរសេរតបទៅ
កំណាព្យរបស់នាងមួយនោះភ្លាម ។

ក្រោយពីបានសរសេរកំណាព្យនេះរួចហើយ លោកវណ្ណៈក៏មាន អារម្មណ៍ថា
បេះដូងរបស់លោកហាក់ដូចជាទទួលភាពរមនាជាង មុនច្រើនណាស់ ។ លោកសំរាន្តកើយដៃ
សម្លឹងដំបូលពិដានម៉ក់ៗ យ៉ាងយូរ ស្រាប់តែស្ទុះដើបភឹង ដើរចុះទៅដី ដាស់ពូតឿ ៖
- ពូតឿ! មើលកូនចៅរបស់ខ្ញុំនិងយាយរៀមផង ។ ខ្ញុំចេញក្រៅ ក្រុងពីរបីថ្ងៃ ។ ប្រាប់ក្មេងផង
ថាកុំអោយគេបារម្ភអីឡើយ ។

ពូតឿក្រោកមកទាំងសើងមើង រួចលើកដៃមើលនាឡិកា ៖
- នេះម៉ោងមួយអាធ្រាតហើយ លោកប្រុស! បំរុងអញ្ជើញទៅណា ហ្នឹង ?

ប៉ុន្តែលោកវណ្ណៈមិនឆ្លើយទេ បែរជាហក់ចូលរថយន្ត បរយ៉ាង លឿនចេញទៅ ។
ពូតឿយកដៃអេះក្បាល ៖
- វេវវ៉ាវលឿនៗបែបនេះ គ្មានអ្វីក្រៅពីសន្ទុះកាំរន្ទះស្នេហាដុត រោលបេះដូងទេ...!
មានតែនាយតឿប៉ុណ្ណោះ ដែលមានសំណាង បានដេកឆ្អែត
ព្រោះមិនបាច់ព្រួយរលាកបេះដូងដោយរន្ទះស្នេហា!

ថាហើយ ពូតឿក៏ចូលសំរាន្តវិញទៅ ។

ភ្លឺស្រាងៗ មាន់រងាវ...

លោកវណ្ណៈក៏បានមកដល់ផ្ទះយាយខន ឃើញគាត់កំពុងលប់ មុខ ។
គ្រាន់តែឃើញរថយន្តលោកវណ្ណៈមកដល់ យាយខនភ្ញាក់ ក្រញាងធ្វើភ្នែកមូលក្រឡង់ ។
- ជំរាបសួរលោកអឺ! នាងយ៉ាសុខទុក្ខយ៉ាងម៉េចហើយ បាទ ?
- គឺ... ឃើញស្រួលជាងមុនបន្តិចហើយ នៅខាងលើឯណោះ សូមអញ្ជើញឡើងចូលលេង ។
- បាទ!

ស្រាប់តែនាងចិន្តាជាប្អូនដែលអង្គុយនៅមាត់ជណ្តើរបែរជាគ្រវី
ក្បាលយកដៃចង្អុលទៅក្រោយផ្ទះ និយាយត្រដិតៗថា ៖
- គឺបងយ៉ា នៅ... នៅ... នៅ... មាត់... មាត់ស្រះ...ក្នុង...ចំការ!
- អរគុណអូនដា!

CJIANBOKEO.COM

លោកវណ្ណៈឆ្លើយ រួចហើយក៏ស្ទុះដើររឹងសំដៅដីចំការក្រោយ
ផ្ទះ ស្រាប់តែប្រទះឃើញមាលាទីអង្គុយលើដងឈើមួយសម្លក់
សម្លឹងសត្វកញ្ចាញ់ចេកលោតទំលើស្លឹកព្រលិត ក្រោមសន្សើមព្រឹក ព្រលឹម ។
ថ្វីបើនាងអង្គុយដណ្តប់ក្រមា រំសាយកេសា មានភក្ត្រា ក្រៀមក្រំ
ប៉ុន្តែសោភណ៍របស់នាងបានអណ្តែតលេចធ្លោមកអង្អែល
បេះដូងរបស់លោកវណ្ណៈអោយរំភើបញាប់ញ័ររកថាមិនត្រូវ...

បុរសយើងឈរសម្លឹងនាងពីចំហៀងទៅយ៉ាងយូរ ទំរាំដាច់ចិត្ត ហៅឈ្មោះនារី ៖

- យ៉ា!

មាលាទីភ្ញាក់ព្រើត បែរមុខមកភ្លាម ។ គ្រាន់តែប្រទះឃើញ វត្តមានរបស់លោកវណ្ណៈ
នាងក៏បែរមុខគេចចេញយ៉ាងលឿន ។

- យ៉ា! នេះខ្ញុំមកសុំទោសនាងជាថ្មីណា៎! សូមទោសណា៎យ៉ា! អភ័យទោសអោយខ្ញុំបានទេ?
(លោកវណ្ណៈពោល)

ភ្លាមនោះ នាងយ៉ាឈ្ងោកមុខនៅស្ងៀមស្ងាត់ ។ បន្តិចមក លោកវណ្ណៈក៏មានប្រសាសន៍បន្តថា
៖

- តើអោយខ្ញុំធ្វើដូចម្តេច ដើម្បីអោយនាងរសាយចិត្តឈប់ខឹងនឹង ខ្ញុំតទៅទៀត... ?
ខ្ញុំពិតជាមានវិប្បដិសារីមែនណា៎យ៉ា... ពេលនេះ នាងឃើញនឹងភ្នែកហើយ នាងឈឺ...ខ្ញុំក៏ឈឺ...
នាងគេងមិនលក់... ខ្ញុំក៏គេងមិនលក់ដូចគ្នា... ជីវិតរបស់ខ្ញុំគ្មានសេចក្តីសុខទេ... តាំងពី
ពេលដែលនាងបោះជំហានដើរចេញពីផ្ទះខ្ញុំមក...

ទឹកភ្នែកពីរតំណក់ក៏ហូរស្រក់ចុះមកលើផ្ទៃមុខមាលាទី ៖

- នាងខ្ញុំគ្មានកិត្តិយសអ្វីនឹងទទួលពាក្យសុំទោសពីលោកទេ (នាង យ៉ាឆ្លើយកាត់) ជាតិជាអ្នកក្រ
អ្នកទន់ខ្សោយ គឺចាំតែរងទទួលការ រំលោភធ្វើបាបពីពពួកអ្នកមានតែម្យ៉ាងប៉ុណ្ណោះ
ថ្វីបើអ្នកក្រនោះជា មនុស្សសុចរិតល្អស្អាតយ៉ាងណាក៏ដោយ ។

លោកវណ្ណៈនៅស្ងៀម កាលបើឮនារីស្រដី ព្រោះយល់ថា ការ
ទុកពេលអោយនាងបាននិយាយចេញមក នឹងអាចសម្រាលនូវ កំហឹងក្នុងខ្លួននាងបាន ។
លុះឃើញនិតាស្ងាត់មាត់ទៅវិញ ទើប លោកស្រដីឡើងបន្ត ថា ៖

CHANBOKEO .COM

- នាងនិយាយត្រូវហើយ... ខ្ញុំបានរំលោភសិទ្ធិអ្នកក្រ អ្នកទន់ ខ្សោយជាងខ្ញុំពិតមែន... តែពេលនេះ ខ្ញុំក៏បានដឹងខ្លួន ហើយក៏ មានវិប្បដិសារីណាស់ ទើបចូលខ្លួនមកសុំការអភ័យទោសពីនាង...

- គ្រាន់តែពាក្យសុំទោសមួយម៉ាត់ វាមិនអាចព្យាបាលការឈឺចាប់ របស់អ្នករងគ្រោះបានទេ..! ហើយក៏មិនបានបញ្ជាក់ថាលោកនឹងកែ ប្រែចរិតរបស់លោករៀងទៅដែរ ។

- ឥចឹង តើខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីរំសាយការឈឺចាប់របស់នាង ?

- គឺលុតជង្គង់សុំទោសនាងខ្ញុំហើយលើកដៃសំពះផង មិនមែនឈរ ដូចឯងទង់ជាតិសុំទោសនោះទេ! ពុំនោះសោត យើងគ្មានអ្វីត្រូវ និយាយគ្នាតទៅទៀតឡើយ ។ ចំណែកថ្លៃប្រាក់ខែដែលខ្ញុំធ្វើការជូន លោករួចមកហើយនោះ នាងខ្ញុំមិនយកទេ សូមបូជាជូនព្រះសំរាប់ លាងជាតិអសុរីនៅក្នុងខ្លួនរបស់លោកចុះ ។

លោកវណ្ណៈភ្ញាក់ក្រញាង កាលបើឮប្រយោគនោះ ។ មែន ហើយ លោកជាបុរសទ្វេងប្រាំហត្ថ មានវណ្ណៈឋានៈគ្រាន់បើម្នាក់ ហេតុអ្វីត្រូវមកលុតជង្គង់សុំទោសនារីជនបទដ៏សាមញ្ញ ដូចនាងយ៉ាងនោះ ? តាំងពីក្មេងមក លោកមិនដែលលុតជង្គង់ដើម្បីស្រីណាទេ... តើអោយលោកធ្វើយ៉ាងម៉េចកើត ? មើលទៅនារីចុះ! គេមានវ័យ ត្រឹមតែ២៤ឆ្នាំ ចំណែកលោកវិញ ដល់ទៅ៤០ឆ្នាំ ខុសគ្នាដូចឪពុក និងកូន តើអោយបុរសចាស់ដូចឪពុកលុតជង្គង់សុំទោសកូនយ៉ាង ណា ? តើខ្មែរទូទៅគេនឹងចំអករូបលោកយ៉ាងណា បើសិនគេដឹង ថា លោកលុតជង្គង់សារភាពចំពោះស្ត្រីក្មេងម្នាក់ ?

លោកវណ្ណៈឈរធ្មឹងគិតពិចារណាតែក្នុងចិត្តមិនហ៊ានមាត់ តែក៏ មិនធ្វើតាមនាងដែរ ។ រំពេចនោះ ស្រាប់តែ ៖

- លោកប៉ា! បងយ៉ា!

អ្នកទាំងពីរភ្ញាក់ព្រើត បែរក្រោយឃើញកូនប្រុសស្រីទាំងបី របស់លោកវណ្ណៈរត់មកដល់ ។ លោកវណ្ណៈភ្ញាក់ស្រឡាំងកាំងកាល បើឃើញវត្តមានរបស់កូនទាំងព្រហាម ៖

- ហេតុដូចម្ដេចបានជាកូនមកដល់ទីនេះដែរ ?

- គឺពួកយើងទទួចសុំអោយយាយរៀមនិងពូតឿជូនមក ក៏នាំគ្នា ឡើងតាក់ស៊ីមកទាំងយប់ (នាងតូចវណ្ណនីឆ្លើយ)

- ពុទ្ធោ កូនប៉ា! ហេតុអ្វីកូនធ្វើដល់ម្លឹងផង ?

CHANBOKEO.COM

- គឺកូនទាំងអស់មកសុំអោយលោកប៉ានិងបងយ៉ាត្រឡប់ទៅផ្ទះ !

លោកវណ្ណៈឮដូច្នោះ ក៏ចោលកន្ទុយភ្នែកលួចមើលទៅនាងយ៉ា រួចហើយក៏ឆ្លើយថា ៖

- បងកំពុងខឹងនឹងប៉ា... គេត្រូវការពេលវេលារំសាយចិត្តណាកូន!

- ប៉ុន្តែ... ខ្ញុំចង់អោយបងយ៉ាត្រឡប់ទៅវិញ... បើគាត់មិនព្រម ត្រឡប់ទៅទេ...កូនច្បាស់ជាបាត់បង់លោកប៉ាម្នាក់ទៀតហើយ!

- ហេតុអ្វីនិយាយដូច្នេះកូន ? ប៉ាមិនទៅណាចោលកូនទេ!

- ប៉ុន្តែពេលបងយ៉ាមិននៅ... ប៉ាបានគេចពីកូនៗ មករកបងយ៉ា នៅទីនេះ... ហើយកូនក៏បាត់បង់អ្នកទាំងពីរទៅ ព្រមគ្នាតែម្តង... ធ្វើឲ្យផ្ទះយើងស្ងាត់ក្រៀមក្រំណាស់ ។

ភ្លាមនោះអ្នកទាំងបីក៏រត់ទៅចោមរោមនាងយ៉ា ។ វណ្ណនេត្រ ស្រដីឡើងថា ៖

- យើងទាំងអស់និកហើយបារម្ភពីបងណាស់ បងយ៉ា!

- បងក៏នឹកអ្នកទាំងអស់គ្នាដែរ (នាងយ៉ាតប)

- បើបងនឹកប្អូនៗពិតមែន បងត្រូវត្រឡប់ទៅផ្ទះវិញណា ។

ឮដូច្នោះ នាងយ៉ាចោលកន្ទុយភ្នែកលួចសម្លឹងលោកវណ្ណៈដែល នៅឈរស្ងៀមស្ងាត់ ក្បែរៗនោះ រួចហើយក៏បែរឆ្លើយទៅវិញថា៖

- ទីនេះ គឺជាផ្ទះរបស់បងហើយតើហ៍...!

- អត់ទេ! គឺបងយ៉ាទៅផ្ទះយើង ឯភ្នំពេញវិញ ។

- បងទៅមិនបានទេ ប្រុសតូច ។

- ហេតុអ្វីមិនបាន...បងយ៉ា ?

មាណវីនៅស្ងៀម... មិនដឹងថារកនឹកឆ្លើយយ៉ាងណាអោយសម ស្រាប់តែលោកវណ្ណៈមានប្រសាសន៍ថា ៖

- គឺបងនៅខឹង មិនទាន់អាចអភ័យទោសអោយប៉ានៅឡើយ!

រំពេចនោះក្មេងក៏អង្វរនាងយ៉ាទាំងអស់គ្នា ។

- ត្រឡប់ទៅវិញទៅណាបងណា! ឲ្យប្អូនសូមអង្វរបងចុះ សូម បងអភ័យទោសអោយលោកប៉ាផង... បងឃើញទេ លោកអត់ ដងុយ មិនបានសំរាន្តពីរថ្ងៃជាប់គ្នាហើយ ព្រោះតែលោកចង់មកសុំ ទោសបង ។

CHANBOKEO.COM

ពួកខ្ញុំអាណិតលោកប៉ាណាស់! បងយ៉ាក៏មានចិត្ត ទូលាយ ។
ខ្ញុំជឿថាបងអភ័យទោសអោយលោកប៉ាបាន! ណា៎ ណា៎ បងយ៉ា!

ទាំងបីនាក់ដណ្ដើមគ្នានិយាយទាំងរលីងរលោងទឹកភ្នែក ធ្វើឲ្យនាងយ៉ាអាណិតក្មេងៗគ្រលួចក្នុងចិត្ត ។

- ចា៎ស! បងអភ័យទោសជូនលោកប៉ារបស់ប្អូនបាន! បងឈប់ ខឹងហើយ... ប្អូនឈប់ស្រក់ទឹកភ្នែកទៅ ។

ក្មេងទាំងអស់ក៏ញញឹមទាំងទឹកភ្នែក ។ រីឯលោកវណ្ណៈក៏បង្ហាញនូវភាពញញឹមតាមរយៈក្រសែភ្នែករបស់លោកដែរ ថ្វីបើលោកនៅសម្ដែងទឹកមុខស្ងើៗនៅឡើយ ។

- អញ្ចឹង បងទៅផ្ទះជាមួយយើងពេលនេះណា៎! (វណ្ណនីវាចា)
- អត់ទេ! បងទៅមិនបានទេ...!
- ហេតុអ្វីទៅ ? ក្រែងបងថា បងអភ័យទោសអោយលោកប៉ា ហើយ មិនមែនទេ ?
- ចា៎ស មែនហើយ ប៉ុន្តែ បងមានស្នាមរបួសពេញខ្លួនដោយអំពើ ហឹង្សាមិនទាន់ជាសះស្បើយនៅឡើយទេ ហើយបេះដូងរបស់បងក៏ភ័យរន្ធត់តក់ស្លុតដោយអំពើហឹង្សានោះ មិនទាន់បាត់នៅឡើយ ដែរ ។ បងគ្មានសេចក្ដីក្លាហានគ្រប់គ្រាន់ សំរាប់ប្រឈមមុខនឹង អំពើកម្រោលមកលើខ្លួនបងថែមទៀតទេ...

លោកវណ្ណៈក៏ឆ្លើយ យ៉ាងរហ័ស ថា ៖

- ឲ្យខ្ញុំសូមស្បថជូននាងចុះ ថាខ្ញុំសូមលះបង់នូវភាពកំរោលនោះ ចេញពីក្នុងជីវិតហើយ សន្យាថាមិនអោយវិលមកវិញជាលើកទីពីរ ទៀតទេ អោយតែនាងសុខចិត្តត្រឡប់ទៅផ្ទះយើងវិញចុះណា៎!

នាងយ៉ាងើបមុខឡើងសម្លឹងលោកវណ្ណៈដោយក្រសែភ្នែកយ៉ាង មុតហាក់ដូចជាលែងខ្លាចចិត្តលោកទៀតហើយ រួចហើយក៏វាចា ឡើងថា ៖

- គ្រាន់តែពាក្យសូមទោសនិងពាក្យស្បថ គឺនរណាក៏អាចធ្វើបានដែរ ប៉ុន្តែ ការប្រព្រឹត្តវិញទេតើ ដែលគ្មាននរណាអាចអនុវត្តន៍បានអោយដូចពាក្យសន្យាឬពាក្យសម្បថរបស់ខ្លួនបាន!!
- តែខ្ញុំនឹងបង្ហាញនាងថា ខ្ញុំពិតជាអាចធ្វើបាន!

CHANBOKEO.COM

- បើធ្វើបានមែន មិនបាច់ចាំថ្ងៃក្រោយទេ... លោកធ្វើបង្ហាញឥឡូវ
នេះអោយនាងខ្ញុំបានឃើញនឹងភ្នែកម៉ក ទាន់មានសាក្សីនៅនឹង មុខ ដើម្បីអោយជួយចងចាំថា
លោកនិយាយពិត មិនភូតកុហក!!
- ឥឡូវប្រាប់មក ខ្ញុំនឹងអនុវត្តន៍តាមភ្លាម ដើម្បីបញ្ជាក់ថា ខ្ញុំកំពុង
លាងកំហុសរបស់ខ្ញុំពិតមែន ។
- បើដូច្នោះ លោកលុតជង្គង់សុំទោសនាងខ្ញុំភ្លាមទៅ នោះខ្ញុំនឹង គិតថា
លោកពិតជាទទួលស្គាល់កំហុសរបស់លោក ហើយកែ មិនអោយ
មានជាលើកទីពីរចំពោះខ្ញុំទៀត ។
ពេលនោះ លោកវណ្ណៈឈរទ្រឹង... ធ្វើអេះអុញទៀតហើយ ។
កូនៗទាំងបីនាក់របស់លោកវណ្ណៈ ខ្លាចឪពុកត្រូវបាក់មុខដោយមក ត្រូវលុតជង្គងសុំទោសនារី
គេក៏នាំគ្នាលុតជង្គង់ព្រោងព្រាត ៖
- ពួកយើងទាំងបីសូមលុតជង្គង់ជំនួសលោកប៉ា សូមទោសបងយ៉ា ចំពោះអ្វីៗទាំងអស់ដែល...
- អត់ទេ...! ប្អូនមិនបានធ្វើខុស... បងទទួលមិនបានទេ (នាង
យ៉ាយកដៃចាប់អោយក្មេងងើបឈរ) បងទទួលយកការសុំទោសពី
អ្នកដែលបានធ្វើខុសប៉ុណ្ណោះ ។
- បងយ៉ា! ហេតុអ្វីក៏បងមានចិត្តរឹងត្អឹងចំពោះលោកប៉ាម្ល៉េះ?
ហេតុអ្វីក៏បងលែងទន់ភ្លន់ដូចបងយ៉ារបស់ខ្ញុំពីមុនអញ្ចឹង?
វណ្ណនីស្រដីឡើងទាំងរលីងរលោងទឹកភ្នែក ព្រោះអាណិតឪពុក នាង ។ ឯពីរនាក់ទៀត
ក៏យកដៃផ្ទិតទឹកភ្នែកដែរ ។
នាងយ៉ាឃើញដូច្នោះ ក៏វាចាសួរក្មេងៗថា ៖
- ចុះលោកប៉ារបស់ប្អូនមានទន់ភ្លន់ដាក់បងវិញទេ? លោកប៉ាមាន តែបង្ខំបងអោយធ្វើតាមចិត្ត
តាមអារម្មណ៍របស់លោក ប៉ុន្តែមាន ដងណាដែលលោកគិតពីចិត្តបង អារម្មណ៍បងទេ? ឬក៏អោយ
បងស្តាប់បញ្ជាលោកតែម្ខាង ហើយធ្វើខ្លួនជាអ្នកចាញ់លោកប៉ារហូត
សូម្បីតែបងគ្មានកំហុសក៏ដោយ? ចំណែកអូនទាំងអស់គ្នាក៏ចង់ឲ្យ បងតម្រូវតាមចិត្តអូន
តាមអារម្មណ៍អូន... ប៉ុន្តែ តើអូនមានគិត នូវអារម្មណ៍ឈឺចាប់និងការភ័យខ្លាចរបស់បងទេ
ដែលបងត្រូវទៅ រស់នៅឆ្ងាយផ្ទះឆ្ងាយក្រុមគ្រួសារតែម្នាក់ឯង ហើយត្រូវគេប្រើ ហឹង្សា
ធ្វើបាបដោយអយុត្តិធម៌ដូច្នោះ? បើប្អូនៗជារូបបងវិញ តើប្អូនមានអារម្មណ៍យ៉ាងណា?

CHANBOKEO.COM

តើប្អូនតម្រូវឲ្យអ្នកដែលធ្វើបាប ប្អូនធ្វើយ៉ាងណាវិញ ទើបប្អូនរសាយចិត្តខឹង ? ត្រឹមពាក្យសុំទោសមួយម៉ាត់ តើសមនឹងរបួសដួលដំដែលប្អូនបានទទួលទេ ?

ថាហើយ នាងយ៉ាឈ្ងោកមុខស្រក់ទឹកភ្នែក អួលដើមក ស្ដីអ្វី តទៅទៀតលែងរួច ហើយក៏ងាកគេចបែរមុខចេញ ។ សំដីប៉ុន្មាន ម៉ាត់ចុងក្រោយបានច្របាច់បេះដូងរបស់លោកវណ្ណៈស្ទើរខ្ទេចខ្ទាំ ទៅហើយ ព្រោះលោកបានឮពេញត្រចៀក នូវអារម្មណ៍របស់នារី រងគ្រោះមួយរូប ។ វណ្ណនី វណ្ណនេត្រនិងនាងតូចវណ្ណាក៏ឈរកាន់ ដៃគ្នាធ្វើមុខស្រងូត ព្រោះគេមិនដឹងថា ត្រូវធ្វើយ៉ាងណាទៀត ។

ភ្លាមនោះ លោកវណ្ណៈក៏ទាញកូនទាំងបីអោយថយក្រោយ រួច ហើយឈរស្ងៀមស្ងាត់ ។ នៅក្នុងចិត្ត លោកពិចារណាថា ៖

- តើយើងត្រូវសំដែងខ្លួនជាបុរសពើងទ្រូង មិនព្រមចុះញ៉មស្ត្រី រួចបែរក្រោយ នាំកូនទៅផ្ទះវិញដោយមិនបាច់លុតជង្គង់សុំទោស នារី កុំឲ្យញាតិសើចចំអកឆ្កួយពោះ ឬក៏... យើងត្រូវលុតជង្គង់ចុះ ទទួលការសើចចំអក ដើម្បីរំលត់កំហឹងនិងការឈឺចាប់របស់នារីម្នាក់ហើយស្រវាចាប់យកភាពរមនាក្នុងគ្រួសារសាជាថ្មី ?... បើសិនជាយើងប្រឹងរក្សាកិត្តិយសបុរស មិនព្រមលុតជង្គង់ចុះ ព្រោះខ្លាច ញាតិសើចយំ យើងនឹងកូនត្រូវត្រឡប់ទៅផ្ទះវិញ ដោយគ្មាននាង យ៉ា ។ ពេលនោះ ផ្ទះយើងនឹងក្លាយមកជាស្ងាត់ក្រៀមក្រំដូចពីដើម វិញ ។ ចំណែកគ្រួសារយើងនិងគ្រួសារនាងយ៉ាក៏នឹងមានអរិចិត្ត ចំពោះគ្នាមួយជីវិត ។ ពេលនោះ ប្រវត្តិគ្រួសាររបស់យើងក៏ចោល ក្លិនអាសោចន៍ ព្រោះតែភាពមិនប្រពៃនៃមេគ្រួសារ ព្រោះយើងមិនបានកែប្រែស្ថានភាពគ្រួសារ និងកំហុសរបស់ខ្លួនឲ្យប្រសើរ ឡើង ។ ប៉ុន្តែ បើសិនជាយើងកាត់កេរ្តិ៍ខ្មាស ស្ម័គ្រចិត្តលុតជង្គង់ សុំទោស នាងយ៉ាច្បាស់ជារសាយកំហឹង រួចហើយវិលមករស់នៅ ផ្ទះយើងដូចពីដើមវិញ ។ ភាពរមនាក៏កើតមានសាជាថ្មីក្នុងគ្រួសារយើង... ហើយកូនរបស់យើងទាំងអស់ក៏នឹងរីករាយដូចពីដើមវិញ ដែរ ព្រោះយើងលែងមានកំហឹងគុំគួននឹងគ្នា លែងមានអរិចិត្ត តទៅទៀត ។ កាលបើកូនរបស់យើងមានសេចក្ដីសុខ យើងក៏មាន សេចក្ដីសុខដូចគ្នាដែរ ទោះបីញាតិនៅតែសើចចំអកបន្តុះបង្អាប់ ថាយើងលុតជង្គង់ ដើម្បីស្រីម្នាក់ក៏ដោយ ។ គិតទៅ បែរទៅទិស ណាក៏ញាតិនៅចាំសើចចំអកយើងដដែលហ្នឹង ។ បើដូច្នោះ យើង

CHANBOKEO.COM

ចាំបាច់ទៅគិតខ្វល់ពីការសើចចំអករបស់ញាតិធ្វើអ្វី គិតតែពីជ្រើស រើសផ្លូវណាដែលនាំឲ្យគ្រួសារមានសុភមង្គលរមនានោះទៅ គឺត្រឹម ត្រូវហើយ ។

ភ្លាមនោះ លោកវណ្ណៈក៏យកដៃជូតញើសពីថ្ងាស រួចក៏ដើរទៅ ជិតនាងយ៉ា ។

- លោកប៉ា ? (កូនទាំងបីឧទានព្រមគ្នា ទំនងដឹងថា ឪពុករបស់ គេកំពុងកាត់អាមាសក្នុងចិត្ត លុតជង្គង់សុំទោសនាងយ៉ា)

- មិនអីទេកូន! ដើម្បីកូន... ដើម្បីគ្រួសារយើង ប៉ាអាចធ្វើបាន!

មានប្រសាសន៍រួចហើយ លោកវណ្ណៈក៏សំរុតខ្លួនដាក់ជង្គង់ចុះ ទៅលើដី ធ្វើអោយកូនរបស់លោកទាំងបីភ្ញាក់ក្រញាង ដោយឃើញ ឪពុករបស់គេហ៊ានធ្វើដូច្នោះ ។ បន្ទាប់មក លោកវណ្ណៈក៏មាន ប្រសាសន៍បន្ត ថា ៖

- ចរិយា! សូមនាងទទួលយកនូវការសុំទោសពីខ្ញុំ ហើយសូម រំសាយកំហឹងទៅណា៎ ហើយសូមអធ្យាស្រ័យដល់ខ្ញុំផង!

នាងយ៉ាភ្ញាក់ព្រើតបែរមុខមក ដោយឮលោកវណ្ណៈហៅឈ្មោះ ពិតរបស់នាង ។

- ប៉ុន្តែ នាងខ្ញុំមិនទាន់អាចទទួលបាននៅឡើយទេ!

លោកវណ្ណៈបើកភ្នែកមូលក្រឡង់ ពេលឮនាងយ៉ាពោលដូច្នោះ រួចនឹកខកចិត្តស្រឡេតតែម្តង ។ ស្រាប់តែនាងពោលបន្តថា ៖

- បើសិនជាលោកលុតជង្គង់ចុះ ដើម្បីកូនរបស់លោក ខ្ញុំទទួលមិន បានទេ ព្រោះបើសិនថ្ងៃណាមួយកូនរបស់លោកមិនពេញចិត្តរូបខ្ញុំ ដោយប្រការណាមួយ លោកច្បាស់ជាកាន់ជើងពួកគេ រួចដះកំហឹង មកលើនាងខ្ញុំទៀតមិនខាន ។

- អញ្ចឹង នាងអោយខ្ញុំធ្វើយ៉ាងណាវិញ ?

- ធ្វើយ៉ាងណាក៏បានដែរ ដើម្បីឲ្យនាងខ្ញុំបានទទួលនូវភាពកក់ក្តៅ ក្នុងចិត្តមកវិញ ។

លោកវណ្ណៈលេបទឹកមាត់ផ្ញើមបំពង់ក្លឹកទើបពោលសាជាថ្មី ៖

- ចរិយា! វណ្ណៈខ្ញុំសូមលុតជង្គង់ថ្វាយព្រះរតនត្រ័យ សច្ចាថានឹង លះបង់ចិត្តនិងការប្រព្រឹត្តអំពើហឹង្សា ហើយកែប្រែស្ថានភាព គ្រួសារដើម្បីគ្រប់ៗគ្នាដែលរស់នៅក្នុងផ្ទះ មានសេចក្តីសុខរមនា និងមានសុវត្ថិភាពរៀងរហូតទៅ រួមទាំងចរិយាផង!

CHANBOKEO.COM

រំពេចនោះ ស្នាមញញឹមបានវិលមករកផ្ទៃមុខរបស់ធិតាយើង ដូចដប់ភ្លាមតែម្តង ។ នាងយ៉ាក៏ស្រដីឡើងដោយដួងចិត្តស្រឡះ ស្រោកស្រោនគ្គពីកំហឹងចំពោះលោកវណ្ណៈ ៖

- អរគុណណាស់ ដែលលោកលុតជង្គង់ថ្វាយរតនត្រ័យ សច្ចាលះបង់ចិត្តនិងអំពើហឹង្សាចោលចាប់ពីថ្ងៃនេះតទៅ ។ ខ្ញុំសង្ឃឹមថាភាពហឹង្សានឹងរលត់បាត់ពីបេះដូងរបស់លោកជានិរន្តន៍ ។

លោកវណ្ណៈសម្លឹងមុខនាង សម្តែងភាពស្មោះត្រង់ ៖

- មិនមានជាលើកទីពីរទៀតទេ ចរិយា! ខ្ញុំសន្យា!

ក្មេងទាំងបីនាក់ក៏ញញឹមឡើងទាំងទឹកភ្នែករលីងរលោង ដោយក្តីរំភើបត្រេកអរ ។ លោកវណ្ណៈក៏ងើបឈរឡើង ហុចដៃអោយនាងយ៉ា ដើម្បីតោងឈរឡើង ៖

- ម៉ោះ! ទៅផ្ទះយើងវិញ ?

- ផ្ទះយើង ? (នាងយ៉ាលាន់មាត់)

- មែនហើយ គឺផ្ទះយើងនៅភ្នំពេញនោះអី!

ចរិយាជ្រួញចិញ្ចើម ៖

- ជាផ្ទះរបស់លោក មិនមែនផ្ទះរបស់ខ្ញុំទេ...

- ប៉ុន្តែ នាងក៏ជាអ្នកផ្ទះនោះដែរ... ដឹងហើយនៅ ?

ឃើញនារីនៅអេះអុញមិនព្រមតោងដៃ លោកក៏លូកដៃទៅស្រវាចាប់ដៃរបស់ធិតាអោយងើបឡើង ៖

- ម៉ោះ! ងើបឡើងមក៉!

ពេលនេះ មាណវីមិនប្រកែកទេ ក៏បណ្តោយអោយលោកវណ្ណៈទាញដៃអោយងើបតាមសម្រួល ។ តាមផ្លូវមកផ្ទះវិញ លោកវណ្ណៈ ដើរកាន់ដៃនារីមិនរបេះសោះ ថ្វីបើនាងខំរលាស់ចេញជាច្រើនដង ក៏ដោយ ។ ពេលនោះ ចរិយានឹកភ័យញ័រខ្លួនគគ្រឹកផង ខ្មាសអៀន ផង ដូចជានឹកចម្លែកក្នុងខ្លួនយ៉ាងណាមិនដឹង ។ ឯក្មេងទាំងបីនាក់នោះវិញក៏សប្បាយចិត្តណាស់ ដោយឃើញអ្នកទាំងពីរត្រូវរ៉ូវគ្នា ។ លោកវណ្ណៈដើរបណ្តើរលួចបែរមុខញញឹមដាក់ចរិយាបណ្តើរ ទំនង ហាក់ដូចជារំភើបចិត្តដែលលោកនិងក្រុមគ្រួសារកំពុងធ្វើដំណើរ ឈានទៅរកសុភមង្គលថ្មីមួយ ។

CHANBOKEO . COM

ដើរមិនទាន់មកដល់ផ្ទះយាយខនវិញផង ស្រាប់តែលោកវណ្ណៈ
មានអារម្មណ៍នឹងឆោងងងឹតមុខឃើង ទប់ខ្លួនមិនរួច ក៏ដួលប្រូស ទៅដី បាត់មាត់ឃើងតែម្តង ។

- លោកប្រុស ? លោកប្រុស ?
- លោកប៉ា! លោកប៉ា....!!

ទាំងអស់គ្នាឧទានហៅលោកវណ្ណៈដោយភិតភ័យតក្កមា ។

លោកវណ្ណៈប្រែខ្លួនឡើងសាជាថ្មី ឃើញខ្លួនលោកនៅលើ កន្ទេល
មានញាតិរហង់នៅអង្គុយជុំជិត ។

- លោកប្រុស! ដឹងខ្លួនហើយហ្អេស ?
- យាយរៀម ?
- ចាំស! នេះលោកអត់ងងុយពីរយប់មកហើយណាំ ទើបក្លាយជា ខ្យល់គ របៀបនេះ ។
- ហើយ... ខ្ញុំនៅឯណាហ្នឹង ?
- នៅលើផ្ទះយាយខន ។ លោកបាត់មាត់បាត់កច្រើនម៉ោងហើយ... មើលហ្ន៎ក!

ពួកគេភិតភ័យព្រួយបារម្ភចំពោះលោកគ្រប់ៗគ្នា ។

លោកវណ្ណៈរេភ្នែកបែរមើលជុំវិញខ្លួន ៖

- ចរិយា... ហើយនិងកូនរបស់ខ្ញុំ ទៅណាហើយ ?
- ពួកគេនៅខាងនោះ ។

លោកវណ្ណៈបែរទៅម្ខាង ឃើញនាងយ៉ានិងកូនៗអង្គុយធ្វើមុខ
ស្ងួត ដោយក្តីព្រួយបារម្ភពីលោក ។ កាលបើឃើញឪពុកដឹងខ្លួនមក វិញ
ក្មេងៗក៏នាំគ្នាញញឹមឡើង ហើយរត់មកអោបលោកគ្រប់គ្នា ។
លុះឃើញបរិយាកាសគ្រួសារមានភាពរមនាវិញហើយ ចាស់ៗក៏ លែងនៅរំខានតទៅទៀត
ហើយក៏នាំគ្នាគេចចុះទៅដីអស់ទៅ ។

បន្តិចមក លោកវណ្ណៈក៏មានប្រសាសន៍ប្រាប់កូនៗថា ៖

- អោយប៉ាសុំនិយាយគ្នាជាមួយបងយ៉ា តែពីរនាក់សិនបានទេ ?
កូនចុះទៅលេងនៅខាងក្រោមសិនទៅណាំ!

ក្មេងទាំងបីលួចចោលកន្ទុយភ្នែកដាក់នាងយ៉ា រួចហើយក៏នាំគ្នា
ដើបចេញទៅភ្លាម ។

- ចរិយា! មកជិតខ្ញុំបន្តិចបានទេ ?

CHANBOKEO.COM

នាងយ៉ាដើបឡើង ធ្វើកិរិយាអេះអុញ ព្រោះនាងមានអារម្មណ៍ ចម្លែកយ៉ាងណាមិនដឹង ដែលឃើញលោកវណ្ណៈផ្តល់សម្ពន្ធ័ពិសេស ចំពោះនាង ។ បន្តិចមក លោកវណ្ណៈក៏ប្រឹងដើបអង្គុយ ៖

- នាងមកជិតខ្ញុំបន្តិចមក៏!

ចរិយាដើបលូនទៅដាក់ខ្លួនជិត ស្រាប់តែឃើញលោកលូកដៃ ម្ខាងរាវក្នុងហោប៉ៅ រួចហើយយកដៃម្ខាងទៀតស្រវាចាប់ដៃរបស់ នាង ។ ឃើញដូច្នោះ មាណវីកញ្ឆក់ដកដៃយ៉ាងរហ័ស ព្រោះមិន ចង់អោយលោកវណ្ណៈកាន់ដៃនាងទេ ស្រាប់តែ ៖

- ហុចដៃមក៏! ខ្ញុំមានអ្វីសងនាងវិញណា៎ យ៉ា!!

ធិតាដើបមើលមុខលោកវណ្ណៈ ដែលសម្លឹងមកនាងដោយខ្សែ ភ្នែកយ៉ាងស្រទន់ ។ ចរិយាក៏លើកដៃហុចសន្សឹមៗទំនងខ្លាចចិត្ត ។ លោកវណ្ណៈទទួលដៃនាងហើយ ក៏បំពាក់ខ្សែដៃមាសដែលលោក បានដោះពីដៃរបស់នាង កាលពីថ្ងៃមុននោះអោយវិញ ៖

- សូមទោសណា៎ ដែលខ្ញុំមានការយល់ច្រឡំទៅលើនាង!

ធិតាធ្វើមុខញញឹមដោយក្តីសោមនស្ស ព្រោះបានទទួលខ្សែដៃ ដែលជាកេរ្តិ៍មរតករបស់ម្តាយនាងមកវិញ ។

- ឯណា ដៃម្ខាងទៀត ? (លោកវណ្ណៈសួរ)

ចរិយាភ្ញាក់ព្រើត តែលោកវណ្ណៈមិនស្រដីច្រើនទេ បែរជា ស្រវាចាប់ដៃរបស់នាងម្ខាងទៀតចេញមក ហើយក៏ទាញខ្សែដៃមួយ ទៀតដែលមានក្បាច់រចនាស្រដៀងគ្នានោះ ទៅបំពាក់អោយមាណវី បន្ថែម ។

- នេះ មិនមែនជាខ្សែដៃរបស់ខ្ញុំទេ លោកប្រុស!

ចរិយាឧទានឡើង ។ លោកវណ្ណៈញញឹមហើយឆ្លើយថា ៖

- បន្ទាប់ពីពាក់ជាប់ដៃ យ៉ានិងក្លាយជាម្ចាស់របស់វាហើយ!

មាណវីសម្លឹងមុខលោកវណ្ណៈទំនងងឿងឆ្ងល់ ។ លោកក៏មាន ប្រសាសន៍ថា ៖

- ការពិត ខ្សែដៃនេះគឺជារបស់ប្រពន្ធខ្ញុំមែន តែពេលនេះ ខ្ញុំគិត ថា យ៉ាសក្តិសមធ្វើជាម្ចាស់ជំនួសអ្នកកន្និដ្ឋាហើយ ទើប....

- ប៉ុន្តែ... នាងខ្ញុំមិនមែនជាភរិយារបស់លោកទេ ។

- បើមិនមែន... យ៉ារៀបការនឹងខ្ញុំទៅ នោះនាងនឹងក្លាយជាប្រពន្ធ ខ្ញុំហើយ...

- កុំនិយាយលលេងដូច្នេះ លោកប្រុស!

CHANBOKEO.COM

- ខ្ញុំនិយាយមែនណា៎! យើងរៀបការនឹងគ្នាបានទេ យ៉ា ?
- អត់ទេ! លោកប្រុស! កុំនិយាយលេងសើចអញ្ចឹងអី ។
- មិនបានលលេងទេ គឺខ្ញុំនិយាយមែន!!
- ពុទ្ធោ! គ្មាននរណារៀបការដោយមិនបានស្រឡាញ់គ្នានោះទេ
- អញ្ចឹង យើងចាប់ផ្តើមស្រឡាញ់គ្នាពេលហ្នឹងទៅ!
- អត់ទេ លោកប្រុស! ថ្ងៃនេះ លោកប្រុសមិនស្រួលខ្លួន និយាយរវើរវាយណាស់! ខ្ញុំសុំខ្លួនទៅតាមយាយរៀមសិន!
- មិនរវើរវាយទេ គឺខ្ញុំនិយាយការពិត!
- យ៉ា! ឈប់នៅស្តាប់លោកប្រុសហើយ!

ចរិយាដើបឡើងបំរុងគេចខ្លួនចេញទៅ តែលោកវណ្ណៈស្រវា ចាប់ដៃនាងជាប់ ៖

- ឈប់សិន! នៅមានរឿងមួយទៀត ដែលខ្ញុំចង់សួរនាង!

ចរិយាឮហើយ ក៏ដាក់ខ្លួនចុះវិញ ។

- លោកមានការអ្វីដែរ ចា៎ស ?
- ក្រែងនាងចង់ធ្វើគ្រូមែនទេ ?

ចរិយាបើកភ្នែកម្លូលក្រឡង់ ៖

- ចា៎ស មែនហើយ ? ម៉េចក៏លោកជ្រាបរឿងនេះ ?
- កុំខ្វល់អីថាខ្ញុំដឹងដោយរបៀបណា ដែលសំខាន់នោះគឺខ្ញុំចង់ ជួយអោយក្តីស្រម័យរបស់នាងបានក្លាយជាការពិត ។
- ប៉ុន្តែ ខ្ញុំគ្មានសង្ឃឹមថាអាចទៅរួចទេ ព្រោះគ្រួសារខ្ញុំក្រណាស់ ។ យើងបានកាត់ដីចំការលក់ជិតអស់ទៅហើយ ដើម្បីជួយអោយប្អូន ចា៉ាន់រៀន ពេលនេះគ្មានសមត្ថភាពអាចទៅរួចទេ ។
- ម្តេចក៏នាងព្រមចុះចាញ់ ដោយមិនបានពុះពារអញ្ចឹង ? នាងចាំ ទេ ថានាងជាអ្នកសរសេរប្រយោគមួយនោះនៅលើក្តារខៀនក្នុង រោងស្បូវក្នុងដីចំការរបស់នាង ?

ភ្លាមនោះ ចរិយានឹកភ្នកដល់ឃ្លាដែលនាងធ្លាប់សរសេរថា ៖

- ដើម្បីជោគជ័យ យើងត្រូវតែមានសេចក្តីសង្ឃឹម! ដើម្បីអោយ ក្តីសង្ឃឹមមានរូបរាង យើងត្រូវតែខំពុះពារ ។ បើសិនជារាថយ មិនពុះពារ យើងនឹងក្លាយជាអ្នកចាញ់រហូត មិនអាចរកជោគជ័យ ឃើញឡើយ ។

CHANBOKEO.COM

លោកវណ្ណៈក៏មានប្រសាសន៍បន្តថា :

- តើនាងហ៊ានពុះពារដូចពាក្យនាងសរសេរនោះទេ ?

- មិនខ្លាចទេ... ប៉ុន្តែ ខ្ញុំក្រណាស់ មានប្រាក់អ្វីបង់សាលាទៅ ?

លោកវណ្ណៈក៏មានប្រសាសន៍ឡើង ថា ៖

- ថ្វីបើនាងគ្មានប្រាក់ តែនាងមានប្រាជ្ញានិងសម្បទា ព្រមទាំងមាន សន្តានចិត្តល្អជាមួយក្មេងៗ ។ ខ្ញុំថានាងអាចធ្វើគ្រូបានយ៉ាងល្អ ។ ហើយបើសិនជាអ្នកស្មគ្រ័ពុះពារ ខ្ញុំមានមធ្យោបាយជួយនាងអោយ ធ្វើគ្រូបាន ។

- តើធ្វើគ្រូយ៉ាងណា បើខ្ញុំរៀនមិនចប់មធ្យមសិក្សាផង ?

- បើធ្វើគ្រូមិនបាន  នាងធ្វើម្តាយរបស់កូនខ្ញុំទៅ យ៉ាងម៉េចដែរ ?

- ទៀតហើយ លោកប្រុស! និយាយទៅ និយាយមក... មានតែ រឿងឥតន័យ ដែលមិនអាចទៅរួច ។

- នរណាថា មិនអាចទៅរួច ? រឿងនេះ សំរេចនៅលើនាងនិងខ្ញុំ តែពីរនាក់ទេតើហ៍!

- ខុសហើយលោកប្រុស! រឿងនេះស្ថិតនៅលើមនុស្សច្រើននាក់ គឺលោក កូនរបស់លោក និងខ្ញុំ ។ បើនិយាយពីលក្ខណៈប្រជា ធិបតេយ្យវិញ គឺខ្ញុំជាអ្នកចាញ់រហូត ព្រោះខ្ញុំមានតែម្នាក់ឯង ត្រូវ តែសម្របសម្រួលតម្រូវ តាមមតិភាគច្រើន ជានិច្ច ។ ម្យ៉ាងទៀត ខ្ញុំមិនដែលមានចិត្តចង់ធ្វើជាម្តាយចុងរបស់ក្មេងណាមួយទេ ព្រោះ សង្គមខ្មែរមិនដែលអោយតម្លៃនារីដែលជាម្តាយចុងគេឡើយ ។ គេ តែងតែអោយតម្លៃ ទៅលើភរិយាដើមនិងកូនដើមជានិច្ច ។ ជានារី ដែលគ្មានចំណងដូចខ្ញុំនេះ បើខ្ញុំស្មគ្រ័រៀបការជាមួយលោក មិន ខុសពីយកខ្លួនទៅប្រថុយផ្គាប់ចិត្តមនុស្សទាំងហ្វូងក្នុងផ្ទះនោះឡើយ រួចហើយផ្គាប់ភ្នែកញាតិដែលចាំតែសើចចំអកនោះទៀត ។ ការ រៀបមង្គលការជាមួយបុរសដែលមានកូនប្រពន្ធម្តងហើយ មិនខុស ពីយកសម្លៀកចាស់ៗមកកែម៉ូដនោះទេ គឺពិបាកនឹងកែតម្រូវរាង អោយស្អាតសាជាថ្មីក្រៃលែង ។ ការពិត ការរើសក្រណាត់ថ្មីយកមក ដេរម៉ូដតម្រូវចិត្តខ្លួនតែម្តង វាស្រួលចិត្តជាងឆ្ងាយណាស់ ព្រោះមិន ពិបាកព្រួយរុះរើថ្នេរចាស់អោយស្អាមអាវនោះផង ។ មួយវិញទៀត ក្មេងណាក៏ដូចក្មេងណាដែរ គេមិនដែលអោយតម្លៃស្ត្រីទីពីរស្មើនឹង ម្តាយរបស់ខ្លួនដែរ

CHANBOKEO.COM

សូម្បីតែនាងមានលក្ខណៈសម្បត្តិល្អគ្រប់យ៉ាង បែបណាក៏ដោយ ។
គេធ្លាប់រស់នៅតាមរបៀបមួយដែលម្តាយរបស់ គេធ្លាប់បានអប់រំមក
លុះគេមកជួបម្តាយថ្មីដែលមានបែបបទម្លាប់ ខុសគ្នា គេនឹងចង្អៀតចង្អល់ចិត្តមិនខាន ។
ពេលនោះ ស្ថានភាព គ្រួសារច្បាស់ជាផ្លាស់ស្រកស្រុតភាពរមនាហើយ ហើយកំហុសទាំង
ឡាយក៏ធ្លាក់លើម្តាយចុងដោយស្វ័យប្រវត្តិ ។
- ទោះបីជាយ៉ាងណា យ៉ានៅភ្លេចរឿងមួយទៀត ។
- ភ្លេចរឿងអ្វីទៅ លោកប្រុស ?
- គឺយ៉ាភ្លេចហើយថា យាយខនក៏ជាម្តាយចុងរបស់យ៉ា ប៉ុន្តែគាត់
បានថែទាំចិញ្ចឹមយ៉ាបានយ៉ាងល្អប្រសើរ ហើយយ៉ាក៏ស្រឡាញ់គាត់ វិញយ៉ាងជ្រាលជ្រៅ
ដោយមិនបានគិតថា គាត់ជាម្តាយចុងទេ ។ ពេលនេះ
យ៉ាមានគិតទេថានឹងចម្លងគម្រូល្អនេះចែកនារីដទៃ ចែក
សង្គមខ្មែរទូទៅអោយគេបានស្គាល់នូវតម្លៃសីលធម៌ល្អៗនិងទឹកចិត្ត ប្រពៃរបស់ម្តាយចុង ?
ថែមពីលើនោះ យ៉ាមិនចង់បង្ហាញនូវការ ស្រឡាញ់របស់កូនដើមចំពោះម្តាយទីពីរ
ព្រោះតែបុព្វហេតុគុណធម៌ និងសីលធម៌ព្រមទាំងការថែទាំឃុំគ្រងដ៏កក់ក្តៅ របស់ម្តាយចុងទេ
ហ្ន៎ស ? ខ្ញុំបានឃើញយ៉ាស្រឡាញ់ម្តាយចុង ដោយគ្មានរឱស្ថាន
ក្នុងចិត្ត អ្វីបន្តិចណាទេ ។
ចរិយាព្ទប្រយោគនោះ ក៏ឈ្ងោកមុខនៅស្ងៀម បន្តិចមកក៏វាចា
តបវិញថា ៖
- ខ្ញុំគិតថា ខ្ញុំគ្មានគុណសម្បត្តិល្អគ្រប់គ្រាន់ដូចម៉ែទេ ។ម្យ៉ាងទៀត ខ្ញុំធ្លាប់មានជីវិតជាអ្នកជនបទ
មិនស្គាល់ភាពជឿនលឿនក្នុងទីក្រុង ប្រហែលមិនអាចធ្វើគម្រូល្អដល់ក្មេងៗ
តាមបែបជីវិតអ្នកទីក្រុង បានប្រសើរឡើយ ។
- ប៉ុន្តែ យ៉ាបានធ្វើអ្វីតាមលក្ខណៈជឿនលឿន និងប្រកបដោយ
សីលធម៌រួចហើយតើហ៎ ។ យ៉ាចេះអប់រំក្មេងដោយភាពត្រជាក់ ចេះ
យល់ទុក្ខធុរៈនិងអារម្មណ៍របស់ក្មេងដែលខ្វះការកក់ក្តៅក្នុងចិត្ត ចេះ
រកវិធីផ្សេងៗមករំសាយភាពហ្មួហ្មងក្នុងគ្រួសារ ចេះសរសេរកាព្យ
ចេះធ្វើកាតផ្ញើលើកទឹកចិត្តអ្នកដែលកំពុងក្រៀមក្រំ និងចេះប្រើ ឥន្ទ្រីណិតទៀតផង...
- ម៉េចក៏លោកដឹងកើត ថាខ្ញុំចេះប្រើឥន្ទ្រីណិត ?

CHANBOKEO.COM

- ចុះក្រែងប្អូនចាវ៉ាន់ គេធ្វើការនៅហាងសេវាទូរសព្ទ័និងឥន្ធនៈពិត មែនទេ ? យ៉ាមិនមានរៀនអ្វីពីគេខ្លះទេហ៍ ?

ចរិយានៅស្ងៀម មិនហ៊ានតប ។

- នាងឈប់លាក់នឹងខ្ញុំទៅ ។ ការពិត នាងក៏មានលក្ខណៈសម្បត្តិ ល្អៗជាច្រើន ដែលគួរណាស់តែនាងរកឱកាសបញ្ចេញវាមកប្រើជា ប្រយោជន៍ដល់សង្គមយើង ។

- ប៉ុន្តែ ខ្ញុំជាអ្នកក្រ រៀនមិនចប់ ធ្វើម៉េចនឹង... ?

- ខ្ញុំមានសមត្ថភាព អាចជួយអោយក្ដីស្រម័យរបស់នាង ក្លាយជា ការពិតបានមែនណ៎យ៉ា! នាងអាចធ្វើគ្រូបាន ហើយអាចសរសេរ និពន្ធអ្វីៗ បោះពុម្ពផ្សាយជាប្រយោជន៍ដល់សង្គមយើងទៀតផង ។

- មែនឬ លោកប្រុស ?

- មែន! ខ្ញុំមិនកុហកទេ ។

- អញ្ចឹង តើខ្ញុំត្រូវធ្វើយ៉ាងណាខ្លះ ?

- គឺ... ដំបូង យ៉ារៀបការនឹងបងសិនទៅ...! រួចចាំយើងនិយាយ គ្នាទៀត បានទេអូន ?

ឮដូច្នោះ ចរិយាភ័យញ័រខ្លួនយ៉ាងណាមិនដឹងទេ ដែលមាន បុរសមកនិយាយសុំនាងរៀបការយ៉ាងផុយៗ ដូច្នោះ ។ ផិតានឹក ខ្មាសក្រសែភ្នែករបស់លោក ក៏លែងហ៊ាននៅក្បែរលោកវណ្ណៈតទៅ ទៀត ហើយស្ទុះគេចរឹងចុះទៅដីបាត់ស្រមោល ទុកអោយលោក វណ្ណៈលួចញញឹមតែម្នាក់ឯងដោយក្ដីរំភើបក្នុងចិត្តចំពោះសុភមង្គល ថ្មីដែលលោកកំពុងបានទទួលនៅក្នុងដួងចិត្តជាលើកដំបូង ក្នុងរយៈ ពេលច្រើនខែមកហើយ ។

រសៀលបន្តិច...

លោកវណ្ណៈមានអារម្មណ៍ថា មានកម្លាំងបន្តិចហើយ ក៏រៀបរប នាំគ្រួសារត្រឡប់ទៅភ្នំពេញវិញ ។ បន្ទាប់ពីសំពះលាយាយខន ហើយ លោកក៏ដើរទៅជិតចរិយាដែល ឈរក្បែរម្ដាយនិងប្អូនស្រី ជូនដំណើរលោក រួចហើយស្រវាចាប់ដៃរបស់មាណវីយកមកកាន់ ស្រដីប្រាប់នាងថា ៖

- ថែខ្លួនណ៎យ៉ា! បីបួនថ្ងៃទៀត ពេលអូនស្រួលខ្លួនវិញហើយ បងនឹងអោយពូតឿមកទទួលទៅភ្នំពេញវិញ ។

CHANBOKEO.COM

ចរិយាញញឹម មិនហ៊ានឆ្លើយថាម៉េចទេ ព្រោះខ្មាសក្រសែភ្នែក របស់លោកវណ្ណៈដែលសម្លឹងមកនាង ប្រកបដោយមន្តស្នេហ៍ផ្អែម ល្ហែម ។ បន្តិចមក លោកក៏ដកប្រាក់ហុចអោយយាយខន ៖

- ខ្ញុំជូនម៉ែ ទុកទិញថ្នាំសំរាប់យ៉ានិងសំរាប់ម៉ែ ។

យាយខនភ្ញាក់ព្រើត ដែលលោកវណ្ណៈហៅគាត់ថា ម៉ែៗ ពេញ មាត់ ។ បែរទៅចរិយាវិញ ក៏ក្តៅខ្លួនភាយៗយ៉ាងចម្លែក បែក ញើសព្រោងព្រាត រហូតនិយាយអ្វីលែងចេញ ក្រៅតែពីក្រហាមមុខ ដោយការអៀនខ្មាសតែម្យ៉ាងប៉ុណ្ណោះ ។

លោកវណ្ណៈមានប្រសាសន៍បន្តទៅទៀតថា ៖

- សូមផ្ញើយ៉ា នឹងម៉ែផង! ខ្ញុំនឹងមកទទួលម៉ែឆាប់ៗ!!

រួចហើយលោកបែរញញឹមដាក់ចរិយាជាចុងក្រោយ បន្ទាប់មក ក៏ឡើងឡានចេញទៅ ទុកអោយនាងនៅឈរសម្លឹងពីក្រោយដោយ ដួងចិត្តរន្ធត់ញាប់ញ័រ ។

- ម៉ែគិតថា គេជាគូគ្រងដ៏ល្អសម្រាប់កូនហើយ យ៉ា!

យាយខនស្រដីទៅរកនារីយើង ។

- ហេតុអ្វីក៏គិតដូច្នោះ ម៉ែ ?

- យីអើ! តើមានបុរសអភិជនទីក្រុងឯណា គេមកបន្ទន់ខ្លួនចំពោះ អ្នកក្រដូចយើងនេះ ?

- មកពីគេមានវិប្បដិសារីចំពោះការដែលធ្វើអោយកូនដួលដំរបួស ទេដឹង ?

- មិនមែនទេ! ម៉ែថា មកពីគេពេញចិត្តលក្ខណៈសម្បត្តិរបស់កូន ប៉ែជាជាង ។ បើមិនដូច្នោះទេ គេមិនមកលន់តួសុំទោសកូនស្រីម៉ែ អីដល់ម្លឹងនោះ អស់ណាស់ត្រឹមផ្តាំមកសុំទោស ហើយក៏លែងរាប់គ្នា ទៅតែប៉ុនហ្នឹង ។ ម៉ែគិតថា ម៉ែនឹងបានក្បាលជ្រូកស៊ី ឆាប់ៗនេះ ហើយ ។

ចរិយានឹកអៀនខ្មាសម្តាយពេក ក៏គេចរឹង ទាញក្រមាបាំងមុខ លែងហ៊ាននិយាយជាមួយយាយខនតទៅទៀត ។

*oooooooooooooooooo*

*oooo*

CHANBOKEO . COM

# វគ្គទី៧
# ជីវិតថ្មី

មួយអាទិត្យក្រោយមក...

ពូតឿបរឡានចូលមកដល់ក្នុងបរិវេណផ្ទះ លោកវណ្ណៈ ដោយ មាននាំយាយខន ចរិយានិងប្អូនទាំងពីរនាក់របស់នាងផង ។ ការ ពិត ចារ៉ាន់ជាយុវជនស្អាតបាតម្នាក់ ក្នុងវ័យប្រមាណ២០ឆ្នាំ ។ គេចុះពីរថយន្តដឹកដៃប្អូនស្រីពិការចេញមក ព្រមជាមួយចរិយានិង យាយខនដែលចុះចេញមកតាមពីក្រោយ ។ អ្នកទាំងអស់គ្នាបាន ប្រទះឃើញគេហដ្ឋានរបស់លោកវណ្ណៈ មានការតុបតែងយ៉ាងស្អាត គួរអោយចាប់អារម្មណ៍ ។

រំពេចនោះ កូនប្រុសស្រីទាំងបីនាក់បានរត់ចេញមកពីក្នុងផ្ទះ មកដោយទឹកមុខសោមនស្ស ថែមទាំងនាំគ្នាលើកបដាមួយសរសេរ អក្សរធំៗថា ៖

- ស្វាគមន៍អ្នកគ្រូជាទីស្រឡាញ់!

ចរិយាភ្ញាក់ព្រើត កាលបើឃើញចំណារលើបដានោះ ។ លោក វណ្ណៈក៏លេចខ្លួនឆ្លៀឡើងតាមពីក្រោយ ព្រមជាមួយនឹងស្នាមញញឹម នៅលើផ្ទៃមុខយ៉ាងបំព្រងមកផង ៖

- សិស្សបីនាក់ដំបូងគេ កំពុងរង់ចាំអ្នកគ្រូមកបង្រៀនហើយ!

ភ្លាមនោះ ក្មេងៗនាំគ្នារត់ទៅអោបចរិយាជុំជិត ។

- បងយ៉ា! ពួកយើងនឹកបងណាស់!

- បងក៏នឹកប្អូនគ្រប់គ្នាដែរ ។

CHANBOKEO.COM

- មិនមែនបងទេ កូននី កូននេត្រ កូនវណ្ណា ។ តើកូនត្រូវហៅគេ យ៉ាងម៉េចវិញ ?

ទាំងអស់គ្នាបែរមើលមុខឪពុក ញញឹមយ៉ាងស្រស់ រួចហើយ ក៏បែរមកកចរិយាវិញ ទើបលើកដៃផ្គុំប្រណម្យ វាចាព្រមគ្នាថា ៖

- សូមជំរាបសួរអ្នកគ្រូ!

ចរិយាលើកដៃរា ៖

- មិនបាច់ដល់ម្លឹងទេ ប្អូន! ហៅថាបងៗដូចពីដើមបានហើយ ។

- ចាស! បាទ! បងយ៉ា! (ទាំងបីនាក់ឆ្លើយព្រមគ្នា)

បន្តិចមក លោកវណ្ណៈក៏នាំចាស់ៗព្រមទាំងក្រុមគ្រួសារចូលទៅ ក្នុងផ្ទះ ។ ចរិយាក៏កាន់សំពៀតខោអាវដើរចូលទៅរកបន្ទប់ចាស់ ដែលនាងធ្លាប់ស្នាក់ជាមួយយាយរៀម ស្រាប់តែ ៖

- ខុសហើយបងយ៉ា! បន្ទប់បងនៅខាងលើឯណោះ! យើងរៀប ចំទុកអោយបងយ៉ាងស្អាតណាស់បង! (វណ្ណនីស្រដី)

- ប៉ុន្តែ... បងគិតថានៅខាងក្រោមនេះសមរម្យហើយ អូននី!

ស្រាប់តែយាយរៀមលេចឆ្លោមកដល់ ៖

- ទៅខាងលើទៅចៅ ព្រោះមានគេរង់ចាំជួបចៅនៅទីនោះ ។

- នរណាទៅយាយ ?

- ឡើងទៅខាងលើសិនទៅ នឹងហើយ!

ចរិយាកាន់សំពៀតខោអាវ ដើរឡើងជណ្ដើរ តាមពីក្រោយ យាយរៀម ទុកអោយក្រុមគ្រួសារនៅសំណេះសំណាលគ្នាក្នុងបន្ទប់ ទទួលភ្ញៀវខាងក្រោម ។ មកដល់ក្នុងបន្ទប់មួយ ចរិយាបានប្រទះ នឹងស្ត្រីពីររូបដែលអង្គុយចាំនៅទីនោះស្រេច ។

- ពីរនាក់នេះ គេនឹងជួយរៀបចំស្លៀកពាក់តុបតែងខ្លួនឲ្យនាង ។ បន្តិចទៀត យាយនឹងត្រឡប់មកទទួលនាងវិញណា៎ ។

ចរិយាឈរធ្វើភាំង ត្បិតមិនដឹងថា ចាស់ៗកំពុងត្រៀមអ្វីទេ ។ ប្រហែលមួយម៉ោងក្រោយមក យាយរៀមមកគោះទ្វារហៅ ៖

- រួចរាល់ហើយឬនៅចៅ ?

- ចាស រួចហើយយាយ!

CHANBOKEO . COM

ទ្វាររបើកឡើង បង្ហាញខ្លួនចរិយាក្នុងសម្លៀកបំពាក់មង្គលការយ៉ាង ល្អប្រណិត ។ យាយរៀមញញឹមយ៉ាងស្រស់ដាក់នាងរួចលូកចាប់ដៃ នាងកាន់ដើរចេញមកក្រៅ ។ នៅមាត់ជណ្តើរខាងក្រោម ចរិយា ប្រទះឃើញលោកវណ្ណៈឈរកាន់ផ្កាស្លា ក្នុងសម្លៀកជាកូនកម្លោះ កំពុងរៀបការយ៉ាងសង្ហា បញ្ចេញភាពញញឹមនៅលើផ្ទៃមុខយ៉ាងត្រកាលមករកនាង ព្រមទាំងមានសាច់ញាតិទាំងអស់ឈរបៃហាម ពីក្រោយផង ។ នៅចំពោះមុខនិតា លោកវណ្ណៈសម្លឹងភក្រ្តមាណវី ដោយឥតពព្រិចភ្នែក ទំនងកំពុងផ្តិតភ្ជាប់នូវរូបសោភ័ណដ៏ត្រកាល របស់នារីនាវេលានោះ ចូលក្នុងប្រអប់បេះដូងរបស់លោកហើយ ។ បន្ទាប់មក លោកក៏មានប្រសាសន៍ថា ៖

- បងដឹងថា វាដូចជាទាន់ហាន់ប្រថុចញ៉ុចណាស់ ដែលបងសុំអូន រៀបការ ប៉ុន្តែបងទ្រាំចាំយូរទៀតមិនបានទេ ព្រោះបងចាស់ហើយ ហើយក៏មានកូនច្រើនផង ប្រហែលជាមិនមានពិន្ទុប្រកួតជាមួយ កម្លោះណាបានឡើយ ទើបបងឆ្លៀតឱកាសសុំអូនរៀបការនៅ ពេលនេះ ចំពោះមុខចាស់ទុំសាច់ញាតិទាំងឡាយ ព្រមទាំងកូនចៅ របស់បងគ្រប់គ្នា ដើម្បីបញ្ជាក់ថា បងគ្មានគំនិតលេងសើចទេ គឺ បងសុំទទួលយកអូនជាគូអនាគតយ៉ាងត្រឹមត្រូវ តាមប្រពៃណីនិង តាមច្បាប់ដើម្បីអោយអូនមានការកក់ក្តៅក្នុងចិត្ត ហើយក៏ចង់ប្រាប់ ដែរថា បងសុំអូនរៀបការក៏ព្រោះតែបងស្រឡាញ់អូន... ស្រឡាញ់ នូវគុណសម្បត្តិរបស់អូន ដែលនាំនូវសេចក្តីសុខរមនាចំពោះបង និងកូនគ្រប់គ្នាយ៉ាងប្រសើរបំផុត ។ រីឯកូនចៅរបស់បង ក៏ពេញ ចិត្តនឹងទទួលយកអូនជាម្តាយរបស់គេដែរ ។ ពេលនេះ សូមអូន ព្រមទទួលយកផ្កាស្លាពីបងផងណ៎ា យ៉ា!

ចរិយាឈរធ្មឹង ញ័រខ្លួនទទ្រើក ត្រជាក់ខ្នងស្រេប ។ ចំណែក បេះដូងនាងវិញក៏កញ្ច្រោលឡើងឱបខាក់ៗ ស្ទើរតែធ្លាយទ្រូងមក ក្រៅ ព្រោះនឹកខ្មាសក្នុងចិត្ត មិនដឹងត្រូវនិយាយយ៉ាងណា ។

ឃើញនាងនៅរេរាៗយូរពេក កូនទាំងបីនាក់របស់លោកវណ្ណៈ ក៏ចេញទៅឈរអមឪពុក ហើយលើកដៃសំពះទាំងបីនាក់ រួចស្រដី ព្រមគ្នាថា ៖

- កូនសូមស្វាគមន៍ម៉ាក់មកក្នុងគ្រួសាររបស់យើង ដោយសេចក្តី ស្រឡាញ់និងគោរពបំផុត ។ សូមម៉ាក់ទទួលផ្កាស្លាពីលោកប៉ារបស់ ពួកយើងផង!

ឮដូច្នោះ ចរិយាញញឹមឡើង ដោយទឹកភ្នែករលីងរលោង ត្បិត មិននឹកស្មានថា នាងបានទទួលការស្វាគមន៍ពីកូនរបស់លោកវណ្ណៈ យ៉ាងឧត្តុង្គឧត្តមដល់ម្លឹងទេ ។ ភ្លាមនោះ

CHANBOKEO.COM

នាងតូចវណ្ណាបានឡើងកាំ ជណ្ដើរមកចាប់ដៃចរិយា ដើរចុះត្រឡប់ទៅទទួលផ្កាស្លាពីដៃរបស់លោកវណ្ណៈ ។ ធិតាសម្លឹងទៅម្ដាយរបស់នាង រួចហើយទៅប្អូន ទាំងពីរ ឃើញគេញញឹមបំព្រងទំនងហាក់ដូចជាកំពុងទទួលនូវ សេចក្ដីសុខក្នុងចិត្ត ។ រួចហើយនាងក៏បែរសម្លឹងលោកវណ្ណៈ លូក ដៃឈោងទទួលជើងពានផ្កាស្លាទាំងរន្ធត់ញាប់ញ័រក្នុងចិត្ត ។

ស្នូរទះដៃនិងសម្លេងហោរកញ្ជៀវបានលាន់ឡើងយ៉ាងទ្រហឹងអឺងអាប់ព្រមជាមួយសម្លេងបាយខុនចងដៃយ៉ាងពិរោះភិរម្យបំផុត... លោកវណ្ណៈសង្កេតឃើញថាចរិយាបានលួចញញឹមដាក់លោកទាំង អៀនអន់រហូតដល់ទៅពីរដង នៅពេលអ្នកទាំងពីរកំពុងសំពះផ្ទឹម ផ្កាស្លាទទួលពរជ័យពីចាស់ទុំនិងញាតិការ ។ ថ្ងៃនោះ មេសា ឆាយា និងអ្នកនាងម៉ាលីណាក៏បានមកចូលរួមដែរ ។ មេសាបានដើរទៅជិតអ្នកទាំងពីរហើយជូនពរថា ៖

- សូមផ្ញើប្អូនស្រីជាមួយលោកផង! សូមអោយក្រុមគ្រួសាររបស់ លោកមានសុភមង្គលជានិច្ច ។ អូនយ៉ា! សូមអោយប្អូនជួបតែ សេចក្ដីសុខតទៅ ប៉ុន្តែ បើមានការពិបាកក្នុងជីវិត បងក៏ញាតិម្នាក់ របស់ប្អូនដែរ ។ យើងហៅរកគ្នាជានិច្ច ឮហើយនៅ ?

- ចាស បងមេសា! បងគឺជាបងប្រុសដែលខ្ញុំនឹងទៅរកមុនគេ ពេលខ្ញុំត្រូវការ ។

ចរិយាលើដៃសំពះមេសា ។ នៅក្បែរនោះ អ្នកនាងម៉ាលីណា ធ្វើមុខស្មើៗ ដែលនាងមិនបានក្លាយខ្លួនជាកូនក្រមុំនៅថ្ងៃនោះ ។ អ្នកនាងបានដើរមកជិតអ្នកទាំងពីស្រដីថា ៖

- សូមជូនពរអ្នកទាំងពីរផង!

ថាបានតែត្រឹមនេះ សុភាពស្ត្រីនោះក៏រួលដើមក ហើយគេច ខ្លួនបាត់ទៅ មើលទៅទំនងជាកំពុងសោកសៅ ។ នៅម្ខាងទៀត ឆាយាអង្គុយសំកុក សម្លឹងចរិយាភ្លៀកៗ ធ្វើមុខដូចស្វាទល់ផ្នូក ។

ភ្ញៀវត្រឡប់ទៅវិញអស់ហើយ ។ ឆាយាដើរចូលទៅក្នុងផ្ទះ ឃើញចរិយាកំពុងរៀបប្រអប់ចំណងដៃរៀបការ ៖

- មិននឹកស្មានសោះ ថា យ៉ាផ្លាស់ប្ដូរចិត្ត ប្ដូរមារយាទ បានលឿន ដល់ម្លឹង ? នេះយ៉ាខំគេចពីប្រុសកម្លោះដូចបង ទៅរៀបការបុរសពោះម៉ាយចាស់ស្មើឪពុកមានកូនម៉ាផ្លូនទៅវិញ ? ម៉េចក៏មិនធ្វើឫក សឿងឡើងទៀតទៅ ? ពេលនេះ តើវាបាត់ទៅណាអស់ទៅ អាឫកឆ្មើងកន្ទ្រើង ដែលអួតខ្លួនថាមិនប៉ះរបស់គេជាដាច់ខាត នោះ ?

CHANBOKEO.COM

ចរិយាងាកក្រោយ ឃើញឆាយា ក៏ស្ទុះដើបរឹងដើរចេញទៅ ដោយមិនឆ្លើយតបនរៈយើងវិញទេ ព្រោះឃើញបុរសយើងកំពុង ស្រវឹងពេញបន្ទុកហើយ ។

- ម៉េច ? នៅទ្រាំស្តាប់បងនិយាយការពិតមិនបានទេហ៎ ទើបដើរ គេ ចេញពីបងទៅហ្ន៎ស យ៉ា ?

មាណពក៏ស្ទុះទៅកញ្ឆក់ជាវអាវមង្គលការនារី ស្រាប់តែមានដៃ មួយមកចាប់ដៃឆាយាជាប់ ។ ឆាយាងាកមើល ឃើញលោកវណ្ណៈ ឈរធ្វើមុខមាំ ៖

- លោកពូ ?

- មែនហើយ! មានការអ្វីដែរទៅ បានជាប្រើសំដីធំតូច ហើយ មានកិរិយាមិនល្អដាក់ភរិយារបស់ពូយ៉ាងនេះ ?

ឆាយាលួចដៀងកន្ទុយភ្នែកដាក់ចរិយា រួចហើយក៏ស្រដីថា ៖

- ព្រោះខ្ញុំមិនសប្បាយចិត្តដែលសង្សារលួចទៅរៀបការថ្មី!

- នរណាជាសង្សាររបស់លោក លោកឆាយា ? (ចរិយាបែរឆ្លើយ វិញយ៉ាងលឿន កាលបើឃើញវត្តមានរបស់លោកវណ្ណៈ) លោក កំពុងតែយល់ច្រឡំហើយ ។

- គឺយើងធ្លាប់ជាសង្សារនឹងគ្នា កាលពីនៅបាត់ដំបងនោះអី ។

- ខ្ញុំមិនដែលស្គាល់មនុស្សឧត្បាតដូចលោកទេ លោកឆាយា!! បើ លោកមានប្រសាសន៍ថា ស្គាល់ខ្ញុំច្បាស់មែន អញ្ចឹងលោកមានស្គាល់ បុរសពាលដែលរំលោភលើអូនចិន្តា ប្អូនស្រីពិការរបស់ខ្ញុំទេ ? ពេលនេះ ប្រហែលដល់ពេលហើយទេដឹង ដែលខ្ញុំត្រូវជំរះបញ្ជីនេះ ជាមួយជនឧក្រិដ្ឋនោះ ?

- កាលនោះ បងស្រវឹង... បងគិតស្មានថា ចិន្តាជាអូន... ទើប..

- ទើបលោកឡើងទៅរំលោភបំពាន មែនទេ ? ស្តាយណាស់លោក ឆាយា! បើសិនលោកកាន់តែហើបមាត់ លោកក៏កាន់តែបង្ហាញ ចរិតឧក្រិដ្ឋរបស់លោកដែរ ។ នុ៎ះ ម៉ែនិងអូនដា នៅអង្គុយចាំ ឯខាងក្រៅ ចាំលោកទៅសុំខមាទោសពីពួកគេ ។ បើលោកធ្វើមិន បានទេ យើងមិនបាច់រាប់គ្នាជាញាតិតទៅទៀតទេ ។

- ទោះជាយ៉ាងណា អូនក៏មិនគ្រាន់បើជាងបងអ្វីប៉ុន្មានដែរព្រោះ អូនរៀបការជាមួយ បុរសដែលមានគ្រួសាររួចហើយ...

- ខ្ញុំអន់អ្វីទៅ លោកឆាយា ? ខ្ញុំរៀបការនឹងបុរសពោះម៉ាយ តាមផ្លូវច្បាប់ ដោយមានអាពាហ៍ពិពាហ៍ជាផ្លូវ មិនមែនលួចលាក់ មិនមែនដណ្តើម មិនមែនដោយការបំពាន ។

CHANBOKEO.COM

យ៉ាងណាក៏គង់ថ្លៃថ្នូរ ជាជាងជ្រើសរើសកម្លោះ ដែលមានប្រវត្តិឧក្រិដ្ឋដូចជាលោកដែរ ។
សូមទោស ខ្ញុំជួយអ្វីលោកមិនបានទេ ។ ពេលនេះ លោកមានតែ ផ្លូវពីរគត់ដែលត្រូវជ្រើសរើស
មួយគឺទៅសុំខមាទោសអូនដានិង ម៉ែរបស់ខ្ញុំ ពីរគឺចាកចេញពីទីនេះ កុំអោយខ្ញុំឃើញមុខទៀត ។
បើ មិនដូច្នេះទេ លោកនឹងហើយថាលទ្ធផលវាយ៉ាងម៉េច ។

ថាហើយ ចរិយាក៏ស្រវាអូសដៃលោកវណ្ណៈចេញទៅ ទុកអោយ
ឆាយានៅឈរធ្មឹងដូចរូបចម្លាក់ ។ បន្តិចមក មេសាក៏ដើរមកជិត ឆាយា ហើយស្រដីថា ៖

- ជាបុរសណា៎ ដែលថ្លៃថ្នូរបំផុតនោះ គឺយើងធ្វើខុសហើយ ចេះកែ
មិនមែនខឹ ប្រឹងធ្វើបំពានទាំងកំរោលអោយរិតតែខុសបន្តទៅទៀត នោះទេ ។
ចរិយាមានគុណសម្បត្តិល្អៗជាច្រើន ដែលបុរសប្រាថ្នា ចង់បាន ថែដន្យ
នាងមានតែបេះដូងមួយសំរាប់ប្រគល់ជូនមនុស្ស តែម្នាក់ដែលនាងជ្រើសរើសជាគូជីវិត ។
ពេលនេះ លោកត្រូវកាត់ ចិត្តហើយ ត្បិតអ្នកដែលនាងជ្រើសរើសមិនមែនជាលោក ។ កុំធ្វើអ្វី
ឲ្យចាស់ទុំឬញាតិផងនិន្ទា... ហើយ...មុននឹងយើងដៀលដៀមដាម ដាក់គេ
តើយើងមានមើលខ្លួនយើងទេ ? ហ៊ានដៀលខ្លួនយើងទេ បើសិនណាយើងមានកំហុស ?
ពេលនេះ មើលទៅភាគីនៅម្ខាង ទៀតខាងនោះ ហាក់ដូចជាកំពុងរង់ចាំឲ្យលោកទៅសុំខមាទោស
ហើយ ដើម្បីអោយគេមានឱកាសអហោសិកម្មអោយអ្នកដែលមាន កំហុស
ទាន់មនុស្សនោះនៅមានជីវិតរស់នៅ អាចទទួលការអភ័យ ទោសនោះបាន
រួចហើយមានឱកាសកែខ្លួន ដើម្បីឲ្យក្លាយជាញាតិ ល្អនឹងគ្នាឡើងវិញ
ជាជាងរស់នៅពាក់មុខយក្សដាក់គ្នា មួយជីវិត ដែរ...! លោកគិតមើលទៅ...
តើយើងគួររស់នៅឲ្យគេស្អប់មួយ ជីវិត ឬក៏គួររស់នៅអោយគេអាណិតស្រឡាញ់មួយជីវិត ?

ថាហើយ មេសាក៏ញញឹមដាក់ឆាយាហើយដើរចេញទៅ ។ សំដី ប៉ុន្មានម៉ាត់របស់មេសា
បានដាក់សតិឆាយាអោយស្វាងស្រាតែម្តង! គេឈរសំកុកគិតយ៉ាងយូរ
ទើបដាច់ចិត្តដើរទៅរកយាយខនដែល នៅអង្គុយលេងជាមួយយាយរៀមនិងកូនៗរបស់គាត់ ។
បន្ទាប់មក គេក៏ដាក់ខ្លួនលុតជង្គង់ចុះ ហើយលើកដៃប្រណម្យឡើង ៖

- ឆាយាមកសុំទោសលោកអ៊ំ ដែលបានប្រព្រឹត្តខ្លួនមិនគប្បីទៅលើ អូនដា ។ មួយឆ្នាំកន្លងមកនេះ
ជីវិតរបស់ខ្ញុំមិនដែលមានសេចក្តី សុខសោះ ប្រហែលជាខ្ញុំត្រូវបណ្តាសាទេវតាហើយ ។
ពេលនេះ
សូមលោកអ៊ំមេត្តាខន្តីអភ័យទោសដល់ខ្ញុំផង ។

CHIANBOKEO.COM

យាយខនភ្ញាក់ផ្អើលណាស់ ដែលឆាយាអាចធ្វើដូច្នោះបាន ។
យាយក៏លូកដៃទទួលសំពះរបស់ឆាយា ៖
- អឺ! អីឈប់ខឹងហើយកូន! តែកុំភ្លេចកែខ្លួនឲ្យល្អ ហើយឈប់ ប្រព្រឹត្តផ្ដេសផ្ដាសទៀតទៅ ។
ពេលនោះជីវិតរបស់កូននិងជួប ភាពភ្លឺថ្លាមានសេចក្ដីសុខក្នុងចិត្តវិញហើយ ។
ឆាយាអោនសំពះយាយខនហើយ ក៏បែរទៅរកនាងចិន្តាដែល
អង្គុយក្បែរនោះធ្វើទឹកមុខរាងភិតភ័យផង ភ្ញាក់ផ្អើលផង ។
- អូនដា! បងសុំទោស ដែលបងបានប្រព្រឹត្តមិនគប្បីមកលើអូន!
អហោសិកម្មអោយបងផងណ៎ាដា!
ចិន្តាធ្វើមុខឡឹងឡង់ៗ មួយស្របក់ទើបស្រដីថា ៖
- ដា... ដា... ដា... ខ្លាច.... បង.. បង... ឆាយា... កុំ...កុំ... ធ្វើ.. ធ្វើ... បាបដា....ទៀត....ណ៎!
- អត់ទេ! បងសូមស្បថ! បងពិតជាឈប់ធ្វើបាបដាហើយ! អភ័យទោសអោយបងផងណ៎ា
ដា!
យុវតីងក់ក្បាល ហើយតបវិញ ៖
- គឺ...គឺ... អាចឹង... ក៏...ក៏...បានដែរ!
ឆាយាលើកដៃសំពះលាយាយខននិងយាយរៀម ហើយក៏បែរ
ឈ្វោកដើរចេញទៅទាំងស្រងូតស្រងាត់ ។ ភ្លាមនោះ យាយរៀម មានប្រសាសន៍ថា ៖
- មើលទៅ គេនឹងបានស្ងប់ក្នុងជីវិតហើយ កាលបើគេបានស្គាល់ នូវកំហុសរបស់ខ្លួន
ហើយបានមកសុំខមាទោសអ្នកដែលរងគ្រោះ ដោយអំពើឃោរឃៅរបស់គេ ។
- សង្ឃឹមថាអញ្ចឹងទៅចុះ ណ៎ាបងរៀម ។
យាយខនឆ្លើយ រួចហើយក៏លើកដៃពីរសំពះទូលលើក្បាល បន់
ស្រន់ថា ៖
- សូមអោយគេក្លាយជាមនុស្សល្អ ហើយសូមចាកផុតនូវចរិតឃោរ ឃៅនោះរហូតទៅ សាធុ!!

នៅក្នុងបន្ទប់ផ្ទះធំលោក...
- យ៉ា! អូនសំកុកធ្វើស្រងូតស្រងាត់យូរហើយ ? មានរឿងអ្វី រំខានចិត្តមែនទេ អូន ?
- គឺ ខ្ញុំបារម្ភពីអូនដា លោកប្រុស! ព្រោះនាងប្រហែលមិនទាន់
ភ្លេចការភិតភ័យដែលត្រូវឆាយាធ្វើបាបនោះនៅឡើយទេ...

CHANBOKEO.COM

- កុំបារម្ភអី! នេះជាផ្ទះបង! ឆាយាមិនហ៊ានធ្វើអ្វីផ្ដេសផ្ដាសទេ ។ ម្យ៉ាងទៀត ចាស់ទុំនៅពេញផ្ទះ... អូនជាមានគេការពារជុំជិតហើយ ទៅបារម្ភធ្វើអ្វីទៀត ?

លោកវណ្ណៈក៏ដាក់ខ្លួនក្បែរចរិយា យកដៃមួយក្រសោបចង្កេះ ឯទី ដៃមួយទៀតស្រវាចាប់ដៃនាងមកកាន់យ៉ាងណែន ៖

- ឬក៏អូននៅអាល័យគេ នៅឡើយ ?
- លោកប្រុសមានប្រសាសន៍អ្វីពិបាកស្ដាប់ម្ល៉េះ ?
- បើមិនមែនទេ អូនញញឹមដាក់បងមួយសិនមក៍ ដើម្បីអោយ បេះដូងបងរីករាយផងណា៎ ណា៎!

ចរិយាគេចមុខចេញភ្លាម លួចញញឹមទាំងអៀនខ្មាស មិនហ៊ាន បែរមុខមកអោយលោកវណ្ណៈបានឃើញទេ ។

- យ៉ា! ពេលនេះ យើងរៀបការនឹងគ្នាហើយយើងនឹងមានដំណើរ ជីវិតតែមួយ តើអូនអាចនិយាយអ្វីអោយបងដឹង បងស្គាល់រូបអូន ខ្លះបានទេ ?
- លោកប្រុសចង់ដឹងអ្វីខ្លះទៅ ចា៎ស ?

លោកវណ្ណៈក៏ងើបឡើង អូសដៃភរិយាសំដៅទៅបន្ទប់ធ្វើការ របស់លោក រួចហើយក៏បើកឥន្លឺណិត ៖

- ប្រាប់បងមកមើលថា អូនជាកវីនារី ដែលមាននាមប៉ាកកាថា សោភ័ណដួងចិត្ត ?
- ចា៎ស មែនហើយ! ហេតុម៉េចក៏លោកប្រុសជ្រាប ថាជាខ្ញុំ ?
- គឺ... មកពីកំណាព្យរបស់អូននៅក្នុងវិបសៃថ៍នោះ វាដូចគ្នានឹង កំណាព្យដែលអូននាំកូនៗរបស់បងសរសេរនោះអី ។
- លោកប្រុសចូលចិត្តកំណាព្យដែរ ?
- ចូលចិត្តណាស់ ព្រោះកំណាព្យអាចធ្វើអារម្មណ៍បងត្រជាក់រមនា.. ពេលណាបងមានកង្វល់ បងសរសេរកំណាព្យជានិច្ច ។ បន្ទាប់ពី សរសេរហើយ ទ្រូងបងក៏ធូរស្រាលទុក្ខសោកជានិច្ចដែរ ។
- ហើយចុះលោកប្រុសជាកវីមួយណាដែរ នៅក្នុងគេហ៍ទំព័រនេះ ?
- អូនទាយសិនមើល៍ ក្រែងលោត្រូវ...

ចរិយាក៏បើកទំព័រវិបសៃថ៍ ខ្មែរក្នុងឥន្លឺណិត អានមួយស្របក់ ក៏ឆ្លើយថា ៖

- ច្បាស់ជាកវី ដែលមាននាមប៉ាកកាថា បេះដូងរងា ហើយ!
- អូយ៎ ! ពូកែទាយម្ល៉េះ ? ម៉េចបានអូនដឹង ?

CHANBOKEO.COM

- ព្រោះ គេសរសេរកំណាព្យ មានសាច់រឿងស្រដៀងៗនឹងជីវិត ពិតរបស់លោកប្រុស ។
- អូនពូកែមែន សមជាអ្នកនិពន្ធណាស់ ។ អញ្ចឹង ពេលនេះយើង
តែងកំណាព្យរួមគ្នា យ៉ាងម៉េចដែរអូន ?
- ចាស! តើលោកប្រុសចង់សរសេរពីអ្វីទៅ ?
- គឺ... សរសេរអំពីសុភមង្គលរបស់យើងថ្ងៃនេះ នោះអី!
ភ្លាមនោះ ចរិយាញញឹមឡើងយ៉ាងស្រស់ជាលើកដំបូង ធ្វើឲ្យ
លោកវណ្ណៈសម្លឹងមុខនាងយ៉ាងភ្លឹកអារម្មណ៍ ៖
- យ៉ា! ពេលអូនញញឹមអញ្ចឹងទៅ ស្រស់ណាស់ដឹងទេ? មិនតែ ប៉ុណ្ណោះ
ស្នាមញញឹមរបស់អូនបានធ្វើអោយបេះដូងបងរំភើបដើរ ខុសចង្វាក់តែម្តង ។
ចរិយាអៀន ឈ្ងោកមុខចុះ ។
- យ៉ា! អោយបងសួរមួយទៀត បានទេ?
- ចាស! លោកប្រុសសួរមកចុះ!
- ហេតុអ្វីអូនយល់ព្រមរៀបការនឹងបង ?
មាណវីខាំមាត់ គេចមុខចេញធ្វើអៀនប្រៀន ៖
- លោកប្រុសជ្រាបស្រាប់ហើយតើហ៎...!
- ជ្រាបស្អី ? បើអូនមិនទាន់ប្រាប់បងផង ?
- អញ្ចឹង លោកប្រុសសាកទាយទៅមើល ?
- គឺមកពីបងសន្យាថានឹងជួយអូនអោយបានធ្វើគ្រូ ?
- អត់ទេ!
- មកពីការអង្វរកររបស់កូនប្រុសស្រីទាំងបីរបស់បង ?
- ក៏មិនមែនដែរ!
- មកពីបងចូលស្តីមានចាស់ទុំ ?
- ក៏មិនមែនទៀត!
- អញ្ចឹងមកពីអ្វីទៅ យ៉ា ដែលធ្វើអោយអូនទទួលរូបបងបាន ?
- ប៉ុន្តែ លោកប្រុសប្រាប់ខ្ញុំសិនមក ថាហេតុអ្វីលោកប្រុសដណ្តឹង ខ្ញុំរៀបការរហ័សដល់ម្លឹង ?
- ពុទ្ធោ! គឺមកពីបងស្រឡាញ់អូនហ្នឹងណា៎!
- ស្រឡាញ់យ៉ាងណា កាលបើលោកទើបតែស្គាល់ខ្ញុំថ្មីៗយ៉ាងនេះ ?

- ការពិត បងលួចពេញចិត្តរូបអូនតាំងពីថ្ងៃដំបូងម្ល៉េះអូនដឹងទេ ?
គឺនៅពេលដែលអូនរត់ចេញទៅក្រៅ ចាប់កូនស្រីរបស់បងមិនឲ្យ ទៅលេងក្លិបនោះអី ។
ពេលនោះ បងដឹងថា អូនជាមនុស្សមាន សន្តានចិត្ត ចេះគិតខ្វល់ខ្វាយពីសុវត្ថិភាពរបស់ក្មេង
មិនអោយគេ ភ្លើតភ្លើនតាមទំនើងចិត្ត ។ ជាពិសេសទៅទៀតនោះ គឺអូនបានមក
ពន្យល់បងមិនអោយប្រើធម៌ក្តៅប្រដៅកូនទេ ថ្វីបើដេញទាន់ជាន់ កែងទៅហើយ ។ ពេលនោះ
បងដឹងថា បងអាចទុកចិត្តស្ត្រីដូច អូនបាន ។ ក្រោយមក
អូនក៏វាយមន្តស្នេហ៍តាមកាព្យក្នុងកាតលើក ទឹកចិត្ត ផ្ញើតាមកូនរបស់បងរៀងរាល់ល្ងាច
បងក៏លង់ក្នុងសំណាញ់ ស្នេហ៍របស់អូនទៅដោយមិនដឹងខ្លួន ។ ជាពិសេសគឺអូនមានទេព
កោសល្យអំណោយទានពិសេសដែលអាចទាញយកចំណាប់អារម្មណ៍
និងការស្រឡាញ់ពីកូនទាំងបីរបស់បងអស់រលីង ថែមទាំងនាំគេឲ្យ
សរសេរកំណាព្យដាក់ស្នេហ៍បងទៀតផង ។
- មែនហ្ន៎ស ?
- មែនណា៎ ! កំណាព្យមួយណាក៏ពិរោះផ្អែមល្ហែមដែរ អានហើយ
ជ្រាយបេះដូងបងអស់រលីងតែម្តង ! ហើយយប់ណាដែលបានអាន កំណាព្យរបស់អូន
បងមានអារម្មណ៍ហាក់ដូចជាមានទេពធិតាមក បបោសថ្នាក់ថ្នមចិត្តបងអោយក្សេមក្សាន្តជានិច្ច ។
- ការពិត ពាក្យពេចន៍ខ្លះជាការជ្រើសរើសរបស់ អ្នកនាងតូចទេ តើហ៍ ។
- ប៉ុន្តែក៏មានពាក្យពេចន៍របស់អូនយោងជាគោលផង ទើបពិរោះ រណ្តំយ៉ាងនេះ ។
ឥឡូវដល់ពេលអូនហើយ ! ពេលនេះ ប្រាប់បង មក
ថាហេតុអ្វីអូនយល់ព្រមរៀបការនឹងបងដោយឥតប្រកែកមួយ ម៉ាត់ អញ្ចឹង ?
- គឺ មកពី... យ៉ាខ្លាចចិត្តចាស់ៗនោះអី !
- បងថាមិនមែនទេ !
- ហើយខ្លាច មិនចង់អោយកូនទាំងបីរបស់បងបាក់ទឹកចិត្ត ។
- បងថាមិនមែនទៀត ។ មើល៍ប្រាប់បងអោយត្រង់មកណា៎ ! ឲ្យ
យើងបានយល់ចិត្តគ្នាទៅវិញទៅមក ទើបគ្រួសាររបស់យើងមាន សុភមង្គលណា៎អូន
ចរិយាឈ្ងោកមុខទំនងអៀនប្រៀនមួយស្របក់ ទើបកាត់ចិត្ត និយាយជំរាបលោកវណ្ណៈថា ៖
- គឺ លោកប្រុសបានចាប់បេះដូងរបស់ខ្ញុំទុក នៅពេលដែលជង្គង់
របស់លោកប្រុសលុតប៉ះដីមាត់ស្រះ ក្នុងចំការក្រោយផ្ទះរបស់ខ្ញុំនៅ បាត់ដំបងនោះម្ល៉េះ

CHANBOKEO . COM

ព្រោះខ្ញុំមិននឹកស្មានថា លោកហ៊ានធ្វើដល់ថ្នាក់ នោះទេ ។ បុរសខ្មែរទូទៅមានចរិតរឹងត្អឹងណាស់ មិនងាយសុខចិត្ត មកបន្ទន់ចិត្តបន្ទន់កាយចំពោះនារីដូច្នោះឡើយ ទោះបើនៅក្នុងចិត្ត របស់គេពោរពេញទៅដោយវិប្បដិសារីយ៉ាងណាក៏ដោយ ។ ប៉ុន្តែ លោកអាចធ្វើបាន ហើយធ្វើដោយសុទ្ធចិត្តទៀតផង គឺធ្វើដើម្បី ពន្លត់ភ្លើងទោសៈដែលកំពុងឆាបឆេះនៅក្នុងចិត្តរបស់នារី ដែល បានទទួលការឈឺចាប់ ។ ភាពទន់ភ្លន់នោះបានបង្ហាញអោយខ្ញុំដឹង ថា លោកជាបុរសដែលព្រមវែកញែក ត្រូវអោយដាច់ពីខុស ល្អ ដាច់ពីអាក្រក់ហើយហ៊ានទទួលខុសត្រូវ ចំពោះកំហុសរបស់ខ្លួន យ៉ាងពេញមុខ មិនរាថយ ។ នោះហើយជាលក្ខណៈបុរសដែល ចរិយាពេញចិត្តជាទីបំផុត ។

- ហើយអូនមិនគិតខ្លះទេហ៏ កាលបើបងជាមនុស្សចាស់ពោះម៉ាយ ហើយមានកូនច្រើនផងនោះ ?

- ចា៎ស! ចឺមិនគិត! ប៉ុន្តែ លោកប្រុសជាមនុស្សទន់ភ្លន់ ដឹងខុស ឆាប់កែ ។ ចំណែកកូនៗរបស់លោកប្រុសក៏ដូចគ្នា ។ គេមិនមែន ជាមនុស្សរឹងរូសដែរ ។ ពេលគេដឹងខ្លួនគេខុស គេក៏ចេះសុំទោស ហើយកែខ្លួនគេឲ្យស្ថានភាពគ្រួសាររមនាឡើងមកវិញ មិនមានះ ក្រៅតម្រាឡើយ ។ នេះជាតម្លៃដ៏ល្អបំផុតរបស់គ្រួសារលោកប្រុស ដែលធ្វើអោយខ្ញុំមានការកក់ក្តៅក្នុងចិត្តបំផុត ។ ជាពិសេសទៅ ទៀត លោកប្រុសក៏ព្រមទទួលយកម៉ែខន ថាជា ម៉ែ ពេញមុខ ដោយឥតរើសអើង ទើបខ្ញុំសំរេចចិត្តទទួលយកផ្កាស្លានោះទៅ ។

- អូនពិតជាគិតវែងឆ្ងាយមែន យ៉ា! ហើយអូនមិនដែលពេញ ចិត្តបុរសណាពីមុនមកទេ ?

- ចា៎ស! ចឺក៏មិនមាន ។

- នរណាគេខ្លះ ? មេសាមែនទេ ?

- បងមេសាជាមនុស្សល្អណាស់ ថៃដន្យយើងមិនដែលមានសម្ពន្ធ័ អ្វីនឹងគ្នាអោយលើសពីញាតិជិតខាងឡើយ ។ ខ្ញុំគោរពគាត់ជាបង ប្រុសម្នាក់យ៉ាងពេញលក្ខណៈ ហើយគាត់ក៏មិនដែលគិតអ្វីចំពោះខ្ញុំ អោយលើសពីប្អូនស្រីដែរ ។

- ចុះ ឆាយាវិញ ?

- គឺ...យើងស្គាល់គ្នាតាមរយៈមិត្តភក្តិ ពេលខ្ញុំទៅរៀនប្រើឥន្ទ្រីយ៍ណិត ដំបូង ។ ដំបូងខ្ញុំគិតថា ខ្ញុំអាចទុកចិត្តបងឆាយាបាន ។ ប៉ុន្តែ មានថ្ងៃមួយ ម៉ែនិងខ្ញុំមិននៅផ្ទះ អាល័យទៅជួយបុណ្យខ្មោចអ្នក ជិតខាង មកផ្ទះវិញយប់ជ្រៅ ស្រាប់តែប្រទះបងឆាយាកំពុងតែ

CHANBOKEO.COM

បំពារបំពានលើអូនដានៅក្នុងផ្ទះ ទើបយើងឆោឡោដេញបង ឆាយាចេញទៅ
រួចហើយក៏លែងរាប់គ្នារហូតមក ។
- ហើយ ក្រៅពីនោះ ?
- ខ្ញុំមិនដែលស្គាល់បុរសឯទៀតណាទេ ព្រោះខ្ញុំរាងចាលចំពោះអំពើ
ឧក្រិដ្ឋរបស់បងឆាយា ។ ណាមួយ ខ្ញុំក៏ក្រីក្រ រូបសម្បត្តិក៏សាមញ្ញ វិជ្ជាក៏មិនសូវជ្រៅជ្រះ
ការងារក៏ធ្វើមិនបានទៀងទាត់...
- ហើយចុះមុននឹងអូនមកភ្នំពេញនេះ អូនធ្វើការអីដែរ ?
- គឺ ធ្វើការនៅហាងសេវាទូរសព្ទ័និងឥន្ធនីណិត ហើយចាវ៉ាន់ធ្វើការ
នៅហាងលក់និងជួសជុលកុំព្យូទ័រ ជាប់ជញ្ជាំងគ្នាហ្នឹង ។  តាំងពីខ្ញុំ ឈប់ធ្វើការទីនោះមក
ចាវ៉ាន់ក៏ទៅជួយធ្វើការទាំងសងខាង ព្រោះ ហាងពីរនោះមានម្ចាស់តែមួយ
ហើយគាត់ក៏ស្គាល់រាប់អានយើង ទាំងពីរនាក់តាំងពីក្មេងៗ ទើបគាត់ស្រឡាញ់ទុកចិត្តហៅអោយ
ជួយមើលការខុសត្រូវក្នុងហាង ហាក់បីដូចជាកូនចៅរបស់គាត់ ។
- អញ្ចឹងតើហ៍ បានជាអូនចេះប្រើឥន្ធនីណិត ហើយចេះសរសេរ
កំណាព្យផ្សាយតាមវិបសៃថ៍ជាច្រើនផង ។ ហើយអូនមានទាក់ភ្នែក
ទាក់អារម្មណ៍នឹងកំណាព្យណាមួយទេ ?
- មាន! មានច្រើនណាស់! ជាពិសេស គឺកំណាព្យរបស់កវីដែល មាននាមប៉ាកកាថា
បេះដូងរងា!
- អូហ៍! មែនឬយ៉ា ?
លោកវណ្ណៈស្រវាអោបចង្កេះភរិយាយ៉ាងណែន ដោយក្តីរំភើប ចិត្ត ត្បិតដឹងថា
ចរិយានិងលោកមានចំណងអារម្មណ៍ពាក់ពន្ធ័ផ្ទែក
មនោសញ្ចេតនានឹងគ្នាយ៉ាងជ្រាលជ្រៅដោយមិនដឹងខ្លួន ។
- យ៉ា! ដឹងទេ ថាបងស្រឡាញ់អូនប៉ុនណា ?
- ចា៎ស មិនដឹងទេ ។
ចរិយាញញឹមទាំងអៀនប្រៀន ត្បិតនឹកខ្មាសស្វាមី ។ លោក វណ្ណៈក៏ភ្ញើយចង្កានារី
សម្លឹងកែវភ្នែករបស់នាង ហើយវាចាតទៅ ទៀតថា ៖
- អូនសម្លឹងកែវភ្នែកបងមក នោះអូននឹងយល់ច្បាស់មិនខាន!

CHANBOKEO.COM

និតាងើបមុខឡើង សម្លឹងកែវភ្នែកលោកវណ្ណៈវិញទាំងដួងចិត្ត ញាប់ញ័រ ។ លោកវណ្ណៈក៏សួរនាងថា ៖

- យ៉ា! អូនធ្លាប់បានសរសេរកំណាព្យមួយដែលមានចំណងជើងថា ពេលឃើញបងញញឹម... មែនទេ ?

- ម៉េចក៏លោកប្រុសដឹង ?

- ព្រោះបងចាប់អារម្មណ៍ពីអូនពេកហ្នឹងណា៎ បានជាតាមដានអូន លេងៗទៅ ។ ហើយនៅពេលនេះ បងចង់ដឹងណាស់ថា តើអូន សរសេរកាព្យមួយហ្នឹងអោយនរណា ? យ៉ាឆ្លើយប្រាប់បងបានទេ ?

ចរិយាញញឹមក្របួចមាត់ធ្វើអៀនប្រៀន ៖

- គឺ... សរសេរឲ្យបុរសម្នាក់ ដែលកំណាញ់ស្នាមញញឹមនោះអី!

- ជានរណាគេទៅ ?

ចរិយាដាក់ភ្នែក អោនមុខចុះ មិនហ៊ានឆ្លើយ ។ លោកវណ្ណៈក៏ចាប់ភ្ញើយចង្កាអោយនាងសម្លឹងមុខលោកសាជាថ្មី ៖

- អូនប្រាប់មកណា៎! ថាម្ចាស់ស្នាមញញឹមនោះ ជានរណា ?

- គឺ... ជា... ជាបុរសម្នាក់... ដែលលួចតាមសម្លឹងយ៉ា ព្រឹកល្ងាចៗ ធ្វើមុខស្លូតៗ ស្ងៀមៗ មិននិយាយស្តី...

- អូហ៍! ដឹងខ្លួនដែរថា មានគេលួចតាមសម្លឹងមើលអូន ?

- ចឹក៏មិនដឹង គ្រាន់តែយ៉ាមិនហ៊ានមើលគេវិញ ខ្លាច...

- ខ្លាចអ្វី... ?

- គឺ... ខ្លាច... ខ្លាចគេឆក់យកបេះដូងយ៉ាបាត់!!

- មានន័យថា អូនក៏លួចចាប់អារម្មណ៍ពីបងដែរមែនទេ ?

- គឺ....គឺ....ភ័យខ្លួនជាជាង

- ហើយគេមានឆក់បេះដូងរបស់យ៉ាបាត់ទេ អូន ?

- ចាំស! តែគេមិនបានឆក់បេះដូងរបស់អូនយកបាត់ទេ ។

- អូហ៍.. ? (លោកវណ្ណៈធ្វើមុខស្លូតហាក់ខកចិត្ត)

ស្រាប់តែចរិយាញញឹមហើយស្រដីបន្តថា ៖

- តែគេបានយកបេះដូងគេមកប្រគល់អោយយ៉ា ហើយសុំប្តូរយក បេះដូងយ៉ាទៅវិញ ។

CHANBOKEO .COM

- ហើយអូនមានប្រគល់បេះដូងរបស់អូនទៅគេវិញទេ ?

ចរិយាងក់ក្បាលហើយញញឹមយ៉ាងបំព្រង ធ្វើឲ្យលោកវណ្ណៈ រំភើបចិត្តទ្រាំមិនបាន ក៏ឈ្ងោកផ្ទិតនាសាលើថ្ពាល់នារីយ៉ាងរហ័ស ធ្វើអោយចរិយាភ្ញាក់ក្រញាង នឹកខ្មាសឡើងក្រហមមុខ ។ ឃើញ ប្រពន្ធអៀនខ្លាំងពេក លោកវណ្ណៈក៏មានប្រសាសន៍ថា ៖

- ពេលនេះ តើអូនចង់ដឹងទេ ថា ម្ចាស់ស្នាមញញឹមនោះ គេឆ្លើយ យ៉ាងណាវិញ ចំពោះកំណាព្យដែលអូនសរសេរនោះ ?

- ចា៎ស !... តើ... គេសរសេរថាម៉េចខ្លះដែរទៅ ?

- អូនឱនត្រចៀកសិនមកណា៎... ចាំបងខ្សិបប្រាប់....

ញញឹមដើម្បីអូន...!

| | |
|---|---|
| រៀមបងញញឹមដើម្បីអូន | ជូនស្រស់ស្រីស្ងួនទេពមន្តស្នេហ៍ |
| ចរិយាសោភ័ណសមម្លេះទេ | កែវរមុំមាសមេបងក្សេមក្សាន្ត ។ |
| បងញញឹមស្រស់ព្រោះតែស្រី | សំណព្វហឫទ័យកែវកល្យាណ |
| វាយសំណាញ់ស្នេហ៍សួគ៌ាឋាន | ឱ្យបងក្សេមក្សាន្តអង្គទ័យា ។ |
| បងភ្លេចញញឹមមកយូរហើយ | តែពៅត្រាណត្រើយខាបទាញទារ |
| នាំដួងចិត្តបងដែលរងា | វិលជួបរមនាក្នុងជីវិត ។ |
| បងសូមញញឹមដើម្បីអូន | លាងភាពស្រពោនសោកវិបរិត |
| អោយយើងស្គាល់តែភាពអម្រិត | ស្នេហាផ្តេកផ្តិតនិត្យត្រកាល ។ |

ពេលនេះ បងញញឹមហើយណ៎ា... គឺញញឹមដើម្បីអូន...!!

ពេលនេះ លោកវណ្ណៈមានអារម្មណ៍ថាលោកបានទទួលសេចក្តី សុខរមនាក្នុងដួងចិត្តណាស់ គឺរំភើបនោះសែនរំភើប ចំពោះនារី យើងរកពាក្យអ្វីថ្លែងស្មើមិនបាន ។ ពិតមែនតែរូបសោភ័ណរបស់ នាងមិនជាស្រស់ស្អាតប៉ុន្មាន រៀនវិញក៏មិនបានចប់មធ្យមសិក្សា ឋានៈក្រុមគ្រួសារក៏ត្រឹមជាអ្នកជនបទ ប៉ុន្តែនាងមានទេពកោសល្យ ធម្មជាតិក្នុងការសរសេរនិពន្ធ មានគំនិតចាស់ទុំ មានចរិតនឹងធឹង មានសតិប្រាជ្ញប្រដំប្រសងនិងលោក មិនចាញ់គ្នាទេ ។ លោកវណ្ណៈ គិតថាចាប់ពីថ្ងៃនេះតទៅបេះដូងរបស់លោកលែងរងាហើយ ។

ចំពោះមាណវីវិញ ថ្វីបើគ្រាមួយ នាងធ្លាប់ទទួលនូវភាព កម្រោលពីលោកវណ្ណៈ ប៉ុន្តែនាងជឿថា នោះជាកំហុសអចេតនា ហើយលោកក៏បានសារភាព ហើយសុំឱកាសកែប្រែស្ថានការណ៍ឲ្យ ល្អប្រសើរមកវិញ ។ ទោះបីលោកជាមនុស្សចាស់

CHANBOKEO.COM

ពោះម៉ាយមាន កូនដល់ទៅបួននាក់ ប៉ុន្តែលោកធ្លាប់ជាមេគ្រួសារគ្រប់គ្រងកូនចៅបានយ៉ាងកក់ក្តៅរមនា ។ រីឯកូនចៅរបស់លោកវិញក៏សុទ្ធតែជាក្មេងដែលអាចនិយាយស្តាប់គ្នាបាន ដូច្នេះអាចចុះសម្រុងជាមួយ នាងយ៉ាងងាយស្រួល ។ ជាពិសេសទៅទៀត លោកវណ្ណៈក៏ទទួល ស្គាល់ម្តាយនិងប្អូនៗរបស់នាងដែលជាអ្នកជនបទ ដោយមិនរើស អើងឆ្មើងកន្ទ្រឹង ។ ចរិយាគិតថា ចាប់ពីថ្ងៃនេះតទៅ ជីវិតរបស់នាងនឹងបានទទួលនូវសេចក្តីសុខយ៉ាងពេញលក្ខណៈ ។

*ooooooooooooooooo*

*oooooo*

CHANBOKEO . COM

# វគ្គទី៨
# រនាំងគ្រួសារ

នៅវាលចំណតយន្តហោះអន្តរជាតិភ្នំពេញ...

យុវជនរាងសង្ហាមួយរូប ក្នុងវ័យប្រមាណ១៨ឆ្នាំ ពាក់វ៉ែនតា ខ្មៅ លាបសក់ហាយឡៃ ម៉ូដបះច្រូងលើក្បាល ពាក់ខ្សែកមាសស ភ្លឺរន្ទាល អាវចំហទ្រូង ស្បែកជើងប៊ូតទឹកកកកវែងសំញែង កណ្តាលថ្ងៃត្រង់ ខោខៅប៊ិយដំឡេវពណ៌ប្រាក់ភ្លឺភ្លែកៗប្រហែលពីរ ពាន់គ្រាប់ ដើរចេញមកពីមន្ទីរគយ ស្ពាយសាក់កាដូមួយលើស្មា ដើរដើយក្រអឺត ច្រមុះនៅក្នុងមេឃ សំដៅទៅម្តុំដែលមានឡាន តាក់ស៊ីចតព្រោងព្រាត ។

- ចង់អញ្ជើញទៅខាងណាដែរលោក ?

សូហ្វ័រតាក់ស៊ីម្នាក់សួរ ។ យុវជនធ្វើឫកក្រអឺត ទាញនាមបត្រ័ មួយសន្លឹកចេញមក ៖

- ទៅអាសយដ្ឋានមួយនេះ ។
- បាទ! អញ្ជើញ!

នៅក្នុងរថយន្ត...

សូហ្វ័រឡានលួចសម្លឹងមើលយុវជនសង្ហាភ្លៀកៗ ៖

- លោកជាអនិកជនមកពីបរទេសហ្ន៎ស ? (នាយតាក់ស៊ីសួរ)
- មែនហើយ!
- មកពីអាមេរិកមែនទេ ?
- គឺស្រដៀងៗហ្នឹងឯង...

CHANBOKEO.COM

- យី! ប្លែកណាស់ លោកនៅក្មេង តែនិយាយខ្មែរបានច្បាស់ដល់ ហើយ មិនដូចអនិកជនមកពីអាមេរិកខ្លះទេ វ័យស្របាលលោក ភ្លេចខ្មែរអស់រលីង ។

តែយុវជនធ្វើមិនឮ ។ បន្តិចមក រថយន្តក៏បានមកដល់ផ្លូវ បំបែកមួយ ។

- ឈប់ត្រង់នេះហើយ!
- មិនទាន់ដល់ផ្ទះដែលនៅក្នុងកាតនោះនៅឡើយទេលោក ។
- មិនអីទេ! ខ្ញុំចង់ចុះដើរមើលទិដ្ឋភាពក្រុង បន្តិច ។ នេះលុយ ថ្លៃដឹក... មិនបាច់អាប់ទេ ។
- អរគុណបាទ!

យុវជនសង្ហាដើរចេញពីឡានមក ដើរដាក់ច្រមុះទៅក្នុងមេឃ ទៀតហើយ ។ សម្លេងខ្សែច្រវាក់លើចង្កេះយុវជនដែលអង្រួនទៅ អង្រួនមកលាន់រ៉ឺកៗ បានបញ្ចេញសូរសៀងទាក់អារម្មណ៍អ្នកទាំងឡាយដែលនៅតាមដងផ្លូវអោយបែរមើលនរៈគ្រប់គ្នា ។ កាលបើគេឃើញការតុបតែងខ្លួនយ៉ាងចំឡែក គេក៏នាំគ្នាកេះអ្នកជិតខាងឲ្យ បែរមើលរិតតែច្រើន ធ្វើអោយយុវជនសង្ហាកាន់តែបានចិត្តខ្លាំង ឡើងៗតែម្តង ។ ភ្លាមនោះ ស្រាប់តែគេប្រទះស្ត្រីមានគភ៌ម្នាក់ កំពុងដើរចេញពីផ្ទះមួយក្បែរនោះ ។ គ្រាន់តែគេក្រឡេកឃើញនាងភ្លាម គេហាក់ដូចជាចាប់អារម្មណ៍ចំពោះរូបសោភណ័របស់នាង ណាស់ ខុសតែនាងកំពុងមានផ្ទៃពោះ ។ យុវជននោះសម្លឹងនាង យ៉ាងភ្លឹករួចហើយក៏បែរមុខចេញ ហើយជញ្ជក់មាត់និយាយខ្សិបៗ តែម្នាក់ឯងថា ៖

- ស្រអែមស្រស់ណាស់ ខុសតែមានម្ចាស់ កុំអីញ៉ែលេងហើយ ។

ស្រាប់តែស្ត្រីនោះដើរស្របផ្លូវជាមួយយុវជនយើងដែរ ប៉ុន្តែ នាងមិនបានចាប់ភ្លឹកចាប់អារម្មណ៍អ្វីពីយុវជនសង្ហាទេ ។ មាណវី ចេះតែឈ្ងោកដើរស្ងាត់ៗធ្វើមិនដឹង តែម្នាក់ឯង ។ យុវជនយើង នឹកព្រើល ក៏ធ្វើជាដើរទៅទន្ទឹមដោយថៃដន្យ ប៉ុន្តែមិនបានដើរឲ្យ ហួសទេ មើលទៅ ទំនងជាចង់បន្លំថា គេជាគូសង្សារ ឬជាស្វាមី នាងហើយ ។ ស្រាប់តែស្ត្រីនោះហាក់ដូចជាចាប់ភ្លឹកថា មានគេដើរ ក្បែរក៏ងាកមើល ហើយសួរថា ៖

- ប្អូនមានការអ្វីចង់សួរបងមែនទេ ? ឬក៏ប្អូនកំពុងវង្វេងផ្លូវ ?

យុវជនភ្ញាក់ក្រញាង ត្បិតមិននឹកស្មានថា នារីនោះនឹងស្រដី មករកខ្លួន ។ គេក៏លើកដៃរា ហើយឆ្លើយថា ៖

CHANBOKEO.COM

- មិនអីទេ! អរគុណ!

រួចហើយ គេធ្វើជាគេចដើរទៅរកទិញទឹកអំពៅនៅតាមដងផ្លូវ នោះបរិភោគ ។ ឯស្ត្រីនោះក៏ដើរហួសទៅ ។ កំពុងតែឈរបឺតទឹក អំពៅស្រាប់តែ ៖

- អេហ៍! វណ្ណឌី! ទើបនឹងមកពីជប៉ុនមែនទេ?

យុវជនងាកមើលម្ចាស់សម្លេង ក៏ឃើញបុរសម្នាក់បើកឡាន មួយមកដល់ ។

- បងឆាយា? (យុវជនលាន់មាត់)

- មែនហើយ! ត្រូវការអោយបងដឹកទៅផ្ទះទេ? បងទៅតាមផ្លូវហ្នឹងស្រាប់ ។

- មិនបាច់ទេបង! ខ្ញុំជិះហោះយូរម៉ោង អង្គុយយូរឡើងចុកខ្នង ទៅហើយ ចង់ដើរអោយយឺតសរសៃបន្តិច ។

- អញ្ចឹង បងទៅសិនហើយណ៎!

- បាទ!

បន្តិចមក យុវជនក៏បានមកដល់គេហដ្ឋានស្តុកស្តម្ភមួយ ក៏ស្ទុះផ្លោះរបងភ្លែតចូលទៅក្នុងផ្ទះ ។

- ចោរ! ចោរ! មានចោរស្លៀកពាក់ចម្លែកលោតផ្លោះរបង ចូលផ្ទះលោកវណ្ណៈហើយ! ទំនងដូចជាក្មេងស្ទាវជើងកាងញៀន អាភៀនផង ក៏មិនដឹង ។

អ្នកស្រុកម្តុំនោះស្រែកឆោឡោឡើង ។ ប៉ូលីសផ្ទុកញ្ញេច្រេចៗ បំរុងនឹងផ្លោះរបងទៅតាមដែរហើយ ស្រាប់តែប្រទះឃើញទ្វារតូច ឯចំហៀងផ្ទះ បើកចំហ ក៏លាន់មាត់ថា ៖

- ហើយចុះវាស្ទីហ្នឹង? ទ្វារចំហមិនចូល ម៉េចបានជាទៅផ្លោះ របងទៅវិញ? ចម្លែកមែន!

លុះប៉ូលីសទាំងពីរនាក់ចូលទៅដល់ក្នុងផ្ទះ ស្រាប់តែឃើញ យុវជននោះកំពុងអង្គុយគងទាក់ខ្លាលើសាឡុង នៅក្នុងបន្ទប់ទទួល ភ្ញៀវ បើកទូរទស្សន៍មើល ។

- មានការអ្វីដែរពូ? (យុវជនសួរប៉ូលីស)

- គឺមានអ្នកស្រុកស្រែកថាមានចោរចូលទីនេះ ។

- អញ្ចឹងទៅប្រាប់អ្នកស្រែកវិញទៅ ថាចោរហ្នឹងវាងាប់បាត់ហើយ ព្រោះភ័យនឹងអ្នកស្រុកស្រែកខ្លាំងៗពេក ។

CHANBOKEO.COM

ពូប៉ូលីសពីរនាក់នោះមើលមុខគ្នា ញាក់មុខហើយដើរចេញទៅ វិញបាត់ទៅ ។ បន្តិចមក មនុស្សពីរនាក់ដើរចុះជណ្តើរមកដល់ ។ យុវជននោះបែរភ្នែកក្រឡេកមើលឃើញដូនចាស់ម្នាក់ នឹងស្រ្តីមាន គភ៌ដែលគេបានជួបតាមផ្លូវនោះ កំពុងដើរមករកនាយ ។

- ជំរាបសួរយាយ !
- ពុទ្ធោ! អ្នកប្រុសវណ្ណឌីទេហ៍ ? បែកពីផ្ទះមួយឆ្នាំ ត្រឡប់មក វិញ តែងខ្លួនប្លែកអញ្ចឹងទៅ យាយមើលលែងស្គាល់តែម្តង ។

ពេលនោះ យុវជនក៏ជ្រួញចិញ្ចើមដាក់ស្ត្រីយើង ។ យាយរៀម ឃើញដូច្នោះ ក៏ណែនាំអោយស្គាល់គ្នា ៖

- នេះគឺមីងចរិយា ត្រូវជាភរិយារបស់លោកប៉ាណា៎អ្នកប្រុស !

ស្រាប់តែយុវជនបើកភ្នែកធំៗសំដែងការភ្ញាក់ផ្អើល រួចហើយ ក៏ដើបគេចយ៉ាងរហ័ស ដើរឡើងទៅខាងលើបាត់ទៅ ដោយមិន រវល់នឹងសំពះសួរគួរសមអ្វីនឹងចរិយាទេ ។

- ស្លាប់ហើយ កូននេះ ? ទៅបរទេសមួយឆ្នាំ ក្លាយជាក្មេងជងនង លែងចេះសំពះចាស់រលីងតែម្តង ។
- កុំបន្ទោសគេអីយាយ ! ប្រហែលជាគ្នាមិនទាន់បានត្រៀមចិត្ត ទទួលខ្ញុំនៅឡើយទេ ។

យាយរៀមនៅស្ងៀម កាលបើឮដូច្នោះ ។

ថ្ងៃត្រង់មកដល់...

ពូតឿបើកឡាននាំលោកវណ្ណ:និងកូនទាំងអស់មកដល់ ។ ក្មេង ទាំងអស់រត់ព្រួទៅដូរខោអាវនឹងអាលមកបរិភោគអាហារ ។ លោក វណ្ណ:ក៏ដើរហួសទៅចង្ក្រានបាយ ឃើញចរិយាកំពុងរៀបអាហារ ។ លោកក៏ដើរទៅស្រវាអោបថើបកញ្ចឹងកនាងពីក្រោយ សម្តែងនូវក្តី ស្រឡាញ់និងការយកចិត្តទុកដាក់ចំពោះភរិយា ៖

- ថ្ងៃនេះ អូនស្រួលបួលទេ យ៉ា ?
- ចា៎សបង ខ្ញុំមិនអីទេ ។ ពេទ្យប្រាប់ថា ប្រហែលជាត្រូវសំរាល ក្នុងអាទិត្យនេះហើយ ។
- អូនទៅរក្សាសុខភាពនៅគ្លិនិកជិតផ្ទះយើងនេះ មែនទេ ?
- ចា៎ស មែនហើយ ព្រោះជិត ស្រួលដើរទៅមក នឹងអាលបាន សម្រាលកូនស្រួលផង ។
- អូនដើរប្រយត្ន័ៗផងណា៎ ! ពេលភ្លៀង ផ្លូវម្តុំនេះរអិលណាស់ !

CHANBOKEO.COM

- ចាំសបង!

- ហើយអូនធ្វើម្ហូបអីហ្នឹង យ៉ា ?

- គឺសុទ្ធតែជាម្ហូបដែលបងនឹងកូនចូលចិត្តទាំងអស់ ចាំស!

រំពេចនោះ កូនៗទាំងបីនាក់ក៏មកចូលមកដល់ ដាក់ខ្លួនអង្គុយ តាមកន្លែងរៀងខ្លួន ។

- អូ៎យ ធំឈ្ងុយដល់ហើយម៉ាក់ (នាងតូចវណ្ណាស្រដី) ធ្វើអោយ កូនឃ្លានបាយតែម្តង!!

ស្រាប់តែ...

- នរណាគេទៅ ជាម៉ាក់របស់ប្អូន អូនវណ្ណា ?

ទាំងអស់គ្នាបែរមើលវឹងទៅរកម្ចាស់សម្លេង ស្រាប់តែប្រទះ ឃើញយុវជនសង្ហារបស់យើង ក្នុងសម្លៀកបំពាក់ម៉ូដថ្មីយ៉ាងខេងរ៉ែង ពាក់ក្រវិលមួយចំហៀង ។

- បងវណ្ណឌី!

ក្មេងទាំងអស់ឧទានព្រមគ្នាឡើង រួចហើយក៏រត់ព្រូទៅស្រវា អោបបងប្រុស ដោយក្តីរីករាយ ។

- វណ្ណឌី ? កូនមកដល់ពីអង្កាល់ហ្នឹង ? ម៉េចមិនអោយដំណឹងប៉ា ជាមុនអញ្ចឹង គ្រាន់នឹងយើងបានទៅទទួលកូននៅចំណតយន្តហោះ

លោកវណ្ណៈពោលទាំងទឹកមុខញញឹមរីករាយ ដែលឃើញកូន ត្រឡប់មកផ្ទះវិញ ។ លោកក៏ដើរទៅជិត យកដៃអង្អែលក្បាលកូន សម្តែងនូវការនឹករលឹក និងសេចក្តីស្រឡាញ់របស់លោក ។

- វណ្ណឌី! កូនជួបប្រពន្ធរបស់ប៉ាហើយឬនៅ ?

យុវជនសង្ហាសម្លឹងមុខចរិយា ដោយក្រសៃភ្នែកស្អប់ខ្ពើម រួច ហើយឆ្លើយថា ៖

- មួយជីវិតនេះ ខ្ញុំមានម្តាយតែម្នាក់ទេ ។

ពួទាំងអស់គ្នាពួដូច្នោះ ក៏សម្លឹងមុខគ្នាទៅវិញទៅមក ។ វណ្ណឌី ក៏ដើរលូកហោប៉ៅដើរធ្វើព្រងើយចេញទៅ ទុកអោយទាំងអស់គ្នា មើលតាមក្រោយធ្វើកិរិយាស្ងៀមស្ងាត់ ។

- តោះ ញ៉ាំបាយទៅកូន! (លោកវណ្ណៈហៅកូន)

វណ្ណនី វណ្ណនេត្រ និងវណ្ណា ក៏ចាប់ស្លាបព្រាបរិភោគ រួចហើយ នាំគ្នាលួចចោលកន្ទុយភ្នែកមើលចរិយា ឃើញនាងធ្វើកិរិយាធម្មតា

CHANBOKEO.COM

ហាក់ដូចជាមិនខឹងតបតអ្វីនឹងវណ្ណឌីទេ ។ មួយស្របក់ក្រោយមក
លោកវណ្ណៈក៏ត្រឡប់ទៅធ្វើការវិញ ។ មុននឹងឡើងរថយន្តទៅ លោកកេះភរិយាឱ្យប្រាប់ថា ៖
- យ៉ា! អូនកុំប្រកាន់អីនឹងវណ្ណឌីណា៎! ទុកពេលអោយគេស្គាល់ អូនបន្តិចទៅ
នោះគេនឹងផ្លាស់ប្តូរចរិតរបស់គេមិនខាន ។
- ចាស មិនអីទេបង! កុំបារម្ភអ្វី! អូនដឹងថា ត្រូវធ្វើយ៉ាងណា ហើយ ។
- អរគុណណាស់ យ៉ា! បងទុកចិត្តអូនទាំងស្រុងហើយ!

លោកវណ្ណៈក៏អោយពូតឿជូនចេញទៅ ។ ចរិយាក៏វិលបែរដើរ ចូលផ្ទះវិញ
ស្រាប់តែឃើញយុវជនវណ្ណឌី ឈរអោបដៃផ្អែកមាត់ ទ្វារវាយឫកក្រអឺត
បោះសំដីផ្លែផ្កាដាក់នាងថា ៖
- ស្រីរកស៊ី វាតែប៉ុនហ្នឹង! ឃើញប្រុសអ្នកមាន ខំស្រវាតោង ក្រែងលោកេវបានកាកលាភ ។
គិតទៅគួរអោយឆ្ងល់មែន សម័យ ឥឡូវនេះ មនុស្សមានដៃមានជើងមានខួរក្បាល
មិនស្កូវចេះពឹង អាត្មាសោះ ចាំតែធ្វើជាឃ្លើងក្រេបជញ្ជក់ឈាមរបស់គេ ស្រាប់ៗ តែម្យ៉ាង..!
អនិច្ចា! អនិច្ចា!

ចរិយាដើរធ្វើមិនឮចូលទៅក្នុងផ្ទះ ។ ស្រាប់តែ វណ្ណឌីស្រដី បន្តទៀតថា ៖
- ថ្លង់ ឬក៏ល្ងង់ បានជាស្តាប់ភាសាមនុស្សអត់បាន ? ឬក៏ជាឃ្លើង បានជាដីដើដូចដោះ
ចេះតែជញ្ជក់ឈាម ?

ចរិយាដើរហួសទៅ ស្រាប់តែវណ្ណនេត្របែរសួរពីក្នុងផ្ទះមក ៖
- ចង់ថាអោយនរណាគេ បងវណ្ណឌី ? ពួកយើងជាកូនរបស់លោក ប៉ា មិនមែនជាឃ្លើងទេ ។
- បងមិនបានថាអោយប្អូនទេ គឺថាអោយមនុស្សចម្លែកនៅក្នុងផ្ទះ របស់យើង ។
- នរណាគេទៅមនុស្សចម្លែក ?
- គឺនរណាដែលមុខខ្លាញ់ចង់ធ្វើលោកស្រីផ្ទះយើងនេះអី ?

ភ្លាមនោះ វណ្ណនីកាត់យល់ថា បងប្រុសកំពុងដៀមដាមអោយ
ចរិយាក៏យកដៃកេះវណ្ណនេត្រមិនអោយនិយាយច្រើន ក្រែងនាំ
អោយបងប្រុសខឹងរិតតែខ្លាំងទៀត ។ ចរិយាដើរទៅអង្គុយជិតនាង តូចវណ្ណាហើយស្រដីថា ៖
- អូនតូចធ្វើលំហាត់សាលាហើយនៅ ? បន្តិចទៀត ដល់ម៉ោងទៅ រៀនវិញហើយ ។
- ចាស់នៅទេ! ម៉ាក់ជួយអូនតូចបន្តិចណា៎!
- អូនហៅនរណាគេម៉ាក់ អូនវណ្ណា ?

CHANBOKEO.COM

វណ្ណឌីដើរមកដល់ច្រត់ចង្កេះ និយាយកាត់ ។

- គឺម៉ាក់យ៉ានោះអី ?
- គេមិនមែនជាម៉ាក់យើងទេ ។ ហេតុអ្វីក៏អូនតូចឆាប់ភ្លេច ម៉ាក់យើងម្ល៉េះ ?
- អូនតូចមិនដែលភ្លេចម៉ាក់យើងទេ ប៉ុន្តែ ម៉ាក់មិនបាននៅជាមួយ អូនតូចតទៅទៀត មានតែម៉ាក់យ៉ាទេ ដែលមើលថែអូនតូចរាល់ថ្ងៃ ទើបអូនហៅគាត់ថាម៉ាក់ ។
- គឺ គេកំពុងប្រើល្បិចលួងលោមប្អូន គេងយកទ្រព្យសម្បត្តិមរតក ម៉ាក់និងលោកប៉ានោះអី ។
- ម៉ាក់យ៉ាមិនមែនជាមនុស្សដូច្នោះទេ (វណ្ណនេត្រឆ្លើយជំនួស)
- ឈប់តមាត់បងភ្លាម អូននេត្រ!
- មិនឈប់ទេ បងឌីនិយាយមិនពិត!
- ព្រហើន! សំដីថ្លោសណាស់នាយល្អិត! យូរៗកាន់ជើងអ្នកដទៃ មកតបមាត់តបកនឹងបងប្អូនខ្លួនហើយតើហ៎!
- បងក៏ព្រហើនដូចគ្នា និយាយស្ទី ស្រែកខ្លាំងៗដូចពួកជើងកាង
- ហ៊ានមើលងាយបងផងហ្ន៎ស ?

វណ្ណឌីក៏ស្ទុះដើបទៅជិតវណ្ណនេត្រ លើកដៃរកទះប្អូន ស្រាប់ តែ ចរិយាលូកដៃរាំង ៖

- ប្អូននៅតូចណាស់ កុំវាយគ្នា!
- យើងប្រដៅប្អូនរបស់យើង កុំមកចេះ!
- បើចង់ប្រដៅ កុំប្រើហឹង្សា ព្រោះគ្នានៅតូច មិនអាចទ្រាំនឹង ដៃជើងធំៗបានទេ (ចរិយាឃាត់)
- នែ៎! កុំមកធ្វើឫកជាលោកស្រីឬជាម៉ែខ្ញុំនៅទីនេះអោយសោះ! ស្រីដូចអ្នក ទោះប្រឹងតោងទំទ្រនំខ្ពស់យ៉ាងណា ក៏មិនបាត់ដានក្លិន ទា ក្លិនចក ក្លិនកំប្លោកដែរ ។ កុំចេះមកចេះហែហែ!!

ចរិយាសម្លឹងមុខយុវជនយើងហើយញញឹម រួចសួរវិញថា ៖

- ហើយចុះឫកពានិងសំដី ដែលប្អូនកំពុងសំដែងនេះ មានក្លិន យ៉ាងម៉េចដែរ ? ក្លិនអ្នកថ្លៃថ្នូរ មានការអប់រំ មានការសិក្សា ខ្ពង់ខ្ពស់ ឬក៏ជាក្លិនក្មេងជើងកាងញៀនអាភៀន គេចវេះមិនចូលសាលា ? តើកូនចៅអ្នកថ្លៃថ្នូរ គេនិយាយបែបហ្នឹង មានចរិត បែបហ្នឹង មែនទេ ?

វណ្ណឌីបើកភ្នែកក្រឡោត កាលបើត្រូវចរិយាសើកសៀតអោយ វិញ ។

- យើងធ្វើអ្វីស្រេចតែយើង អ្នកមិនមែនជាម្តាយយើងទេ កុំចេះ មកប្រដៅស្អី ?

CHANBOKEO.COM

- នរណាគេហ៊ានប្រដៅអ្នកចេះដឹងនោះ អ្នកកម្លោះ ? ហើយបើ ប្អូនជាអ្នកចេះដឹងពិតមែននោះ សូមមេត្តាបង្ហាញផង ថាអ្នកចេះ ដឹង អ្នកថ្លៃថ្នូរនោះ គេមានឫកពាយ៉ាងណា ដើម្បីអោយបងបានរៀនសូត្រតាមប្អូនផងណា៎! កុំអោយបងល្ងិតល្ងង់ខ្លៅតទៅទៀត ។

ស្រាប់តែវណ្ណនេត្រឆ្លើយបន្ថែមទៀត ៖

- ទៅជប៉ុនជាងម៉ាឆ្នាំ ត្រឡប់មកវិញ ធ្វើឫកដូចជើងកាងបេះដាក់ ថ្លៃថ្នូរអីអញ្ចឹង ?

- ឈប់មាត់ នាយល្ងិត! តិច!

វណ្ណឌីស្រដីផង លើកដៃយាររកទះប្អូនប្រុសផង ។ ចរិយា ឃើញដូច្នោះ ក៏ងើបលើកដៃរងការពារ ៖

- កុំវាយប្អូន អ្នកប្រុសវណ្ណឌី!

អ្នកកម្លោះខឹងណាស់ ក៏ចាប់ដៃចរិយាគ្រវាសចេញយ៉ាងអស់ ទំហឹង ។ ចរិយាទប់ខ្លួនមិនជាប់ ក៏ដួលអុកខ្លួនទៅលើជ្រុងកៅអី សាឡុងមួយ កៀននោះ ៖

- អ៊ុយ!

ស្រាប់តែនាងធ្វើមុខស្លេក រួចហើយបញ្ឈរភ្នែកស្លឹងឡើង ទន់ ខ្លួនល្វក់តែម្តង ។

- ម៉ាក់! ម៉ាក់! (នាងតូចវណ្ណាស្រែកឡើង)

ក្មេងៗក៏រត់ឈូឆរមកចោមរោមជួយ ។ វណ្ណឌីក្រឡេកឃើញ ដូច្នោះ ក៏ភ័យភើតពោះស្ទុះទៅជួយលើកនាងវិញ ៖

- នែ៎! អីក៏មាយាម្ល៉េះ ? គ្រាន់តែយើងច្រានបន្តិចសោះ ធ្វើជាដួល ដែរ! ចំមែន!

រំពេចនោះ ស្រាប់តែ អ្នកទាំងអស់ឃើញឈាមហូរធ្លាក់ពីខ្លួន របស់ចរិយាយ៉ាងច្រើន... ក្មេងៗភិតភ័យណាស់ ក៏ស្រែកឆោឡោ ឡើង ធ្វើអោយយាយរៀមរត់មកមើលភ្លាម ។

- ម៉ាក់! ម៉ាក់!

- ម៉ាក់ឯងធ្លាយទឹកភ្លោះហើយ ឆាប់ទៅតាមតាក់ស៊ី ឬតាមពេទ្យ អោយលឿនមក...!

វណ្ណឌីឈរធ្វើទ្រឹងដោយការភិតភ័យ ព្រោះនឹកស្មានថា ខ្លួនគេច្រាននាងអោយដួលដំខ្លាំងដល់ម្លឹង ។

- នែ៎ អ្នកប្រុសវណ្ណឌី! នៅឈរដល់ណាទៀត ? ឆាប់ទូរសព្ទ័ទៅ ប៉ា ទៅនរណាក៏បានដែរ ដើម្បីអោយគេមកជួយភ្លាមមក៎...!!

វណ្ណឌីឮហើយ ក៏ស្ទុះទៅទាញទូរសព្ទ័ឡើង...

CHANBOKEO.COM

នៅក្នុងមន្ទីរពេទ្យមួយ...

- យ៉ា! អូនយ៉ាងម៉េចទៅហើយ... ?

ចរិយាប្រែខ្លួនឡើង ឮសម្លេងលោកវណ្ណៈហៅនាងខ្សិបៗក្បែរ ត្រចៀក ។

- វិលមុខណាស់បង!... ហើយចុះកូនរបស់យើង... យ៉ាងម៉េច ទៅហើយ... ?

- ពេទ្យកំពុងពិនិត្យសុខភាពអោយហើយ បន្តិចទៀត លោកគ្រូ ពេទ្យ នឹងនាំដំណឹងមកប្រាប់យើងមិនខាន ។

ចរិយាលូកចាប់ដៃលោកវណ្ណៈ ទាំងញ័រៗ ៖

- អូនសូមបន់ស្រន់ អោយកូនរបស់យើងផុតពីគ្រោះថ្នាក់!

- បងជឿជាក់ថា គេពិតជាផុតពីគ្រោះថ្នាក់មិនខាន អូនកុំបារម្ភអី

- ស្តាយណាស់ដែលអូនមិនបានប្រយត្ន័ខ្លួន ធ្វើឲ្យគ្រោះថ្នាក់ ដល់ កូនយើង ។

- កុំបន្ទោសខ្លួនឯងអី... គិតតែរឿងល្អៗទៅបានហើយណ៎ាអូន!

ចរិយាដាក់ភ្នែកទៅមាត់ទ្វារ ឃើញវណ្ណឌីនិងប្អូនៗលួចឈរ អើតអើមៗមើលនាងពីក្រៅមក ។ មាណវីក៏បក់ដៃហៅ ៖

- ចូលមក៎ កូន!

ទាំងបីនាក់ប្អូននាំគ្នាដើរចូលមក ប៉ុន្តែ វណ្ណឌីនៅឈរអេះអុញ មិនហ៊ានចូល ។ ឃើញដូច្នោះ វណ្ណនីក៏ទាញដៃបងប្រុសអូស ចូលមកដែរ ។

- ម៉ាក់ ស្រួលហើយឬនៅ ? (វណ្ណាសួរ)

- ចាស៎! ម៉ាក់បានគ្រាន់បើហើយ ប៉ុន្តែ ម៉ាក់ចាំដំណឹងពីប្អូនរបស់ កូន មិនដឹងថាគេយ៉ាងណាទៅហើយទេ ។

រំពេចនោះ លោកគ្រូពេទ្យក៏ដើរចូលមកដល់ ៖

- កូនស្រីរបស់លោក សុខសប្បាយទេ!

លោកវណ្ណៈឮហើយក៏បែរញញឹមដាក់ភរិយាដោយសេចក្តីត្រេក អរ ។ ស្រាប់តែលោកគ្រូពេទ្យមានប្រសាសន៍បន្តថា ៖

- ប៉ុន្តែនាងមានស្នាមជាំលើសស្មាឆ្វេងយ៉ាងធំ ដោយការដួលទង្គិច ហើយជាំរហូតដល់ឆ្អឹងទៀតផង ។ នាងត្រូវនៅរក្សាជម្ងឺនៅមន្ទីរ ពេទ្យ យូរថ្ងៃទៀត ទំរាំសះស្បើយ ។

CHANBOKEO.COM

ចរិយារលីងរលោងទឹកភ្នែក ដោយក្តីអាណិតចំពោះទារកតូច ៖

- ពុទ្ធោ កូនស្រីម្តាយ!

ភ្លាមនោះលោកវណ្ណៈបែរមើលវណ្ណឌី ដោយក្រសែភ្នែកយ៉ាង មុតរួចហើយស្រដីទំនងខកចិត្ត ថា ៖

- មកផ្ទះមិនទាន់បានម៉ាងើផង នាំរឿងចូលផ្ទះភ្លាម! យ៉ាប់មែន ឯងនេះ!

ស្រាប់តែវណ្ណឌីថ្លោះទឹកមុខ ធ្វើភ្នែកក្រហមចង់ស្រក់ទឹកភ្នែក ហើយឆ្លើយថា ៖

- មែនហើយ! ខ្ញុំជាឆ្កែកំបែកក្បាល ជាកូនកំព្រា គ្មាននរណាគេ ស្រឡាញ់ គ្មាននរណាគេនឹកនាខ្ញុំទៀតទេ ។ ពេលនេះ លោកប៉ា មានប្រពន្ធថ្មី កូនកំព្រាដូចខ្ញុំវាលែងមានន័យសំរាប់លោកប៉ាទៀត ហើយ ។

ថាហើយ វណ្ណឌីក៏រត់ចេញទៅយ៉ាងលឿន ។ លោកវណ្ណៈគ្រវី ក្បាលហួសចិត្ត រួចមានប្រសាសន៍ប្រាប់កូនស្រីថា ៖

- ឆាប់តាមទៅមើលបងឯងបន្តិចទៅមើល កូននី!

- ចា៎ស!

វណ្ណនីក៏នាំប្អូនរត់ព្រូទៅតាមពីក្រោយភ្លាម ។ ចរិយាឃើញ ដូច្នោះ ក៏ស្រដីថា ៖

- បងបន្ទោសកូនយ៉ាងនេះ នាំតែគេរិតតែអន់ចិត្តថែមទៀត ហើយណា៎បង!

- ព្រោះបងខកចិត្តនោះអី ដែលគេមានចរិតព្រហើនផ្តេសផ្តាស ។

- ប៉ុន្តែ បងមិនគួរស្តីបន្ទោសគេ នៅចំពោះមុខប្អូនៗទេ ។ គេធំ ពេញវ័យហើយ គ្នាខ្មាសប្អូនណា៎បង! ឃើញទេ? គេកំពុងមាន វិប្បដិសារី ដើរអេះអុញៗមកលួចមើលខ្ញុំ មិនហ៊ានចូល គឺមាន ន័យថាគេកំពុងតែដឹងកំហុសរបស់គេហើយ ។ បើបងបន្ទោសគេ ថែមទៀតយ៉ាងនេះ គេច្បាស់ជាតូចចិត្តហើយរិតតែធ្វើផ្តេសផ្តាស ឡើង ។ ខ្ញុំពិភាល់ក្នុងចិត្តណាស់!

លោកវណ្ណៈនៅស្ងៀមមួយភ្លែត ក៏ស្រដីថា ៖

- អំបាញមិញ បងចេះតែនិយាយៗទៅ អោយវាធូរទ្រូង ប៉ុន្តែ បងភ្លេចគិតថា គេកំពុងមានខ្ជក់នៅក្នុងចិត្ត ។

- អញ្ចឹង បងទៅតាមកូនបន្តិចទៅ ។

- តាមធ្វើអី? បន្តិចទៀត គេគង់តែត្រឡប់មកវិញទេ ។

CHANBOKEO.COM

- យ៉ាងណាក៏គួរទៅតាមដែរ ដើម្បីបង្ហាញថា បងស្រឡាញ់គេ ហើយខ្វល់ខ្វាយបារម្ភពីគេ មិនថាវេលាណាទេ មិនថាកូនធ្វើខុស ឬ ធ្វើត្រូវទេ ។ បើបងមិនទៅវិញ នោះគេនឹងគិតថា ឪពុកកំពុងតែ បោះបង់ លែងនឹកនារូបគេហើយ ។

លោកវណ្ណៈសម្លឹងមុខភរិយា គិតមួយស្របក់ ក៏យកដៃអង្អែល ថ្ពាសមាណវី បន្តើរៗ ៖

- អរគុណណាស់អូន ដែលយល់ចិត្តក្មេង យល់អារម្មណ៍របស់ក្មេង ជាងបង ។ អញ្ចឹង បងទៅសិនហើយណា៎! បន្តិចទៀត បងមក មើលអូនវិញ ។

- ចា៎សបង!

លោកវណ្ណៈដើរចេញទៅក្រៅតាមរកវណ្ណឌីភ្លាម ស្រាប់តែមក ប្រទះឃើញគេនៅអង្គុយនៅលើកៅអីថ្ម ក្រោមដើមចំប៉ី យកដៃ ខ្ទប់ថ្ពាស បាំងមុខ ទំនងហាក់ដូចជាកំពុងលាក់ទឹកភ្នែក ។ ចំណែក បីនាក់ទៀត ឈរហែងក្បែរនោះ មិនឃើញធ្វើមាត់ធ្វើកអ្វីទេ ។ លោកក៏ដើរទៅជិត យកដៃអង្អែលក្បាលកូន ។ វណ្ណឌីភ្ញាក់ព្រើត ងើបមុខឡើង ឃើញឪពុក ក៏ស្ទុះងើបរត់រឹងចេញទៅក្រៅរបង យ៉ាងលឿន ដោយមិននិយាយអ្វីជាមួយឪពុកមួយម៉ាត់ឡើយ ។

- វណ្ណឌី! ទៅណាហ្នឹងកូន ? វណ្ណឌី!

លោកវណ្ណៈស្រែកហៅ ប៉ុន្តែ យុវជនយើងបានឡើងម៉ូតូឌុប ចេញទៅ ដោយកិរិយាតោះតើយបំផុត ។ លោកវណ្ណៈគ្រវីក្បាល ហួសចិត្តនឹងភាពឆេវឆាវរបស់កូន ។

១០ថ្ងៃ ក្រោយមក...

ចរិយាបានស្រួលខ្លួនវិញហើយ ប៉ុន្តែទារកតូចរបស់នាងស្ថិត នៅក្រោមការព្យាបាលនៅឡើយ ថ្វីបើ លោកគ្រូពេទ្យបានអនុញ្ញាត អោយម្តាយឪពុកទទួលយកនាងមកថែរក្សានៅផ្ទះហើយក៏ដោយ ។ រៀងរាល់ថ្ងៃ អ្នកគ្រូពេទ្យម្នាក់តែងតែមកពិនិត្យជម្ងឺទារកដល់ផ្ទះ ។ ហើយប៉ុន្មានថ្ងៃនេះ វណ្ណឌីក៏បាត់ពីផ្ទះទៅដែរ មិនឃើញគេត្រឡប់ មកផ្ទះវិញទេ ។ លោកវណ្ណៈខ្វល់ខ្វាយសំរាន្តមិនលក់អស់ច្រើនថ្ងៃ ព្រោះមិនដឹងទៅតាមរកកូននៅឯណា ។

- បងកុំព្រួយពេក! មិនយូរមិនឆាប់ គេគង់ត្រឡប់មករកផ្ទះវិញ ទេ ។ គេមិនភ្លេចផ្ទះគេឡើយ ។ បងព្រួយចិត្តមិនសំរាន្តបែបនេះ ប្រយត្ន័ឈឺណា៎បង!

ចរិយាលួងលោមស្វាមី ។

CHANBOKEO.COM

- បងកាត់ចិត្តថា មិនព្រួយដែរ តែកាត់មិនដាច់ទេអូន ។ អូនមិន ឃើញទេ ចរិតរបស់គេ ការតុបតែងខ្លួនរបស់គេ វាខុសប្លែកពីកូន វណ្ណឌីរបស់បងពីមុននោះណាស់ ។ ពីដើម គេជាក្មេងស្រគត់ស្រគំ ពេលនេះ ក្លាយជាព្រហើនកោងកាច ។ ចំណែកការស្លៀកពាក់វិញ គឺមិនខុសពីពពួកក្មេងជើងកាងតាមចិញ្ចើមថ្នល់ទេ ។

- នោះ គឺមកពីគេមានបញ្ហាចិត្តវិបត្តិ ដោយការបាត់បង់ម្ដាយ ធ្វើ អោយដួងចិត្តគេខ្វះការកក់ក្ដៅ ។ ម្យ៉ាងទៀត គេនៅក្មេងហើយ ត្រូវទៅនៅឆ្ងាយពីគ្រួសារ គ្មាននរណានៅជិតនឹងផ្ដល់ការកក់ក្ដៅ ដល់គេ គ្មានអ្នកជួយលើកកម្លាំងចិត្ត ទើបគេចេះតែស្វែងធ្វើអ្វីៗ ដែលប្លែកៗ ដើម្បីអោយចិត្តគេបាត់តប់ប្រមល់ ។

- ប៉ុន្តែគេជាប្រុសហើយកំពុងពេញកម្លោះដែរ គួរណាស់តែមាន ចិត្តរឹងប៉ឹង មិនគួរបណ្ដោយអោយចិត្តវិបត្តិវាបំពានជីវិតបានទេ ។

- ធម្មជាតិមនុស្សយើង មិនថាវ័យណា ចំណាស់ណាទេ តែងតែ ត្រូវការភាពកក់ក្ដៅក្នុងចិត្តជានិច្ច ជាពិសេសពីក្រុមគ្រួសាររបស់ ខ្លួនតែម្ដង ។ ចំពោះវណ្ណឌី គ្នាទើបតែបាត់បង់ម្ដាយថ្មីៗ បន្ទាប់មក ក៏ត្រូវចាកចេញពីប្រទេស ទៅរៀននៅប្រទេសក្រៅឆ្ងាយសង្គម គ្រួសារដែលខ្លួនធ្លាប់បានទទួលការកក់ក្ដៅ គេពិតជាមិនអាចទ្រាំ បានទេ ដែលគេបាត់បង់ដល់ទៅពីរជាន់ គឺបាត់បង់ម្ដាយហើយ បាត់បង់ប្រភពកម្លាំងចិត្តក្បែរខ្លួនទៀត ។ ដូច្នេះហើយទើបគេគិត ថា ក្នុងលោកនេះ គ្មាននរណាស្រឡាញ់គេ គ្មាននរណាយកចិត្តទុក ដាក់នឹងគេ ។ មនុស្សខ្លះមានភាពរឹងប៉ឹងអាចទ្រាំទ្រនិងទទួលយក ការបាត់បង់នេះបាន ហើយប្រឹងប្រែងដើរឆ្លងជីវិតទៅមុខទៀត ដោយមិនបែរមើលទុក្ខសោក ដែលគេទម្លាក់ចោលនៅពីក្រោយខ្នង ប៉ុន្តែចំពោះបុគ្គលខ្លះ ឧទាហរណ៍ដូចជាវណ្ណឌី គេមិនមានស្មារតីនិងចិត្ត រឹងប៉ឹងទេ ។ គេកំពុងត្រូវការចំណាប់អារម្មណ៍ពីគ្រួសារ ទើបគេធ្វើ អ្វីប្លែកៗទាមទារការចាប់អារម្មណ៍ពីឪពុកនិងពីបងប្អូន ។

លោកវណ្ណៈស្ដាប់ភរិយាពន្យល់ផង គិតផង បន្ទាប់មកក៏មាន ប្រសាសន៍ថា ៖

- ហេតុអ្វីក៏នឹងច្រើនម្លេះ យ៉ា ?

- បងមិនចាំទេឬ ? អូនក៏ធ្លាប់ជាក្មេងដែលបាត់បង់ម្ដាយ បាត់បង់ ភាពកក់ក្ដៅដូចគ្នានឹងវណ្ណឌីអញ្ចឹង... ដូច្នេះហើយ ទើបអូនអាច យល់អារម្មណ៍របស់គ្នាបាន ។

លោកវណ្ណៈញញឹមដាក់ប្រពន្ធ ៖

- នេះប្រហែលជាបងទុកនាទីនេះ អោយប្រពន្ធបងសម្រួលស្ថាន ការណ៍ជាមួយកូនឌីតែពីរនាក់ មើលទៅបែបជាមានប្រសិទ្ធិភាព ជាង ។

- បងទុកចិត្តអូនមែនហ្ន៎ស ?

- មែនណា !

- អូនសង្ឃឹមថា អូនអាចនិយាយជាមួយគេស្តាប់បាន បើសិនជាគេ មានអំណត់គ្រប់គ្រាន់នឹងអង្គុយស្តាប់ខ្ញុំនិយាយ ។

- បើអញ្ចឹង យើងនឹងតាមរកគេ ដើម្បីសម្រុះសម្រួល កុំអោយគេ ចេះតែខឹងនឹងអូនដោយឥតរឿងហេតុទៀត ។

- ម៉េចក៏បងថាអត់រឿងហេតុអញ្ចឹង ?

- អូហ៍ ហើយចុះមានរឿងហេតុអ្វីទៅ ?

- គឺរឿងអូនរៀបការជាភរិយារបស់បងនោះអី ! គេកំពុងខឹងនឹង អូនដែលមកដណ្តើមកន្លែងរបស់ម្តាយគេ ។

- តែម្តាយគេបានចែកស្ថានទៅហើយ ។

- បងដឹងទេ ? ទោះបីលោកបានធ្វើមរណកាលទៅមែន តែលោក នៅតែមានជីវិតរស់រវើកក្នុងបេះដូងកូន អារម្មណ៍កូនជានិច្ច ជា ពិសេស ចំពោះម្តាយឪពុកដែលធ្លាប់ផ្តល់ភាពជិតដិតស្និទ្ធស្នាលនិង ក្តីស្រឡាញ់ដល់កូនកម្រិតណា ស្រមោលលោកក៏នៅរស់រវើកក្នុង បេះដូងកូនយ៉ាងជិតដិតស្និទ្ធស្នាលកម្រិតនោះដែរ មិនថាលោក ទើបចែកស្ថានទៅឬក៏ចែកស្ថានទៅយូរអង្វែងយ៉ាងណាក៏ដោយ ។

- ពុទ្ធោអើយ ! អ្នកគ្រូពេទ្យចិត្តសាស្ត្រ ! ពិតជាមានទ្រឹស្តីពិរោះ ដល់ហើយ ។ បងសង្ឃឹមថា អូននឹងក្លាយជាទៀនបំភ្លឺផ្លូវឯងជិតដល់ កូនវណ្ណឌី អោយគេបែរមករកភាពកក់ក្តៅវិញឆាប់ៗនេះ ។

ចរិយាញញឹមដាក់ស្វាមី សួរថា ៖

- ហើយចុះឯណាថាបងជួយអូនអោយទៅរៀនធ្វើគ្រូនោះ ? អូន កំពុងរង់ចាំឱកាសនោះហើយ ។

លោកវណ្ណៈញញឹមដាក់ប្រពន្ធ រួចហើយយកដៃបូតច្រមុះនាង ដោយក្តីស្រឡាញ់ ៖

- ប៉ុនចាំច្រើនម្ល៉េះ ប្រពន្ធសម្លាញ់ ? ពេលនេះអូនសរសៃខ្ចី បងមិនទាន់ចង់អោយអូនចេញពីផ្ទះ ទៅណាមកណាទេ ។

CHANBOKEO.COM

- កាលមុន អូនចង់ទៅរៀន បងថា អូនមានផ្ទៃពោះ នៅថៃខ្លួន បន្តិចសិន ។ ពេលនេះ ខ្លួនអូនទំនេរហើយ បងថាអូនសរសៃខ្ចី... ចុះនៅមានលេសស្អីទៀតដែរទេបង ?
- គឺនៅពពោះអោយបងបានកូនពីរបីនាក់សិនបានទេ ?
- អត់ទេ! សម័យឥឡូវ មានកូនច្រើន មិនជឿនលឿនទេ ព្រោះ អាល័យតែកូនច្រើន ម្តាយមិនបានរៀនសូត្រ តើម្តាយមានចំណេះ ចេះដឹងអីនឹងប្រដៅអប់រំកូនអោយល្អបាន ក្រៅពីការប្រដៅអប់រំ បែបបុរាណនោះ ? ពេលនេះ សង្គមយើងជឿនលឿនណាស់បង ។ យើងជាម្តាយឪពុកត្រូវតែខំរៀនសូត្រដែរ ដើម្បីយកការចេះដឹង មកអប់រំប្រដៅកូន នោះទើបកូនយើងមានអភិវឌ្ឍន៍ក្នុងការសិក្សា រៀនសូត្រ ហើយអាចរត់ទាន់ការជឿនលឿននៃពិភពលោកផង ។
- មែនហើយ! អូននិយាយត្រូវណាស់ ។ ការពិត បងលលេងអូន ទេតើហ៍ ។ បងក៏ចង់អោយអូនត្រឡប់ចូលរៀនវិញដូចគ្នា ព្រោះ អូនមានសម្បទានិស្ស័យអាចទទួលការសិក្សាបានថែមទៀត ហើយ អាចប្រើការចេះដឹងរបស់អូនចែកចាយដល់កូនៗរបស់យើង និង ដល់ក្មេងទូទៅ ។ នៅក្នុងប្រទេសខ្មែរយើងសព្វថ្ងៃនេះ បើម្តាយ ទូទៅគិតដូចអូនគ្រប់ៗគ្នា ប្រទេសប្រហែលជាចំរុងចំរើនជឿន លឿនមិនខាន ។
- ប្រហែលជាមិនខ្វះអ្នកគិតដូច្នោះទេណ៎បង! គ្រាន់តែថា ខ្លះក៏ គ្នាមានសមត្ថភាព លទ្ធភាព និងថវិកាអាចទៅបាន ។ ខ្លះទៀត ទៅរួចត្រឹមតែគំនិត តែខ្វះលុយ ខ្វះពេលវេលា ព្រោះជីវភាព គ្រួសារវាអត្តខាត់ពេក ។
- បងសង្ឃឹមថា អូននឹងក្លាយជាម្តាយគំរូដ៏ល្អម្នាក់ប្រចាំកម្ពុជា ហើយ ។
- សរសើរតែគោខ្លួនឯងសោះហើយ បងឯងនេះ!
- សរសើរគោអ្នកដទៃម្តេចកើត បើមិនដែលស្គាល់ផង ? ត្រូវតែ សរសើរគោខ្លួនឯងអញ្ចឹងហើយ ព្រោះបានឃើញសកម្មកិច្ចនិង សមត្ថភាពរបស់គោយើងហ្នឹងរាល់ថ្ងៃ ដោយផ្ទាល់ភ្នែក ដឹងច្បាស់ ថាបងអាចទុកចិត្តបានត្រឹមណា ។

ភ្លាមនោះ អ្នកទាំងពីរក៏សើចរអឹកដាក់គ្នាឡើង យ៉ាងរីករាយ រមនា ។

oooooooooooooooooo

# វគ្គទី៩
# សារាណីយមាតា

មួយខែកន្លងទៅ...

វណ្ណឌីក៏បាត់មុខទៅ មិនឃើញត្រឡប់មកផ្ទះសោះ ។ លោក វណ្ណៈពិបាកចិត្ត មុខស្រងូតរាល់ថ្ងៃព្រោះនឹកព្រួយដល់សុវត្ថិភាព របស់កូន ។ ថ្ងៃមួយ ចរិយាក៏ពិគ្រោះជាមួយស្វាមីថា ៖

- អូនគិតថា អូនមានមធ្យោបាយហៅអោយគេត្រឡប់មកផ្ទះបាន ។
- មែនឬយ៉ា ?
- ចា៎ស! សង្ឃឹមថា ប្រហែលជាមានប្រសិទ្ធិភាព ។
- អញ្ចឹង យើងធ្វើយ៉ាងម៉េចទៅ ?

ចរិយាក៏អោនខ្សឹបដាក់ត្រចៀកលោកវណ្ណៈ រួចហើយញញឹម ៖

- សាកមើលទេ បង ?
- សាកក៏សាក! កិច្ចការតូចប៉ុនហ្នឹង បងធ្វើបាន!
- អញ្ចឹង បងទូរសព្ទ័ភ្លាមទៅ ។

លោកវណ្ណៈក៏លើកទូរសព្ទ័ឡើង ហៅ ៖

- ជំរាបសួរបាទ! សូមជួបលោកនាយការផ្សាយពត៌មានបាទ!

នៅម្ខាងទៀតនៃបន្ទប់ទទួលភ្ញៀវ កូនទាំងបីនាក់របស់លោក កំពុងតាមមើលម្តាយឪពុកពិគ្រោះគ្នា សំដែងការងឿងឆ្ងល់ ។

CHANBOKEO.COM

- មានគំរោងអីហ្នឹងម៉ាក់ ? (វណ្ណនីសួរ)

- គឺហៅបងឌីអោយត្រឡប់មកផ្ទះវិញណា៎ !

- ជយោ ! សូមអោយបងឌីឆាប់មកផ្ទះវិញ (នាងតូចវណ្ណាស្រែក ហ៊ោរ)

ទាំងអស់គ្នា ក៏ស្រែកហ៊ោរតាមថែមទាំងលើកដៃបន់សុំអោយ បងប្រុសឆាប់មកផ្ទះវិញផង ។

ព្រឹកស្អែកឡើង...

លោកវណ្ណៈស្រស់ស្រូបអាហារហើយ ក៏រៀបចំខ្លួនឡើងឡាន ចេញទៅធ្វើការ ស្រាប់តែយុវជនម្នាក់ស្ទុះមកដល់ភ្លែត ឈរវាំង ផ្លូវរថយន្តនៅមាត់ទ្វាររបងផ្ទះ ៖

- វណ្ណឌី ?

លោកវណ្ណៈឧទានឡើងដោយក្តីត្រេកអរ ។

- សុខសប្បាយទេកូន ?

ថៃដន្យ វ៉ាន់ឌីមិនឆ្លើយទេ ។ គេបែរជាធ្វើមុខក្រញូវទំនងខឹង ខកចិត្តរឿងអីមិនដឹង ។ នៅដៃ គេមានកាន់កាសែតសារពត៌មាន មួយសំណុំមកផង ។ នរៈឈរសម្លក់ឪពុកគេមួយស្របក់ ទើបចាប់ សំណុំកាសែតនោះគប់ផាំង ទៅលើក្បាលរថយន្ត ហើយស្រែកវ៉ាង ឡើងថា ៖

- លោកប៉ាចុះកាសែតនេះ មានន័យថាម៉េច ?

លោកវណ្ណៈឈរនៅស្ងៀម រួចហើយក៏ស៊ីញ៉េអោយពូតឿដើរ គេចចេញ ដើម្បីអោយលោកបាននិយាយជាមួយកូនប្រុសតែពីរ នាក់ ។

- កាសែតចុះពត៌មានថាម៉េចខ្លះកូន ?

- លោកប៉ាអញ្ជើញអានខ្លួនឯងទៅ ។

- ក្រែងកូនបានអានហើយហ្ន៎ស ? បើដូច្នោះ ប្រាប់ប៉ាមក ថា កាសែតគេនិយាយពីអ្វី បានជាកូនច្រឡោតខឹងដល់ម្លឹង ?

- លោកប៉ា ! ពេលនេះ លោកប៉ាស្រឡាញ់ប្រពន្ធថ្មីរហូតដល់ភ្លេច កូនរបស់លោកប៉ាអស់ហើយមែនទេ ?

- នរណាថា ? គឺកូនទេតើ ដែលកាត់កាល់ប៉ា ភ្លេចប៉ា ភ្លេចប្អូន ភ្លេចផ្ទះ ! ចំណែកប៉ា ប៉ាស្រឡាញ់ហើយបារម្ភពីកូនជានិច្ច ។

- បើលោកប៉ាស្រឡាញ់កូនមែន ហេតុអ្វីក៏លោកប៉ាចង់ហែកទ្រព្យ សម្បត្តិកេរ្តិ៍មរតករបស់ប៉ានិងម៉ាក់របស់កូន អោយទៅប្រពន្ធថ្មី កូនថ្មីរបស់ប៉ាទៅវិញ ?

លោកវណ្ណៈបែរជាញញឹមហើយឆ្លើយថា ៖

CHANBOKEO.COM

- វណ្ណឌី! បើនឹងថា កូនកំពុងនិយាយខុស កូនអាចនិយាយម្តង ទៀតបានណាកូន ។ ប៉ាចាំស្តាប់!

ភ្លាមនោះ យុវជនយើងលេបទឹកមាត់ ធ្វើរេរាបន្តិចទើបស្រដី បន្តទៅទៀតថា ៖

- គឺ... ខ្ញុំចង់នឹងថា ហេតុអ្វីលោកប៉ាចង់យកចំណែកមរតកដែល ម៉ាក់ប៉ាទុកអោយខ្ញុំ ទៅអោយប្រពន្ធនិងកូនថ្មីរបស់លោកប៉ា ?

- ហើយប៉ាមិនទាន់បានចែកឯណា ? ប៉ាគ្រាន់តែផ្សាយរកកូនដើម្បី សួរថា បើកូនប្រុសរបស់ប៉ាឈ្មោះវណ្ណឌី កាត់កាល់ក្រុមគ្រួសារ និង កាត់កាល់ខ្លួនចេញពីកេរ្តិ៍មរតករបស់ម្តាយឪពុកនោះ ប៉ានឹងសុំយក ចំណែកនោះទៅអោយទារកតូចដែលជាសាច់ឈាមរបស់ប៉ា អោយ គ្នាមានដើមទុន សំរាប់រៀនសូត្រនៅពេលគេធំឡើង ។

- ហើយចុះខ្ញុំមានដែលកាត់កាល់ខ្លួនពីក្រុមគ្រួសារខ្ញុំឯណា ?

- អូហ៍ ? បើមិនកាត់កាល់ទេ ហេតុដូចម្តេចក៏មិនមកផ្ទះ រស់នៅ ជាកូនជាចៅក្នុងគ្រួសារដូចគេឯងទូទៅអញ្ចឹង ? តើកូនបាត់ទៅ ណា ជាងមួយខែ គ្មានដំណឹង ?

- ខ្ញុំចង់ទៅណាស្រេចតែខ្ញុំ កាលបើផ្ទះនេះ គេលែងស្វាគមន៍រូបខ្ញុំ ទៅហើយនោះ!

(វណ្ណឌីស្រដីទាំងទឹកភ្នែករលីងរលោង)

- តើនរណាទៅមិនស្វាគមន៍រូបកូន ? គឺរូបកូនទេតើហ៍ ដែលធ្វើ ខ្លួនអោយគេឯងខ្លាចរអារ មិនហ៊ានចូលជិតស្វាគមន៍រូបកូននោះ! មើលចុះ! ពេលនេះ កូនប្រុសប៉ាបានក្លាយជាក្មេងដែលមានកំហឹង និងមានសំដី ឫកពាច្រឡោងខាមមើលមិនយល់ ។

- ព្រោះខ្ញុំជាកូនដែលគ្មានម៉ែឪសំរាប់ប្រដៅទៅហើយ ចង់ខ្ញុំធ្វើ យ៉ាងណាក៏ស្រេចតែចិត្តខ្ញុំ...

(យុវជនស្រដីទ្រគោះអោយឪពុក)

- នរណាថាកូនគ្មានម៉ែឪប្រដៅ ? ពិតមែនតែកូនគ្មានម្តាយ តែកូន ក៏នៅសល់ឪពុកគ្រាន់នឹងប្រដៅដែរ... ប៉ុន្តែ... គឺកូនទេតើដែលរត់ គេចពីការប្រៀនប្រដៅរបស់ឪពុក ។ តើកូនមានដែលគិតទេ ថា កូនភ្លេចមិនបានចូលយកខ្លួនមកអោយប៉ាប្រដៅ តាំងពីថ្ងៃដែលកូន ត្រឡប់មកពីជប៉ុនវិញ ?

វណ្ណឌីលេបទឹកមាត់ក្អឹកៗ រួចឆ្លើយវិញថា ៖

- ព្រោះមកពីខ្ញុំឃើញប៉ាមានពេលជាប់រវល់ថ្នាក់ថ្នមប្រពន្ធថ្មីរបស់ ប៉ា ទើបខ្ញុំមិនហ៊ានរំខាន ។

CHANBOKEO.COM

- កុំបាច់រកលេសមកឆ្លើយអោយរួចខ្លួនអី វណ្ណឌី! កូនមិនដែល ឲ្យឱកាសប៉ាឡើយ សូម្បីតែប្រាំនាទី ដើម្បីនិយាយជាមួយកូន ។ តាំងពីកូនមកដល់ផ្ទះវិញ កូនបានតាំងខ្លួនជាសត្រូវនឹងប៉ា សត្រូវ នឹងអូនចរិយាយ៉ាងពេញមុខ ថែមទាំងបញ្ចេញចង្កូមដាក់ពួកយើង តាំងពីវិនាទីដែលកូនឈានមកដល់ក្នុងផ្ទះវិញ ។

- នោះក៏ព្រោះខ្ញុំស្អប់ស្ត្រីម្នាក់នោះ...!

- ហេតុអ្វីក៏កូនត្រូវស្អប់គេផង ?

- ព្រោះគេបានដណ្តើមលោកប៉ាពីម៉ាក់ ដណ្តើមលោកប៉ាពីពួកយើង

- ត្រង់ណាទៅដែលបង្ហាញថាគេដណ្តើម ? គឺប៉ាទេតើដែលសុំគេ រៀបការ ហើយប្អូនទាំងបីរបស់កូនទេតើដែលសុំគេជាម្តាយ បន្ទាប់ មក គេក៏យល់ព្រមទទួលពាក្យរបស់យើង ។

- ខ្ញុំមិនជឿទេ ថាប្អូនរបស់ខ្ញុំគេធ្វើដូច្នោះ! ខ្ញុំគិតថា លោកប៉ា ច្បាស់ជាបង្ខិតបង្ខំអោយគេទៅសុំស្ត្រីម្នាក់នោះជាម្តាយហើយ ។

- តើកូនមានសួរប្អូនៗហើយឬនៅ ថាប៉ាបានបង្ខំពួកគេអោយ ធ្វើតាមប៉ា ?

 វណ្ណឌីឈ្ងោកមុខនៅស្ងៀម បន្តិចមកក៏ងើបមុខមកវិញ ហើយ ពោលបន្តទៅទៀតថា ៖

- ធម្មតាទេ គេក្មេងហើយស្រស់ស្អាត! គេចេះពង្រាយមន្តស្នេហ៍ អោយលោកប៉ាឈ្លក់វង្វេង...! តើនៅក្នុងលោកនេះ មានស្រីក្មេង ឯណា មកមានភក្តីភាពស្នេហាជាមួយបុរសចំណាស់ពោះម៉ាយកូន ច្រើនដូចលោកប៉ានោះ ? បើមាន... ក៏គឺដើម្បីលុយតែម្យ៉ាងប៉ុន ហ្នឹង មិនមែនដើម្បីសុភមង្គលគ្រួសារ និងភាពកក់ក្តៅក្នុងដួងចិត្ត របស់សមាជិកគ្រប់គ្នាក្នុងផ្ទះនោះទេ ។

- ផ្ទុយទៅវិញ បើគេជាមនុស្សល្អ ហើយមានភក្តីភាពចំពោះបុរស ចំណាស់ពោះម៉ាយ កូនច្រើនដូចលោកប៉ា ស្មគ្រ័រៀបការនិងប៉ា ដើម្បីភាពរមនានិងសេចក្តីសុខសម្រាប់គ្រប់ៗគ្នា រួមទាំងកូនរបស់ ប៉ាផង តើកូនស្មគ្រ័ហៅគេថា ម៉ាក់ ទេ ?

 យុវជនយើងងើបមុខឡើងសម្លឹងកែវភ្នែករបស់ឪពុក ហើយ ឆ្លើយរឹងថា ៖

- វណ្ណឌីមិនខ្លាចទេ បើសិនជាស្ត្រីនោះមានលក្ខណៈសម្បត្តិល្អពិត ប្រាកដ ដូច្នោះមែន ។

CHANBOKEO COM

- បើអញ្ចឹង កូនហ៊ានពិសោធន៍ទេ ថាគេជាមនុស្សយ៉ាងម៉េចពិត ប្រាកដឬយ៉ាងណា ?
មានន័យថា កូនអាចយកសតិប្រាជ្ញនិងការ ចេះដឹងរបស់កូន មកពិសោធន៍រូបគេដោយខ្លួនឯង
យ៉ាងម៉េចដែរ កូនឌី ?

វណ្ណឌីនៅស្ងៀម ។ លោកវណ្ណៈក៏មានប្រសាសន៍បន្តថា ៖

- ឬក៏កូនខ្លាច ?

- ខ្ញុំមិនខ្លាចទេ លោកប៉ា!

វណ្ណឌីឆ្លើយកាត់រឹង ព្រោះខ្លាចឪពុកថាខ្លួនខ្វះក្តីក្លាហាន ។

- បើដូច្នេះ កូនត្រូវត្រឡប់មកផ្ទះវិញ ដើម្បីបង្ហាញភាពក្លាហាន របស់កូន ។ ម្យ៉ាងទៀត
បើកូនរិតតែភ័យខ្លាចថា គេជាមនុស្សមាន ចិត្តសមាន្យប៉ុនណា កូនត្រូវតែមកផ្ទះវិញការពារប្អូន
អោយបាន សុខប៉ុននោះដែរ ក្រែងលោគេលួចធ្វើបាបប្អូន នៅពីក្រោយខ្នង ប៉ា ។
ជាកូនប្រុសហើយជាកូនច្បង កូនត្រូវតែនៅការពារប្អូន ជាពិសេសពេលប៉ាមិននៅ មែនទេកូន ?

វណ្ណឌីមិនទាន់ឆ្លើយទៅឪពុកវិញផង ស្រាប់តែ ៖

- យើ! អាឌី! មានម៉ែឪអ្នកមានយ៉ាងនេះ ហេតុម៉េចក៏ជំពាក់ លុយអញអត់សង
បែរជាលួចគេចខ្លួនអោយព្រងើយទៅវិញ ?

ភ្លាមនោះ ម៉ូតូមួយបានបោះពួយរឹងមកប្រឆាបវណ្ណឌីអោយ
ដួលបោកក្បាលទៅដីបះជើងច្រងាងទៅដី ។ លោកវណ្ណៈភ្ញាក់ព្រើត
ស្ទុះទៅចាប់កូនប្រុសលើកឡើង ស្រាប់តែក្មេងស្ទាវបរម៉ូតូត្រឡប់ វិលមកដល់ជិត
ស្ទុះធាក់លោកពីក្រោយខ្នងផាំង ធ្វើអោយលោក ច្រឡោតដួលផ្កាប់មុខទៅដីរឹងភីង ។
ក្មេងម្នាក់ទៀតបាក់ចុះពីម៉ូតូ យ៉ាងរហ័ស រត់ទៅលូកដៃស្រវាហែកហោប៉ៅខោខាងក្រោយរបស់
លោកវណ្ណៈ យកកាបូបលុយចេញមក ។ ភ្លាមនោះ ស្រាប់តែមាន ទំពក់ឬស្សីមួយហោះរឹង
ត្រូវចំក្បាលនាយម្នាក់នោះម៉ោកៗ ផាំងៗ ដួលភីងបះជើងច្រងាង
រួចហើយទំពក់ឬស្សីនោះក៏ហោះកាត់មុខ ក្មេងដែលបរម៉ូតូនោះចំកណ្តាលមុខខ្វាប់! ផស!
នាយម្នាក់នោះក៏ បែកអំពិលអំពែកមើលផ្លូវលែងឃើញ ជ្រុលចង្កូតម៉ូតូទៅបុកគល់
ដើមក្រោកមួយនៅមុខផ្ទះ ប្រកាច់ម៉ឺងធ្លាក់អុកគូទ ធ្វើមាត់ស្មេញ ដូចសត្វស្វាធ្លាក់ពីចុងឈើ
រួចហើយក៏ដួលត្មោលបះជើងទៅដី បាត់មាត់ឈឹង កំរើកលែងរួច ។

លោកវណ្ណៈបែរក្រោយ ឃើញចរិយាលើកទំពក់ឬស្សី ចង្អុល មុខក្មេងស្ទាវទាំងពីរ
ហើយស្រដីថា ៖

CHANBOKEO.COM

- អស់លោកអញ្ជើញមកពីណាដែរ បានជាមកស្វាគមន៍ពួកយើង បានល្អយ៉ាងនេះ ? ជាម្ចាស់ផ្ទះ យើងសូមជូនការស្វាគមន៍ដ៏កក់ក្តៅ សងវិញអោយសមរម្យបំផុត មិនអោយខកចិត្តភ្ញៀវទេ ។

ភ្លាមនោះ ពូតឿនិងអ្នកជិតខាងប្អូនដប់នាក់ក៏មកដល់ព្រមៗគ្នា ព្រោះគេបានឮសូរសម្លេងម៉ូតូបុកដើមឈើដួលប្រាវៗអំបាញ់មិញ ។ មួយស្របក់ក្រោយមក ក្រុមប៉ូលីសក៏មកដល់ដាក់ខ្នោះដៃក្មេងស្ទាវ ទាំងពីរចេញទៅ ។

នៅក្នុងគេហដ្ឋានរបស់លោកវណ្ណៈ...

វណ្ណឌីអង្គុយត្រដុសដៃ ឈ្ងោកមុខនៅក្នុងសាឡុង មិននិយាយ ស្តីអ្វីទេ ព្រោះនឹងថា ខ្លួនកំពុងជាប់សគុណម្តាយចុងមួយហើយ ។ នៅជ្រុងម្ខាងទៀត ក្នុងបន្ទប់គ្រួសារ ចរិយាកំពុងយកអាល់កុល លាងស្នាមរបួសលើមុខ កែងដៃ និងក្បាលជង្គង់ទាំងសងខាងរបស់ លោកវណ្ណៈ ។

- អរគុណណាស់ យ៉ា ដែលមកជួយបងនិងកូនឌីទាន់ពេលវេលា ។

ចរិយាញញឹមដាក់លោកវណ្ណៈ តែមិននិយាយអ្វីទេ គិតតែពី ជូតសំអាតរបួសជូនលោកបន្តទៅទៀត ។ លោកវណ្ណៈក៏មានវាចា បន្តទៀតថា ៖

- បងមិនដឹងសោះថា ប្រពន្ធបងចេះក្បាច់គុនគុងហ្វូដែរ ?

ចរិយាសើចខឹកៗ តបយ៉ាងកំប្លែងថា ៖

- ខុសហើយបង! ហ្នឹងមិនមែនជាក្បាច់គុនគុងហ្វូទេ តែគឺជាក្បាច់ ដងអំបោសបោះរបស់ខ្មែរយើងទេតើហ៍ ។

លុះបិទរបួសជូនលោកវណ្ណៈហើយ ចរិយាក៏ដើរទៅជិតវណ្ណឌី សួរថា ៖

- ប្អូនប្រហែលមានរបួសដែរហើយ! ចង់អោយបងលាងរបួស អោយទេ ដើម្បីកុំអោយដរដំបៅ ?

វណ្ណឌីងើបមុខឡើង សម្លឹងមុខចរិយា ប៉ុន្តែមិនហ៊ានឆ្លើយថា ម៉េចទេ ។ មាណវីក្រឡេកឃើញស្នាមឈាមប្រឡាក់កអាវវណ្ណឌី ក៏លាន់មាត់ឡើងថា ៖

- ស្លាប់ហើយ... ប្អូនបែកក្បាលទេតើហ៍! ម៉េចក៏នៅស្ងៀមមិន មាត់អញ្ចឹង ?

នាងងាកក្រោយហៅពូតឿ ៖

- ពូ...! នាំក្មួយទៅមន្ទីរពេទ្យបានទេ ? អោយគេពិនិត្យដេរស្នាម របួសលើក្បាលខាងក្រោយផង ។

ពូតឿក៏រត់មកដល់ ៖

CHANBOKEO.COM

- តោះ អ្នកប្រុស! អញ្ជើញ!

វណ្ណឌីដើបឡើងដើរសំដៅរត់យន្តដោយមិនមានស្តីវ៉ាចាអ្វីទាំង អស់ មិនដឹងថាក្នុងចិត្តរបស់គេគិតយ៉ាងណាទេ ។

ពីរម៉ោងក្រោយមក...

ចរិយាកំពុងអង្គុយបំបៅកូន ក្បែរលោកវណ្ណៈដែលកំពុងអាន កាសែត ស្រាប់តែឮសូរសម្លេងរថយន្តចូលមកដល់វិញ ។ មាណវី ងាកបែរមើល ឃើញវណ្ណឌីដើរចុះមក ដោយមានរុំរបួសនៅក្បាល និងកែងដៃស្តាំ ហើយមានកិរិយាទំនងស្វាហាប់ជាងមុន ។ ពេលនោះ នាងក៏ឃើញគេអូសវ៉ាលីសមួយចូលមកផ្ទះ ដើរឡើងទៅ ខាងលើឡៅផុតទៅដោយមិនមាត់មិនក ។ លោកវណ្ណៈសរសៀរ មកជិតប្រពន្ធ ហើយខ្សិបដាក់នាងថា ៖

- ផែនការរបស់អូនពិតជាមានប្រសិទ្ធភាពមែន អាចធ្វើអោយកូន ត្រឡប់មកផ្ទះបាន ។

- ចាស! ប៉ុន្តែ បងត្រូវបន្តកិច្ចការរបស់បងតទៅទៀត ដើម្បី ទប់កូនកុំអោយគេត្រឡប់ទៅវិញ ក្រែងលោត្រូវក្មេងដទៃតាមមក រកសងសឹក ដូចព្រឹកនេះទៀត ។

- បងដឹងហើយ!

ថ្ងៃនោះ វណ្ណឌីមិនចុះមកបរិភោគបាយទេ ។ គេសំងំនៅក្នុង បន្ទប់រហូត សូម្បីតែប្អូន ឬក៏លោកវណ្ណៈឡើងទៅគោះទ្វារហៅ យ៉ាងណាក៏ដោយ ។ លុះយប់អាធ្រាតស្ងាត់ ពេលគេចូលដំណេក អស់ ទើបវណ្ណឌីលួចដើបដើរលបៗចុះមកចង្ក្រានបាយ ។ កំពុងតែឈ្ងោកមើលក្នុងទូទឹកកក រកនេះ រកនោះ ស្រាប់តែ ៖

- បងបានចាប់ម្ហូបអោយប្អូន ទុកនៅលើតុអាហារឯណោះ ។ ចង់ ញ៉ាំទេ? ចាំបងកំដៅអោយ ។

វណ្ណឌីងាកក្រោយឃើញចរិយា ក៏ដើបឈរឡើង ងក់ក្បាល ៖

- បាទ!

មើលទៅគេ ដូចជាបន្ទន់ឥរិយាបថជាងមុនបន្តិច ចំពោះចរិយា ព្រោះគេជំពាក់ពាក្យថា សុំទោស អំពីរឿងគ្រោះថ្នាក់ដួលដំថ្ងៃមុន និងពាក្យថា អរគុណ ចំពោះនារីយើងដែលបានជួយធ្វើអន្តរាគមន៍ កាលពីព្រឹកមិញ ។

បន្ទាប់ពីកំដៅអាហារអោយយុវជនយើងហើយ ចរិយាក៏ដើរ ត្រឡប់ចេញពីផ្ទះបាយទៅវិញ ស្រាប់តែ ៖

- បងស្រី!

CHANBOKEO.COM

ចរិយាភ្ញាក់ព្រើត ដែលយុវជនយើងហៅនាង ។ នាងបែរ ក្រោយហើយឆ្លើយថា ៖

- ចា៎ស ? មានការអ្វីដែរ ប្អូន ?
- អរគុណណាស់ ដែលបានជួយខ្ញុំនិងលោកប៉ា កាលពីព្រឹកមិញ!
- អូហ៎ មិនអីទេ!
- ហើយខ្ញុំក៏សុំទោសបងដែរ ដែលធ្វើអោយបងដួលដំ បណ្តាលឲ្យ មានគ្រោះថ្នាក់ដល់កូនខ្ចី ។
- ប្អូន កុំបារម្ភអី ! គេជាសះស្បើយវិញហើយ មិនមានបញ្ហាខាង សុខភាពទេ ។ ថ្ងៃណាទំនេរ មកមើលប្អូនផងណា៎! គេចង់ស្គាល់ បងប្រុសគេណាស់ នឹងទេ ?

បើសិនជាបានបងប្រុសបីថ្នាក់ថ្នមខ្លះ ប្រហែលជាគេកក់ក្តៅក្នុងអារម្មណ៍របស់គេមិនខានឡើយ ។

វណ្ណឌីញញួញ្ញូច្នោះ ក៏រលីងរលោងទឹកភ្នែកតែម្តង ៖

- មែនហើយ! ខ្ញុំភ្លេចគិតអោយឈឹង ថាគេក៏ជាប្អូនរបស់ខ្ញុំដែរ!
- បើប្អូនគិតឃើញហើយ សូមកុំអោយវេលាកន្លងហួសទៅដោយ មិនបានបង្ហាញការស្រឡាញ់របស់បង ចំពោះប្អូនណា៎! ប្អូនតូចពិត ជាមានអារម្មណ៍កក់ក្តៅ បើសិនបានបងៗស្រឡាញ់ថ្នាក់ថ្នម ។

វណ្ណឌីសម្លឹងមុខធិតាមួយស្របក់ ក៏វាចាសួរថា ៖

- ហេតុអ្វីបងស្រីមិនដែលខឹង មិនអន់ចិត្ត តបនឹងខ្ញុំវិញដូច្នោះ ?
- នរណាថាបងមិនខឹង មិនអន់ចិត្ត ?

វណ្ណឌីភ្ញាក់ព្រើតដែលចរិយាឆ្លើយដូច្នោះ ។ គេក៏ជ្រួញចិញ្ចើម ឡើង ។ ឃើញកិរិយារបស់វណ្ណឌី មាណវីក៏ពោលបន្តមួយៗ ដោយ សំដីទន់ភ្លន់ចំពោះនរៈ ថា ៖

- ការពិត បងខឹងហើយអន់ចិត្តណាស់ ដែលសុខៗ បងទទួលការ ប្រមាថពីយុវជនម្នាក់ដែលបងមិនធ្លាប់ស្គាល់ ។ គ្រាន់តែដឹងថា គេ មានឋានៈជាកូនដើមភ្លាម ស្រាប់តែគេមានសិទ្ធមកជេរជៀមដាម ប្រមាថកាតទានបងភ្លាម មិនតែប៉ុណ្ណោះ ប្រព្រឹត្តហឹង្សាមកលើបង បណ្តាលអោយគ្រោះថ្នាក់ដល់ទារកតូច ដែលជាប្អូនបង្កើតរបស់គេ ទៀតផង ។ ប៉ុន្តែ បងបានរំសាយចិត្តខឹងនោះចោលអស់ទៅវិញ ហើយ ព្រោះយល់ថា គេភ្លេច...មិនបានប្រើសតិប្រាជ្ញរបស់គេមក ពិនិត្យគុណសម្បត្តិរបស់បងអោយឃើញពិតប្រាកដ ដោយភ្នែកខ្លួន ឯង... នោះគឺមានន័យថាគេនៅល្ងង់ឆោត ជឿតាមបំណាក់ផ្តត់របស់ សង្គម ដែលទម្លាប់នាំគ្នាជាទូទៅប្រមាថម្តាយចុងថា ជាស្រីលោភ លន់ទ្រព្យសម្បត្តិ ឬក៏ជាស្រីដែលមានចិត្តឆន្ទាចំពោះកូនដើម ។ ពេលនោះ

CHANBOKEO.COM

បងក៏ទុកឱកាសអោយគេរៀនទទួលស្គាល់ការពិតវិញថា
មិនមែនម្តាយចុងទាំងអស់សុទ្ធតែជាកាឡីឆន្នា រៀបការសេដ្ឋីក្តុម្ពី ដើម្បីទ្រព្យសម្បត្តិនោះឡើយ
ហើយកូនដើមទាំងអស់ ក៏មិនមែន សុទ្ធតែល្អបរិសុទ្ធគ្រប់យ៉ាងនោះដែរ ។
នៅក្នុងសង្គមខ្មែរយើង មានខ្វះទេម្តាយចុងដែលមានលក្ខណ:សម្បត្តិល្អប្រពៃ ជាម្តាយគួរ
អោយគោរព ប៉ុន្តែយើងទម្លាប់ធ្មេចភ្នែក មិនព្រមនាំគ្នាធ្វើការកត់ សំគាល់អំពើល្អ
ឬគុណសម្បត្តិល្អរបស់ម្តាយចុងទាំងនោះឡើយ ។
សង្គមយើងមានទម្លាប់ដកស្រង់នូវអ្វីៗខាងផ្នែកអាក្រក់ យកមក អង្គុយវិភាគពិចារណា
រួចហើយក៏នាំគ្នាសើចយំតែប៉ុណ្ណោះ មិនសូវ នាំគ្នាជួយរកមធ្យោស្រាយដោះស្រាយស្ថានការណ៍
អោយធូរស្រាល ដើម្បីអោយមនុស្សក្លាយជាញាតិនឹងគ្នាឡើងវិញសោះ ។ យើងមាន
តែជួយពន្យុះគ្នាបន្ថែមឲ្យជួយខឹង ជួយសងសឹកគ្នាទៅវិញទៅមក ពោលគឺជួយរកឱបាយបំផ្លាញ
ឬសម្លាប់ភាគីណាដែលគេគិតថាជា ឆន្នា ។ ថៃដន្យ សម័យឥឡូវនេះជាសម័យអភិវឌ្ឍន៍ ។
មនុស្ស បានរៀនសូត្រទទួលការចេះដឹង ជ្រៅជ្រះជាងពីបុរាណ ។ ដូច្នេះ
ល្មមដល់ពេលហើយទេដឹង ដែលយើងទាំងអស់គ្នាត្រូវរៀនកត់ សំគាល់អំពើល្អ
និងលក្ខណ:សម្បត្តិល្អរបស់មនុស្ស មិនថាគេជា ម្តាយចុង កូនចុង ឬកូនដើមអ្វីនោះទេ ។
ម្យ៉ាងទៀត យើង ទាំងអស់គ្នាគួររៀនត្រិះរិះរកមធ្យោបាយ ដោះស្រាយភាពវឱស្ថាន
ក្នុងគ្រួសារអោយបានធូរស្រាលមកវិញ ពោលគឺណែនាំអោយ
មនុស្សចេះសម្របសម្រួលចុះសម្រុងនឹងគ្នា ចេះស្តាប់គ្នា ចេះត្រិះ រិះហេតុផល
មិនមែនជួយពន្យុះអោយមនុស្សរិតតែគុំគួនសងសឹក គ្នា ថែមទៀតទេ ។ ប្អូនវណ្ណឌី គិតទៅមើល
បងនិយាយនេះ សមហេតុផលទេ ?

វណ្ណឌីអង្គុយនៅស្ងៀម ចាំស្តាប់មាណវីនិយាយរហូតដល់ចប់ ចុងចប់ដើម ។ មែនហើយ
ប្រយោគទាំងឡាយរបស់ចរិយាបានធ្វើ អោយគេមានអារម្មណ៍ប្លែកណាស់ ព្រោះគេមិនគិតស្មានថា
នារីមាន គំនិតវែងឆ្ងាយ អាចវិភាគជីវិតគ្រួសារអោយរូបនាយបានស្តាប់
យ៉ាងពិរោះមានអត្ថរសដល់ម្លឹងសោះ ។ បន្តិចមក គេក៏ស្រដីថា ៖

- អោយខ្ញុំសូមទោសផងដែលខ្ញុំបានប្រព្រឹត្តកិរិយានិងសំដីមិនគប្បី ចំពោះបងស្រី គិតទុទដ្ឋិ
អវិជ្ជមាន ក្តីវង្វេងនិងភាពអាត្មានិយម
មិនបានគិតដល់ចិត្តដល់អារម្មណ៍អ្នកដែលរស់នៅក្នុងគ្រួសារ មិន
បានអនុញ្ញាតខ្លួនឯងឲ្យរៀនស្គាល់បងស្រី មុននឹងសន្មតថាបងជា មនុស្សលក្ខណ:ឆន្នា ។ គិតទៅ

CHIANBOKEO.COM

ខ្ញុំនឹករអាមាសក្នុងចិត្តណាស់ ដែល ខ្ញុំបានបំផ្លាញពេលវេលានៅក្រៅផ្ទះអស់ជាងមួយខែ ឃ្លាតចាកនូវ ភាពកក់ក្តៅក្នុងគ្រួសារ ព្រោះតែចរិតឆេវឆាវនិងការគិតអគតិ របស់ខ្ញុំចំពោះបងស្រី ។ គួរអោយស្តាយពេលវេលានោះណាស់! មិនតែប៉ុណ្ណោះ ជាងមួយខែដែលខ្ញុំនៅក្រៅផ្ទះ ខ្ញុំក៏បានទទួលការ ពិសោធន៍ជាច្រើនដែលបានធ្វើអោយខ្ញុំដឹងថា គ្មានទីណាកក់ក្តៅជា ជាងផ្ទះរបស់យើងទេ ។

- មិនមានអ្វីដែលគួរអោយស្តាយទេ! ការពិតទៅ ជាងមួយខែ ដែលប្អូននៅក្រៅផ្ទះ បាននាំមេរៀនជីវិតយ៉ាងល្អដល់ប្អូន អោយ ប្អូនបានបែរមករកភាពកក់ក្តៅក្នុងគ្រួសារវិញ ហើយទទួលភាព រមនាក្នុងចិត្តចាប់តាំងពីថ្ងៃនេះតទៅរហូតយូរអង្វែង ។ ធម្មតាទេ! នរណាក៏ធ្លាប់មានកំហុសដែរ ប៉ុន្តែដែលល្អបំផុតនោះ គឺពេលដែល យើងដឹងថា ខ្លួនយើងមានកំហុស យើងកែភ្លាម មិនឌឺ មិនជជេស មានះទៅខាងផ្លូវវិបរិតតទៅទៀត ។ ពេលនេះ យើងគឺជាវីរបុរស ព្រោះយើងអាចរកឃើញភាពត្រឹមត្រូវសុក្រិតក្នុងជីវិតឃើញដោយ ខ្លួនឯង ។

- បងស្រី... បងជាមនុស្សល្អណាស់!

- អរគុណ! ប្អូនវិញក៏ជាមនុស្សល្អដែរ ។

- មិនល្អអ្វីប៉ុន្មានទេ បងស្រី ព្រោះអីខ្ញុំបានប្រព្រឹត្តកំហុសជាច្រើន

- ប៉ុន្តែភាពល្អរបស់ប្អូនបាននាំប្អូនមកស្គាល់ផ្លូវត្រូវវិញ ហើយក៏ ទទួលយកផ្លូវនោះដើរទៅមុខទៀត នៅក្នុងជីវិត ។

វណ្ណឌីនៅស្ងៀមមួយស្របក់ ទើបស្រដីថា ៖

- ខ្ញុំគិតថា ពេលនេះ ខ្ញុំស្គាល់បងកាន់តែច្បាស់ហើយ ។

- នៅសល់ពេលយូរតទៅទៀត ដែលប្អូនត្រូវរៀនស្គាល់បង! ពេលនេះ យប់ហើយ! បងសុំខ្លួនទៅសំរាកហើយណ៎! 

- បាទ បង!

ចរិយាញញឹមដាក់វណ្ណឌី ហើយក៏ដើរឡើងទៅលើឡៅបាត់ទៅ ទុកអោយវណ្ណឌីនៅអង្គុយពិចារណាតែម្នាក់ឯង ។ បន្តិចមក នរៈ ក៏ដើរឡើងតាមក្រោយរកចូលដំណេកដែរ ។ លុះចូលមកដល់បន្ទប់ ស្រាប់តែគេប្រទះឃើញបណ្ណ័ជូនពរមួយនៅលើពូក ។ គេឆក់យ៉ាង លឿនយកមកអាន ៖

CHANBOKEO.COM

- បងឌី! ប្អូនៗនឹកបងណាស់! មកផ្ទះយើងវិញណាំបង! ការ រស់នៅខាងក្រៅផ្ទះ មិនកក់ក្តៅរមនាដូចនៅក្នុងគ្រួសាររបស់យើង ទេ ។ សព្វថ្ងៃ ប្អូនៗបានទទួលសេចក្តីសុខណាស់ ហើយក៏ចង់ចែក រំលែកសេចក្តីសុខនេះជាមួយបងដែរ ។ មិនដឹងថាបងរងាក្នុងចិត្ត យ៉ាងណា ពេលបងរស់នៅឆ្ងាយពីលោកប៉ានិងពួកយើង ។ ការ ពិត ម៉ាក់យ៉ាជាមនុស្សល្អណាស់ ។ ប្អូនៗស្រឡាញ់គាត់គ្រប់គ្នា ។ ថ្វីបើគាត់មិនអាចជំនួសម៉ាក់របស់យើងបានមែន ប៉ុន្តែពេលលោកប៉ាយើងមិននៅ គាត់អាចជួយផ្តល់ភាពកក់ក្តៅខ្លះៗបានដល់ពួក យើង មិនអោយយើងនៅកំព្រារងាតែម្នាក់ឯងក្នុងពិភពលោកទេ ។ គាត់បានថែរក្សាពួកយើងដោយយកសីលធម៌ជាគោល ។ ពួកយើង គិតថា ម៉ាក់យ៉ាជាម្តាយចុងគំរូដ៏ល្អមួយរូបគួរកត់សំគាល់ ។ បងឌី គួរតែរកពេលស្វែងយល់អំពីលក្ខណៈសម្បត្តិពិតប្រាកដ របស់ម៉ាក់ យ៉ាហើយ ដើម្បីអោយបងរំលត់ក្តីសង្ស័យ និងការស្អប់ខ្ពើមម៉ាក់ យ៉ានៅក្នុងចិត្តបង ហើយទទួលយកភាពសុខរមនារបស់គ្រួសារ យើងជំនួសវិញ ។ ពីប្អូននី ប្អូននេត្រ និង ប្អូនវណ្ណា!

វណ្ណឌីអានផង ស្រក់ទឹកភ្នែករលីងរលោងផង ៖

- អូននី! នេត្រ! អូនតូច! បងក៏នឹកប្អូនទាំងបីដូចគ្នា... ហើយក៏ស្រឡាញ់ប្អូនណាស់ទៀតផង ។ ពេលនេះ បងវិលមកវិញហើយ ណាំអូន មករកគ្រួសារយើង មករកភាពកក់ក្តៅដែលប្អូនៗប្រាប់ថា ប្អូននឹងចែករំលែកមកឲ្យបង ។ ទទួលបងផងណាំ ប្អូនសម្លាញ់!

នៅក្នុងបន្ទប់របស់លោកវណ្ណៈនិងភរិយា...

- ល្បិចល្បួងកូនឌីអោយត្រឡប់មកផ្ទះ ពិតជាមានប្រសិទ្ធភាព ណាស់ យ៉ា! អរគុណណាស់ប្រពន្ធសម្លាញ់ ដែលធ្វើអ្វីៗដើម្បីបង (លោកវណ្ណមានប្រសាសន៍)

- ខុសហើយបង! គឺអូនធ្វើដើម្បីក្រុមគ្រួសារយើងទាំងមូលតើហ៏! ការវិលត្រឡប់របស់វណ្ណឌី នឹងធ្វើអោយគ្រប់គ្នាសប្បាយចិត្ត រួម ទាំងវណ្ណឌីផង ។

លោកវណ្ណៈញញឹមពព្រាយ ៖

- បងមិននឹកស្មានថា បងរៀបការប៉ះចំអ្នកគ្រូពូកែខាងចិត្តសាស្ត្រ អញ្ចឹងសោះ ។

- បងណាក់ កុំបញ្ជោរអូនពេកមើល៍!

CHANBOKEO.COM

- មែនណា៎! បងនិយាយពិតមែនណា៎! អូហ៍ មែនហើយ! តើអូន
ជឿថាវណ្ណឌីគេនឹងផ្លាស់ផ្តូរចរិតគេទេ ?
- ចា៎ស! គឺគេច្បាស់ជាផ្លាស់ប្តូរបានជោគជ័យជាទីបំផុត ។
- អូនមានជំនឿដល់ម្លឹងផងហ្ន៎ស ?
- ចា៎សបង!
- អញ្ចឹង បងសូមច្បាប់គេងលក់ យល់សប្តិល្អ មួយយប់ទល់ភ្លឺ ម្តង បានទេ ?
- ចា៎ស! សូមបងសំរានលក់ យល់សប្តិល្អរាល់យប់រហូតទៅ!

លោកវណ្ណៈក៏ឈ្ងោកអោនថើបភរិយា ហើយស្រវាត្រកងកាយ ឆវីមកផ្តិតជាប់ឱរាលោកយ៉ាងណែន ដោយក្តីស្រឡាញ់និងការរំភើប ចិត្តចំពោះសន្តានចិត្តដ៏ទូលំទូលាយរបស់ភរិយា ។

ព្រឹកស្អែកឡើង...

វណ្ណឌីចុះជណ្តើរមកដល់ខាងក្រោម ស្រាប់តែ...
- សូមស្វាគមន៍ចំពោះការវិលត្រឡប់របស់បងឌីជាទីស្រឡាញ់!

វណ្ណឌីភ្ញាក់ក្រញាង បែរមើលឃើញប្អូនទាំងបីនាក់កំពុងឈរ កាន់បាច់ផ្កា ។
- អូននី! អូននេត្រ! អូនតូច!

គេក៏ទទួលបាច់ផ្កាពីប្អូន ។ រំពេចនោះ ស្រាប់តែនរៈដាក់ភ្នែកទៅចំចរិយាដែលកំពុងបីទារកតូចនៅក្នុងដៃ ឈរពីក្រោយក្មេងៗ ក្បែរលោកវណ្ណៈ ក៏ស្រដីថា ៖
- ការពិត បាច់ផ្កានេះ គួរតែជាបាច់ផ្កាស្វាគមន៍សមាជិកថ្មីក្នុង គ្រួសាររបស់យើងវិញទើបសម ។

ថាហើយ គេក៏ដើរទៅជិត ហើយក៏ហុចបាច់ផ្កាទៅចរិយា ៖
- ខ្ញុំសូមស្វាគមន៍សមាជិកថ្មីទាំងពីរនៅក្នុងផ្ទះរបស់យើង!

ចរិយាក៏ញញឹមឡើង លើកដៃទទួលយកបាច់ផ្កាពីវណ្ណឌី ។
- អោយខ្ញុំសុំបីប្អូនបន្តិចបានទេ ? (វណ្ណឌីសួរ)
- ដោយរីករាយ ណា៎ វណ្ណឌី!

លោកវណ្ណៈលួចសម្លឹងមើលតាមវណ្ណឌី ដែលទទួលយកទារក តូចពីដៃចរិយា ធ្វើទឹកមុខទំនងមិនចង់ជឿថា វណ្ណឌីផ្លាស់ប្តូរលឿន ដល់ម្លឹង ។ រំពេចនោះ ស្រាប់តែមានក្មេងប្រុសៗមកជិះម៉ូតូប្រឆាប

CHANBOKEO.COM

មុខផ្ទះហើយស្រែកឡូឡាដូចកាលពីម្សិលមិញទៀតហើយ ។ វណ្ណឌី ធ្វើទឹកមុខស្លេក កាលបើឃើញហ្វូងក្មេងស្ទាវមករំខានរូបនាយដល់ ផ្ទះ ។ ប៉ុន្តែ យុវជនយើងមិនទាន់និយាយអ្វីផង លោកវណ្ណៈក៏ទាញ ទូរសព្ទលើកឡើង ៖

- សុំកងកម្លាំងរក្សាសន្តិសុខបន្តិចបាទ... ព្រោះមានក្មេងមកបង្ក ចលាចល...

វណ្ណឌីហុចទារកទៅអោយចរិយាវិញ ហើយស្រដីថា ៖

- សូមទោសដែលខ្ញុំនាំភាពច្របូកច្របល់មកឲ្យក្រុមគ្រួសារ! ទុក អោយខ្ញុំជាអ្នកដោះស្រាយចុះ ។

បន្តិចមក គេក៏មូរដៃអាវដើរចេញទៅយ៉ាងក្លាហាន ។ ព្រមជា មួយគ្នានោះ កងតម្រួតសន្តិសុខក៏បានមកដល់ស្ទាក់រាំងពួកក្មេងៗបី បួននាក់ ដែលជិះម៉ូតូស្រែកឡូឡាក្រៅរបងមុខផ្ទះគេហដ្ឋានលោក វណ្ណៈ អំបាញ់មិញ ។ មានក្មេងស្ទាវម្នាក់ស្រែកថា ៖

- ពួងឯងមកស្ទាក់ចាប់ពួកយើងធ្វើអ្វី ? បើចង់ចាប់ ទៅចាប់អាមួយ ដែលកំពុងដើរចេញមកនោះ ឈ្មោះវណ្ណឌី វាជំពាក់លុយពួកយើង មិនព្រមសងទេ ។

- មែនហើយ! ពេលនេះ យើងនឹងព្រមសងឯងវិញគ្រប់ទាំងអស់ តែឯងត្រូវសារភាពផង ថាឯងជាក្រុមដើរចែកថ្នាំញៀន ឲ្យយើង ជាអ្នកដើរលក់អោយឯង (វណ្ណឌីឆ្លើយពីចម្ងាយមក)

- នែ៎កុំមួយបង្កាច់យើងទាំងរស់ទើុយ អាឌី!

- បើចិត្តសឿងមែន ឯងហ៊ានអោយគេជោះឈាមមើលទេ ថាជាតិ ថ្នាំញៀនដែលស្តុកនៅក្នុងឈាមឯងមានខ្ពស់ដល់កំរិតណាហើយ ?

- យើងមិនជោះទេវើុយ សុខៗអោយគេយកម្ជុលរុកសាច់ស្អី ? អញមិនចូលចិត្តទេ!

ថាហើយពួកនោះ ក៏នាំគ្នាជិះម៉ូតូវ៉ាវ វិះកិននាយតម្រួតម្នាក់ ដែលនៅឈរទ្វាងផ្លូវ ។

- យី! ក្មេងអស់នេះ! ចំមែន! (នាយតម្រួតលាន់មាត់)

ឃើញពួកនោះរត់គេច ពួកតម្រួតសន្តិសុខក៏ថយទៅវិញទៅ ទុកអោយវណ្ណឌីឈរធ្វើមុខស្ញើកតែម្នាក់ឯង ទំនងស្តាយក្រោយ ដែលគេបាននាំភាពអ៊ូអរចម្លែកៗមកផ្ទះរបស់ខ្លួនដែលធ្លាប់តែស្ងប់ ស្ងាត់មនោរម្យមានសន្តិសុខ ។ បន្តិចមក គេក៏ដើរចូលផ្ទះវិញ ជួប ប្អូនៗឈររហង់នៅមាត់ទ្វារសម្តែងទឹកមុខព្រួយបារម្ភ ។

- អោយបងសូមទោសប្អូនទាំងអស់គ្នាផងដែលនាំរឿងនាំហេតុចូល ផ្ទះ អោយប្អូនភិតភ័យ ។

CHANBOKEO.COM

រួចហើយគេក៏ឈ្ងោកទ្រោបមុខនឹងសន្លឹកទ្វារ ទំនងទទួលរង នូវវិប្បដិសារី ។ រំពេចនោះ ស្រាប់តែមានដៃមួយមកអង្អែលក្បាល របស់នាយ ព្រមជាមួយសំដីល្ហងលោមថា ៖

- ឈប់គិតច្រើនទៅកូន! ហោចណាស់ កូនបានមកដល់ផ្ទះមាន ចាស់ទុំការពារ មានបងប្អូនកក់ក្ដៅ មិនសង្វេគកណ្ដោចកណ្ដែង ពេកទេ ។ បើសិនមានការអ្វី ពួកយើងនឹងចេញមុខជួយការពារគ្នា ប្រសើរជាជាងកូននៅក្រៅផ្ទះ ហើយត្រូវប្រឈមនិងពួកជើងកាង តែម្នាក់ឯងដែរ ។

វណ្ណឌីងើបមុខឡើងឃើញឪពុកញញឹមដាក់ ក៏បែរក្រោយឱប ឪពុកយ៉ាងណែន ៖

- លោកប៉ា! អភ័យទោសអោយកូនផង!

លោកវណ្ណៈបបោសខ្នងកូន ៖

- ប៉ាអភ័យទោសអោយកូនជានិច្ច ណា៎វណ្ណឌី ។

ភ្លាមនោះ ស្រាប់តែឮសូរសន្ធឹករថយន្តមួយបានមកដល់មុខ ផ្ទះទៀតហើយ ។ លុះអ្នកទាំងអស់គ្នាបែរមុខទៅ ស្រាប់តែឃើញ ឆាយានាំនារីរូបស្រស់ម្នាក់ក្នុងវ័យប្រមាណ១៨ឆ្នាំចូលមកដល់ ៖

- ជំរាបសួរបាទ! (ឆាយាលើកដៃសំពះម្ចាស់ផ្ទះទាំងពីរនាក់)

លោកវណ្ណៈនិងចរិយាលើកដៃសំពះទទួល ស្រាប់តែ ៖

- ជំរាបសួរលោកពូ! នេះខ្ញុំ ឆដា ប្អូនស្រីបងឆាយាណា៎! មើលខ្ញុំ មិនស្គាល់ទេឬពូ បានជាធ្វើភាំងអញ្ចឹង ?

- ស្លាប់ហើយ ក្មួយដា! តែងខ្លួនស្រស់ស្អាត ពូមើលមិនស្គាល់តែ ម្ដង ។ ហើយចុះក្មួយទៅណាមកណាហ្នឹង ?

- គឺមកសុំនាំប្អូនៗទៅជប់លៀងបុណ្យកំណើតរបស់បងឆាយា ។

ស្រាប់តែនារីដាក់ភ្នែកទៅចំវណ្ណឌី ក៏ធ្វើភ្នែកមូលក្លំ រួចឧទាន ទាំងភ្ញាក់ផ្អើលថា ៖

- បងវណ្ណឌី មែនទេ ?

- បាទ! មែនហើយ!

- អូយ៎ ពុទ្ធោពុទ្ធំ... ហើយយ៉ាងម៉េចយ៉ាងម៉ា បានជាបងប្រែក្រឡា រូបដូចជា... ? (ឆដាយកដៃខ្ទប់មាត់)

- ដូចស្ទីទៅ ឆដា ?

CHANBOKEO.COM

- ហៃ៎សៗ! ឃើញសក់បងវណ្ណឌីហាយខ្សែច្រើនពណ៌យ៉ាងហ្នឹង មើលម៉ាក្លែត ខ្ញុំស្មានថា សេក!
(ឆដាសើចខឹកៗ) ហើយបងជួប បញ្ហាធ្ងន់ធ្ងរនៅក្នុងជីវិតមែនទេ
បានជាតុបតែងខ្លួនអោយគេឯង ចាប់អារម្មណ៍លើបង យ៉ាងនេះ ?

វណ្ណឌីឈរឆ្មើរអេះអុញ ញញឹមលែងសមតែម្តង ។ បន្តិចមក នាងក៏បបួលជាថ្មី ៖

- បងវណ្ណឌីចង់ទៅជាមួយពួកយើងទេ ? ឆាប់ទៅផ្លាស់សម្លៀក បំពាក់មក!
- នេះ បងស្លៀកពាក់រួចហើយតើហ៍!
- អាម៉ូងនៅលើខ្លួនរបស់បងហ្នឹងហ្មែស ? ពុទ្ធោ! ឆដាមិនហ៊ាន
នាំបងដើរតាមជាមួយទេ ខ្លាចគេច្រឡំថា ជាតួយីកេវង្វេងឆាក ។

ឮនាងឆដាបង្អាប់ពេក ទ្រាំមិនបាន វណ្ណឌីក៏រត់វេវឡើងទៅ លើឡៅបាត់ ។
ចរិយាឃើញទឹកមុខយុវជនយើងដូចមិនសូវស្រួល ក៏ហុចកូចតូចទៅអោយលោកវណ្ណ: ៖

- បង! ខ្ញុំទៅមើលវណ្ណឌីម៉ាក្លែត!

ថាហើយ នាងក៏ដើរឡើងទៅតាមក្រោយ ។ មកដល់មុខបន្ទប់ របស់វណ្ណឌី
ចរិយាឃើញនាយឈរទ្រោបមុខនៅមាត់ទ្វារ ៖

- កំពុងតូចចិត្តដែលគេបង្អាប់ប្អូនមែនទេ ?

វណ្ណឌីងើបមុខឡើងឆ្លើយថា ៖

- ខ្ញុំឈឺចិត្តណាស់ បងស្រី!
- ឈឺចិត្តរឿងអី ?
- គឺរឿងដែលគេថា រូបខ្ញុំដូចសេក ដូចតួយីកេ...
- ហើយរូបប្អូនដូចនាងថាមែនហ្មែស បានជាឈឺចិត្តដល់ម្លឹង ?
- គឺ... ខ្ញុំមិនមែន...

ស្រាប់តែនាយទុចង៉ក់ មិនហ៊ានឆ្លើយ ។ ចរិយាស្រដីបន្ថែម ៖

- តើប្អូនចង់ផ្លាស់ទង្ហិរបស់ឆដាទេ ដើម្បីកុំអោយនាងប្រដូចប្អូនថា ជាសេក ឬជាតួយីកេ
តទៅទៀត ?
- បាទ!... តើខ្ញុំត្រូវធ្វើយ៉ាងម៉េចវិញ ?
- ធ្វើតួឯកដ៏សង្ហានោះអី ? អោយនារីឃើញហើយស្ទុតជង្គង់ភ្លាម! ម៉ោះ!
បងទៅជួយរកម៉ូដខោអាវអោយ ។

ចរិយាក៏នាំវណ្ណឌីទៅក្នុងបន្ទប់ រាវរកសម្លៀកបំពាក់ថ្មី ។

CHANBOKEO.COM

នៅខាងក្រោម ទាំងអស់គ្នាសំលោះសំណាលសើចកក្អឹក ស្រាប់តែឃើញចរិយាចុះមកវិញទាំងទឹកមុខញញឹម ហើយស្រដីថា ៖

- ថ្ងៃនេះ មីងសុំផ្ញើបុរសសង្ហាអោយទៅជាមួយម្នាក់ផង ឆដា!

ទាំងអស់គ្នាបែរមើល ស្រាប់តែឃើញសុភាពយុវជនម្នាក់ដើរ ចុះមកក្នុងសម្លៀកយ៉ាងថ្លៃថ្នូរហើយមានចងក្រវ៉ាត់កផង ។ ឆដា ភ្ញាក់ក្រញាង លាន់មាត់សាជាថ្មី ៖

- ព្រះអើយ! ហេតុអ្វីក៏ប្រែក្រឡាលឿនម្ល៉េះ បងប្រុសខ្ញុំ? ហើយបាត់សក់ហាយម្លៃទៅណាអស់ហើយ?

វណ្ណឌីលូកហោប៉ៅខោឈរជ្រែងយ៉ាងសង្ហា ហើយឆ្លើយថា ៖

- បងបានដេញសេកអោយទៅនៅព្រៃវិញហើយ ហើយក៏ដេញតួយីកែអោយគេត្រឡប់ទៅរកឆាកវិញដែរ ។ ចំណែកអ្នកដែល ប្អូនឆដាឃើញនេះ គឺជាបងវណ្ណឌីកូនប្រុសកម្លោះលោកពូវណ្ណៈទាំង សាច់ទាំងឈាមតែម្ដង ។

ឆដាក៏រត់ទៅកៀកដៃភ្លាម ហើយវាចាតបវិញ ៖

- បើសង្ហាយ៉ាងហ្នឹង ឆដាសុំបណ្ដើរធ្វើដៃគូម៉ាល្ងាចហើយណា៎!

ភ្លាមនោះ វណ្ណឌីញញឹមឡើងស្រស់តែម្ដង ព្រោះគេបានទទួលនូវចំណាប់អារម្មណ៍ពិសេសពីនារីក្រមុំសោភា ។

ច្រើនថ្ងៃកន្លងទៅ...

តុក! តុក! តុក!

- ចូលមកកូន! ទ្វារឥតមានចាក់គន្លឹះទេ (លោកវណ្ណៈវាចា)

វណ្ណឌីបើកទ្វារទៅក៏ប្រទះនឹងចរិយាកំពុងបំបៅទារក ចំណែកលោកវណ្ណៈកំពុងអានសៀវភៅនៅតុម្ខាងទៀត ។ គ្រាន់តែឃើញ មុខកូនប្រុសភ្លាម លោកក៏មានប្រសាសន៍ថា ៖

- មានការអ្វីកូន បានជាមករកប៉ាទាំងយប់?
- គឺ...ខ្ញុំចង់មកអរគុណបងស្រី...
- រឿងអ្វីទៅ ប្អូនឌី? (ចរិយាសួរ)
- ការពិតទៅ... ប្អូនៗហៅបងស្រីថាម៉ាក់ ពិតជាសមរម្យណាស់...

CHANBOKEO.COM

ព្រោះបងមានលក្ខណៈសមរម្យជាម្ដាយរបស់ពួកយើងជាច្រើនយ៉ាង
ថ្វីបើបងធ្វើអ្វីៗប្លែកពីម៉ាក់របស់ពួកយើងខ្លះក៏ដោយ ។ ជាច្រើនថ្ងៃ
ដែលខ្ញុំបានត្រឡប់មករស់នៅក្នុងផ្ទះនេះវិញ ជីវិតរបស់ខ្ញុំក៏បាន ទទួលនូវភាពកក់ក្ដៅជាគ្រួសារ
មិនមានកំហឹងគុំគួននិងការស្អប់ ខ្ពើម មិនមានការប្រជែងយកមុខមាត់ ឬចំណាប់អារម្មណ៍
មិនមាន ការមើលបំណាំគ្នា មិនធ្វើអ្វីបញ្ឆោះបញ្ឆោក ឬបំផ្លាញគ្នា មានតែការ
ដោះស្រាយទុក្ខធុរៈអោយគ្នាទៅវិញទៅមក ។ ច្រើនថ្ងៃមកនេះ ខ្ញុំ
បានស្គាល់បងស្រីច្រើនជាងមុន ឃើញថា ខ្ញុំអាចរស់នៅចុះសម្រុង ជាមួយបងបាន
ទើបសំរេចចិត្តថាមកសុំអនុញ្ញាតបងស្រី សុំហៅ បងស្រីថាជាម៉ាក់
អោយដូចជាប្អូនទាំងអស់បានហៅរាល់ថ្ងៃ ។ ពិត មែនតែបងមានវ័យច្រើនជាងខ្ញុំតែប៉ុន្មានឆ្នាំ
តែបងមានលក្ខណៈ សម្បត្តិសមស្មើជាម្ដាយរបស់ពួកយើងពេកក្រៃ ។ សូមបងទទួល
យកខ្ញុំជាកូនម្នាក់ផង !

ចរិយាភ្ញាក់ព្រើត បែរមើលលោកវណ្ណៈ ឃើញលោកសម្ដែង អាការៈភ្ញាក់ផ្អើលដូចគ្នាដែរ
ដែលឃើញវណ្ណឌីនិយាយដូច្នោះ ។ បន្ទាប់មក មាណវីក៏ស្រដីតបវិញថា ៖

- ការពិត បងមិនដែលគិតទេ ថាប្អូនហៅបង ឬហៅថា ម៉ាក់ ឲ្យ តែប្អូនមានសេចក្ដីសុខក្នុងចិត្ត
នោះខ្ញុំសប្បាយចិត្តណាស់ទៅហើយ មិនចង់បានអ្វីលើសពីហ្នឹងទៀតទេ ។
បងអនុញ្ញាតអោយប្អូនហៅ បងយ៉ាងណាក៏បាន អោយតែសមរម្យជាសមាជិករួមគ្រួសារ ដោយ
មិនមានការប្រមាថនៅក្នុងចិត្ត នោះបងទទួលយកទាំងអស់ ។
- ប៉ុន្តែ ខ្ញុំគិតថា ខ្ញុំសុំហៅថាម៉ាក់ សមរម្យជាង ។
- អរគុណណាស់វណ្ណឌី ដែលអោយកិត្តិយសបងដល់ម្ល៉ឹង !

វណ្ណឌីញញឹមហើយបែរមកលុតជង្គង់ចុះ លើកដៃទាំងទ្វេសំពះ
ឪពុក ហើយមានវាចាថា ៖

- កូនសូមទោសលោកប៉ានូវអ្វីទាំងឡាយ ដែលកូនបានប្រព្រឹត្តមិន សមរម្យ ។
សូមលោកប៉ាមេត្តាអភ័យទោសដល់កូនលោកប៉ាផង ! ហើយកូនសូមជូនពរលោកប៉ានិងម៉ាក់
ព្រមទាំងក្រុមគ្រួសារយើង ជួបតែសេចក្ដីសុខរៀងរហូតទៅ ។

លោកវណ្ណៈលូកដៃទទួលការសំពះរបស់កូន ហើយក៏អង្អែល ក្បាលកូនបន្ដើរៗ ៖

- ប៉ារំភើបចិត្តណាស់ ដែលឃើញកូនរបស់ប៉ាមានសម្បជញ្ញៈនិង មនសិការខ្ពស់
ស្គាល់ខុសនិងត្រូវ ចេះជ្រើសរើសផ្លូវជីវិតសុក្រិត សំរាប់ដើរ ដើម្បីអនាគតល្អ

CHANBOKEO.COM

និងដើម្បីភាពរមនាក្នុងជីវិត មិនជឿ ពាក្យគេ តែជឿលើខ្លួនឯង ហើយចេះវែកញែកខុសត្រូវ មិនមានះ ជជេសយកឈ្នះទាំងកំពោល ចេះខុស ប៉ុន្តែ ចេះកែខ្លួនហើយដោះស្រាយស្ថានការណ៍អោយធូរស្រាលមកវិញ ។ នេះជាគុណសម្បត្តិដ៏ ប្រសើររបស់កូនណាំវណ្ណឌី ។

វណ្ណឌីលូកដៃស្រវាអោបឪពុកយ៉ាងណែន ៖

- កូនស្រឡាញ់លោកប៉ាណាស់ លោកប៉ា!
- ប៉ាក៏ស្រឡាញ់កូនដូចគ្នាដែរណាំកូន!

វណ្ណឌីក៏បែរមករកចរិយាហើយស្រដីបន្តថា ៖

- ម៉ាក់គឺជាស្ត្រីដ៏ល្អមួយរូប ដែលយើងគ្រប់គ្នាគួរកត់សំគាល់ហើយ ចងចាំ ។ ខ្ញុំសូមប្រគល់នាមជូនម៉ាក់ថា ជា សាវាណីយមាតា ប្រចាំ ប្រទេសខ្មែរ សតវត្សទី២១ហើយ ។

ចរិយាញញឹមតបវិញយ៉ាងបំព្រង ៖

- អរគុណណាស់ឌី ! ប៉ុន្តែ អ្នកដែលគួរទទួលរហស្សនាមថា ជា សាវាណីយមាតាប្រចាំកម្ពុជានោះ គឺជាស្ត្រីមួយរូបផ្សេងទៀតទើប សមរម្យជាជាង ។

វណ្ណឌីបើកភ្នែកធំៗ ៖

- ហេតុអ្វីបានជាដូច្នេះទៅវិញ ម៉ាក់ ?
- គឺព្រោះស្ត្រីម្នាក់នោះ បានប្រព្រឹត្តខ្លួនយ៉ាងពេញលក្ខណៈ ជា ម្តាយដ៏មានចិត្តធម៌បំផុត ជាទីគោរពនិងជាទីចងចាំរបស់កូន ដែល ខ្វះពំនាក់អាស្រ័យ ថ្វីបើគាត់មានឋានៈត្រឹមជាម្តាយចុងក៏ដោយ ។ គាត់ធ្លាប់បានបង្ហូរញើសឈាមធ្វើការរកស៊ីតក់ៗ ដើម្បីចិញ្ចឹមក្មេង ដែលជាកូនដើមផង ជាកូនចិញ្ចឹមផង និងក្មេងពិការជាកូនបង្កើត ផង ក្រោយពីបុរសជាស្វាមីអស់បុណ្យទៅ ពេលនោះកូនស្រីរបស់គាត់ទើបប្រសូត្រមកមិនបានប៉ុន្មានខែផង ។ ដោយសារតែគំរូដ៏ល្អ នេះហើយ ទើបម៉ាក់បានក្លាយជាម្តាយម្នាក់ទៀត បន្តវេនល្អរបស់ គាត់នោះផ្សព្វផ្សាយមេត្តាធម៌ដល់ក្មេង ដែលខ្វះការកក់ក្តៅ ដោយ បរិសុទ្ធចិត្ត ។
- ហើយចុះគាត់ជានរណាដែរទៅ ម៉ាក់ ។
- បើកូនចង់ស្គាល់ ចាំម៉ាក់នាំកូនទៅជួបលោក នៅដំណាច់សប្តាហ៍ នេះ យ៉ាងម៉េចដែរ ?
- បាទ! កូនពិតជាចង់ស្គាល់លោកណាស់!

នៅភូមិបឹងរាំង តាមដងផ្លូវពីបាត់ដំបងទៅភ្នំសំពៅ...

CHANBOKEO.COM

ចាវ៉ាន់កំពុងច្រៀកអុសក្បែរផ្ទះ តម្រៀបហាលថ្ងៃ ស្រាប់តែក្រឡេកឃើញរថយន្តមួយបរចូលមកដល់ទីធ្លាមុខផ្ទះ ក៏ស្ទុះដើប ឡើង ស្រែកហៅ ៖

- ម៉ែ! ម៉ែ! អូនដា! បងយ៉ានាំក្រុមគ្រួសារមកលេងយើងនែ៎ក!

យាយខននិងនាងដាកំពុងរលាស់ខោអាវហាល មិនឆ្ងាយពីនោះប៉ុន្មានទេ ។ គ្រាន់តែឮសម្លេងចាវ៉ាន់ស្រែកហៅក៏នាំគ្នារត់មកទទួលយ៉ាងលឿន ។

- កូនយ៉ា! លោកវណ្ណៈ ។
- ជំរាបសួរម៉ែ (នាងយ៉ាលើកដៃសំពះម្តាយ)
- អឺ! អឺ! ម៉ែនឹកកូនណាស់ យ៉ា ?
- ជំរាបសួរម៉ែ! (លោកវណ្ណៈលើកដៃសំពះយាយខន) ថ្ងៃនេះ ខ្ញុំនិងអូនយ៉ានាំចៅៗមកលេង!
- អូហ៍ អឺ! អរគុណណាស់កូន! ម៉ែក៏កំពុងនឹកចៅគ្រប់គ្នាដែរ ។
- ជំរាបសួរយាយ! (ចៅៗលើកដៃសំពះ)
- លើកដៃថ្វាយព្រះណា៎ចៅ!

រំពេចនោះ វណ្ណឌីដើរចុះពីឡានក្រោយគេ កាន់ថាសប្រាក់ដាក់ផ្កានិងស្លាធម៌ព្រមទាំងវត្ថុអនុស្សាវរីយ៍ពិសេសៗជាច្រើនមុខទៀត ដើរចូលដល់ចំពោះមុខយាយ រួចហើយក៏បន្ទន់កាយវន្ទា ៖

- ចៅឈ្មោះវណ្ណឌី ជាកូនប្រុសច្បងរបស់លោកប៉ាវណ្ណៈ ថ្ងៃនេះសុំចូលខ្លួនមកជំរាបអរគុណនិងមកសូមជូនពរយាយ ចំពោះការដែលយាយបានជប់មនុស្សល្អម្នាក់សំរាប់គ្រួសាររបស់ចៅ នោះគឺម៉ាក់យ៉ា របស់ពួកយើង ។ សូមយាយមេត្តាទទួលនូវអំណោរគុណពីចៅផង!

ថាហើយ គេក៏លុតជង្គង់ជូនថាសប្រាក់ដល់យាយខន ដោយ កិរិយាអោនលំទោន ។ យាយខនឈរធ្មើភាំង ។ លោកវណ្ណៈក៏មាន ប្រសាសន៍ពន្យល់ថា ៖

- សូមម៉ែទទួលពីចៅផង ព្រោះគេមានសេចក្តីរំភើបសោមនស្សដែលគេបានទទួលនូវសេចក្តីកក់ក្តៅក្នុងគ្រួសារ តាំងពីថ្ងៃដែលយ៉ាបានមករស់នៅជាមួយពួកយើងមក ។

យាយខនបែរមើលលោកវណ្ណៈនិងចរិយា រួចហើយបែរមើល

CHANBOKEO.COM

មុខចៅៗទាំងអស់គ្នា ទំនងចង់ដឹងថា តើគាត់គួរទទួលឬក៏យ៉ាង ណា ។ លុះឃើញស្នាមញញឹមលើផ្ទៃមុខគ្រប់ៗគ្នា យាយក៏ញញឹម ឡើង លូកដៃទទួលយកថាសប្រាក់ពីដៃចៅដោយដួងចិត្តរំភើប ។

បន្តិចមក ទាំងអស់គ្នាអង្គុយសំណេះសំណាលជាក្រុមគ្រួសារ ។ នៅលើគ្រែឫស្សីមួយក្រោមផ្ទះ វណ្ណឌីអង្គុយសម្លឹងនាងចិន្តាមិន ដាក់ភ្នែក ។ ចរិយាឃើញដូច្នេះក៏ដើរទៅជិតនរៈហើយស្រដីថា ៖

- វណ្ណឌីឃើញទេ ? សូម្បីតែចិន្តាដែលជាក្មេងពិការហើយធ្លាប់បាន ប្រទះនិងព្យុះជីវិតយ៉ាងកំណាច ក៏ពិតមែន ប៉ុន្តែនាងអាចដើរឆ្លង គ្រោះនោះផុតមកដោយជោគជ័យ ។ នោះក៏ព្រោះតែកម្លាំងចិត្តនិង ភាពកក់ក្តៅនៅក្នុងរង្វង់គ្រួសារ ដែលធ្វើអោយនាងទទួលភាព រឹងប៉ឹងផ្លូវចិត្តមកវិញយ៉ាងមុតមាំ ។ មនុស្សយើងណា៎! មិនថា អ្នក មានអ្នកក្រ ចាស់ក្មេង ប្រុសស្រីយ៉ាងណាទេ តែងតែត្រូវការកម្លាំង ចិត្តពីគ្រួសាររបស់យើងជានិច្ច ។ ការរត់គេចចោលផ្ទះ ការកាត់ ចំណងរបស់ខ្លួនពីគ្រួសារ មិនបានធ្វើអ្វីអោយជីវិតរបស់យើងគាប់ ប្រសើរជាងមុនទេ ។ គ្រួសារជាប្រភពកម្លាំងចិត្ត ជាមូលដ្ឋាននៃ ភាពកក់ក្តៅក្នុងជីវិតមនុស្ស ។ កាលបើគ្រួសារគ្មានសេចក្តីសុខ ជីវិតរបស់សមាជិកគ្រួសារនឹងវិបរិត ទៅតាមនោះដែរ ។

- បាទ! មែនហើយ! ហើយខ្ញុំក៏បានពិសោធន៍ជីវិតនោះដោយ ខ្លួនឯងផ្ទាល់ ឃើញថា ជីវិតភ្លើតភ្លើតរំភើបសប្បាយនៅក្រៅផ្ទះ នោះ គ្រាន់តែជាស្រមោលភូតភរអោយយើងភ្លេចស្មារតីប៉ុណ្ណោះ ។ ជីវិតនោះមិនបាននាំអោយចិត្តយើងស្ងប់សុខ មានលំនឹងឋិតថេរ ដូចភាពកក់ក្តៅក្នុងគ្រួសារ ដែលយើងធ្លាប់បានទទួលនោះឡើយ ។ ពេលនេះ ខ្ញុំយល់ហើយថា ហេតុអ្វីចាស់ៗចូលចិត្តផ្តាំកូន កុំអោយ ប្រព្រឹត្តខ្លួនជាបុគ្គលឆាប់ភ្ញាក់ផ្អើល ឆាប់ជឿសំដីគេ ឆាប់ច្រឡោត ភ្លេចការពិចារណាហេតុផល ខុសនិងត្រូវ ។

- មែនហើយ! វណ្ណឌីបានទទួលមេរៀន ហើយបានដឹងខ្លួនទាន់ ពេលវេលា អាចមានឱកាសវែងឆ្ងាយតទៅទៀត សំរាប់ដើរស្វែង រកភាពចម្រុងចម្រើន ។ គិតទៅវណ្ណឌី ជាមនុស្សដែលមានភព្វ សំណាងដ៏ប្រសើរម្នាក់ ដឹងទេ ?

- ហើយខ្ញុំសូមបន់អោយខ្ញុំសំណាងដូច្នេះរហូតទៅណា៎ ម៉ាក់!

អ្នកទាំងពីរញញឹមដាក់គ្នាយ៉ាងបំព្រង ។

CHANBOKEO.COM

នៅក្នុងរោងស្បូវក្នុងដីចំការ លោកវណ្ណៈអង្គុយមើលកូនៗ ដែលរត់ប្រឡែងគ្នាជុំវិញមាត់ស្រះព្រលិត ទាំងទឹកមុខញញឹម ។ នៅក្បែរនោះ ចរិយាអង្គុយយោលអង្រឹងក្រមាអោយនាងតូចពៅ គេង ។ ភ្លាមនោះ លោកវណ្ណៈបែរមកមើលភរិយាហើយក៏មាន ប្រសាសន៍ឡើងថា ៖

- បងមិនដែលនឹកស្មានសោះថា ស្រុកជនបទស្រែចំការមានភាព មនោរម្យដល់ម្លឹង អូនយ៉ា!
- ចាស! ស្រុកជនបទស្រែចំការ ថ្វីបើមិនជឿនលឿន តែផ្តល់នូវ ភាពមនោរម្យដល់ជីវិតមនុស្សគ្រប់ៗគ្នា ។
- ប្រហែលជាដូច្នេះទេដឹង បានជាអ្នកជនបទមានចិត្តគំនិតស្ងប់ សុខ ជាងអ្នកទីក្រុង!
- ហេតុអ្វីទៅ ដែលនាំអោយបងមានគំនិតដូច្នោះ ?
- គឺអ្នកស្រុកមិនសូវអាត្មានិយម ប្រកាន់ខ្លួនដូចអ្នកទីក្រុងនោះអី!
- បងឃើញអញ្ចឹងមែនហ្អែស ?
- មែនណា៎! ដូចជាភាពមនោរម្យនៅភូមិបឹងរាំងនេះអញ្ចឹង បាន ធ្វើអោយបេះដូងបុរសទីក្រុងដូចជាបងនេះ ទន់ជ្រាយអស់រលីង នៅពេលបងប្រទះក្រមុំអ្នកភូមិម្នាក់នោះ ។ បន្ទាប់មក... បងក៏ ឈ្លក់ស្រឡាញ់នាង ដើមមុខលែងរួចតែម្តង!

ចរិយាញញឹមទ្រង់អៀន ៖

- បញ្ឆោរអូនទេដឹង បង ?
- បងនិយាយពិតណា៎យ៉ា! មើល៍! សូម្បីតែពលរដ្ឋសាមញ្ញដូចម៉ែ ក៏មានសីលធម៌ក្នុងខ្លួនពេញលក្ខណៈ គ្រប់គ្រងកូនចៅសុខក្សេម ក្សាន្ត គ្មានរឹខិស្ថានដែរ មិនខុសឡើយពីភាពមនោរម្យរបស់ភូមិ នេះទេ ។ បើគិតអោយហ្មត់ចត់ទៅ មិនមែនមានតែអ្នកទីក្រុង ឋានៈខ្ពង់ខ្ពស់នោះទេ ដែលអាចអប់រំកូនចៅអោយប្រសើរបាន សូម្បីតែអ្នកស្រុកជនបទធម្មតាៗ ក៏អាចអប់រំកូនអោយប្រសើរ បានដែរ បើសិនជាគេស្គាល់នូវតម្លៃសីលធម៌ពិតប្រាកដ ។

លោកវណ្ណៈលូកចាប់ដៃភរិយាមកកាន់ ហើយស្រដីថា ៖

- កាលបើម្តាយអូនជាសារាណីយមាតា រូបអូនជាសារាណីយមាតា កូនៗរបស់យើង ក៏បានទទួលនូវភាពកក់ក្តៅពីសារាណីយមាតា សង្ឃឹមថាមាតាបិតាទូទៅក្នុងសង្គម នឹងត្រងត្រាប់នូវគោលគំនិត សារាណីយមាតា ផ្តល់ក្តីមេត្តា សន្តោស ករុណា និងក្តីស្រឡាញ់

CHANBOKEO.COM

ដល់ក្មេងទូទៅ មិនថាក្មេងទាំងនោះជាកូនបង្កើត កូនដើម កូនចុង ឬគ្រាន់តែជាក្មេងកំព្រាអនាថាក្ដី ។ កាលបើក្មេងបានទទួលសេចក្ដី កក់ក្ដៅពីក្រុមគ្រួសារហើយ គេច្បាស់ជាក្លាយជាក្មេងរឹងប៉ឹង មាន ជំនឿលើខ្លួនឯង សាងខ្លួនល្អ ដើរផ្លូវល្អ មិនបណ្ដោយខ្លួនឲ្យធ្លាក់ ក្នុងជីវិតវិបរិតឬឧក្រិដ្ឋឡើយ ។ យ៉ាគិតថាបងនិយាយត្រូវទេ ?

- ចា៎ស ត្រូវណាស់ ប៉ុន្តែ បងនៅភ្លេចរឿងមួយទៀត ។
- រឿងអ្វីទៅយ៉ា ?
- រឿងដែលបងថា នឹងជួយអោយអូនបានធ្វើគ្រូនោះអី ?
- ពុទ្ធោអើយ! បងមិនភ្លេចទេ យ៉ា! អូនពូកែសរសេរកំណាព្យណាស់ ហើយអូនក៏ធ្លាប់ចេះប្រើឥន្ទ្រីណិតទៀតផង ។ ចាំដល់អូនរឹង ដៃរឹងជើងជាងនេះបន្តិច អូនអាចចូលរៀនហ្វឹកហ្វឺនខាងស្ថាបនា គេហទំព័រ ដើម្បីបង្កើតវិបសៃថ៍បង្រៀនខ្មែរពីការនិពន្ធកំណាព្យ និពន្ធអត្ថបទផង បង្រៀនសីលធម៌ផង រក្សាវប្បធម៌អក្សរសាស្ត្រ យើងផង ហើយអាចអោយក្មេងចូលមកបញ្ចេញស្នាដៃរបស់គេ នៅលើគេហទំព័រនោះផង ។ នៅពេលនោះ អូននឹងក្លាយជាអ្នកដឹកនាំនៅលើគេហទំព័រមួយនោះមិនខាន ។ ម្យ៉ាងទៀត អូនក៏អាចយកស្នាដៃទាំងឡាយរបស់អូនមក បោះពុម្ពជាសៀវភៅចែកចាយ ពេញកម្ពុជាថែមទៀត ។ បងពិតជាមិនបណ្ដោយឲ្យទេពកោសល្យ និងគុណសម្បត្តិដ៏ល្អរបស់អូនត្រូវសាបសូន្យបាត់ទៅដោយអាសារ បង់ នោះឡើយ... នឹងហើយឬនៅ ប្រពន្ធបណ្ដូលចិត្តបង ?

ចរិយាញញឹមដាក់ស្វាមីដោយដួងចិត្តសោមនស្ស ហើយនិង មានមោទនភាពបំផុត ៖

- ចា៎ស! អរគុណណាស់ប្ដីសម្លាញ់ ដែលមិនទុកអោយអូនធ្វើការ ងារត្រឹមជាមេផ្ទះ ថែគ្រួសារ ។ អូនពិតជាត្រូវការបង្អែកកក់ក្ដៅ ពីបងណាស់ ដើម្បីអោយក្ដីស្រម័យរបស់អូនបានក្លាយជាការពិត ។

ចរិយាផ្ដេកកេសាលើស្មាលោកវណ្ណៈសម្ដែងនូវទំនុកទុកចិត្តនិង ក្ដីគោរពយ៉ាងជ្រាលជ្រៅចំពោះស្វាមី ។ រីឯលោកវណ្ណៈវិញក៏ស្រវា ត្រកងថង្កេះភរិយាយ៉ាងណែន ដើម្បីបញ្ជាក់នូវសេចក្ដីស្រឡាញ់ របស់លោកចំពោះមាណវី ពេញបេះដូង...

# ចប់

CHANBOKEO.COM